ប្លុក 3 – ហាងឆេង 1.13 ប្រាក់ភ្នាល់ €100

ជម្រើសទី 1

ប្លុក 1 ចាញ់។ ការភ្នាល់ទាំងមូលចាញ់ ព្រោះមិនមានប្រាក់ភ្នាល់សម្រាប់ប្លុកបន្ត។

ជម្រើសទី 2

ប្លុក 1 ឈ្នះ។ ចំនួនទឹកប្រាក់សងវិញគឺ €115 ។

ប្លុក 2 (ទ្វេដង) ប្រាក់ភ្នាល់ត្រូវបានកំណត់ជាអតិបរមា (€115)។ ត្រង់នៃគឺឈ្នះ ដូច្នេះហើយផលត្រឡប់មកវិញគឺ (1,39 x 1.13) x 115 = 1.57 x 115 = €180.63 ។

ប្រាក់ភ្នាល់សម្រាប់ប្លុក 3 គឺត្រូវបានដកចេញពីប្រាក់សងវិញ។ ប្រាក់ភ្នាល់សម្រាប់ប្លុក 3 មានចំនួន €100 ។ 180.63 – 100 = €80.63 ។ សរុបចំនួន €80.63 ត្រូវបានបញ្ចូលទៅក្នុងគណនីការភ្នាល់តាមលក្ខខណ្ឌ។

ប្លុក 3 ចាញ់។

សមតុល្យក្នុងគណនីការភ្នាល់តាមលក្ខខណ្ឌមានចំនួន €80.63 ។ ប្រាក់សងវិញគឺ €80.63 ។

ជម្រើសទី 3

ប្លុក 1 ឈ្នះ។ ចំនួនទឹកប្រាក់សងវិញគឺ €115 ។

ប្លុក 2 (ទ្វេដង) ប្រាក់ភ្នាល់ត្រូវបានកំណត់ជាអតិបរមា (€115)។ ប្រាក់សងវិញគឺ (1.39 x 1.13) x 115 = 1.57 x 115 = €180.63 ។

ប្រាក់ភ្នាល់សម្រាប់ប្លុក 3 គឺត្រូវបានដកចេញពីប្រាក់សងវិញ។ ប្រាក់ភ្នាល់សម្រាប់ប្លុក 3 គឺ €100 ។ 180.63 – 100 = €80.63 ។ សរុបចំនួន

€80.63 ត្រូវបានបញ្ចូលទៅក្នុងគណនីការភ្នាល់តាមលក្ខខណ្ឌ។

ប្លុក 3 ឈ្នះ - 100 x 1.13 = €113

ចំនួនទឹកប្រាក់សងវិញគឺ 80.63 + 113 = €193.63

ជម្រើសទី 4

ប្លុក 1 ឈ្នះ។ ចំនួនទឹកប្រាក់សងវិញគឺ €115 ។

ប្លុក 2 (ទ្វេដង) ចាញ់។ ប្រាក់ភ្នាល់នៃប្លុក 2 ត្រូវបានកំណត់ជាអតិបរមា ដូច្នោះទឹកប្រាក់សរុបចំនួន €115 ត្រូវចាញ់។

ប្លុក 3 ឈ្នះ។ ប្រាក់ភ្នាល់គឺ €100 ។ នៅពេលប្លុក 2 ចាញ់ គឺមិនមានប្រាក់ភ្នាល់ទេ។

ប៊ិងភ្នាល់ចាញ់។

4.9. ការភ្នាល់បកបញ្ច្រាស់

ការភ្នាល់បកបញ្ច្រាស់ គឺផ្ទុយពីការភ្នាល់បក ដែលទាក់ទងនឹងការទូទាត់ការភ្នាល់ ដោយមានន័យថាការភ្នាល់នឹងឈ្នះ ប្រសិនបើការភ្នាល់បកពាក់ព័ន្ធចាញ់។ ការភ្នាល់ត្រូវតែរួមបញ្ចូលជម្រើសពីរ ឬច្រើនលើព្រឹត្តិការណ៍ដែលមិនទាក់ទងគ្នា ហើយការភ្នាល់នឹងឈ្នះ បើយ៉ាងហោចណាស់ជម្រើសមួយនឹងត្រូវចាញ់។
ចំនួនហាងឆេងរួមផ្សំនៃការភ្នាល់បកបញ្ច្រាស់ ត្រូវបានគណនាផ្អែកលើការផ្ទុយនៃប្រូបាប៊ីលីតេឈ្នះនៃការភ្នាល់បកដែលមានជើងដូចគ្នា។

ឧទាហរណ៍។ ប៊ិងភ្នាល់រួមមានជម្រើស 3 ។

ជម្រើសទី 1 – ហាងឆេង 1.25

ជម្រើសទី 2 – ហាងឆេង 1.65
ជម្រើសទី 3 – ហាងឆេង 1.85

សម្រាប់ការភ្នាល់បកនេះ ហាងឆេងរួមគឺ 3.81 ។ ហាងឆេងឈ្នះនៃការភ្នាល់បកបញ្ជ្រាស់នីមួយៗ ដែលគណនាដោយសុសវែររបស់យើង គឺស្មើនឹង 1.17 ។ ប្រាក់ភ្នាល់នៃការភ្នាល់បកបញ្ជ្រាស់ អាចត្រូវបានទូទាត់ដូចខាងក្រោម៖

ជម្រើសទី 1
ប្រសិនបើយ៉ាងហោចណាស់ជម្រើសមួយមិនឈ្នះ (មិនត្រូវបានគេទស្សន៍ទាយត្រឹមត្រូវ) ហើយជម្រើសផ្សេងទៀតឈ្នះ ការសងវិញនឹងត្រូវបាន 100 x 1,17 = €117 ។
ជម្រើសទី 2
ប្រសិនបើមានការទូទាត់សងនៅហាងឆេង 1.00 លើជម្រើសទី 3 ហាងឆេងចុងក្រោយនៃការភ្នាល់បកគឺនឹងត្រូវបាន 2.06 ។ ដូច្នោះហើយ ហាងឆេងដែលឈ្នះ នៃការភ្នាល់បកបញ្ជ្រាស់នីមួយៗ នឹងកើនឡើងពី 1.17 ដល់ 1.58 ។ ប្រសិនបើជម្រើសទី 1 ឬជម្រើសទី 2 មិនឈ្នះ (មិនត្រូវបានគេទស្សន៍ទាយត្រឹមត្រូវ) ប្រាក់ភ្នាល់នៃការភ្នាល់បកបញ្ជ្រាស់នឹងឈ្នះ ហើយប្រាក់សងវិញគឺនឹងត្រូវបាន 100 x 1.58 = €158 ។
ជម្រើសទី 3
ប្រសិនបើមានការទូទាត់សងនៅហាងឆេង 1.00 លើជម្រើសទី 2 និងជម្រើសទី 3 ហាងឆេងចុងក្រោយនៃការភ្នាល់បកគឺនឹងត្រូវបាន 1.25 ។ ដូច្នោះហើយ ហាងឆេងដែលឈ្នះនៃការភ្នាល់បកបញ្ជ្រាស់នីមួយៗនឹងកើនឡើងពី 1.17 ដល់ 3.16 ។ ប្រសិនបើជម្រើសទី 1 មិនឈ្នះ (មិនត្រូវបានគេទស្សន៍ទាយត្រឹមត្រូវ) ការភ្នាល់បកបញ្ជ្រាស់នឹងឈ្នះ ហើយប្រាក់សងវិញនឹងត្រូវបាន 100 x 3.16 = €316 ។
ជម្រើសទី 4
ប្រសិនបើកជម្រើសណាមួយឈ្នះ (ត្រូវបានទស្សន៍ទាយត្រឹមត្រូវ) ហើយប្រសិនបើមានការទូទាត់សងនៅហាងឆេង 1.00 លើជម្រើសដែលនៅសល់ ប្រាក់ភ្នាល់នៃការភ្នាល់បកបញ្ជ្រាស់នឹងចាញ់។
ប្រសិនបើមានការទូទាត់សង សម្រាប់ជម្រើសទាំងបី នៅហាងឆេង 1.00 ប្រាក់ភ្នាល់នឹងត្រូវបង្វិលចូលទៅគណនីរបស់អតិថិជនវិញ។

4.10. សំណាង

ការភ្នាល់នាំសំណាង គឺជាបន្សំនៃការភ្នាល់ទោល និងការភ្នាល់បកដែលមាននិងជាប់ទាក់ទងទាំងអស់ សម្រាប់ចំនួនជម្រើសជាក់លាក់មួយ។ ចំនួនជម្រើសអប្បបរមាគឺ 2 ហើយចំនួនជម្រើសអតិបរមាគឺ 8 ។
ដើម្បីទទួលបានការទូទាត់ យ៉ាងហោចណាស់ត្រូវមានជម្រើសនៃការទស្សន៍ទាយមួយដែលត្រឹមត្រូវ។

ឧទាហរណ៍។ ប៊ុងភ្នាល់រួមមានជម្រើស 4 ។
ជម្រើសទី 1 – ហាងឆេង 2
ជម្រើសទី 2 – ហាងឆេង 3.5

ជម្រើសទី 3 – ហាងឆេង 4

ជម្រើសទី 4 – ហាងឆេង 1.5

ប្រាក់ភ្នាល់គឺ €150 ។

ការភ្នាល់នាំសំណាង នឹងរួមបញ្ចូលការភ្នាល់ដូចខាងក្រោម៖

ការភ្នាល់ទោលចំនួន 4

ការភ្នាល់ទ្វេដងឆ្លាស់ចំនួន 6

ការភ្នាល់បីដងឆ្លាស់ចំនួន 4

ការភ្នាល់បកប្ងនដងចំនួន 1

អ្នកមានការភ្នាល់សរុបចំនួន 15 ។ ប្រាក់ភ្នាល់នឹងត្រូវបានគណនាដូចតទៅ៖ €150/ការភ្នាល់ 15 = €10 ក្នុងមួយការភ្នាល់។

ការភ្នាល់មួយៗមានចំនួន €10 ទោលចំនួន 4 ដែលនី

ជម្រើស	ជម្រើស	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1	2.00	20
ព្រឹត្តិការណ៍ 2	3.50	35
ព្រឹត្តិការណ៍ 3	4.00	40
ព្រឹត្តិការណ៍ 4	1.50	15

ការភ្នាល់ទ្វេដងឆ្លាស់ចំនួន 6 ដែលនីមួយៗមានចំនួន €10

ជម្រើស	ជម្រើស	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2	2.00 x 3.50	70
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 3	2.00 x 4.00	80
ព្រឹត្តិការណ៍ 1+ ព្រឹត្តិការណ៍ 4	2.00 x 1.50	30
ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3	3.50 x 4.00	140
ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 4	3.50 x 1.50	52.5
ព្រឹត្តិការណ៍ 3+ ព្រឹត្តិការណ៍ 4	4.00 x 1.50	60

ការភ្នាល់បីដងឆ្លាស់ចំនួន 4 ដែលនីមួយៗមានចំនួន €10

ជម្រើស	ជម្រើស	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3	2.00 x 3.50 x 4.00	280
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 4	2.00 x 3.50 x 1.50	105
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	2.00 x 4.00 x 1.50	120
ព្រឹត្តិការណ៍ 2+ ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	3.50 x 4.00 x 1.50	210

ការភ្នាល់បកបួនដងចំនួន 1 ដែលមានចំនួន €10

ជម្រើស	ជម្រើស	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	2.00 x 3.50 x 4.00 x 1.50	420

ប្រសិនបើការភ្នាល់ទោលឈ្នះទាំងអស់ ជម្រើសផ្សេងទៀតទាំងអស់នៅលើប៊ិងភ្នាល់នឹងត្រូវបានចាត់ទុកថាបានឈ្នះ។ ប្រាក់សងមកវិញទាំងអស់នឹងបន្តែមរហូតដល់ €1,677.50 ។

ប្រសិនបើមានតែជម្រើសមួយឈ្នះ ជាឧទាហរណ៍ចំពោះជម្រើស 4 ប្រាក់សងវិញគឺនឹងត្រូវបាន 1.5 x €10 = €15 ។ ជម្រើសដែលនៅសល់ទាំង 14 នឹងត្រូវចាញ់។

4.11. ប៉ាតង់

ប៉ាតង់ពាក់ព័ន្ធនឹងការភ្នាល់បកដែលអាចកើតមានទាំងអស់ ដោយបានមកពីសំណុំនៃជម្រើសមួយចំនួន។ ចំនួនជម្រើសអប្បបរមាគឺ 3 ហើយចំនួនជម្រើសអតិបរមាគឺ 8។
ដើម្បីឈ្នះ យ៉ាងហោចណាស់ការភ្នាល់បកមួយ ចាំបាច់ត្រូវទស្សន៍ទាយឱ្យបានត្រឹមត្រូវ (នេះមានន័យថាជម្រើសអប្បបរមាចំនួនពីរគួរតែត្រូវបាន ទស្សន៍ទាយឱ្យបានត្រឹមត្រូវ)។

ឧទាហរណ៍។ មានជម្រើសចំនួន 4 នៅលើប៊ិងភ្នាល់។
ជម្រើសទី 1 – ហាងឆេង 2
ជម្រើសទី 2 – ហាងឆេង 3.5
ជម្រើសទី 3 – ហាងឆេង 4
ជម្រើសទី 4 – ហាងឆេង 1.5
ប្រាក់ភ្នាល់គឺ €110 ។

ប៉ាតង់នឹងរួមបញ្ចូលការភ្នាល់ដូចខាងក្រោម៖
ការភ្នាល់ទ្វេដងឆ្លាស់ចំនួន 6
ការភ្នាល់បីដងឆ្លាស់ចំនួន 4
ការភ្នាល់បកបួនដងចំនួន 1 ។

មានបន្សំចំនួន 11 ។ ប្រាក់ភ្នាល់ត្រូវបានគណនាដូចខាងក្រោម៖ €110/11 បន្សំ = €10 ក្នុងមួយបន្សំ។

ការភ្នាល់ទ្វេដងឆ្លាស់ចំនួន 6 ដែលនីមួយៗមានចំនួន €10

ជម្រើស	**ហាងឆេង**	**ប្រាក់សងវិញ**
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2	2.00 x 3.50	70

ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 3	2.00 x 4.00	80
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 4	2.00 x 1.50	30
ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3	3.50 x 4.00	140
ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 4	3.50 x 1.50	52.5
ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	4.00 x 1.50	60

ការភ្នាល់បីដងចំនួន 4 ដែលនីមួយៗមានចំនួន €10

ជម្រើស	ហាងឆេង	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3	2.00 x 3.50 x 4.00	280
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 4	2.00 x 3.50 x 1.50	105
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	2.00 x 4.00 x 1.50	120
ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	3.50 x 4.00 x 1.50	210

ការភ្នាល់បកបួនដងចំនួន 1 ដែលមានចំនួន €10

ជម្រើស	ហាងឆេង	ប្រាក់សងវិញ
ព្រឹត្តិការណ៍ 1 + ព្រឹត្តិការណ៍ 2 + ព្រឹត្តិការណ៍ 3 + ព្រឹត្តិការណ៍ 4	2.00 x 3.50 x 4.00 x 1.50	420

ប្រសិនបើការភ្នាល់ទោលឈ្នះទាំងអស់ នោះជម្រើសទាំងអស់នៅក្នុងប៊ីងភ្នាល់នេះនឹងត្រូវបានចាត់ទុកថាបានឈ្នះ។ ប្រាក់សងមកវិញទាំងអស់នឹងបន្ថែមរហូតដល់ €1,567.50 ។
ប្រសិនបើជម្រើសមួយក្នុងចំណោមជម្រើសទាំងបួន ត្រូវបានលេងដូចដែលបានទស្សន៍ទាយទុក នោះជម្រើសទាំងអស់នៅក្នុងប៊ីងភ្នាល់នេះ នឹងត្រូវបានចាត់ទុកថាបានចាញ់។

5. ការដកខ្លួនចេញ

1. 1xcambodia.com ផ្តល់ជូនមុខងារ "ដកខ្លួនចេញ" ដែលអនុញ្ញាតឱ្យអ្នកបិទគណនីរបស់អ្នករហូតដល់ 5 ឆ្នាំ។ គណនីរបស់អ្នកនឹងត្រូវបានប្តូរចោល បន្ទាប់ពីសំណើសុំ "ដកខ្លួនចេញ" របស់អ្នក ត្រូវបានផ្ទៀងផ្ទាត់ពេញលេញ។ ប្រសិនបើអ្នកបើកដំណើរការមុខងារនេះ អ្នកនឹងមិនអាចដាក់ភ្នាល់នៅ 1xcambodia.com បានទៀតទេ។
2. ប្រសិនបើអ្នកចង់ដាក់កំណត់ប្រភេទនៃដែនកំណត់ណាមួយលើសកម្មភាពអនឡាញរបស់អ្នក ដូច្នេះ សូមទាក់ទងមកយើងខ្ញុំតាមរយៈ block@1xcambodia.com។
3. នៅពេលដែលកដែនកំណត់ណាមួយត្រូវបានអនុវត្តចំពោះគណនីរបស់អ្នក ដែនកំណត់នោះនឹងបន្តអនុវត្តរហូតដល់រយៈពេលដែលបានកំណត់នោះបានកន្លងផុត។នៅពេលដែលរយៈពេលដែនកំណត់បានបញ្ចប់ អ្នកអាចនឹងបន្តប្រើប្រាស់សេវាកម្មនៅលើគេហទំព័ររបស់យើងបាន។
4. ក្នុងអំឡុងពេលដកខ្លួនចេញ ឬរយៈពេលសម្រាកមួយរយៈនេះ អ្នកមិនត្រូវប៉ុនប៉ងបើកគណនីថ្មីឡើយ ហើយអ្នកត្រូវតែទទួលស្គាល់ថា ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវហិរញ្ញវត្ថុ ហើយក៏មិនត្រូវទទួលខុសត្រូវអ្វីដែរ ប្រសិនបើអ្នកបន្តដាក់ភ្នាល់ ឬប្រើប្រាស់គណនីថ្មីមួយជាមួយសេវាកម្មនេះក្រោមឈ្មោះ ឬអាសយដ្ឋានមួយផ្សេងទៀត។ ក្នុងករណីពិសេស គណនីរបស់អតិថិជន អាចនឹងត្រូវបានបើកឡើងវិញ មុនរយៈពេលនៃការដកខ្លួនចេញនេះ ផុតសុពលភាព។

6. ការដោះស្រាយវិវាទ

1. យោងទៅតាមប្រការនេះ ប្រសិនបើអតិថិជនមិនយល់ស្របជាមួយក្រុមហ៊ុនភ្នាល់លើបញ្ហាណាមួយ ពាក់ព័ន្ធនឹងការគោរព និងការអនុវត្តតាមការរៀបចំការភ្នាល់រវាងអតិថិជន និងក្រុមហ៊ុនភ្នាល់ រួមទាំងការទូទាត់សង លទ្ធផល ហាងឆេង និងលក្ខខណ្ឌជាសារវន្តផ្សេងទៀតនៃការរៀបចំនោះ ក៏ដូចជាការប្រកាសថា ការរៀបចំនោះមិនទាន់បានបញ្ចប់ ឬចាត់ទុកជាមោឃៈ អតិថិជនយល់ស្របថា វិវាទណាមួយនឹងត្រូវដោះស្រាយដោយការដាក់ពាក្យបណ្តឹងទៅកាន់ក្រុមហ៊ុនភ្នាល់។
2. ក្រោមនីតិវិធីមុនការជំនុំជម្រះ ប្រសិនបើអតិថិជនជឿជាក់ថា សិទ្ធិរបស់ខ្លួនត្រូវបានគេរំលោភបំពាន ដូច្នេះ ពួកគេត្រូវផ្ញើពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រុមហ៊ុនភ្នាល់តាមរយៈអ៊ីមែល។
3. ពាក្យបណ្តឹងនឹងត្រូវផ្តល់ជូនក្នុងរយៈពេលដប់ 10 (ដប់) ថ្ងៃ គិតចាប់ពីថ្ងៃដែលអតិថិជនបានដឹង ឬគួរតែបានដឹងអំពីការរំលោភសិទ្ធិរបស់ពួកគេ។ ត្រូវភ្ជាប់មកជាមួយនូវឯកសារជំនួយ និងឯកសារបញ្ជាក់ពីពាក្យបណ្តឹងនោះ។ ក្នុងករណីដែលគ្មានមូលដ្ឋានពុំគ្រប់គ្រាន់សម្រាប់ពាក្យបណ្តឹង ពាក្យបណ្តឹងតវ៉ានឹងត្រូវប្រគល់ត្រឡប់ទៅវិញអតិថិជនដោយពុំមានការត្រួតពិនិត្យឡើយ។ អាចធ្វើការទាមទារឱ្យគណនាការភ្នាល់សម្រាប់ហ្គេម Cyber-Live ក្នុងរយៈពេលរហូតដល់ 72 ម៉ោង គិតចាប់ពីពេលដែលហ្គេមបានបញ្ចប់។
4. ក្រុមផ្តល់ជំនួយគាំទ្រអតិថិជន ប្តេជ្ញាផ្តល់ជូនអតិថិជននូវការឆ្លើយតបពេញលេញ និងលម្អិតទាក់ទងនឹងពាក្យបណ្តឹងនោះ ក្នុងរយៈពេលសាមសិប (30) ថ្ងៃ គិតចាប់ពីថ្ងៃដាក់ពាក្យបណ្តឹង។ លើសពីនេះទៅទៀត ប្រសិនបើដំណោះស្រាយស្ថិតនៅលើអតិថិជនដែលត្រូវផ្តល់ព័ត៌មានបន្ថែម នោះរយៈពេលសាមសិប (30) ថ្ងៃនេះ នឹងត្រូវពន្យាររហូតដល់ពេលដែលព័ត៌មានចាំបាច់ទាំងអស់ត្រូវបានប្រគល់ជូន។
5. អ្នកភ្នាល់ក៏មានសិទ្ធិផងដែរ ក្នុងការដាក់ប្តឹងតាមរយៈទម្រង់បែបបទពិសេស នៅលើគេហទំព័រ 1xcambodia.com។
6. នៅក្នុងករណីមានភាពចម្រូងចម្រាស ដែលមានការចុះផ្សាយលទ្ធផលខុសគ្នានៃព្រឹត្តិការណ៍តែមួយដោយប្រភពផ្សេងៗគ្នា ហើយមាន កំហុសជាក់ស្តែង ដូច្នេះ ការសម្រេចចិត្តចុងក្រោយអំពីការកំណត់លទ្ធផលនៃការទូទាត់ការភ្នាល់ នឹងត្រូវធ្វើឡើងដោយក្រុមហ៊ុន។ នៅក្នុងករណីមានភាពចម្រូងចម្រាសដែលមិនធ្លាប់មានពីមុនមក ការសម្រេចចិត្តចុងក្រោយនឹងត្រូវធ្វើឡើងដោយក្រុមហ៊ុនភ្នាល់។
7. អតិថិជនគួរទាក់ទងតែទៅផ្នែកល្បែងស៊ីសងអេឡិចត្រូនិករបស់ប្រទេសគួរាសៅ (Curaçao eGaming) ប៉ុណ្ណោះ (ម្ចាស់អាជ្ញាប័ណ្ណធំ) ប្រសិនបើពួកគេជឿថា ក្រុមហ៊ុនបានបំពានអាជ្ញាប័ណ្ណនេះ។ រាល់ជម្លោះទាំងអស់ជាមួយក្រុមហ៊ុនទាក់ទងនឹងការទូទាត់ប្រាក់ គណនីដែលត្រូវបានប្តូក ពន្យារពេល មុខងារមិនដំណើរការ ។ល។ និង ។ល។ គួរតែដាក់ប្តឹងដោយផ្ទាល់ជាមួយក្រុមហ៊ុនភ្នាល់។

7. គណនី ការទូទាត់សង បូណាស

7.1. គណនី

1. អតិថិជនដែលបានចុះឈ្មោះម្នាក់ៗ អាចមានគណនីត្រឹមតែមួយប៉ុណ្ណោះ។ អតិថិជនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះបង្កើតគណនីបានតែមួយគត់ ក្នុងមួយគ្រួសារ អាសយដ្ឋានមួយ អាសយដ្ឋានអ៊ីមែលមួយ អាសយដ្ឋាន IP មួយ ប័ណ្ណឥណទាន/ប័ណ្ណឥណពន្ធមួយ កាបូបអេឡិចត្រូនិចមួយ ឬវិធីសាស្ត្រទូទាត់តាមប្រព័ន្ធអេឡិចត្រូនិចមួយ។ បើមិនដូច្នេះទេ បុគ្គលដែលមានពាក់ព័ន្ធជាមួយអតិថិជន នឹងមិនត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះនៅលើគេហទំព័រនេះទេ។
2. គ្មានអតិថិជនដែលបានចុះឈ្មោះរួចណាម្នាក់ ដែលត្រូវបានអនុញ្ញាតឱ្យចុះឈ្មោះជាអតិថិជនថ្មីឡើយ (ក្រោមឈ្មោះថ្មី ជាមួយអាសយដ្ឋានអ៊ីមែលថ្មី ។ល។)។
3. ក្នុងករណីមាន
    - ការចុះឈ្មោះស្ទួន (រួមទាំងការចុះឈ្មោះក្រោមឈ្មោះថ្មី) ការប្រគល់ឯកសាររបស់មនុស្សម្នាក់ផ្សេងទៀត ឬឯកសារគ្មានសុពលភាព ឬឯកសារក្លែងក្លាយ (រួមទាំងឯកសារដែលត្រូវបានកែដោយប្រើសុសវែរ ឬកម្មវិធីកែក្រាហ្វិចគ្រប់ប្រភេទ)។
    - ការរំលោភបំពានជាច្រើនដងលើខនិងលក្ខខណ្ឌរបស់ក្រុមហ៊ុនភ្នាល់
    - ការសង្ស័យអំពីអត្តសញ្ញាណរបស់អតិថិជន ឬព័ត៌មានដែលពួកគេបានផ្តល់ឱ្យ (ឧទាហរណ៍ អាសយដ្ឋាន ព័ត៌មានលម្អិតរបស់ប័ណ្ណឥណទាន/ឥណពន្ធដែលបានកែ ទិន្នន័យផ្សេងទៀត)
    - ការក្លែងបន្លំក្នុងប្រភេទណាមួយ ដែលបានធ្វើឡើងដោយអ្នក ឬដោយមនុស្សម្នាក់ផ្សេងទៀតដែលធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់អ្នក ឬនៅក្នុងការឃុបឃិតជាមួយអ្នក រួមមានជាអាទិ៍៖
        - ក) ការសងប្រាក់វិញ ឬការបន្លំប្រាក់
        - ខ) ការប្រើប្រាស់ប័ណ្ណធនាគារដែលត្រូវបានគេលួច ឬមិនបានបញ្ជាក់ធ្វើជាប្រភពប្រាក់
        - គ) សកម្មភាពណាមួយដែលអ្នកបានអនុវត្ត ឬប៉ុនប៉ងអនុវត្ត ដែលអាចចាត់ទុកថាជាហេតុផលខុសច្បាប់នៅក្នុងយុត្តាធិការដែលពាក់ព័ន្ធ ដែលត្រូវបានប្រព្រឹត្តដោយចេតនា ឬមានចេតនាបោកបញ្ឆោត និង/ឬ ចៀសវាងការដាក់កំហិតនានាដែលមានចែងក្នុងច្បាប់ ដោយមិនគិតថាតើសកម្មភាព ឬការប៉ុនប៉ងនោះ ទីបំផុតទៅបណ្តាលឱ្យបាត់បង់ ឬខូចគណនីរបស់អ្នកឬអត់នោះទេ
    - នៅពេលដែលអតិថិជនដាក់ភ្នាល់ ពួកគេមានព័ត៌មានពាក់ព័ន្ធនឹងលទ្ធផលនៃព្រឹត្តិការណ៍នោះ
    - អតិថិជនអាចមានឥទ្ធិពលលើលទ្ធផលនៃព្រឹត្តិការណ៍មួយ ដោយសារតែការចូលរួមដោយផ្ទាល់របស់ពួកគេនៅក្នុងការប្រកួត (កីឡាករ គ្រូបង្វឹក អាជ្ញាកណ្តាល ។ល។) ឬដោយសារតែពួកគេបានធ្វើសកម្មភាពក្នុងនាមជាអ្នកចូលរួម
    - ការភ្នាល់ត្រូវបានដាក់ដោយក្រុមអ្នកភ្នាល់ ដែលដើរតួរួមគ្នា (ជាបណ្តាញមួយ) ដើម្បីធ្វើឱ្យលើសពី

ដែនកំណត់ ដែលក្រុមហ៊ុនភ្នាល់បានកំណត់ ក៏ដូចជាឃុបឃិតជាមួយអ្នកដទៃ ដើម្បីទទួលបានអត្ថប្រយោជន៍អយុត្តិធម៌ តាមរយៈគ្រោងការបូណឹស ឬប្រូម៉ូសិនដទៃផ្សេងទៀតណាមួយដែលផ្តល់ដោយភាគីខាងយើង។

- អ្នកភ្នាល់ត្រូវបានគេសង្ស័យថាបានប្រើសុសវែរ ឬហាដវែរពិសេស ដែលជួយសម្រួលដល់ការភ្នាល់ដោយស្វ័យប្រវត្តិ រួមមានជាអាទិ៍ ការប្រើប្រាស់ភាពមិនទៀងទាត់ កំហុស ឬបញ្ហានៅក្នុងសុសវែររបស់យើង ទាក់ទងនឹងសេវាកម្មដែលយើងផ្តល់ជូន (រួមទាំងការភ្នាល់); ការប្រើឧបករណ៍ និងកម្មវិធីបញ្ឆោត ឬប្រព័ន្ធវិភាគ រួមមានជាអាទិ៍ សុសវែរដែលអនុញ្ញាតឱ្យអតិថិជនដាក់ភ្នាល់ដោយគ្មានការអន្តរាគមន៍ពីមនុស្ស (ឧទាហរណ៍ មនុស្សយន្ត) ។ល។
- ប្រសិនបើមធ្យោបាយអយុត្តិធម៌គ្រប់ប្រភេទ ត្រូវបានប្រើដើម្បីទទួលបានព័ត៌មាន ឬគេចវេះពីការដាក់កំហិតដែលធ្វើឡើងដោយក្រុមហ៊ុន។

តាមការសម្រេចចិត្តរបស់ខ្លួន គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនមានសិទ្ធិស្នើសុំឯកសារណាមួយពីអ្នកភ្នាល់ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ពួកគេ ឬទិន្នន័យផ្សេងទៀតដែលពួកគេបានផ្តល់ឱ្យ (ឧទាហរណ៍ ព័ត៌មានលម្អិត លិខិតឆ្លងដែន អាសយដ្ឋានស្នាក់នៅ) ក៏ដូចជាលុបចោលការទូទាត់ប្រាក់ណាមួយ រហូតដល់ព័ត៌មានលម្អិតទាំងអស់នោះ ត្រូវបានផ្ទៀងផ្ទាត់រួច។

គណៈគ្រប់គ្រងរបស់ក្រុមហ៊ុន រក្សាសិទ្ធិក្នុងការធ្វើសន្ទនាតាមវីដេអូ ដែលជាផ្នែកមួយនៃដំណើរការបញ្ជាក់អត្តសញ្ញាណ (ឬដោយការស្នើសុំវីដេអូនៃឯកសារ) និង/ឬស្នើសុំឱ្យគេផ្ញើឯកសារតាមប្រៃសណីយ៍។ ការផ្ទៀងផ្ទាត់អាចចំណាយពេលរហូតដល់ 72 ម៉ោង ចាប់ពីការទទួលបាននូវឯកសារ។ លទ្ធផលនៃការសន្ទនាតាមវីដេអូ អាចត្រូវបានផ្តល់ជូនទៅអតិថិជនក្នុងរយៈពេល 5 ថ្ងៃធ្វើការ បន្ទាប់ពីបានធ្វើការសន្ទនាតាមវីដេអូរួច។ ការផ្ទៀងផ្ទាត់ឯកសារវីដេអូ អាចចំណាយពេលរហូតដល់ 14 ថ្ងៃធ្វើការ។

4. ប្រសិនបើអតិថិជនបដិសេធមិនព្រមអនុវត្តការផ្ទៀងផ្ទាត់ ក្រុមហ៊ុនរក្សាសិទ្ធិ ក្នុងការលុបចោលការភ្នាល់របស់ពួកគេ (រួមទាំងការភ្នាល់ដែលបានដាក់ពីគណនីស្នូនផងដែរ)។ លើសពីនេះទៀត គណៈគ្រប់គ្រងរក្សាសិទ្ធិក្នុងការចាត់វិធានការសមហេតុផលណាមួយ រួមមានជាអាទិ៍ ការបប្លុកគណនី និងការបង្កកទឹកប្រាក់ដែលមានរហូតដល់មានម្ចាស់គណនី ហើយវិធីសាស្ត្រនៃការដាក់ប្រាក់របស់ពួកគេ ត្រូវបានបញ្ជាក់។
5. នៅពេលបញ្ចប់ការស៊ើបអង្កេត ក្រុមហ៊ុនអាចធ្វើការសម្រេចចិត្តណាមួយ ដែលខ្លួនចាត់ទុកថាត្រឹមត្រូវ និងសមហេតុផល រួមមាន៖

- ប្លុក(បិទ) គណនី (រួមទាំងគណនីស្នូនណាមួយផង) ដែលអាចរួមបញ្ចូលនូវ៖
  - រាល់បូណឹសទាំងអស់ ការភ្នាល់ដោយឥតគិតថ្លៃ និងការឈ្នះដែលទទួលបានពីបូណឹសនិងការភ្នាល់ដោយឥតគិតថ្លៃទាំងនោះ នៅពេលប្រើគណនីស្នូននេះ នឹងត្រូវចាត់ទុកជាមោយៈ ហើយអតិថិជនជាអ្នកចាញ់
  - តាមការសម្រេចចិត្តផ្តាច់មុខរបស់យើង ដើម្បីធ្វើការលុបចោលរាល់ប្រាក់ឈ្នះទាំងអស់ និងទាមទរសមតុល្យនៃគណនីរបស់អ្នកត្រឡប់មកវិញ នៅពេលចាប់ផ្តើមការស៊ើបអង្កេត (ដករាល់ប្រាក់ឈ្នះដែលបានលុបចោល) ដែលបានធ្វើឡើងពីគណនីចម្បង និងគណនីស្នូន

របស់អ្នក។ យើងក៏មានសិទ្ធិក្នុងការដកយកប្រាក់ក្នុងចំនួនណាមួយមកវិញដែលជំពាក់យើងទាក់ទងនឹងគណនីស្នួននេះ ដោយផ្ទាល់ពីគណនីណាមួយរបស់អ្នក (រួមទាំងគណនីស្នួនផ្សេងទៀតផងដែរ)។

- តាមការសម្រេចចិត្តផ្តាច់មុខរបស់យើង (ក្នុងករណីពិសេស) ដើម្បីអនុញ្ញាតឱ្យបន្តការប្រើប្រាស់គណនីចម្បង និងដើម្បីទទួលស្គាល់ថាគណនីនោះមានសុពលភាព ចំណែកឯការភ្នាល់ទាំងអស់ដែលបានដាក់ដោយអ្នកពីគណនីស្នួននឹងត្រូវចាត់ទុកជាមោយៈ ឬដើម្បីប្តូរនិង/ឬលុបចោលគណនីស្នួន តាមការសម្រេចចិត្តរបស់ក្រុមហ៊ុន (ការសម្រេចចិត្តនឹងត្រូវធ្វើឡើងសម្រាប់ករណីជាក់លាក់នីមួយៗដាច់ដោយឡែកពីគ្នា យោងទៅតាមទំហំនៃការរំលោភបំពាន)។

6. អតិថិជននឹងត្រូវទទួលខុសត្រូវលើការរក្សាការសម្ងាត់ពាក្យសម្ងាត់និងលេខគណនីរបសពួកគេ នៅពេលចុះឈ្មោះ។ រាល់ការភ្នាល់ទាំងអស់ ដែលបានចុះឈ្មោះជាមួយក្រុមហ៊ុនភ្នាល់ នឹងត្រូវមានសុពលភាព។ ការលុបចោលការភ្នាល់ នឹងត្រូវអនុវត្តតាមច្បាប់ទាំងនេះ។ ប្រសិនបើព័ត៌មានលម្អិតឡុកអ៊ីនរបស់អតិថិជនធ្លាក់ក្រោមការគ្រប់គ្រងរបស់ភាគីទីបី ក្រុមហ៊ុនភ្នាល់ត្រូវតែទទួលបានការជូនដំណឹងអំពីបញ្ហានេះ ហើយអតិថិជនត្រូវតែផ្លាស់ប្តូរឈ្មោះអ្នកប្រើប្រាស់និងពាក្យសម្ងាត់របស់ពួកគេ ព្រមទាំងប្តូរពាក្យសម្ងាត់អ៊ីម៉ែលរបស់ពួកគេឱ្យរឹងមាំជាងមុន។ អ្នកមិនត្រូវបង្ហាញលេខកូដដកប្រាក់ ឬលេខកូដណាមួយសម្រាប់ការផ្លាស់ប្តូរលេខទូរសព្ទរបស់អ្នក ទៅឱ្យភាគីទីបីណាមួយឡើយ។
7. ម្ចាស់គណនីបញ្ជាក់ថា សកម្មភាពណាមួយនៅលើគណនី គឺខ្លួនពួកគេជាអ្នកធ្វើដោយផ្ទាល់។ ប្រសិនបើគណនីនោះត្រូវបានគ្រប់គ្រងដោយភាគីទីបី នោះម្ចាស់គណនីត្រូវទទួលខុសត្រូវទាំងស្រុងសម្រាប់ការចូលប្រើគណនីនោះ។
8. ប្រសិនបើគណនីមិនដំណើរការរយៈពេល ៣ ខែ ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបប្តូកគណនីនោះ។ ដើម្បីបើកគណនីដែលបានប្តូកចោលឡើងវិញ សូមទាក់ទងទៅកាន់ក្រុមការងារផ្នែកសន្តិសុខរបស់យើង តាមរយៈ security-en@11xcambodia.com ។
9. ប្រសិនបើគណនីរបស់អ្នកប្រើប្រាស់ត្រូវបានប្តូកដោយហេតុផលណាមួយ ការចូលទៅប្រើគេហទំព័រទាំងអស់ដែលទាក់ទងនឹងម្ចាស់អាជ្ញាប័ណ្ណ ACOM LATIN AMERICA N.V. នឹងត្រូវបានរឹតបន្តឹង។ នេះមានន័យថា អ្នកប្រើប្រាស់នឹងមិនអាចឡុកអ៊ីនទៅគេហទំព័រនោះ ឬចូលទៅប្រើសេវាកម្ម ឬមុខងារណាមួយដែលផ្តល់ដោយគេហទំព័រនោះបានទេ រហូតទល់តែគណនីរបស់ពួកគេមិនត្រូវបានដោះការប្តូកចេញវិញ។

   គោលការណ៍នេះត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាសុវត្ថិភាព និងសុចរិតភាពនៃគេហទំព័រដែលពាក់ព័ន្ធជាមួយ ACOM LATIN AMERICA N.V. និងដើម្បីការពារផលប្រយោជន៍របស់ម្ចាស់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់របស់ពួកគេ។ ការដែលអ្នកប្រើប្រាស់គោរពតាមខនិងលក្ខខណ្ឌនៃការប្រើប្រាស់សម្រាប់គេហទំព័រទាំងនេះ ដើម្បីជៀសវាងការប្តូកគណនីរបស់ពួកគេ គឺពិតជាមានសារៈសំខាន់ណាស់។

7.2. ប្រាក់ដាក់ និងប្រាក់ទូទាត់សង

1. មានវិធីខុសៗគ្នាជាច្រើនក្នុងការដាក់ប្រាក់និងដកប្រាក់ពីគណនីរបស់អតិថិជន។ រាល់វិធីសាស្ត្រដាក់ប្រាក់និងដកប្រាក់ទាំងអស់ អាចស្វែងរកបាននៅផ្នែក "ការទូទាត់"។
2. រាល់សំណើដកប្រាក់ត្រូវបានដំណើរការ 24/7។
3. សេវាសន្តិសុខរបស់ 1xcambodia មានសិទ្ធិ៖
    - បដិសេធសំណើដកប្រាក់ ប្រសិនបើការដាក់ប្រាក់ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធទូទាត់អេឡិចត្រូនិក។
    - បដិសេធការដកប្រាក់ណាមួយ ដែលចំនួនទឹកប្រាក់នៃការដាក់ឬដកប្រាក់មិនត្រូវគ្នានឹងការភ្នាល់ដែលបានដាក់ (អតិថិជនត្រូវតែភ្នាល់ជាមួយប្រាក់ភ្នាល់ ដែលបូកបន្ថែមទៅលើចំនួនប្រាក់ដាក់ទាំងអស់ ហើយការភ្នាល់ត្រូវមានហាងឆេងយ៉ាងហោចណាស់ 1.10។ ចំនួនទឹកប្រាក់ភ្នាល់ខ្ពស់ដែលមានផលប៉ះពាល់តិចតួចបំផុតចំពោះសមតុល្យរបស់អ្នក នឹងមិនត្រូវបានគិតពិចារណានោះទេ ពោលគឺការភ្នាល់ដែលបានលើលទ្ធផលផ្ទុយនៅក្នុងហ្គេម ដូចជា រ៉ូឡែត បាការ៉ាត់ ក្រាបស៍ និងគ្រាប់ឡុកឡាក់)។ ចំនួនទឹកប្រាក់ដកដែលបានអនុញ្ញាត នឹងត្រូវបានគណនា ដោយផ្អែកលើចំនួនទឹកប្រាក់នៃការភ្នាល់ ដែលបានដាក់ពីការដាក់ប្រាក់ណាមួយ។
    - បដិសេធការដកប្រាក់ណាមួយ ប្រសិនបើគណនីការភ្នាល់ត្រូវបានប្រើប្រាស់ខុស។ ក្នុងករណីនេះ គណនីត្រូវតែធ្វើការផ្ទៀងផ្ទាត់ មុនពេលអាចធ្វើការដកប្រាក់បាន។
4. សេវាសន្តិសុខរបស់ 1xcambodia មិនណែនាំឱ្យអតិថិជន៖
— ផ្ទេរប្រាក់ពីប្រព័ន្ធទូទាត់មួយទៅប្រព័ន្ធមួយទៀតឡើយ
— ដាក់ប្រាក់និងដកប្រាក់ ដោយមិនបានដាក់ការភ្នាល់
ប្រសិនបើករណីខាងលើនេះកើតឡើង ប្រវាក់នឹងត្រូវប្រគល់ទៅឱ្យគណនីរបស់អតិថិជនវិញ។
5. អ្នកអាចដកប្រាក់បានតែដោយប្រើព័ត៌មានលម្អិតនៃការទូទាត់ដូចគ្នា ដែលបានប្រើសម្រាប់ការដាក់ប្រាក់ចូលទៅក្នុងគណនីរបស់អ្នកតែប៉ុណ្ណោះ។ ប្រសិនបើអ្នកប្រើវិធីសាស្ត្រផ្សេងក្នុងការដាក់ប្រាក់ ការដកទឹកប្រាក់គួរតែសមាមាត្រទៅនឹងប្រាក់ដែលបានដាក់ ដោយប្រើវិធីជាក់លាក់ណាមួយ។
6. 1xcambodia អាចបដិសេធការដកប្រាក់តាមរយៈប្រព័ន្ធទូទាត់ប្រាក់ ឬជាសាច់ប្រាក់ និងផ្តល់ជូននូវការផ្ទេរប្រាក់តាមធនាគារជំនួសវិញ។ ក្រុមហ៊ុនអាចដាក់កំហិតវិធីទូទាត់ប្រាក់មួយ ឬច្រើនតាមការសម្រេចចិត្តរបស់ខ្លួន ដែលអ្នកប្រើដើម្បីដាក់ប្រាក់ និង/ឬដកប្រាក់។
7. សូមកត់សម្គាល់ថា រដ្ឋបាលរបស់យើងខ្ញុំ មិនណែនាំឱ្យដាក់ប្រាក់ និងដកប្រាក់ ដោយប្រើកាបូបអេឡិចត្រូនិចរបស់អ្នកដទៃឡើយ។
    - ក្រុមការងារផ្នែកសន្តិសុខរបស់យើងរក្សាសិទ្ធិក្នុងការចាត់ទុកប្រាក់ដាក់នេះថាជាការក្លែងបន្លំ និងប្តូកប្រតិបត្តិការរបស់អ្នកប្រើប្រាស់នោះ ដោយគ្មានការជូនដំណឹងជាមុនឡើយ។
    - រដ្ឋបាលរបស់យើងមានសិទ្ធិក្នុងការបដិសេធការដកប្រាក់ដោយប្រើព័ត៌មានលម្អិតនៃការទូទាត់ដែលមិនមែនជាកម្មសិទ្ធិរបស់ម្ចាស់គណនី។
8. ក្នុងកាលៈទេសៈមួយចំនួន និងពាក់ព័ន្ធជាមួយនឹងអតិថិជនមួយចំនួន 1xcambodia អាចធ្វើការសម្រេចមិនទូទាត់សងថ្លៃសេវាដែលបានគិតប្រាក់តាមរយៈប្រព័ន្ធទូទាត់ទៅលើការដាក់ប្រាក់ឬដកប្រាក់ ដែលតាមធម្មតា 1xcambodia តែងសងទៅវិញ។

9. អត្រាប្តូរប្រាក់ដែលបង្ហាញសម្រាប់ប្រតិបត្តិការទូទាត់ប្រាក់ផ្សេងៗ នឹងអាចមិនដូចគ្នាទៅនឹងអត្រាប្តូរប្រាក់បច្ចុប្បន្នដែលបង្ហាញនៅលើគេហទំព័ររបស់យើងខ្ញុំនោះទេ។ ក្នុងអំឡុងពេលដំណើរការប្រតិបត្តិការ (ការដាក់ប្រាក់ និងដកប្រាក់) រូបិយប័ណ្ណត្រូវបានបំប្លែងតាមអត្រាប្តូរប្រាក់ដែលបានកំណត់នៅលើគេហទំព័ររបស់ក្រុមហ៊ុននៅពេលនោះ។
អត្រាប្តូរប្រាក់នេះមិននៅថេរទេ ហើយអាចផ្លាស់ប្តូរច្រើនដងក្នុងមួយថ្ងៃ ឬផ្ទុយទៅវិញអត្រាប្តូរប្រាក់អាចនៅតែមិនផ្លាស់ប្តូរក្នុងរយៈពេលយូរ លើសពីនេះទៀត កាលបរិច្ឆេទ និងពេលវេលាដែលឥណពន្ធពិតប្រាកដកើតឡើង នឹងអាស្រ័យលើអត្រាប្តូរប្រាក់ដែលបានជ្រើសរើសនៅលើគេហទំព័រនៅពេលនោះ។ ចំនួនទឹកប្រាក់ដកប្រាក់ចុងក្រោយ និងអត្រាប្តូរប្រាក់ពិតប្រាកដ អាចរកមើលបាននៅក្នុងទម្រង់ស្នើសុំដាក់ប្រាក់/ដកប្រាក់។
សូមចំណាំថាក្រុមហ៊ុនមិនទទួលខុសត្រូវចំពោះអ្នកភ្នាល់ណាមួយសម្រាប់ការខាតបង់ដោយប្រយោលឧប្បត្តិហេតុ ឬដោយចៃដន្យណាមួយដែលទាក់ទងនឹងអត្រាប្តូរប្រាក់ និងការបំប្លែងរូបិយប័ណ្ណទេ
10. ក្នុងករណីមួយចំនួន ក្រុមហ៊ុនមានសិទ្ធិបង្កើតនីតិវិធីផ្សៀងផ្ទាត់ជាឯកតោភាគីសម្រាប់ការទូទាត់ប្រាក់របស់អតិថិជន និងស្នើសុំព័ត៌មានបន្ថែមពីប្រព័ន្ធទូទាត់ប្រាក់នោះ។
គណនីរបស់អតិថិជនអាចនឹងត្រូវប្លុកចោល សម្រាប់គោលបំណងនីតិវិធីហិរញ្ញវត្ថុ ក្នុងអំឡុងពេលដំណើរការផ្សៀងផ្ទាត់។
យោងតាមលក្ខខណ្ឌរបស់ប្រព័ន្ធទូទាត់ប្រាក់មួយចំនួន នីតិវិធីផ្សៀងផ្ទាត់អាចមានរយៈពេលច្រើនយូរបំផុតរហូតដល់ 180 ថ្ងៃ។
11. ប្រសិនបើអតិថិជនមិនគោរពតាមច្បាប់របស់ក្រុមហ៊ុន (ឧទាហរណ៍ ដោយរំលោភលើខនិងលក្ខខណ្ឌ មិនបានដាក់ភ្នាល់ មុនពេលស្នើសុំដកប្រាក់ ។ល។) ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការបដិសេធមិនអនុញ្ញាតឱ្យអតិថិជនធ្វើការដកប្រាក់នោះទេ។
12. នឹងមិនគិតថ្លៃសេវានោះទេ ប្រសិនបើប្រាក់ត្រូវបានដាក់ចូល ឬដកចេញពីគណនីរបស់អ្នកប្រើប្រាស់ជារូបិយបណ្ណ BTC ដោយប្រើប្រព័ន្ធទូទាត់ Bitcoin។
13. យោងតាមច្បាប់បច្ចុប្បន្ននៅក្នុងប្រទេសម៉ូសំប៊ិក ទឹកប្រាក់ចំនួន 15% នឹងត្រូវកាត់ចេញពីរង្វាន់ដែលបានឈ្នះ (IRPS និងពន្ធប្រថាប់ត្រា)
របាយការណ៍ប័ណ្ណឥណទានរបស់អ្នក នឹងសរសេរ "ការភ្នាល់_ការដាក់ប្រាក់។"

7.3. ប្លុកឈាស

1. ផ្នែកនេះរៀបរាប់អំពីកម្មវិធីប្លុកឈាសដែលផ្តល់ជូនដោយក្រុមហ៊ុនភ្នាល់។
2. ប្លុកឈាសមានផ្តល់ជូនសម្រាប់តែអតិថិជនដែលបានចុះឈ្មោះតែប៉ុណ្ណោះ។
3. ចន្លោះទិន្នន័យផ្ទាល់ខ្លួនទាំងអស់នៅក្នុងគណនីរបស់អតិថិជន ត្រូវតែបំពេញ។
4. ចាំបាច់ត្រូវគូសធីកនៅក្នុងប្រអប់ "ចូលរួមក្នុងការទទួលយកប្លុកឈាស" នៅក្នុង "គណនីរបស់អ្នក"។
5. ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការត្រួតពិនិត្យកំណត់ត្រានិងកំណត់ហេតុប្រតិបត្តិការរបស់អតិថិជន ក្រោម

ហេតុផលណាមួយ។ ស្ថិតក្រោមការត្រួតពិនិត្យនោះ ប្រសិនបើបង្ហាញថា អតិថិជនម្នាក់ ឬច្រើននាក់កំពុងចូលរួមនៅក្នុងយុទ្ធសាស្ត្រដែលក្រុមហ៊ុនយល់ថាជាការរំលោភបំពានតាមការសម្រេចចិត្តផ្តាច់មុខរបស់ខ្លួន ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការដកហូតសិទ្ធិរបស់អតិថិជននោះមិនឱ្យទទួលបានប្រូម៉ូសិន និងចាត់ទុកបូណឹសជាមោយ:។

6. អតិថិជនម្នាក់ ក្រុមគ្រួសារមួយ អាសយដ្ឋានមួយ កុំព្យូទ័រប្រើប្រាស់រួមគ្នាមួយ អាស័យដ្ឋាន IP ប្រើប្រាស់រួមគ្នាមួយ និងព័ត៌មានលម្អិតគណនីដូចគ្នាណាមួយ រួមមាន អាសយដ្ឋានអ៊ីមែល ព័ត៌មានលម្អិតគណនីធនាគារ ព័ត៌មានប័ណ្ណឥណទាន និងគណនីប្រព័ន្ធទូទាត់មួយ មានសិទ្ធិទទួលបានបូណឹសតែមួយប៉ុណ្ណោះ។ វាល់ការបំពានណាមួយទៅលើការផ្តល់ជូនបូណឹសនេះ នឹងឈានទៅដល់ការបិទគណនីនោះ។
7. ប្រសិនបើចាំបាច់ អតិថិជនត្រូវផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដើម្បីបញ្ជាក់អត្តសញ្ញាណរបស់ពួកគេ (KYC)។ ការខកខានមិនបានផ្តល់ឯកសារទាំងនេះទៅតាមការស្នើសុំពីក្រុមការងារផ្នែកសន្តិសុខ នឹងអាចនាំទៅដល់លុបចោលបូណឹស/ប្រាក់ឈ្នះណាមួយ។ នៅពេលណាមួយ ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការស្នើសុំឱ្យអតិថិជនផ្តល់នូវកស្តុតាងជារូបថតដែលពួកគេកាន់អត្តសញ្ញាណប័ណ្ណ (ផ្ទៃមុខអតិថិជនត្រូវតែមើលឃើញច្បាស់នៅក្នុងរូបថត) ឬឆ្លងកាត់ការបញ្ជាក់អត្តសញ្ញាណតាមរយៈទូរសព្ទ។
8. ប្រសិនបើក្រុមហ៊ុនរកឃើញភស្តុតាងដែលបង្ហាញថា មានការរំលោភបំពានលើការផ្តល់ជូនបូណឹសកនេះ ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការចាត់វិធានការដូចខាងក្រោមប្រឆាំងនឹងអតិថិជនដែលប្រព្រឹត្តបំពាន៖ លុបចោលបូណឹស និងការឈ្នះបូណឹសបច្ចុប្បន្នទាំងអស់ ហើយបប្លុកគណនីរបស់អតិថិជន។
9. ក្រុមហ៊ុនរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ជូនបូណឹស ឬផ្អាក ឬបញ្ចប់ការផ្តល់ជូននេះគ្រប់ពេលវេលា។

បូណឹសចុះឈ្មោះ

ធ្វើការដាក់ប្រាក់។

បូណឹសដាក់ប្រាក់លើកដំបូងត្រូវតែទាមទារយកតាមរយៈការភ្នាល់ចំនួនប្រាក់ដាក់។

នៅពេលដែលរយៈពេលសុពលភាពនៃបូណឹសបានផុតកំណត់ បូណឹសនោះនឹងត្រូវបានចាត់ទុកថាបាត់បង់។

ខនិងលក្ខខណ្ឌពេញលេញនៃបូណឹស "ការដាក់ប្រាក់លើកដំបូង"

បូណឹសនៃការដាក់ប្រាក់

មានតែអតិថិជនសកម្មដែលបានធ្វើប្រតិបត្តិការប្រចាំថ្ងៃដោយប្រើគណនីរបស់ពួកគេប៉ុណ្ណោះ ដែលមានសិទ្ធិទទួលបានការផ្តល់ជូននេះ។

ធ្វើការដាក់ប្រាក់។

បូណឹសត្រូវតែត្រូវទាមទារយកតាមរយៈការភ្នាល់ចំនួនប្រាក់ដាក់។

នៅពេលដែលរយៈពេលសុពលភាពនៃបូណឹសបានផុតកំណត់ បូណឹសនោះនឹងត្រូវបានចាត់ទុកថាបាត់បង់។

ខនិងលក្ខខណ្ឌពេញលេញរបស់បូណឹស "ថ្ងៃសុក្រនាំសំណាង"

ខនិងលក្ខខណ្ឌពេញលេញរបស់បូណឹស "ថ្ងៃពុធ x2"

កាដូ

កាដូគឺជាប្រភេទបូណឹសជាក់លាក់ដែលតម្រូវឱ្យធ្វើការដាក់ប្រាក់ (លើកលែងតែមានចែងផ្សេងពីនេះក្នុងច្បាប់)។ កាដូរួមមានការបង្វិលដោយឥតគិតថ្លៃ ឬគ្មានលក្ខខណ្ឌតម្រូវឱ្យដាក់ភ្នាល់ ក៏ដូចជាលេខកូដប្រូម៉ូសិន សម្រាប់ការបង្វិលដោយឥតគិតថ្លៃ និងប្រាក់បូណឹសដោយមានឬគ្មានលក្ខខណ្ឌតម្រូវឱ្យដាក់ភ្នាល់ប្រាក់ពិតប្រាកដ។

កាដូអាចស្ថិតក្រោមខនិងលក្ខខណ្ឌជាក់លាក់ ដូច្នេះ មុនពេលបើកដំណើរការកាដូទាំងនោះ យើងសូមណែនាំឱ្យអ្នកអានច្បាប់ដែលពាក់ព័ន្ធទាំងនោះដោយយកចិត្តទុកដាក់ដើម្បីឱ្យបានដឹង (ចំនួនបូណឹស លក្ខខណ្ឌតម្រូវកឱ្យដាក់ភ្នាល់ ។ល។) នៅក្នុងផ្នែកដែលពាក់ព័ន្ធនៃគណនីរបស់អ្នកសម្រាប់ព័ត៌មានលម្អិតបន្ថែម និងដើម្បីជៀសវាងការយល់ច្រឡំណាមួយ។

កាដូអាចនឹងត្រូវបានផ្តល់ជូនតាមវិធីមួយក្នុងចំណោមវិធីពីរយ៉ាង៖ អាចនឹងមានផ្តល់ជូនភ្លាមៗនៅក្នុងផ្នែកសមស្របនៃគណនីរបស់អតិថិជន (បូណឹស និងកាដូ) ឬផ្ញើកាដូទាំងនោះទៅអតិថិជនជាលេខកូដប្រូម៉ូសិន (តាមរយៈគេហទំព័រដៃគូ ក្នុងសារផ្ទាល់ខ្លួន ។ល។) ដែលត្រូវតែវាយបញ្ចូលក្នុងចន្លោះសមស្របនៅក្នុងផ្នែក "បូណឹស និងកាដូ"។

ការប្រើប្រាស់កាដូនេះ ពុំតម្រូវឱ្យអតិថិជនធ្វើការដាក់ប្រាក់នោះទេ។ ក៏ប៉ុន្តែ ជាញឹកញាប់ ត្រូវតែបំពេញតាមលក្ខខណ្ឌមួយចំនួន ដើម្បីអាចប្រើប្រាក់ណាមួយដែលបានឈ្នះពីការប្រើកាដូ។

ក្នុងមួយលើក។ អាចមានកាដូដែលកំពុងដំណើរការតែមួយប៉ុណ្ណោះ។ កាដូដទៃផ្សេងទៀត ត្រូវតែមិនមានដំណើរការ ផ្អាក ឬលុបចោល។

លេខកូដប្រូម៉ូសិន និងកាដូដែលបានផ្តល់ជូនជាលេខកូដប្រូម៉ូសិន អាចបើកដំណើរការបានតែនៅលើកាបូបចម្បងរបស់អតិថិជនតែប៉ុណ្ណោះ។ ការប្រើលេខកូដប្រូម៉ូសិនពីកាបូបលុយក្នុងរូបិយប័ណ្ណផ្សេងទៀត នឹងឈានទៅដល់ការលុបចោលការផ្តល់ជូន និងបាត់បង់វឌ្ឍនភាពនៃការភ្នាល់ណាមួយ។

កាដូ និងប្រាក់ឈ្នះណាមួយដែលទទួលបានតាមរយៈកាដូនោះ នឹងត្រូវបាត់បង់បន្ទាប់ពីកាលបរិច្ឆេទផុតកំណត់។ កាលបរិច្ឆេទផុតកំណត់នឹងត្រូវបានបង្ហាញនៅក្នុងផ្នែក "បូណឹស និងកាដូ" នៃគណនីរបស់អតិថិជន។

នៅពេលដែលការផ្តល់ជូននេះកំពុងដំណើរការ អតិថិជននៅតែអាចដាក់ការភ្នាល់ដោយប្រើប្រាក់ពីគណនីចម្បងរបស់ពួកគេបានដដែល។ ការធ្វើដូច្នេះនឹងមិនបណ្តាលឱ្យការផ្តល់ជូនកាដូដែលកំពុងមានដំណើរការផុត

សុពលភាពឡើយ។

លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ បើពុំដូច្នោះទេ ប្រាក់ពីកាដូដែលបានបំពេញតាមលក្ខខណ្ឌតម្រូវឱ្យដាក់ភ្នាល់ នឹងត្រូវដាក់បញ្ចូលទៅក្នុងសមតុល្យគណនីរបស់អតិថិជនក្នុងរយៈពេល 24 (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលដែលបានបំពេញតាមលក្ខខណ្ឌតម្រូវនៃការដាក់ភ្នាល់នោះ។

ធូណាមិន

ដើម្បីចូលរួមក្នុងធូណាមិន អ្នកត្រូវតែចុះឈ្មោះដោយចុចប៊ូតុង "ចូលរួម" នៅលើទំព័រផ្តល់ជូន។

រង្វាន់ទាំងអស់នឹងត្រូវផ្តល់ជូនទៅអ្នកឈ្នះធូណាមិនក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីធូណាមិនដែលពាក់ព័ន្ធបានបញ្ចប់។

ក្នុងករណីដែលអតិថិជនពីរនាក់មានចំណាត់ថ្នាក់ឈ្នះរង្វាន់ដូចគ្នា អ្នកឈ្នះនឹងក្លាយជាអតិថិជនដំបូងគេដែលបំពេញលក្ខខណ្ឌនៃធូណាមិននោះ។

នៅពេលគណនាលទ្ធផល មានតែការភ្នាល់ដែលបានដាក់ដោយប្រាក់ពិតប្រាកដប៉ុណ្ណោះដែលត្រូវបានរាប់បញ្ចូល។

8. ការភ្នាល់ផ្សាយផ្ទាល់

1. ការភ្នាល់ផ្សាយផ្ទាល់ ត្រូវបានទទួលយកនៅលើទីផ្សារចម្បង (ឈ្នះ សរុប គ្រាប់ត) និងទីផ្សារបន្ថែម (HT-FT ។ល។)។ អ្នកអាចដាក់ការភ្នាល់ផ្សាយផ្ទាល់ទោល ឬដាក់បញ្ចូលវានៅក្នុងការភ្នាល់បក។
2. ការភ្នាល់នឹងត្រូវបានចាត់ទុកថា បានទទួលយក នៅពេលដែលវាត្រូវបានចុះបញ្ជីនៅលើសឺរី ហើយការបញ្ជាក់តាមអនឡាញត្រូវបានទទួលយក។ អ្នកមិនអាចផ្លាស់ប្តូរការភ្នាល់ នៅពេលដែលវាត្រូវបានទទួលយកហើយទេ។ ប្រសិនបើកាល:ទេស: ដែលបានបញ្ជាក់នៅក្នុងទំព័រ.2.7 នៃ "លក្ខខណ្ឌទូទៅ" កើតឡើង ការភ្នាល់ផ្សាយផ្ទាល់អាចត្រូវបានទូទាត់តាមហាងឆេង 1។
3. ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះភាពមិនត្រឹមត្រូវណាមួយ ដែលទាក់ទងនឹងពិន្ទុបច្ចុប្បន្ននៃការប្រកួត ដែលការភ្នាល់កំពុងត្រូវបានទទួលយកលើនោះទេ។ អតិថិជនគួរតែយោងទៅលើ ប្រភពព័ត៌មានឯករាជ្យផ្សេងទៀត។
4. គ្មានការភ្នាល់ផ្សាយផ្ទាល់ណាមួយ ដែលអាចត្រូវបានកែសម្រួល ឬលុបចោលឡើយ។

9. លទ្ធផលនៃការប្រកួត កាលបរិច្ឆេទនិងពេលវេលាចាប់ផ្តើម ការដោះស្រាយវិវាទ

ការទូទាត់ការភ្នាល់អាចត្រូវបានពិនិត្យឡើងវិញ នៅពេលក្រុមហ៊ុនភ្នាល់បង្ហាញថាលទ្ធផលមិនត្រឹមត្រូវ។

1. ការភ្នាល់ត្រូវបានទូទាត់ផ្អែកលើម៉ោងចាប់ផ្តើមជាក់ស្តែងនៃព្រឹត្តិការណ៍ដែលត្រូវបានកំណត់ដោយអនុលោមតាមឯកសារផ្លូវការនៃអង្គភាពដែលរៀបចំព្រឹត្តិការណ៍នេះ។ ការខកខានមិនបានទទួលនូវឯកសារដែលមានប្រសិទ្ធិភាពនោះ ព័ត៌មានត្រូវយកចេញពីវេបសាយផ្លូវការរបស់សហព័ន្ធកីឡា វេបសាយក្លឹបកីឡា និងប្រភពព័ត៌មានកីឡាដទៃទៀត។
2. ក្រុមហ៊ុនភ្នាល់មិនទទួលខុសត្រូវចំពោះភាពខុសគ្នារវាងកាលបរិច្ឆេទនិងពេលវេលាដែលបានបញ្ជាក់ និងកាលបរិច្ឆេទនិងពេលវេលាជាក់ស្តែងនៃព្រឹត្តិការណ៍នោះទេ។ កាលបរិច្ឆេទនិងពេលវេលាចាប់ផ្តើមនៃព្រឹត្តិការណ៍ ដូចដែលបានបង្ហាញនៅក្នុងផ្នែក "កីឡា" គឺជាការបង្ហាញឱ្យឃើញ។ ការភ្នាល់ត្រូវបានទូទាត់ទៅតាមពេលវេលាចាប់ផ្តើមជាក់ស្តែងនៃព្រឹត្តិការណ៍ដែលបានបញ្ជាក់នៅក្នុងឯកសារផ្លូវការរបស់អ្នករៀបចំព្រឹត្តិការណ៍នោះ។
3. ក្រុមហ៊ុនភ្នាល់សូមមិនទទួលខុសត្រូវចំពោះ ឯកសារយោងមិនត្រឹមត្រូវទៅនឹងឈ្មោះនៃប្រកួតដណ្តើមជើងឯក ឬរយៈពេលនៃការប្រកួត (ព្រឹត្តិការណ៍កីឡា) ឡើយ។ ព័ត៌មានលម្អិតបង្ហាញនៅក្នុងផ្នែក "កីឡា" ឬ "ផ្សាយផ្ទាល់" គឺជាការបង្ហាញឱ្យឃើញ។ អតិថិជនគួរប្រើប្រភពព័ត៌មានឯករាជ្យផ្សេងទៀត ដើម្បីរកព័ត៌មានលម្អិតនៃព្រឹត្តិការណ៍កីឡាដែលពាក់ព័ន្ធ។
4. ព័ត៌មានអាកាសធាតុនៅក្នុងផ្នែក កីឡា និង ផ្សាយផ្ទាល់ គឺជាការបង្ហាញឱ្យឃើញ។ ភាពមិនស៊ីគ្នានៃលក្ខខណ្ឌអាកាសធាតុ នៅក្នុងផ្នែក កីឡា និង ផ្សាយផ្ទាល់ មិនអាចជាមូលហេតុនៃការលុបចោលការភ្នាល់ដែលបានដាក់នោះទេ។
5. ពាក្យបណ្តឹងអំពីលទ្ធផលគួរតែត្រូវបានបញ្ជូនក្នុងរយៈពេល 10 ថ្ងៃនៃថ្ងៃប្រតិទិន ចាប់ពីចុងបញ្ចប់នៃព្រឹត្តិការណ៍ប្រសិនបើមានឯកសារផ្លូវការទាក់ទងនឹងលទ្ធផលនៃព្រឹត្តិការណ៍ដែលចេញដោយអ្នករៀបចំព្រឹត្តិការណ៍នោះ។
6. ការភ្នាល់ ដែលត្រូវបានដាក់បន្ទាប់ពីម៉ោងចាប់ផ្តើមនៃព្រឹត្តិការណ៍ នឹងត្រូវបានទូទាត់តាមហាងឆេង 1 (លើកលែងតែការភ្នាល់ផ្សាយផ្ទាល់) ហើយនៅក្នុងការភ្នាល់បក ហាងឆេងនៃជើងបែបនេះ នឹងត្រូវបានយកហាងឆេង 1។
7. ប្រសិនបើអតិថិជនដាក់ការភ្នាល់លើព្រឹត្តិការណ៍ ដែលលទ្ធផលត្រូវបានគេដឹងនោះ ការភ្នាល់បែបនេះនឹងត្រូវលុបចោល។ នៅក្នុងករណីនេះ ក្រុមហ៊ុនភ្នាល់ត្រូវធ្វើការសម្រេចចិត្ត តែបន្ទាប់ពីមានការស៊ើបអង្កេតឯកជនពិសេសប៉ុណ្ណោះ។ រាល់សកម្មភាពដែលទាក់ទងនឹងការភ្នាល់បែបនេះ ត្រូវបានផ្អាកជាបណ្តោះអាសន្នសិន។
8. ការភ្នាល់-មុនការប្រកួត។ ប្រសិនបើការប្រកួត ឬការប្រកួតប្រជែង ត្រូវបានពន្យាពេល (កំណត់ពេលវេលាឡើងវិញ)លើសពី 48 ម៉ោង ដោយហេតុផលណាមួយ រាល់ការភ្នាល់លើព្រឹត្តិការណ៍

ទាំងអស់ នឹងត្រូវចាត់ទុកជាមោឃៈ (នេះគឺជាពេលវេលាប្រហាក់ប្រហែល ក្រុមហ៊ុនភ្នាល់នឹងមានសិទ្ធិក្នុងការរក្សាការភ្នាល់ទាំងនោះ លើការសំរេចចិត្តជាដាច់ខាតរបស់យើង ដើម្បីចៀសវាងវិវាទ ដែលអាចកើតឡើង ប្រសិនបើការប្រកួតត្រូវបានពន្យារពេលលើសពី 48 ម៉ោង គិតចាប់ពីពេលវេលាចាប់ផ្តើមផ្លូវការ)។ ព្រឹត្តិការណ៍នេះត្រូវបានចាត់ទុកថាត្រូវបានពន្យារពេល ឬកំណត់ពេលវេលាឡើងវិញ ប្រសិនបើពេលវេលាចាប់ផ្តើមជាផ្លូវការនៃព្រឹត្តិការណ៍ ត្រូវបានផ្លាស់ប្តូរ។

9. ការភ្នាល់ផ្សាយផ្ទាល់។ ប្រសិនបើការប្រកួតឬការប្រកួតប្រជែងត្រូវបានអាក់ខាន ដោយហេតុផលណាមួយ និងបន្តក្នុងរយៈពេល 5 ម៉ោង ចាប់ពីពេលចាប់ផ្តើម ការភ្នាល់ទាំងអស់នឹងមានសុពលភាព។ ប្រសិនបើការប្រកួតអាក់ខាន ឬការប្រកួតនោះមិនបន្តក្នុងរយៈពេល 5 ម៉ោង ចាប់ពីពេលចាប់ផ្តើម ការភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែពេលដែលលទ្ធផលនៃការភ្នាល់ត្រូវបានកំណត់រួចហើយ។ ច្បាប់នេះមិនអនុវត្តចំពោះព្រឹត្តិការណ៍ ដែលអាចបញ្ចប់ក្នុងរយៈពេលលើសពី 5 ម៉ោង ដែលស្ថិតក្រោមច្បាប់របស់ពួកគេឡើយ (សូមមើលទំព័រ 9 "ច្បាប់កីឡា")។
10. ប្រសិនបើការប្រកួតមួយមិនបានបញ្ចប់ ហើយត្រូវបានគេបោះបង់ចោល (សូមមើលទំព័រ 9 "ច្បាប់កីឡា") លទ្ធផលដែលបានកំណត់មុនពេលបោះបង់ចោលនោះ (ឧទាហរណ៍ ទីផ្សារពាក់កណ្តាលដំបូង គ្រាប់បាល់ទីមួយ និងទីផ្សារពេលវេលារបស់វា ។ល។) ត្រូវបានរាប់បញ្ចូលនៅឯការទូទាត់ការភ្នាល់។ រាល់ការភ្នាល់ដែលនៅសល់នឹងត្រូវទូទាត់តាមហាងឆេង 1។
11. ប្រសិនបើអ្នកចូលរួមដកខ្លួនមុនព្រឹត្តិការណ៍ចាប់ផ្តើម ដូច្នេះរាល់ការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ។
12. ប្រសិនបើអ្នកចូលរួមបោះបង់ ក្នុងអំឡុងពេលនៃការប្រកួត ដោយហេតុផលណាមួយ (ការរងរបួស ការដកប្រាក់ ។ល។) រាល់ការភ្នាល់ទាំងអស់ ដែលបានដាក់មុនពេលចាប់ផ្តើម ជុំចុងក្រោយនៃការប្រកួតដែល គាត់/នាងបានចូលរួមនឹងត្រូវបន្ត។ រាល់ការភ្នាល់ផ្សេងទៀតទាំងអស់ នឹងត្រូវបានចាត់ទុកជាមោឃៈ។ ប្រសិនបើកីឡាករដកខ្លួនចេញពីការប្រកួតកីឡាតេន្នីស នោះការភ្នាល់នឹងត្រូវបានទូទាត់យោងតាមច្បាប់នៃទំព័រទី. 9.23 ។
13. ប្រសិនបើសមាជិកនៃក្រុមមួយ (កីឡាករបាល់ទាត់ ហុកគី បាល់បោះ។ល។) មិនបានចូលរួមក្នុងការប្រកួតទេ ហាងឆេងដែលឈ្នះ ពាក់ព័ន្ធនឹងពួកគេ នឹងត្រូវបានទុកថាស្មើនឹង 1 លើកលែងតែមានការចែងផ្សេងពីនេះ។
14. ប្រសិនបើការដកខ្លួនឬការដកសិទ្ធិ ធ្វើឡើងមុនពេលចាប់ផ្តើមនៃកីឡាតេន្នីស ហាងឆេងទឹកប្រាក់ឈ្នះនឹងមានចំនួន 1 លើកលើកលែងតែការភ្នាល់លើការឈ្នះរបស់អ្នកចូលរួមក្នុងការប្រកួតនេះ (ការភ្នាល់នឹងត្រូវបានចាត់ទុកថាចាញ់)។ ប្រសិនបើការប្រកួតតេន្នីសត្រូវបានអាក់ខាន មិនបញ្ចប់នៅថ្ងៃដដែល ហើយត្រូវបានពន្យារពេល នោះការភ្នាល់ទាំងអស់ នឹងមានសុពលភាពរហូតដល់ចុងបញ្ចប់នៃធូណាមិនដែលបានគ្រោងទុក រហូតដល់ការប្រកួតត្រូវបានបញ្ចប់ ឬអ្នកចូលរួមណាម្នាក់ដកខ្លួនចេញ។ ប្រសិនបើកីឡាករដកខ្លួនចេញពីការប្រកួតកីឡាតេន្នីសនោះការភ្នាល់នឹងត្រូវបានទូទាត់យោងតាមច្បាប់នៃទំព័រទី. 9.23 ។
15. នៅពេលគូប្រជែងដែលត្រូវបានដាក់ឈ្មោះជាក់លាក់ចំនួនពីរ (ក្រុម កីឡាករ) ត្រូវបានរំពឹងថា នឹងចូលរួមក្នុងព្រឹត្តិការណ៍មួយ (ការប្រកួត ការប្រកួតប្រជែង ឬការប្រយុទ្ធ) ប៉ុន្តែក្រោយមកគូប្រជែងមួយឬ

ទាំងពីរផ្លាស់ប្តូរ នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានលុបចោល។

16. នៅក្នុងការប្រកួតជាក្រុម នៅពេលដែលកីឡាករម្នាក់ឬច្រើននាក់ត្រូវបានជំនួសនៅក្នុងក្រុមណាមួយ ដោយហេតុផលណាមួយ ការភ្នាល់ទាំងអស់នៅលើលទ្ធផលនៃការប្រកួតនឹងត្រូវបន្ត។
17. នៅក្នុងការប្រកួតទ្វេដង នៅពេលដែលឈ្មោះនៃដៃគូត្រូវបានបញ្ជាក់ ហើយយ៉ាងហោចណាស់ អ្នកចូលរួមម្នាក់ត្រូវបានជំនួស ហាងឆេងដែលឈ្នះគឺ 1 ។ នៅពេលដែលឈ្មោះនៃដៃគូមិនត្រូវបានបញ្ជាក់ ការភ្នាល់ទាំងអស់នឹងត្រូវបន្ត។
18. នៅក្នុងការប្រកួតប្រជែង ដែលពាក្យ "ក្រុមម្ចាស់ផ្ទះ" និង "ក្រុមភ្ញៀវ" ត្រូវបានប្រើប្រាស់ ក្នុងករណីដែលព្រឹត្តិការណ៍នេះនឹងប្រព្រឹត្តទៅនៅកន្លែងផ្សេងនា នោះត្រូវអនុវត្តដូចខាងក្រោម៖
    - ប្រសិនបើកន្លែងអព្យាក្រឹត ការភ្នាល់នឹងមានសុពលភាព;
    - ប្រសិនបើកន្លែងប្រកួតរបស់ក្រុមប្រឆាំង ការភ្នាល់នឹងមានសុពលភាព។
19. នៅពេលដែលពាក្យ "ក្រុមម្ចាស់ផ្ទះ" និង "ក្រុមភ្ញៀវ" មិនអនុវត្តចំពោះព្រឹត្តិការណ៍មួយ (ឧទាហរណ៍ ក្នុងកីឡាពីរនាក់ឬឯកត្តជន) ក្នុងករណីដែលព្រឹត្តិការណ៍ណាមួយកើតឡើងនៅទីកន្លែងខុសពីអ្វីដែលបានកំណត់ដំបូង ការភ្នាល់នឹងត្រូវបន្ត។ NBA, NHL, AHL, CHL, OHL, WHL និងលីគហុកគីឆ្នេរខាងកើត អាចត្រូវបានបង្ហាញតាមលំដាប់ផ្ទាល់ (ក្រុមម្ចាស់ផ្ទះ – ក្រុមភ្ញៀវ) និងតាមលំដាប់បញ្ច្រាស់។
ប្រសិនបើជាករណីចុងក្រោយ គ្មានប្រាក់ភ្នាល់ណាត្រូវបានបង្វិលសងវិញទេ។
20. នៅក្នុងការប្រកួតមិត្តភាព រួមទាំងការប្រកួតមិត្តភាពរបស់ក្លឹប នៅពេលព្រឹត្តិការណ៍នេះប្រព្រឹត្តទៅនៅកន្លែងផ្សេង រាល់ការភ្នាល់នឹងមានសុពលភាព។
21. ប្រសិនបើមិនមានការពិពណ៌នា អំពីការទូទាត់ការភ្នាល់សម្រាប់កីឡាឬស្ថានភាពណាមួយទេនោះ ច្បាប់នេះនឹងត្រូវគ្រប់គ្រងដោយលក្ខខណ្ឌទូទៅ។
22. នៅពេលមានទំនាស់ប្រភេទជាក់លាក់មួយកើតឡើងជាលើកដំបូង ក្រុមហ៊ុនភ្នាល់ត្រូវធ្វើការសម្រេចចុងក្រោយ។
23. ក្នុងករណីដែលស្ថិតិពីប្រភពផ្លូវការនិងឯករាជ្យមានភាពខុសគ្នា ក្រុមហ៊ុនសូមរក្សាសិទ្ធិក្នុងការទូទាត់ការភ្នាល់ផ្អែកលើស្ថិតិដែលទទួលបានពីការថតវីដេអូឬប្រភពឯករាជ្យ។
24. ក្នុងករណីមានភាពខុសគ្នាលើទិន្នន័យពីប្រភពព័ត៌មានផ្សេងៗគ្នា (កាលបរិច្ឆេទ ពេលវេលា លទ្ធផល ឈ្មោះក្រុម) ក្រុមហ៊ុនត្រូវផ្អាកការទូទាត់ រហូតដល់ភាពត្រឹមត្រូវនៃទិន្នន័យបែបនេះត្រូវបានបង្កើតឡើងតាមរយៈការស៊ើបអង្កេត។ ប្រសិនបើលទ្ធផលនៃព្រឹត្តិការណ៍ដែលបានបញ្ចប់មួយ ដែលបានចេញផ្សាយនៅលើវេបសាយផ្លូវការ ខុសពីអ្វីដែលបានបង្ហាញនៅក្នុងការចាក់ផ្សាយតាមទូរទស្សន៍ នោះក្រុមហ៊ុនភ្នាល់ សូមរក្សាសិទ្ធិក្នុងការទូទាត់ការភ្នាល់ដោយផ្អែកលើការចាក់ផ្សាយតាមទូរទស្សន៍។
25. ប្រសិនបើមានកំហុសក្នុងការអនុវត្តលទ្ធផលហាងឆេង និងក្រុមហ៊ុនភ្នាល់ទទួលស្គាល់កំហុសបែបនេះ ការភ្នាល់ទាំងអស់លើជម្រើសបែបនេះនឹងត្រូវបានចាត់ទុកថាឈ្នះ ហើយការទូទាត់សងនឹងត្រូវធ្វើឡើងតាមហាងឆេង 1។
26. ក្រុមហ៊ុនភ្នាល់អាចចេញផ្សាយលក្ខខណ្ឌទាំងនេះជាភាសាផ្សេងៗគ្នា ដោយបង្ហាញពីគោលការណ៍ដូចគ្នានៅក្នុងលក្ខខណ្ឌនីមួយៗ។ លក្ខខណ្ឌនេះត្រូវបានធ្វើក្នុងគោលបំណងផ្តល់ព័ត៌មាន និងជំនួយការដល់អតិថិជន។ ក្នុងពេលជាមួយគ្នានេះ លក្ខខណ្ឌគឺជាកំណែភាសាអង់គ្លេស ដែលបម្រើជាច្បាប់

មូលដ្ឋានសម្រាប់ទំនាក់ទំនងរវាងអតិថិជន និងក្រុមហ៊ុនភ្នាល់។ ក្នុងករណីមានភាពមិនស្របគ្នារវាងលក្ខខណ្ឌអត្ថបទភាសាអង់គ្លេស និងអត្ថបទជាភាសាផ្សេងទៀតនោះ អត្ថបទជាភាសាអង់គ្លេសត្រូវអនុវត្តតាម។

27. ប្រសិនបើលទ្ធផលដំបូងនៃព្រឹត្តិការណ៍ដែលបានបញ្ចប់មួយ ត្រូវបានពិនិត្យឡើងវិញនៅពេលក្រោយដោយហេតុផលណាមួយ ហើយភាគីណាមួយបានបោះបង់ចោលការប្រកួត (ការបោះបង់ចោលនឹងមិនត្រូវបានយកមកគិត) រាល់ការភ្នាល់នឹងត្រូវបានទូទាត់តាមលទ្ធផលដំបូង (ជាក់ស្តែង)។ លទ្ធផលជាក់ស្តែង គឺជាលទ្ធផលដែលបានប្រកាស ផ្អែកលើនាទីផ្លូវការនិងប្រភពព័ត៌មានផ្លូវការផ្សេងទៀតភ្លាមៗ បន្ទាប់ពីបញ្ចប់ព្រឹត្តិការណ៍។

10. ច្បាប់ស្តីពីកីឡា

10.1. ច្បាប់បាល់ទាត់អូស្ត្រាលី

1. ក្រុមហ៊ុនភ្នាល់ទទួលយកការភ្នាល់៖
   - នៅម៉ោងធម្មតា 80 នាទី (បួនតង់ ដែលមួយតង់ៗមានរយៈពេល 20 នាទី ឬពីរតង់ដែលមួយតង់ៗមានរយៈពេល 40 នាទី)
   - នៅម៉ោងធម្មតា រាប់បញ្ចូលទាំងម៉ោងបន្ថែម (ដាក់ស្លាក "រួមទាំងម៉ោងបន្ថែម")។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួតឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. ប្រសិនបើការប្រកួតត្រូវបានអាក់ខាន មុនពេលផុតកំណត់ 80 នាទី រាល់ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារទាំងនោះដែលបានកំណត់ដោយគ្មានលក្ខខណ្ឌរួចហើយនៅពេលការប្រកួតត្រូវបានអាក់ខាន។
3. ប្រសិនបើកន្លែងប្រកួតត្រូវបានផ្លាស់ប្តូរនោះការភ្នាល់ដែលបានដាក់រួចហើយនឹងនៅមានសុពលភាពបន្តបើក្រុមម្ចាស់ផ្ទះគឺនៅតែត្រូវបានកំណត់ជាបែបនោះ។
4. **នឹងរកបានគ្រាប់ដំបូង ។** ប្រសិនបើកីឡាករមិនបានចូលរួមក្នុងការប្រកួត ឬត្រូវបានបញ្ចូលជាអ្នកជំនួសបន្ទាប់ពីគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី ការភ្នាល់ទាំងអស់លើកីឡាករនេះនឹងត្រូវចាត់ទុកជាមោឃៈ។ ការភ្នាល់លើកីឡាករ ដែលត្រូវបានប្តូរចេញឬបណ្តេញចេញ មុនពេលគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី នឹងត្រូវចាញ់។ ប្រសិនបើគ្រាប់បាល់ដំបូងត្រូវបានទាត់ដោយកីឡាករណាដែលគ្មានតម្លៃត្រូវបានផ្តល់ជូន ការភ្នាល់ទាំងអស់លើកីឡាករផ្សេងទៀតនឹងចាញ់ លើកលែងតែទីផ្សារ "កីឡាករផ្សេងទៀត"។ ប្រសិនបើការប្រកួតត្រូវបានអាក់ខាន មុនពេលគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី ការភ្នាល់ទាំងអស់នឹងត្រូវបានលុបចោល។
5. គ្រាប់បាល់មួយ (6 ពិន្ទុ) គឺនៅពេលដែលបាល់ត្រូវបានទាត់ចូលចន្លោះបង្គោលទីតូចខាងក្នុង ដោយមិនប៉ះកីឡាករណាម្នាក់ទៀត ហើយក្រុមដែលរកពិន្ទុ គឺទទួលបាន 6 ពិន្ទុ។
6. គ្រាប់នៅពីក្រោយ (1 ពិន្ទុ) គឺនៅពេលដែលបាល់ត្រូវបានទាត់ចូលចន្លោះបង្គោលទីខាងក្នុងនិងបង្គោលទីខាងក្រៅនៅក្រោយ ឬបាល់ប៉ះនឹងបង្គោលទី ឬក៏ឆ្លងកាត់លើច្រកទ្វារឬខ្សែខាងក្រោយ។
7. ការភ្នាល់នៅលើទីផ្សារ “HT-FT” ត្រូវបានទទួលយក នៅពាក់កណ្តាលតង់និងការប្រកួតទាំងមូល។

10.2. បាល់ឱបអាមេរិក

1. ការភ្នាល់ត្រូវបានទទួលយកនៅម៉ោងធម្មតា ដោយរាប់បញ្ចូលទាំងម៉ោងបន្ថែម លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។
2. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ នោះការភ្នាល់ទាំងអស់នឹងត្រូវទូទាត់សងតាមហាងឆេង 1.00 លើកលែងតែក្នុងករណីដូចខាងក្រោម៖
    - ប្រសិនបើលទ្ធផលនៃការភ្នាល់ត្រូវបានដឹងរួចហើយយ៉ាងច្បាស់លាស់នៅពេលចប់ការប្រកួត។
    - ប្រសិនបើការប្រកួតត្រូវបានលេងយ៉ាងហោចណាស់ 55 នាទីនៅពេលដែលការប្រកួតត្រូវបានបញ្ឈប់។ ក្នុងករណីនេះ ការប្រកួតនឹងត្រូវបានចាត់ទុកថាបានកើតឡើង ហើយការភ្នាល់នឹងត្រូវបានទូទាត់សងដោយផ្អែកលើពិន្ទុជាក់ស្តែង។
3. សម្រាប់ការភ្នាល់លើទីផ្សារ "ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន" ប្រសិនបើក្រុមទាំងនោះមិនអាចឆ្លងផុតវគ្គជម្រុះចេញពីពូលបានទេ នោះអាទិភាពនឹងត្រូវផ្តល់ដោយផ្អែកលើចំណាត់ថ្នាក់រៀងៗខ្លួននៅក្នុងពូលនោះ ហើយបន្ទាប់មកផ្អែកលើចំនួនពិន្ទុ ឬភាគរយឈ្នះ។
4. "តង់ដប់ប្រាំនាទីដែលរកបានពិន្ទុខ្ពស់បំផុត (ទាបបំផុត) – តូតាល់"។ ប្រសិនបើតង់ដប់ប្រាំនាទីចំនួនពីរឬច្រើនត្រូវបញ្ចប់ដោយមានពិន្ទុខ្ពស់បំផុត/ទាបបំផុតដូចគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់សងដោយផ្អែកតាមចំនួនសរុបជាក់ស្តែង។ ក្នុងកាល:ទេស:បែបនេះ មិនមានការសងប្រាក់វិញទេ។
5. "តង់ដប់ប្រាំនាទីដែលរកបានពិន្ទុខ្ពស់បំផុត"។ ប្រសិនបើតង់ដប់ប្រាំនាទីដែលរកបានពិន្ទុខ្ពស់បំផុត មិនអាចកំណត់បានទេ (ឧទាហរណ៍៖ នៅពេលតង់ដប់ប្រាំនាទីចំនួនពីរឬច្រើនជាងនេះ បានបញ្ចប់ដោយមានចំនួនពិន្ទុរកបានដូចគ្នា) នោះការភ្នាល់លើតង់ទាំងនោះ នឹងត្រូវទូទាត់សងតាមហាងឆេង 1.00។ ការភ្នាល់នៅតង់ដប់ប្រាំនាទីផ្សេងទៀតនឹងត្រូវចាញ់។
6. "តង់ដែលរកបានពិន្ទុខ្ពស់បំផុត"។ ក្នុងករណីដែលតង់ទាំងពីរ បញ្ចប់ទៅដោយមានចំនួនពិន្ទុដូចគ្នា នោះការភ្នាល់នឹងត្រូវទូទាត់សងតាមហាងឆេង 1.00។
7. ប្រសិនបើការប្រកួត (រាប់ទាំងម៉ោងបន្ថែម) បញ្ចប់ក្នុងលទ្ធផលស្មើគ្នា នោះការភ្នាល់ W1 និង W2 នឹងត្រូវទូទាត់សងតាមហាងឆេង 1.00។ ការភ្នាល់លើចំនួនសរុប និងគ្រាប់តនឹងត្រូវទូទាត់សងដោយផ្អែកលើលទ្ធផលជាក់ស្តែងរបស់ការប្រកួត។
8. ការភ្នាល់លើការដាក់បាល់ដល់ក្រោយទីគូប្រកួតរបស់កីឡាករ (គ្រប់ពេល ដំបូងគេ/ក្រោយគេសរុប) រួមមានការដាក់បាល់ដល់ក្រោយទីគូប្រកួតដែលរកបានតាមរយៈការគប់បាល់ ការទទួលបាល់ ការដណ្តើមយកបាល់មកវិញ ការទាត់បាល់ពីលើទីលាន ការទាត់បាល់ទម្លាក់ចេញពីដៃ និងរបួតបាល់ពីដៃវិញ។
9. "លទ្ធផលគ្រប់គ្រងបាល់ (X)"។ ប្រសិនបើការគ្រប់គ្រងបាល់មិនត្រូវបានបញ្ចប់ដោយសារតែចុងបញ្ចប់តង់ ឬការប្រកួត នោះការភ្នាល់លើទីផ្សារនេះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1.00។
    - ការដាក់បាល់ដល់ក្រោយទីគូប្រកួត៖ ការភ្នាល់នេះឈ្នះ ប្រសិនបើក្រុមដែលគ្រប់គ្រងបាល់បានដាក់បាល់ដល់ក្រោយទីគូប្រកួតនៅពេលចាប់ផ្តើមគ្រប់គ្រងបាល់ រួមទាំងលទ្ធផលនៃសកម្មភាពរបស់ខ្សែប្រយុទ្ធ ឬក្រុមពិសេស (ឧទាហរណ៍ ការទាត់បាល់លើទីលាន)។
    - គ្រាប់បាល់ស៊ុតពីក្នុងទីលាន៖ ការភ្នាល់នេះឈ្នះទាំងការស៊ុតចូលទីជោគជ័យ និងមិនជោគជ័យ (រួមទាំងការរារាំង ការខកខាន ឬការលោតចេញពីរបារ) លើកលែងតែពេលដែលក្រុមការពារ

បញ្ជូនបាល់ត្រឡប់មកវិញសម្រាប់ការដាក់បាល់ដល់ក្រោយទីគូប្រកួត។ ក្នុងករណីនោះ ភ្នាល់លើ "ការដណ្តើមបាល់ដោយខ្សែការពារ" ឈ្នះ។
    - ការដណ្តើមបាល់ដោយខ្សែការពារ។ នេះរួមបញ្ចូលទាំងការដណ្តើមយកបាល់មកវិញ ការរបូតបាល់ ការដណ្តើមបាល់ និងការបាត់បង់បាល់ទាំងអស់ដែលរកបានដោយក្រុមការពារ មិនថាដោយក្រុមការពារ ឬក្រុមពិសេសនោះទេ។
    - ការទាត់បាល់ពីលើទីលាន។ ការភ្នាល់នេះឈ្នះលុះត្រាតែការគ្រប់គ្រងបាល់ត្រូវបានឆ្លងកាត់ក្រុមម្ខាងទៀតបន្ទាប់ពីទាត់បាល់ពីលើទីលាន លើកលែងតែក្នុងករណីដូចខាងក្រោម៖
        - ប្រសិនបើក្រុមវាយលុករកបានការដាក់បាល់ដល់ក្រោយទីគូប្រកួត ក្នុងអំឡុងពេលប្រកួត នោះការភ្នាល់ "ការដាក់បាល់ដល់ក្រោយទីគូប្រកួត" នឹងឈ្នះ។
        - ប្រសិនបើក្រុមការពាររកបានពិន្ទុការដាក់បាល់ដល់ក្រោយទីគូប្រកួតក្នុងអំឡុងពេលប្រកួត នោះការ ភ្នាល់ "ការដាក់បាល់ដល់ក្រោយទីគូប្រកួត" ឈ្នះ។
    - ផ្សេងៗទៀត៖ ការភ្នាល់នេះឈ្នះជាលទ្ធផលនៃលទ្ធផលដែលបានបញ្ចប់ផ្សេងទៀតដែលមិនស្ថិតនៅក្រោមប្រភេទខាងលើ។
10. "បណ្តើរបាល់បានដប់យ៉ាត (X) - មែន/មិនមែន"
    - មែន៖ ការភ្នាល់នេះឈ្នះប្រសិនបើក្រុមសម្រេចបានការបណ្តើរបាល់បានដប់យ៉ាតម្តង រួមទាំងការបណ្តើរបាល់បានដប់យ៉ាតដោយស្វ័យប្រវត្តិដែលផ្តល់ដោយការពិន័យ។
    - មិនមែន៖ ការភ្នាល់នេះឈ្នះប្រសិនបើមិនមានបណ្តើរបាល់បានដប់យ៉ាតក្នុងអំឡុងពេលដាក់បាល់ដល់ក្រោយទីគូប្រកួត។
    - ប្រសិនបើការដាក់បាល់ដល់ក្រោយទីគូប្រកួតមិនត្រូវបានបញ្ចប់ដោយសារតែចុងបញ្ចប់នៃតង់ ឬការប្រកួត ហើយលទ្ធផលនៃការភ្នាល់មិនត្រូវបានកំណត់ នោះការភ្នាល់លើទីផ្សារនេះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1.00។

10.3. វាយសី ប៉ែងប៉ុង បាល់ទះលើឆ្នេរខ្សាច់

1. ប្រសិនបើការចាប់ផ្តើមការប្រកួតត្រូវបានពន្យាពេលឬលើកពេល ដោយហេតុផលណាមួយ ការភ្នាល់ទាំងអស់ នឹងមានសុពលភាពបន្តរហូតដល់ការប្រកួតឬធ្នូណាមិន ដែលលក្ខណៈពិសេសនៃការប្រកួតត្រូវបានបញ្ចប់ ឬរហូតដល់ការដកអ្នកចូលរួមណាម្នាក់ចេញ។
2. ប្រសិនបើការប្រកួតមួយត្រូវបានអាក់ខាន ដោយសារការដកចេញឬការដកសិទ្ធិរបស់ក្រុមណាមួយ នៅក្នុងការប្រកួត/សេតដំបូង រាល់ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេងទី 1 លើកលែងតែទីផ្សារណា ដែលត្រូវបានកំណត់ដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។ ការភ្នាល់លើអ្នកឈ្នះការប្រកួត នឹងត្រូវបានទូទាត់តាមហាងឆេង 1 ក្នុងករណីនេះ។
3. ប្រសិនបើការប្រកួតមួយត្រូវបានអាក់ខាន ដោយសារតែការដកចេញ ឬដកសិទ្ធិរបស់ក្រុមណាមួយ ការប្រកួត/សេតដំបូងដាច់ខាតត្រូវតែបានបញ្ចប់ ដើម្បីឱ្យការភ្នាល់លើអ្នកឈ្នះនៃការប្រកួតមានសុពលភាព

បើមិនដូច្នេះទេ រាល់ការភ្នាល់លើលទ្ធផលនេះនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ក្នុងករណីមានការដកខ្លួនឬការដកសិទ្ធិកីឡាករ នោះការដកហូតនឹងត្រូវបានប្រកាស។

4. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនត្រូវបានបញ្ចប់ ដោយហេតុផលណាមួយ (ឧទាហរណ៍ ប្រសិនបើគូប្រជែងម្នាក់ បដិសេធមិនបន្ត ឬត្រូវបានដកសិទ្ធិ) និង ច្រើនជាង ពីរហ្គេម/សេត ត្រូវបានលេង លទ្ធផលដែលត្រូវបានកំណត់ ដោយគ្មានលក្ខខណ្ឌរួចហើយ នៅពេលនោះការប្រកួតត្រូវបានអាក់ខាន (ឧទាហរណ៍ លទ្ធផលនៃហ្គេមដំបូង/សេតដំបូង ចំនួនសរុបនៃហ្គេមដំបូង/សេតដំបូង ។ល។) នឹងត្រូវរាប់បញ្ចូលក្នុងការទូទាត់ការភ្នាល់។ ការសងប្រាក់លើការភ្នាល់ផ្សេងទៀត នឹងត្រូវធ្វើឡើងតាមហាងឆេង 1 លើកលែងតែការភ្នាល់លើអ្នកឈ្នះនៃការប្រកួត។ ក្រុមដែលឈានទៅវគ្គបន្ត ឬអ្នកឈ្នះធូណាមិននឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះនៃការប្រកួត។
5. មិនមានការភ្នាល់ណានឹងត្រូវបានលុបចោល ដោយសារតែការព្រីនមិនត្រឹមត្រូវនូវឈ្មោះកាត់របស់កីឡាករ/កីឡាការនីណាម្នាក់ (ឧទាហរណ៍ B. Smith ជំនួសឱ្យ A. Smith) ឡើយ។ នៅក្នុងករណីនេះ ការភ្នាល់នឹងត្រូវមានសុពលភាព។
6. "ឈ្នះការប្រកួត"។ ប្រសិនបើកីឡាករណាមួយ ដែលមានឈ្មោះនៅក្នុងលទ្ធផល ត្រូវបានជំនួសមុនពេលចាប់ផ្តើមការប្រកួត នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោឃៈ។
7. គ្រាប់តនិងតូតាល់សម្រាប់កីឡាដែលបានរៀបរាប់ខាងលើ ត្រូវតែបញ្ជាក់នៅក្នុងពិន្ទុ លើកលែងតែទីផ្សារ "គ្រាប់តដោយសេត" និង "តូតាល់សេត"។
8. "អ្នកឈ្នះ"។ កីឡាករ/កីឡាការនី (ក្រុម) ដែលទទួលបានចំណាត់ថ្នាក់លេខមួយនៅក្នុងធូណាមិន នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករ/កីឡាការនីដកខ្លួនចេញពីការប្រកួត មុនពេលចាប់ផ្តើមធូណាមិន ការភ្នាល់លើកីឡាករ/កីឡាការនីនោះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
9. "ដើម្បីជាប់ជម្រុះ"។ អតិថិជនគួរទស្សន៍ទាយថាតើកីឡាករមួយណា ក្នុងចំណោមកីឡាករទាំងពីរដែលបានចុះបញ្ជី នឹងឈានទៅមុខបន្តទៀត នៅក្នុងស៊េរីនៃធូណាមិន។ ប្រសិនបើកីឡាករទាំងពីរត្រូវបានជម្រុះចេញពីធូណាមិន អ្នកដែលបានឈានទៅមុខបន្តទៀតនៅក្នុងស៊េរីនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករទាំងពីរត្រូវបានជម្រុះចេញពីជុំដូចគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ប្រសិនបើកីឡាករ ដកខ្លួនចេញពីធូណាមិន មុនពេលចាប់ផ្តើមការប្រកួត នោះការភ្នាល់នឹងត្រូវទូទាត់តាមហាងឆេង 1 ។

10.4. បាល់បោះ

1. ក្រុមហ៊ុនភ្នាល់ទទួលយកការភ្នាល់៖
    - នៅម៉ោងធម្មតា (ម៉ោងលេងអាចមាន 48 នាទីមានបួនត្រីមាស ដែលត្រីមាសនីមួយៗមាន12នាទី ឬ 40 នាទីមានបួនត្រីមាស ដែលត្រីមាសមួយៗមាន 10 នាទី; NCAA – មានពីរតង់ ដែលតង់មួយៗមាន 20 នាទី)
    - នៅម៉ោងធម្មតា រាប់បញ្ចូលទាំងម៉ោងបន្ថែម (ដាក់ស្លាក "រួមទាំងម៉ោងបន្ថែម")។ ការភ្នាល់លើស្ថិតិ

រួមបញ្ចូលទាំងម៉ោងបន្ថែម OT លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ លក្ខខណ្ឌការភ្នាល់ផ្សេងទៀតអាចត្រូវបានបញ្ជាក់នៅក្នុងផ្នែកការភ្នាល់។

2. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើការប្រកួតនឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានអាក់ខាន។
3. ប្រសិនបើរយៈពេលនៃការប្រកួតគឺ 40 នាទី យ៉ាងហោចណាស់ត្រូវតែលេងឱ្យបាន 35 នាទី ទើបការភ្នាល់នៅមានសុពលភាព។ ប្រសិនបើរយៈពេលនៃការប្រកួតគឺ 48 នាទី យ៉ាងហោចណាស់ត្រូវតែលេងឱ្យបាន 40 នាទី ទើបការភ្នាល់នៅមានសុពលភាព។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលនៅពេលការប្រកួតត្រូវបានអាក់ខាន។
4. នៅក្នុងការប្រកួតបាល់បោះ (សម្រាប់ព្រឹត្តិការណ៍ ដែលមានស្លាក "រួមទាំង ម៉ោងបន្ថែម") ការភ្នាល់នៅលើទីផ្សារ គ្រាប់ត និងតូតាល់ នៅក្នុងត្រីមាសទីបួននិងតង់ទីពីរ ត្រូវបានទូទាត់ដោយមិនរាប់បញ្ចូលម៉ោងបន្ថែម។
5. ក្រុម NBA អាចត្រូវបានបង្ហាញ តាមលំដាប់លំដោយផ្ទាល់ (ក្រុមម្ចាស់ផ្ទះ–ក្រុមភ្ញៀវ) ក៏ដូចជាតាមលំដាប់បញ្ច្រាស។ ប្រសិនបើជាករណីចុងក្រោយ គ្មានប្រាក់ភ្នាល់ណាត្រូវបានបង្វិលសងវិញទេ។
6. "ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន"។ ប្រសិនបើក្រុមមិនជាប់ជម្រុះចូលរួមពីគ្រុបរបស់ពួកគេនោះទេ ការភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើចំណាត់ថ្នាក់ដែលពួកគេបានបញ្ចប់នៅក្នុងគ្រុប។ ប្រសិនបើក្រុមមានចំណាត់ថ្នាក់ស្មើគ្នានៅក្នុងគ្រុប នោះការភ្នាល់នឹងត្រូវបានទូទាត់ដោយផ្អែកលើពិន្ទុរបស់ពួកគេ។
7. អតិថិជនគួរតែពិនិត្យមើលច្បាប់នៃការប្រកួតមិត្តភាពកីឡាបាល់បោះ (មិនថាជាការប្រកួតពានរង្វាន់ឬមិត្តភាពរវាងក្លឹប) តាមរយៈប្រភពផ្លូវការ។ ប្រសិនបើការប្រកួតមិត្តភាព បញ្ចប់ក្នុងលទ្ធផលស្មើគ្នា (ច្បាប់នៃការប្រកួតត្រូវបានផ្លាស់ប្តូរ) ការភ្នាល់លើអ្នកឈ្នះនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
ទោះជាយ៉ាងណាការភ្នាល់លើទីផ្សារ តូតាល់និងគ្រាប់ត នឹងត្រូវបានទូទាត់ទៅតាមលទ្ធផល។
8. ប្រសិនបើការថែមម៉ោងត្រូវបានលេងនៅក្នុងការប្រកួតពានរង្វាន់ ដោយសារលទ្ធផលសរុបនៃការប្រកួតមានពីរជើង នោះការថែមម៉ោងនឹងត្រូវបានយកទៅគិត ដើម្បីទូទាត់ការភ្នាល់នៅលើការប្រកួតទីពីរ។
ដូចគ្នានេះដែរ ការលេងថែមម៉ោង ដែលត្រូវបានលេងដោយសារលទ្ធផលសរុបនៃការប្រកួតមានជើងពីរក៏ត្រូវបានរាប់បញ្ចូលក្នុងការភ្នាល់ "ដើម្បីជាប់ជម្រុះ" "ត្រូវបានជាប់/ធ្លាក់" "អ្នកឈ្នះធូណាមិន" និងការភ្នាល់ស្រដៀងគ្នាផ្សេងទៀត។
9. ប្រសិនបើការប្រកួតបាល់បោះបញ្ចប់ក្នុងលទ្ធផលស្មើ ការភ្នាល់ "តើនឹងមានការបន្ថែមម៉ោងដែរឬទេ? – បាទ/ចាស" នឹងឈ្នះ ហើយការភ្នាល់ "តើនឹងមានការបន្ថែមម៉ោងដែរឬទេ? – ទេ" នឹងចាញ់។
10. ការភ្នាល់ "ពាក់កណ្តាលតង់/ពេញតង់"។ នៅក្នុងផ្នែក កីឡា អក្សរ “W” តំណាងឱ្យការឈ្នះ ហើយអក្សរ “X” តំណាងឱ្យការស្មើគ្នា។ លទ្ធផលនៃតង់ទីមួយត្រូវបានបង្ហាញមុនគេ ហើយត្រូវបង្ហាញបន្តទៀតបន្ទាប់ពីលទ្ធផលនៃហ្គេមបន្ទាប់ពីម៉ោងធម្មតា។ ឧទាហរណ៍ W1W2 មានន័យថាក្រុម 1 បានឈ្នះ (W1) តង់ទីមួយ រីឯក្រុម 2 ជាអ្នកឈ្នះ (W2) នៅចុងបញ្ចប់នៃម៉ោងធម្មតា។
ការភ្នាល់ "ពាក់កណ្តាលតង់/ពេញមតង់" រួមទាំងម៉ោងបន្ថែម។ អតិថិជនត្រូវទស្សន៍ទាយថាតើក្រុមមួយ

ណា នឹងឈ្នះក្នុងតង់ទីមួយ ហើយក្រុមណានឹងឈ្នះការប្រកួតជាមួយនឹងម៉ោងបន្ថែម។ អតិថិជនអាចមិនភ្នាល់លើលទ្ធផលស្មើ។

11. "ត្រីមាសដែលមានពិន្ទុខ្ពស់បំផុត (ទាបបំផុត) – តូតាល់"។ ប្រសិនបើមាន ត្រីមាសដែលមានពិន្ទុខ្ពស់បំផុត (ទាបបំផុត) ចំនួនពីរឬច្រើន ដែលមានចំនួនសរុបដូចគ្នា នោះគ្មានប្រាក់ភ្នាល់នឹងមិនត្រូវបានសងប្រាក់វិញទេ។ នៅក្នុងករណីនេះ ការភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើគ្រាប់សរុប (នៅពេលដែលគ្រាប់សរុបនៃត្រីមាសទីបួនគឺត្រូវបានទូទាត់ គ្មានពិន្ទុដែលស៊ុតបញ្ចូលទីបាននៅក្នុងម៉ោងបន្ថែមនឹងត្រូវបានរាប់បញ្ចូលឡើយ)។
12. "ត្រីមាសដែលមានពិន្ទុខ្ពស់បំផុត"។ ប្រសិនបើ ត្រីមាសដែលមានពិន្ទុខ្ពស់បំផុត មិនអាចកំណត់បានដោយគ្មានលក្ខខណ្ឌទេ (ឧទាហរណ៍ នៅពេលត្រីមាសពីរឬច្រើនបញ្ចប់ដោយលទ្ធផលដូចគ្នា) ការភ្នាល់នៅលើត្រីមាសបែបនេះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ការភ្នាល់នៅលើត្រីមាសផ្សេងៗនឹងចាញ់ (នៅពេលដែលគ្រាប់សរុបនៃត្រីមាសទីបួនគឺត្រូវបានទូទាត់ គ្មានពិន្ទុដែលស៊ុតបញ្ចូលទីបាននៅក្នុងម៉ោងបន្ថែមនឹងត្រូវបានរាប់បញ្ចូលឡើយ)។
13. "តង់ដែលមានពិន្ទុខ្ពស់បំផុត"។ ប្រសិនបើតង់ទាំងពីរបានបញ្ចប់ដោយលទ្ធផលដូចគ្នា ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 (នៅពេលគ្រាប់សរុបនៃតង់ទីពីរត្រូវបានទូទាត់ គ្មានពិន្ទុដែលស៊ុតបញ្ចូលទីបាននៅក្នុងម៉ោងបន្ថែមនឹងត្រូវបានរាប់បញ្ចូលឡើយ)។
14. "ក្រុម...នឹងឈ្នះទាំងពីរតង់ – បាទ/ចាស"។ នៅពេលដែលគ្រាប់សរុបនៃតង់ទីពីរត្រូវបានទូទាត់ គ្មានពិន្ទុដែលស៊ុតបញ្ចូលទីបាននៅក្នុងម៉ោងបន្ថែមនឹងត្រូវបានរាប់បញ្ចូលឡើយ។ "ក្រុម...នឹងឈ្នះទាំងពីរតង់ – ទេ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើក្រុមដែលបានបញ្ជាក់ បានស្មើរឬចាញ់ យ៉ាងហោចណាស់មួយតង់។
15. "ក្រុមនីមួយៗនឹងរកបានពិន្ទុលើសពី 72.5 – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើគ្រាប់សរុបដែលបានស៊ុតបញ្ចូលទីដោយក្រុមនីមួយៗ ក្នុងការប្រកួត មានចំនួនរហូតដល់ 73 ឬច្រើនជាងនេះ។
16. "ក្រុមនីមួយៗនឹងរកបានពិន្ទុលើសពី 72.5 – ទេ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើយ៉ាងហោចណាស់ក្រុមមួយមិនបានឈានដល់គ្រាប់សរុបដែលបានដកស្រង់។
17. "គ្រាប់សម្រាប់ត្រីមាសនីមួយៗ តូតាលអូវ័រ 32.5 – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើគ្រាប់សរុបដែលបានស៊ុតបញ្ចូលទី នៅក្នុងត្រីមាសនីមួយៗ មានចំនួន 33 ឬច្រើនជាងនេះ។
18. ការភ្នាល់ "កំហុសដំបូង" និង "កំហុសសរុប"។ ការទូទាត់សងការភ្នាល់ត្រូវបានអនុវត្តដោយផ្អែកលើតារាងពិន្ទុចុងក្រោយដែលរួមបញ្ចូលតែកំហុសផ្ទាល់ខ្លួនដោយកីឡាករប៉ុណ្ណោះ។ កំហុសបច្ចេកទេសដែលទទួលបានដោយគ្រូបង្វឹក អ្នកតំណាងក្រុមផ្លូវការ ឬកីឡាកររៀលលើកៅអីបម្រុងអាចត្រូវបានបង្ហាញនៅក្នុងការអត្ថាធិប្បាយនីមួយៗ ប៉ុន្តែមិនត្រូវបានរាប់បញ្ចូលក្នុងការទូទាត់ទេ។ ទោះជាយ៉ាងណាក៏ដោយ កំហុសបច្ចេកទេសដែលបានបញ្ជាក់នៅក្នុងតារាងពិន្ទុផ្លូវការត្រូវបានរាប់បញ្ចូល។
19. "គ្រាប់ផ្លាតដំបូង"។ ទស្សន៍ទាយថាតើក្រុមមួយណានឹងក្លាយជាក្រុមដំបូងគេដែលមានគ្រាប់ផ្លាត។
20. ការភ្នាល់នៅលើទីផ្សារ ធីនអូវ័រ" ត្រូវបានទូទាត់ដោយផ្អែកលើស្ថិតិបុគ្គលរបស់កីឡាករ ជាជាងស្ថិតិក្រុម។
21. ការភ្នាល់លើទីផ្សារ "គ្រាប់បាល់ផ្លាត" ត្រូវបានទូទាត់ចប់សព្វគ្រប់ ដោយផ្អែកលើស្ថិតិបុគ្គលរបស់កីឡាករ និងស្ថិតិក្រុម។ សម្រាប់ការប្រកួត NBA, WNBA មានតែគ្រាប់បាល់ផ្លាតផ្ទាល់ខ្លួនប៉ុណ្ណោះ ដែលត្រូវបានពិ

ចារណា។

22. ការភ្នាល់លើទីផ្សារ "ការប្រណាំងយក...ពិន្ទុ" នៅក្នុងផ្នែក "កីឡា" អាចមានជាមួយ៖
    - លទ្ធផលពីរ (W1 W2)។ សម្រាប់ការភ្នាល់បែបនេះ ប្រសិនបើគ្មានក្រុមណាមួយទទួលបានពិន្ទុដែលបានបញ្ជាក់ទេនោះ ការភ្នាល់លើអ្នកឈ្នះ នឹងត្រូវទុកជាមោយ: (ឧទាហរណ៍ ប្រសិនបើពិន្ទុគឺ 19–19 ការភ្នាល់ "ការប្រណាំងយក 20 ពិន្ទុ W1" នឹងត្រូវចាត់ទុកជាមោយ:)។
    - លទ្ធផលបី (W1, W2, គ្មានទាំងពីរ) នៅក្នុងករណីនេះ ការភ្នាល់នឹងត្រូវបានទូទាត់ដោយយោងទៅតាមលទ្ធផល។
23. ការភ្នាល់ "ពិន្ទុដោយត្រីមាស 2–0" នឹងឈ្នះ ប្រសិនបើក្រុម 1 បានឈ្នះពីរត្រីមាស ក្នុងចំណោមបួនតង់ ហើយពីរត្រីមាសទៀតដែលនៅសល់ត្រូវបានបញ្ចប់ដោយលទ្ធផលស្មើគ្នា។ ការភ្នាល់ "ពិន្ទុដោយត្រីមាស 1–1" នឹងឈ្នះ ប្រសិនបើក្រុមមួយបានឈ្នះមួយត្រីមាស ក្រុមផ្សេងទៀតបានឈ្នះមួយត្រីមាស ហើយពីរត្រីមាសទៀតដែលនៅសល់ត្រូវបានបញ្ចប់ដោយលទ្ធផលស្មើគ្នា។
24. "គ្រាប់តដោយត្រីមាស"។ ឧទាហរណ៍ "2 គ្រាប់តដោយត្រីមាស −2.5"។ ពិន្ទុចុងក្រោយគឺ 81:102 (17:22, 26:25, 18:20, 20:35) ដូច្នេះពិន្ទុត្រីមាសនីមួយៗគឺ 1:3 (0:1, 1:0, 0:1, 0:1 រៀងៗខ្លួន)។ ការភ្នាល់ចាញ់នៅពេលដែលគ្រាប់តដល់ក្រុមទី 2 ត្រូវបានអនុវត្ត ពិន្ទុតាមត្រីមាសគឺ 1:0.5 ។
25. "ទីផ្សារ "ត្រីមាសដែលគ្រាប់សរុបស្មើគ្នា" "គ្រាប់តដោយត្រីមាស", "ពិន្ទុ ដោយត្រីមាស" និង "ឈ្នះដោយត្រីមាស" គឺត្រូវបានទូទាត់ ដោយផ្អែកទៅលើលទ្ធផលនៅម៉ោងធម្មតា។
26. ការភ្នាល់លើ "ការឈ្នះខុសគ្នា 1 ក្នុងពិន្ទុចន្លោះពិន្ទុពី −1 ដល់ 9" នឹងឈ្នះ ប្រសិនបើភាពខុសគ្នានៃចំនួនពិន្ទុដែលរកបានដោយក្រុមលេខ 1 និងក្រុមលេខ 2 ស្ថិតនៅចន្លោះពេលពី −1 ដល់ 9 ពិន្ទុ។ ឧទាហរណ៍ ពិន្ទុគឺ (85:90) ដូច្នេះការឈ្នះខុសគ្នារបស់ក្រុម 1 គឺ −5 ហើយនោះការភ្នាល់នឹងត្រូវចាញ់។
27. ការភ្នាល់លើ "ភាគរយនៃការរកបានពិន្ទុដោយការស៊ុតលើទីលានពីចំណុចទី-2" "ភាគរយនៃការរកបានពិន្ទុដោយការស៊ុតលើទីលានពីចំណុចទី-3" និង "ភាគរយនៃការបោះបញ្ចូលទីដោយសេរី" ត្រូវបានទូទាត់ដោយផ្អែកលើស្ថិតិពីវេបសាយជាផ្លូវការ ដែលតម្លៃភាគរយត្រូវបានបង្គត់ទៅលេខទាំងមូលដែលនៅជិតបំផុត។
28. ការភ្នាល់លើទីផ្សារ "ពេលវេលាលេងសរុប" គួរតែត្រូវបានកំណត់ជានាទី។ ប្រសិនបើគ្រាប់សរុបត្រូវបានគេដាក់ឈ្មោះពិតប្រាកដ នោះការភ្នាល់នឹងត្រូវបានទូទាត់ទៅតាមហាងឆេង 1។ ឧទាហរណ៍ ទាក់ទងទៅនឹងការភ្នាល់ "សរុបរបស់ Kyrie Irving អូវ័រ 39.5" ប្រសិនបើពេលវេលាលេងសរុបរបស់កីឡាករមានចំនួន 39 នាទី 30 វិនាទី នោះការភ្នាល់នឹងត្រូវបានទូទាត់ទៅតាមហាងឆេង 1 ។
29. ណេតបល គឺជាប្រភេទបាល់បោះនារី (មានបួនតង់ដែលមួយតង់ៗមាន 15 នាទី)។ ការភ្នាល់ គឺត្រូវបានធ្វើឡើងនិងទូទាត់នៅម៉ោងធម្មតា រាប់បញ្ចូលទាំងម៉ោងបន្ថែម (ដាក់ស្លាក "រួមទាំង ម៉ោងបន្ថែម")។
30. **បាល់បោះ។ លទ្ធផល។ ក្រុមនឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន។** ការភ្នាល់នៅលើទីផ្សារនេះ ត្រូវបានទូទាត់ដោយផ្អែកលើស្ថិតិដែលមាននៅលើគេហទំព័រផ្លូវការ។
31. "ស៊ុបពើតូតាល់ () អូវ័រ/អាន់ឌ័រ"។ អតិថិជនគួរទស្សន៍ទាយថាតើក្រុមនឹងទទួលបានពិន្ទុតិចឬច្រើនជាងគ្រាប់សរុបដែលបានដកស្រង់។ ឧទាហរណ៍ "ស៊ុបព័រតូតាល់៖ (166–167 សងប្រាក់វិញ) 167.5 អូវ័រ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើក្រុមទាំងអស់រកពិន្ទុស៊ុតបញ្ចូលទីសរុបបានច្រើនជាង 167.5 ពិន្ទុ។

ប្រសិនបើក្រុមរកពិន្ទុស៊ុតបញ្ចូលទីសរុបបាន 166 ឬ 167 សរុប នោះប្រាក់ភ្នាល់នឹងត្រូវបានសងមកវិញ។

32. "ស៊ុបព័រគ្រាប់ត 1/2 ()"។ អតិថិជនគួរទស្សន៍ទាយថាក្រុមនឹងឈ្នះឬទេ ដោយគិតគូរពិចារណាលើគ្រាប់ត ដែលបានដកស្រង់។ ឧទាហរណ៍ "ស៊ុបព័រគ្រាប់ត 2: (-4; -3 សងប្រាក់វិញ) -4,5"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើពិន្ទុខុសគ្នារហូតដល់ 5 ពិន្ទុ ឬច្រើនជាងនេះ ដោយក្រុម 2 ជាក្រុមនាំមុខ។ ប្រសិនបើជាការស្មើគ្នា បន្ទាប់ពីតម្លៃគ្រាប់ត (-4) ឬ (-3) ត្រូវបានអនុវត្ត នោះប្រាក់ភ្នាល់នឹងត្រូវបានសងមកវិញ។
33. ការភ្នាល់លើស្ថិតិកីឡាករជាមធ្យមក្នុងរដូវកាល NBA ធម្មតា (ពិន្ទុ គ្រាប់បាល់ផ្លាត ជំនួយ ការស៊ុតបញ្ចូលទីត្រូវបានប្តូក ។ល។) ត្រូវបានទូទាត់ដោយផ្អែកលើស្ថិតិដែលមាននៅលើគេហទំព័រផ្លូវការនៃធូណាមិន។
34. ទ្វេដង-ទ្វេដង (បីដង-ទ្វេដង) ក្នុងការប្រកួត។ សម្រាប់ការភ្នាល់នេះ វាចាំបាច់ត្រូវទាយថាតើអ្នកលេងនឹងមានឬមិនមានគុណផលពីរខ្ទង់ នៅក្នុងប្រភេទពីរ (ទ្វេដង-ទ្វេដង), ប្រភេទបី (បីដង-ទ្វេដង) នៅក្នុងការប្រកួត។ ប្រភេទស្ថិតិ៖ ពិន្ទុ គ្រាប់បាល់ផ្លាត ជំនួយ ការស៊ុតបញ្ចូលទីត្រូវបានប្តូក។ ប្រសិនបើកីឡាករមានការភ្នាល់បីដង-ទ្វេដងមួយ នោះការភ្នាល់ ទ្វេដង-ទ្វេដង លើកីឡាករនេះនឹងត្រូវបានទូទាត់ជាការឈ្នះ។
35. ពិន្ទុក្នុងចន្លោះពេល។ សម្រាប់ទីផ្សារនេះ គឺត្រូវបានគេណែនាំឱ្យទាយថាតើពិន្ទុត្រីមាសនឹងស្ថិតក្នុងចន្លោះពេល ដែលបានជ្រើសរើសដែរឬទេ។ នៅផ្នែកខាងឆ្វេង ជួរសម្រាប់ពិន្ទុក្រុមដំបូងត្រូវបានចង្អុលបង្ហាញនៅផ្នែកខាងស្តាំ - ជួរសម្រាប់ពិន្ទុក្រុមទីពីរ។ ឧទាហរណ៍។ "ពិន្ទុក្នុងចន្លោះពេលនៃត្រីមាសទី 3 ។ 22-33៖ 8-19 - បាទ/ចាស។" ការភ្នាល់នឹងឈ្នះ ប្រសិនបើត្រីមាសទី 3 បញ្ចប់ដោយពិន្ទុ 24-15 ។
36. បាល់បោះ 4x4 ។ ហ្គេមមានពីរតង់ ដែលតង់នីមួយៗមានរយៈពេល 10 នាទី។ ប្រសិនបើហ្គេមបញ្ចប់ដោយស្មើគ្នា នោះការថែមម៉ោង 5 នាទី នឹងត្រូវបានលេង។
    ភាពខុសគ្នាសំខាន់ៗ នៅក្នុងហ្គេម៖
    - គ្រាប់ស្តង់ដារមួយមានតម្លៃ 2 ពិន្ទុ។
    - គ្រាប់ស៊ុតពីទីលានមួយ (ចាប់ពីខ្សែរ 3 ពិន្ទុ) ទទួលបាន 3 ពិន្ទុ។
    - ការហាក់បង្ក្រាបាល់ចូលកន្ត្រកទីទទួលបាន 3 ពិន្ទុ។
    - ក្រុមមានពេល 24 វិនាទី ដើម្បីស៊ុត ក្នុងអំឡុងពេលវាយលុក។
37. Basketball 1x1 ហ្គេមលេងរហូតដល់ពិន្ទុឈ្នះមានដល់ 11 ពិន្ទុ ឬ 10 នាទីបានកន្លងផុតទៅ (អាស្រ័យលើមួយណាដល់មុន)។ ប្រសិនបើការប្រកួតមួយបញ្ចប់ដោយលទ្ធផលស្មើគ្នា នោះនឹងមានការលេងក្នុងម៉ោងបន្ថែម ដែលមានរយៈពេលប្រាំនាទី។ ការប្រកួតវគ្គផ្តាច់ព្រ័ត្រ នឹងត្រូវលេងដោយកីឡាករកំពូលទាំងបីបន្ថែម 11 ពិន្ទុដើម្បីឈ្នះ។ ភាពខុសគ្នាសំខាន់ៗនៅក្នុងហ្គេម៖
    - ស៊ុតបាល់ចំពីពាក់កណ្តាលតារាងរាប់ជា 2 ពិន្ទុ។
    - ស៊ុតបាល់ចំពីចម្ងាយឆ្ងាយ (ពីខាងក្រៅបន្ទាត់បីបន្ទាត់) រាប់ជា 3 ពិន្ទុ។
    - ប្រសិនកីឡាករក្រុមណាស៊ុតបាល់ កីឡាកររនោះត្រូវមានសិទ្ធិដើម្បី "រកពិន្ទុ និងយកបាល់វិញ"
    - បាល់ត្រូវតែស៊ុតក្នុងរយៈពេល 7 វិនាទីបន្ទាប់ពីបានបាល់នៅក្នុងដៃ

10.5. កីឡាបាល់បោះ 3x3

1. ការប្រកួតមានមួយតង់ ដែលមានរយៈពេល 10 នាទី។ ការប្រកួតត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលដែលពេលវេលាបានបញ្ចប់ ឬក្រុមណាមួយរកបាន 21 ពិន្ទុ។ ប្រសិនបើការប្រកួតមួយបញ្ចប់ដោយលទ្ធផលស្មើគ្នា នោះនឹងត្រូវលេងក្នុងម៉ោងបន្ថែម រហូតដល់ក្រុមមួយរកបាន 2 ពិន្ទុ។
2. ភាពខុសគ្នាសំខាន់ៗនៅក្នុងការប្រកួត៖
    - ការស៊ុតបាល់ពីពាក់កណ្តាលតារាងរាប់ 1 ពិន្ទុ
    - ការស៊ុតបាល់ពីចម្ងាយ (ពីខាងក្រៅបន្ទាត់បី‌ពិន្ទុ) រាប់ 2 ពិន្ទុ
    - ពេលវេលាស៊ុតបាល់ មានរយៈពេល 12 វិនាទី។
3. ច្បាប់ទូទៅរបស់កីឡាបាល់បោះ ក៏អនុវត្តចំពោះកីឡាបាល់បោះ 3x3 ផងដែរ៖
    - ប្រសិនបើការប្រកួតមួយចាប់ផ្តើម ប៉ុន្តែមិនទាន់បានបញ្ចប់ នោះរាល់ការភ្នាល់ទាំងអស់លើការប្រកួតនោះ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00 លើកលែងតែទីផ្សារទាំងឡាយណាដែលបានកំណត់រួចជាស្រេច នៅពេលការប្រកួតនោះត្រូវបានបញ្ឈប់ប៉ុណ្ណោះ។
    - ការភ្នាល់លើស្ថិតិ ក៏រួមបញ្ចូលម៉ោងបន្ថែមផងដែរ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។
    - ការភ្នាល់លើទីផ្សារ ″តើនឹងមានការបន្ថែមម៉ោងដែរឬទេ? – មាន" ឈ្នះ ហើយការភ្នាល់លើទីផ្សារ "តើនឹងមានការបន្ថែមម៉ោងដែរឬទេ? – មិនមាន″ ចាញ់។
    - ការភ្នាល់លើទីផ្សារ "ភាគរយនៃការស៊ុតបាល់ពីក្នុងទីលានរកបាន 2 ពិន្ទុ″, "ភាគរយនៃការស៊ុតបាល់ពីក្នុងទីលានរកបាន 3 ពិន្ទុ″ និង "ភាគរយនៃការស៊ុតបាល់ពិន័យ" ត្រូវទូទាត់សងដោយផ្អែកលើស្ថិតិពីគេហទំព័រផ្លូវការ ហើយតម្លៃគិតជាភាគរយ ត្រូវបង្គត់ទៅជាលេខគត់។
    - ការភ្នាល់លើស្ថិតិជាមធ្យមរបស់អត្តពលិក ត្រូវទូទាត់សងផ្អែកលើស្ថិតិពីគេហទំព័រផ្លូវការនៃធូណាមិននេះ។
    - ការភ្នាល់លើ "កំហុសដំបូង" និង "កំហុសសរុប"។ នៅពេលទូទាត់សងការភ្នាល់ មានតែកំហុសផ្ទាល់ខ្លួនដែលកីឡាករបានប្រព្រឹត្តនៅលើទីលានប៉ុណ្ណោះ ដែលត្រូវរាប់បញ្ចូល។
    - កំហុសបច្ចេកទេសប្រព្រឹត្តដោយគ្រូបង្វឹក មន្ត្រីរបស់ក្រុម ឬកីឡាករបម្រុង នឹងមិនត្រូវរាប់បញ្ចូលនោះទេ។

10.6. បេស្បល សហ្វបល

1. ការភ្នាល់លើការប្រកួតកីឡាបេស្បលត្រូវបានទទួលយក រួមបញ្ចូលទាំងអ៊ីននីងបន្ថែម។ ឈ្មោះរបស់កីឡាករគប់ក្លូនបាល់នឹងត្រូវយកមកពិចារណា នៅពេលទទួលយកការភ្នាល់ ប្រសិនបើឈ្មោះត្រូវបានបញ្ជាក់ទាក់ទងទៅនឹងព្រឹត្តិការណ៍។ កីឡាករគប់ក្លូនបាល់ចុះបញ្ជីទាំងពីរត្រូវតែចាប់ផ្តើម ហើយការគប់នីមួយៗយ៉ាងហោចណាស់មានមួយដង ដើម្បីឱ្យការភ្នាល់មានសុពលភាព។ ប្រសិនបើរាល់កីឡាករគប់ក្លូនបាល់ដែលបានចុះបញ្ជីណាម្នាក់ខកខានក្នុងការចាប់ផ្តើមដោយមូលហេតុណាមួយ ការភ្នាល់ទាំងអស់នៅលើហ្គេមនឹងត្រូវបានចាត់ទុកជាមោយ:។ ប្រសិនបើកីឡាករគប់ក្លូនបាល់ដែលត្រូវចាប់ផ្តើមមិនបានចុះបញ្ជី នោះការភ្នាល់នឹងត្រូវបានទទួលយក ដោយមិន

គិតថាកីឡាករគប់កូនបាល់ដែលត្រូវចាប់ផ្តើមជានរណានោះទេ។

2. ការភ្នាល់នឹងមានសុពលភាព ប្រសិនបើចំនួនអ៊ីននីងដែលគ្រោងត្រូវបានបន្តយ ស្របតាមបទបញ្ញត្តិនៃធូណាមិន ឬការប្រកួតមួយត្រូវបានកាត់បន្តយរយៈពេលខ្លី ដោយសារតែក្រុមមួយក្នុងចំណោមក្រុមដៃដែលមិនអាចវាយលុកកំពុងមានការនាំមុខ។
3. "ក្នុងដី – ក្រៅដី"។ ក្នុងអំឡុងថ្ងៃប្រកួត ប្រសិនបើមានការប្រកួតយ៉ាងតិចមួយត្រូវបានលុបចោល ពន្យារពេល មិនបានបញ្ចប់ និងចាត់ទុកថាមិនបានប្រកួត (បានលេងតិចជាង 5 ជុំពេញ) នោះការភ្នាល់លើទីផ្សារនេះ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00។
4. ក្រុមដែលវាយនៅខាងក្រោមនៃអ៊ីននីងមួយ ត្រូវបានចាត់ទុកជាក្រុមម្ចាស់ផ្ទះ ទោះបីជាការប្រកួតនៅទីតាំងណាក៏ដោយ។
5. ការភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមលទ្ធផលផ្លូវការនៃការប្រកួត រួមទាំងអ៊ីននីងបន្ថែមទាំងអស់ (លើកលែងតែការភ្នាល់ដែលបានធ្វើឡើងលើផ្នែកខ្លះនៃការប្រកួត)។
6. រាល់ការភ្នាល់ត្រូវមានសុពលភាព ប្រសិនបើយ៉ាងហោចណាស់ពេញទាំងប្រាំ ឬ 4.5 ទឹកត្រូវបានលប្រកួត។ ប្រសិនបើប្រកួតបានតិចជាង 4.5 ទឹក ក្រុមហ៊ុនភ្នាល់នឹងទូទាត់ការភ្នាល់ លទ្ធផលដែលត្រូវបានកំណត់រួចហើយនៅពេលដែលការប្រកួតត្រូវបានបញ្ឈប់។ ការភ្នាល់ផ្សេងទៀតលើការប្រកួតនេះនឹងត្រូវទូទាត់តាមហាងឆេង 1។
7. **ទីផ្សារមុនការប្រកួត** ។ ប្រសិនបើការប្រកួតបេស្បលមិនបានចាប់ផ្តើមតាមពេលវេលាដែលបានកំណត់ ហើយវេបសាយផ្លូវការបានបញ្ជាក់ថាការប្រកួតត្រូវបានពន្យារពេល នោះរាល់ការភ្នាល់ទាំងអស់លើការប្រកួតនេះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
8. **ទីផ្សារកំពុងលេង** ។ ប្រសិនបើការប្រកួតត្រូវបានបញ្ឈប់ (អាក់ខាន) ហើយដំណើរការក្នុងរយៈពេល 72 ម៉ោង រាល់ការភ្នាល់ទាំងអស់នឹងមានសុពលភាពរហូតដល់ចប់ការប្រកួត។ ប្រសិនបើការប្រកួតមិនត្រូវបានបញ្ចប់ក្នុងរយៈពេល 72 ម៉ោងទេ នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ។
9. ប្រសិនបើពិន្ទុត្រូវបានស្មើគ្នា នៅក្នុងការប្រកួតបេស្បល (នៅក្នុង NPB ឬនៅក្នុងប្រកួតមុនរដូវកាលនៃ MLB និង KBO) ការភ្នាល់ W1 និង W2 នឹងត្រូវបានទូទាត់តាមហាងឆេង 1 (ប្រាក់ភ្នាល់នឹងត្រូវបានបង្វិលសងវិញ)។
10. "កីឡាករ ការប្រកួត"។ អតិថិជនត្រូវតែទស្សទាយថាតើ ម្នាក់ណាក្នុងចំណោមកីឡាករទាំងពីរនាក់ដែលនឹងលេងបានល្អជាង។ ប្រសិនបើកីឡាកប្រកួតស្មើគ្នា ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
11. នៅក្នុងហ្គេម MLB មុនរដូវកាល នៅពេលដែលក្រុមប្រកួតស្មើគ្នានៅចុងបញ្ចប់នៃអ៊ីននីងទី 9 នោះអ៊ីននីងបន្ថែមទី 10 នឹងត្រូវបានលេង។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើគ្មានក្រុមណាមួយឈ្នះនៅក្នុងអ៊ីននីងទី 10 នោះហ្គេមនឹងបញ្ចប់ដោយលទ្ធផលស្មើគ្នា។ ក្នុងករណីនេះការភ្នាល់ W1 និង W2 ត្រូវបានទូទាត់តាមហាងឆេង 1 (ប្រាក់ភ្នាល់ត្រូវបានបង្វិលសងវិញ)។
12. ប្រសិនបើយ៉ាងហោចណាស់ មានការប្រកួតមួយត្រូវបានលុបចោល ពន្យារពេល អាក់ខាន និងបោះបង់ចោលនៅថ្ងៃប្រកួត (តិចជាងប្រាំអ៊ីននីងពេញត្រូវបានលេង) ការភ្នាល់លើព្រឹត្តិការណ៍ "ក្រុមម្ចាស់ផ្ទះ–ក្រុមភ្ញៀវ" នឹងត្រូវទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលត្រូវបានកំណត់រួចហើយ។

13. សហ្វបល គឺជាល្បែងបាល់លេងជាក្រុម និងប្រភេទបេស្បលមួយដែលលេងជាមួយបាល់ធំជាង នៅលើទីលានតូចជាង។ ក្រុមលេងប្រាំពីរអ៊ីននីង ក្នុងការប្រកួតផ្លូវការ។ ប្រសិនបើពិន្ទុត្រូវបានស្មើគ្នា នោះអ៊ីននីងបន្ថែមនឹងត្រូវបានផ្តល់ជូន។

10.7. បាយអាត្លន់

1. "នឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ"។ ទស្សន៍ទាយថាតើមួយណាក្នុងចំណោមកីឡាករបាយអាត្លន់ទាំងពីរ (ឬក្រុម ក្នុងការបញ្ជូនត) នឹងបញ្ចប់ខ្ពស់ជាងនៅក្នុងចំណាត់ថ្នាក់ចុងក្រោយ។ ប្រសិនបើគូប្រជែងទាំងពីរធ្លាក់ចេញពីការប្រកួត ឬប្រសិនបើគូប្រជែងម្នាក់បរាជ័យក្នុងការចាប់ផ្តើម ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ប្រសិនបើអ្នកប្រកួតណាមួយខកខានមិនបានឆ្លងផុតទីបញ្ចប់ នោះការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាចាញ់។
2. "ការបរាជ័យ"។ ប្រៀបធៀបគ្រាប់សរុបដែលខុសគោលដៅដោយអ្នកចូលរួម។ ទស្សន៍ទាយថាតើកីឡារករបាយអាត្លន់មួយណាដែលនឹងខុសគោលដៅច្រើនជាងគេបំផុត។ ប្រសិនបើចំនួននៃការបរាជ័យស្មើនឹងតម្លៃគ្រាប់ត នោះហាងឆេងដែលឈ្នះនឹងមានចំនួន 1 ។ ប្រសិនបើគូប្រជែងធ្លាក់ចេញពីការប្រកួត ដោយមិនបានបាញ់គ្រប់ជុំទេ នោះហាងឆេងដែលឈ្នះនឹងមានចំនួន 1 ។
3. "ការបរាជ័យក្នុងការបញ្ជូនបន្ត"។ ចំនួននៃការបរាជ័យក្នុងការបញ្ជូនបន្តត្រូវបានគណនាដោយបូកបន្ថែមចំនួនរង្វិលជុំប៉ៃណាល់ទី និងគ្រាប់បន្ថែមសម្រាប់សមាជិកក្រុមទាំងអស់។
4. "កីឡាករកំពូលៗនៃប្រទេសណា នឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ"។ ព្យាករណ៍ថាតើកីឡាករបាយអាត្លន់រត់ប្រណាំងកំពូលៗមកពីប្រទេសទាំងពីរដែលបានចុះបញ្ជី នឹងទទួលបានចំណាត់ថ្នាក់ខ្ពស់ជាង ក្នុងចំណាត់ថ្នាក់ចុងក្រោយនៃការប្រណាំងដែរឬទេ។
5. "អ្នកឈ្នះនៃការប្រណាំង"។ អ្នកប្រកួតប្រជែង ដែលនាំមុខចំណាត់ថ្នាក់ចុងក្រោយ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះនៃការប្រណាំង។ ប្រសិនបើអ្នកប្រកួតប្រជែងពីរឬច្រើននាក់ត្រូវបានប្រកាសជាអ្នកឈ្នះ ច្បាប់ "ការបញ្ចប់ដំណាលគ្នា" នឹងត្រូវបានយកមកអនុវត្ត។
6. "អ្នកនាំមុខ បន្ទាប់ពីជុំទី 1 (ទី 2។ល។)"។ អ្នកឈ្នះជុំ ត្រូវបានកំណត់លើចំណាត់ថ្នាក់ចុងក្រោយ។ ប្រសិនបើមានអ្នកឈ្នះពីរឬច្រើននាក់ក្នុងមួយជុំ នោះច្បាប់ "ការបញ្ចប់ដំណាលគ្នា" នឹងត្រូវបានយកមកអនុវត្ត។
7. "បាយអាត្លន់។ អ្នកឈ្នះ។ បុរស។ ដេញតាម។ 12.5 គីឡូម៉ែត្រ។ ហុកហ្វៃលស្សិន។ កំពូលទី 1–10 (08.12.2013 | 16:30) – " តើ Daniel Mesotitsch នឹងឈ្នះដែរឬទេ – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើ Daniel Mesotitsch ជាប់ចំណាត់ថ្នាក់ក្នុងចំណោមកីឡាករបាយអាត្លន់កំពូលទាំង 10 នៅក្នុងការប្រណាំង ។
8. "គ្រាប់បន្ថែម។ ប្រទេសស៊ុយអែត (13.12.2013 | 17:25) តូតាល់អាន់ឌ័រ 7.5"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើកីឡាកររបស់ប្រទេសស៊ុយអែតប្រើគ្រាប់បន្ថែមចំនួន 7 ឬតិចជាងនេះ។
9. "ការឈ្នះខុសគ្នារបស់កីឡាករ លើសពីចំណាត់ថ្នាក់ទីពីរ 0–20 វិនាទី – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ

ប្រសិនបើអ្នកឈ្នះយកឈ្នះអ្នករត់ប្រណាំងត្រឹមតែ 20 វិនាទី ឬតិចជាងនេះ។

10. "ការបរាជ័យ។ ឈរ ច្រើនជាង ក្រាប – បាទ/ទេ"។ ប្រសិនបើចំនួនគោលដៅការបរាជ័យគោលដៅ ពេលកំពុងក្រាប ស្មើនឹងពេលកំពុងឈរ (ឬបើមិនមានការបរាជ័យ) នោះការភ្នាល់ "ការបរាជ័យ។ ឈរច្រើនជាងក្រាប – ទេ" នឹងឈ្នះ ហើយការភ្នាល់ "ការបរាជ័យ។ ឈរច្រើនជាងក្រាប – បាទ/ចាស" នឹងត្រូវចាញ់។
11. "ពេលវេលាបាញ់"។ ទស្សន៍ទាយថាតើពេលវេលានឹងមានចំនួនប៉ុន្មាន (គិតជាវិនាទី)។
12. "ពេលវេលានៅទីលានបាញ់"។ ទស្សន៍ទាយថាតើកីឡាករបាយអាតួន់នឹងចំណាយពេលប៉ុន្មាននៅទីលានបាញ់ (គិតជាវិនាទី)។ ពេលវេលានៅទីលាន រួមមានការចូលនិងចេញពីតំបន់បាញ់ ក៏ដូចជាការបាញ់ខ្លួនឯងដែរ។
13. **"ទីផ្សារពាន IBU"**។ ចំណាត់ថ្នាក់ជារួម នឹងត្រូវបានកំណត់ដោយផ្អែកលើលទ្ធផលនៅពេញមួយរដូវកាល ។

10.8. ប្រដាល់ សិល្បៈក្បាច់គុន

1. ការចាប់ផ្តើមនៃការប្រកួតត្រូវបានបន្លឺឡើង ដោយសម្លេងជួងមុនពេលទឹកទីមួយ។
2. ប្រសិនបើការប្រកួតមួយត្រូវបានប្រកាសថាគ្មានការប្រកួត ឬប្រសិនបើការប្រកួតត្រូវបានបញ្ឈប់ដោយហេតុផលណាមួយ មុនពេលដែលអ្នកឈ្នះត្រូវបានកំណត់ នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោឃៈ។ ប្រសិនបើលទ្ធផលនៃការប្រកួតត្រូវបានកំណត់រួចហើយ នោះការភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលដែលបានប្រកាស។
3. ប្រសិនបើចំនួនទឹកត្រូវបានផ្លាស់ប្តូរ នោះការភ្នាល់លើលទ្ធផលនៃការប្រកួតនឹងមានសុពលភាព ប៉ុន្តែការភ្នាល់លើចំនួនទឹកនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
4. "ចំនួនទឹកសរុប"។ អតិថិជនគួរតែទស្សន៍ទាយចំនួនទឹកនៅក្នុងការប្រកួត។ មានតែការប្រកួតដែលបានបញ្ចប់ប៉ុណ្ណោះ ដែលត្រូវបានយកមកពិចារណា សម្រាប់គោលបំណងទូទាត់ប្រាក់ភ្នាល់។
5. គ្រាប់តសម្រេចចិត្តតាមពិន្ទុ (រួមទាំងការឈ្នះក្នុងចម្ងាយ)។ គ្រាប់តត្រូវបានគណនាដោយផ្អែកលើពិន្ទុចុងក្រោយនៃការប្រកួតពេញលេញ ដូចដែលបានផ្តល់ឱ្យនៅក្នុងប្រភពប្រកួតផ្លូវការ។ ប្រសិនបើការប្រកួតបញ្ចប់មុនពេល នោះការភ្នាល់លើអ្នកប្រយុទ្ធដែលឈ្នះក្នុងចម្ងាយនឹងត្រូវបានទូទាត់ថាជាការភ្នាល់ឈ្នះ ហើយការភ្នាល់លើគូប្រកួតរបស់អ្នកប្រយុទ្ធនោះនឹងត្រូវបានទូទាត់ជាការភ្នាល់ចាញ់ (ដោយមិនគិតពីតម្លៃគ្រាប់ត)។
6. ប្រសិនបើកីឡាករមិនចូលក្នុងសង្វៀន បន្ទាប់ពីលឺសម្លេងជួងនៅពេលចាប់ផ្តើមទឹកនៃការប្រកួតទេ នោះការប្រកួតត្រូវបានគេចាត់ទុកថាបានបញ្ចប់នៅទឹកមុន។
7. "1 (2) នឹងឈ្នះ"។ នៅក្នុងផ្នែក "កីឡា" ការភ្នាល់នៅលើទីផ្សារនេះ ត្រូវបានដាក់ស្លាក "1" និង "2" រៀងៗខ្លួន ហើយរួមមានដូចខាងក្រោមនេះ៖
    - "ឈ្នះដោយពិន្ទុ";

- "ឈ្នះដោយការផ្តួលដៃគូឱ្យសន្លប់";
- "ឈ្នះដោយការផ្តួលដៃគូឱ្យសន្លប់តាមបច្ចេកទេស";
- "ឈ្នះដោយការសម្រេចតាមបច្ចេកទេស";
- "ឈ្នះដោយការជម្រុះឬការបដិសេធ"។

8. "ស្មើគ្នា"។ ការភ្នាល់នៅលើទីផ្សារនេះត្រូវបានដាក់ស្លាក “X”។ ការប្រកួតនឹងបញ្ចប់ក្នុងលទ្ធផលស្មើគ្នា នៅពេលដែលចៅក្រមសម្រេចថា កីឡាករទាំងពីរបានពិន្ទុស្មើគ្នានៅចុងបញ្ចប់នៃទឹកចុងក្រោយ។
9. "ឈ្នះដោយពិន្ទុ"។ នេះមានន័យថា អ្នកឈ្នះនឹងត្រូវប្រកាសដោយសេចក្តីសម្រេចរបស់ចៅក្រម នៅចុងបញ្ចប់នៃទឹកចុងក្រោយ។
10. "ឈ្នះមុនការបញ្ចប់ទឹក"។ នេះរាប់បញ្ចូលទាំងការឈ្នះតាមរយៈការផ្តួលដៃគូឱ្យសន្លប់ ការផ្តួលឱ្យដៃគូសន្លប់តាមបច្ចេកទេស ចៅក្រមបញ្ឈប់ការប្រកួតរបស់ដៃគូ ឬដកចេញដៃគូរប្រកួត ក្នុងអំឡុងពេលប្រកួត ។
11. "ឈ្នះ (2 ផ្លូវ)"។ ប្រសិនបើការប្រកួតបានបញ្ចប់ក្នុងលទ្ធផលស្មើគ្នា នោះការភ្នាល់ W1 និង W2 នឹងត្រូវទូទាត់តាមហាងឆេង 1 ។
12. "W2 នៅក្នុងទឹកទី 3 – បាទ/ចាស"។ ការភ្នាល់នេះនឹងឈ្នះ ប្រសិនបើកីឡាករទីពីរឈ្នះមុនការបញ្ចប់ទឹកដោយការផ្តួលដៃគូឲ្យសន្លប់ ឬដោយការសម្រេចតាមបច្ចេកទេស នៅក្នុងទឹកទីបី។
13. ការប្រកួត បិទនឹងបញ្ចប់នៅទឹកទី 10–12"។ ការភ្នាល់នេះនឹងឈ្នះ ប្រសិនបើកីឡាករឈ្នះមុនការបញ្ចប់ទឹក ដោយការផ្តួលឱ្យសន្លប់ ឬការសម្រេចតាមបច្ចេកទេស ក្នុងរយៈពេលពីទឹកទីដប់ដល់ទឹកទីដប់ពីរ។ ឈ្នះដោយ TD។ ការប្រកួតត្រូវបានបញ្ឈប់ ដោយសារតែការរងរបួសឬដោយសារហេតុផលណាមួយ ហើយលទ្ធផលត្រូវបានសម្រេចដោយតារាងពិន្ទុរបស់ចៅក្រម មុនពេលដែលចំនួនទឹកត្រូវបានបញ្ចប់។
14. "ឈ្នះដោយ TD"។ វាជាការបញ្ឈប់ការប្រកួតដោយសារបញ្ហារបួសឬហេតុផលមួយទៀត ជាមួយនឹងការដាក់ពិន្ទុដោយចៅក្រម និងការវាយតំលៃលទ្ធផលសម្រាប់ចំនួនទឹកដែលមិនបានបញ្ចប់។
15. ផ្តួលឱ្យសន្លប់សរុប។ អតិថិជនគួរតែទស្សន៍ទាយចំនួនការផ្តួលឱ្យសន្លប់នៅក្នុងការប្រកួត។ ការផ្តួលឱ្យសន្លប់ទាំងអស់នឹងរាប់ ទាំងការផ្តួលឱ្យសន្លប់ និងឬការផ្តួលឱ្យសន្លប់តាមបច្ចេកទេស។

10.9. UFC

1. ការចាប់ផ្តើមនៃការប្រកួតត្រូវបានបន្លឺឡើង ដោយសម្លេងជួងមុនពេលទឹកទីមួយ។
2. ប្រសិនបើការប្រកួតមួយត្រូវបានប្រកាសថាគ្មានការប្រកួត ឬប្រសិនបើការប្រកួតត្រូវបានបញ្ឈប់ដោយហេតុផលណាមួយ មុនពេលដែលអ្នកឈ្នះត្រូវបានកំណត់ នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោឃៈ។ ប្រសិនបើលទ្ធផលនៃការប្រកួតត្រូវបានកំណត់រួចហើយ នោះការភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលដែលបានប្រកាស។
3. ប្រសិនបើចំនួនទឹកត្រូវបានផ្លាស់ប្តូរ នោះការភ្នាល់លើលទ្ធផលនៃការប្រកួតនឹងមានសុពលភាព ប៉ុន្តែការភ្នាល់លើចំនួនទឹកនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
4. "ចំនួនជុំសរុប"។ ដើម្បីឱ្យការភ្នាល់លើទីផ្សារនេះបានឈ្នះ អតិថិជនត្រូវតែទស្សន៍ទាយចំនួនទឹកនៅក្នុង

ការប្រកួតប្រដាល់ឱ្យបានត្រឹមត្រូវ។ មានតែទឹកណាដែលពេលវេលាផ្តល់ឱ្យច្រើនជាងពាក់កណ្តាលបានកន្លងផុតទៅប៉ុណ្ណោះ ដែលត្រូវរាប់បញ្ចូលក្នុងចំនួនទឹកសរុប។ ចំនួនពាក់កណ្តាលនៃទឹកដែលមានរយៈពេល 5 នាទី គឺ 2 នាទី 30 វិនាទី។ ហេតុនេះ 2.5 ទឹក សំដៅលើចំនួនពីរទឹក និង 2 នាទី 30 វិនាទី នៃទឹកទីបី។ ប្រសិនបើការប្រកួតប្រដាល់បញ្ចប់ត្រឹមពាក់កណ្តាលទឹកគត់ (2 នាទី 30 វិនាទី) ក្នុងទឹកណាមួយ នោះការភ្នាល់ "អូវ័រ/អាន់ដ័រ" លើចំនួនទឹកសរុប នឹងត្រូវទូទាត់សងនៅហាងឆេង 1.00។

5. ប្រសិនបើកីឡាករមិនចូលក្នុងសង្វៀន បន្ទាប់ពីលឺសម្លេងជួងនៅពេលចាប់ផ្តើមទឹកនៃការប្រកួតទេ នោះការប្រកួតត្រូវបានគេចាត់ទុកថាបានបញ្ចប់នៅទឹកមុន។
6. ប្រសិនបើទឹកទីមួយបញ្ចប់ទៅក្នុងរយៈពេល 2 នាទីដំបូង នោះការភ្នាល់លើ "ចំនួនទឹកសរុប អាន់ដ័រ 0.5" នឹងត្រូវប្រកាសលទ្ធផលជាការឈ្នះ។
7. "1 (2) នឹងឈ្នះ"។ នៅក្នុងផ្នែក "កីឡា" ការភ្នាល់នៅលើទីផ្សារនេះ ត្រូវបានដាក់ស្លាក "1" និង "2" រៀងៗខ្លួន ហើយរួមមានដូចខាងក្រោមនេះ៖
    - "ឈ្នះដោយពិន្ទុ";
    - "ឈ្នះដោយការផ្តួលដៃគូឱ្យសន្លប់";
    - "ឈ្នះដោយការផ្តួលដៃគូឱ្យសន្លប់តាមបច្ចេកទេស";
    - "ឈ្នះដោយការសម្រេចតាមបច្ចេកទេស";
    - "ឈ្នះដោយការជម្រុះឬការបដិសេធ"។
8. "ស្មើគ្នា"។ ការភ្នាល់នៅលើទីផ្សារនេះត្រូវបានដាក់ស្លាក “X”។ ការប្រកួតនឹងបញ្ចប់ក្នុងលទ្ធផលស្មើគ្នានៅពេលដែលចៅក្រមសម្រេចថា កីឡាកររកបានពិន្ទុស្មើគ្នានៅចុងបញ្ចប់នៃទឹកចុងក្រោយ។
9. "ឈ្នះដោយពិន្ទុ"។ នេះមានន័យថា អ្នកឈ្នះនឹងត្រូវប្រកាសដោយសេចក្តីសម្រេចរបស់ចៅក្រមនៅចុងបញ្ចប់នៃទឹកចុងក្រោយ។
10. "ឈ្នះមុនការបញ្ចប់ទឹក"។ នេះរាប់បញ្ចូលទាំងការឈ្នះ តាមរយៈការផ្តួលដៃគូឱ្យសន្លប់ ការផ្តួលដៃគូឱ្យសន្លប់តាមបច្ចេកទេស ការខ្លៀ/គ្រៀកក/ការក្លេបង្ខំឱ្យចុះចាញ់ ការជម្រុះចេញនូវដៃគូ ឬដៃគូរដកខ្លួនចេញក្នុងអំឡុងពេលប្រកួត។
11. "ឈ្នះ (2 ផ្លូវ)"។ ប្រសិនបើការប្រកួតបានបញ្ចប់ក្នុងលទ្ធផលស្មើគ្នា នោះការភ្នាល់ W1 និង W2 នឹងត្រូវទូទាត់តាមហាងឆេង 1 ។
12. «() នឹងឈ្នះក្នុងទឹកទី ()»។ ការភ្នាល់នេះនឹងឈ្នះ ប្រសិនបើអត្តពលិកដែលបានជ្រើសរើសឈ្នះក្នុងចម្ងាយដោយការផ្តួលគូប្រកួតឬដោយការសម្រេចចិត្តបច្ចេកទេសក្នុងទឹកដែលបានជ្រើសរើស។
13. ការវាយ។ ការវាយចំល្អ។ នៅពេលទូទាត់សងការភ្នាល់លើទីផ្សារនេះ មានតែការវាយដែលទទួលបានជោគជ័យប៉ុណ្ណោះ ដែលនឹងត្រូវរាប់បញ្ចូល។ ការវាយពុំត្រូវចំគោលដៅ នឹងមិនត្រូវរាប់បញ្ចូលនោះទេ លើកលែងតែមានចែងផ្សេងពីនេះ។
14. គ្រាប់តសម្រេចចិត្តតាមពិន្ទុ (រួមទាំងការឈ្នះក្នុងចម្ងាយ)។ គ្រាប់តត្រូវបានគណនាដោយផ្អែកលើពិន្ទុចុងក្រោយនៃការប្រកួតពេញលេញ ដូចដែលបានផ្តល់ឱ្យនៅក្នុងប្រភពប្រកួតផ្លូវការ។
ប្រសិនបើការប្រកួតបញ្ចប់មុនពេល នោះការភ្នាល់លើអ្នកប្រយុទ្ធដែលឈ្នះក្នុងចម្ងាយនឹងត្រូវបានទូទាត់ថាជាការភ្នាល់ឈ្នះ ហើយការភ្នាល់លើគូប្រកួតរបស់អ្នកប្រយុទ្ធនោះនឹងត្រូវបានទូទាត់ជាការភ្នាល់ចាញ់

(ដោយមិនគិតពីតម្លៃគ្រាប់ត)។

10.10. ការប្រណាំងកង់

1. ការចាប់ផ្តើមនៃវគ្គជម្រុះដំបូងនឹងត្រូវបានចាត់ទុកថាជាការចាប់ផ្តើមនៃការប្រកួត។
2. ទីផ្សារ "ផ្លូវផ្គងគ្នា" (កីឡាករឬក្រុមកីឡា)។ គូប្រជែងទាំងពីរត្រូវតែឆ្លងកាត់បន្ទាត់ចាប់ផ្តើមជាផ្លូវការ ដើម្បីឱ្យការភ្នាល់មានសុពលភាព។
    - ប្រសិនបើគូប្រជែងណាមួយបោះបង់ការប្រកួតប្រជែង ដោយហេតុផលណាមួយ នោះគូប្រជែងរបស់ពួកគេនឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ។
    - ប្រសិនបើអ្នកប្រណាំងម្នាក់ឬទាំងពីរខកខាន មិនបានឆ្លងផុតវគ្គចាប់ផ្តើមផ្លូវការ នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
    - ប្រសិនបើអ្នកប្រណាំងទាំងពីរឈប់ពីការប្រណាំង អ្នកប្រណាំងដែលបានបញ្ចប់ច្រើនជុំបំផុតនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។
    - ប្រសិនបើអ្នកប្រណាំងទាំងពីរបោះបង់ចោលនៅលើជុំដូចគ្នា នោះហាងឆេងដែលឈ្នះនឹងមានដល់ 1 ។
3. "នឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ"។ អតិថិជនគួរទស្សន៍ទាយថាតើអ្នកប្រណាំងមួយណា ក្នុងចំណោមអ្នកប្រណាំងពីរនាក់ (ឬក្រុម) នឹងបញ្ចប់ខ្ពស់ជាងគេ នៅក្នុងចំណាត់ថ្នាក់ចុងក្រោយ។
4. ប្រសិនបើអ្នកប្រណាំងជាច្រើនមានពេលវេលាស្មើគ្នា ក្នុងចំណាត់ថ្នាក់ចុងក្រោយ នោះអ្នកដែលកាន់តំណែងខ្ពស់ជាងគេនឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ។
5. ការភ្នាល់ជាក្រុម។ ការភ្នាល់អាចត្រូវបានដាក់ សម្រាប់តែអ្នកប្រណាំងដែលមានឈ្មោះនៅក្នុងផ្នែក កីឡាប៉ុណ្ណោះ។
    - ប្រសិនបើអ្នកប្រណាំងម្នាក់ឬច្រើននាក់មិនបានចូលរួមក្នុងការភ្នាល់ នោះប្រាក់ភ្នាល់នឹងត្រូវបានបង្វិលសងមកវិញនៅហាងឆេង 1.00 ។
    - ប្រសិនបើគ្មានកីឡាករដែលបានបញ្ជាក់ណាម្នាក់រកបានពិន្ទុនៅក្នុងការប្រកួតទេ នោះប្រាក់ភ្នាល់ទាំងអស់នឹងត្រូវបានបង្វិលសងវិញនៅហាងឆេង 1.00 ។

10.11. បាល់គប់ក្នុងទឹក

1. ការភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមលទ្ធផលចុងក្រោយ នៅពេលចប់ម៉ោងធម្មតា (32 នាទី មានបួនតង់ដែលមួយតង់ៗមាន 8 នាទី)។

ក្រុមហ៊ុនភ្នាល់មិនទទួលខុសត្រូវ ចំពោះការប្រកាសណាមួយដែលមិនត្រឹមត្រូវ អំពីរយៈពេលនៃហ្គេមឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់បាល់គប់ក្នុងទឹកពីប្រភពផ្លូវការ។

2. ការថែមម៉ោងនិងការស៊ុតបាល់ប៉ែណាល់ទីកាត់សេចក្តី នឹងរាប់បញ្ចូលសម្រាប់ទីផ្សារ "ជម្រុះ" "ឈ្នះ" និងទីផ្សារស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
4. យ៉ាងហោចណាស់ ការលេងត្រូវតែកន្លងផុតឱ្យបាន 30 នាទី ទើបការភ្នាល់នៅមានសុពលភាព។ នៅក្នុងករណីនេះ ប្រាក់ភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលដែលបានប្រកាស នៅពេលការប្រកួតត្រូវបានអាក់ខាន។

10.12. បាល់ទះ

1. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ប្រាក់ភ្នាល់ទាំងអស់នៅលើការប្រកួតនេះនឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
2. ប្រសិនបើសេតមួយមិនត្រូវបានលេងរហូតដល់ចប់ លទ្ធផលដែលត្រូវបានកំណត់រួចហើយដោយគ្មានលក្ខខណ្ឌ នៅពេលមានការអាក់ខាន នឹងរាប់បញ្ចូលក្នុងការភ្នាល់។ រាល់ការភ្នាល់ផ្សេងទៀតនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ប្រសិនបើសេតមួយត្រូវបានលេងរហូតដល់ចប់ ប៉ុន្តែការប្រកួតមិនត្រូវបានបញ្ចប់ នោះការភ្នាល់នៅលើសេតនេះនឹងមានសុពលភាព។
3. ការភ្នាល់លើការប្រកួតជើងឯកបាល់ទះអឺរ៉ុប (European Volleyball Championship) និងការប្រកួតពានរង្វាន់ CEV Challenge Cup នឹងត្រូវបានទូទាត់ រួមទាំងហ្គោលឌិនសេត ប្រសិនបើមានជម្រើសបែបនេះ (សេតមាស (រហូតដល់ 15 ពិន្ទុ) ត្រូវបានផ្តល់ជូន ប្រសិនបើក្រុមមានពិន្ទុស្មើគ្នា នៅដំណាក់កាលណាមួយនៃការប្រកួតជើងឯកអឺរ៉ុប European championships)។
4. គ្រាប់តបាល់ទះនិងទីផ្សារគ្រាប់សរុប ត្រូវបានបញ្ជាក់ជាពិន្ទុ លើកលែងតែសេតគ្រាប់តនិងតូតាល់សេត។
5. "ពិន្ទុដោយសេត"។ នៅក្នុងផ្នែក "កីឡា" ជួរឈរដែលពាក់ព័ន្ធមានចំណងជើងថា 3:0 3:1 ។ល។
6. "ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន"។ ប្រសិនបើក្រុមមិនជាប់ជម្រុះទៅដំណាក់កាលបន្ទាប់ទេ នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើចំណាត់ថ្នាក់របស់ពួកគេនៅក្នុងគ្រុប។ ប្រសិនបើក្រុមបញ្ចប់នៅចំណាត់ថ្នាក់ដូចគ្នាក្នុងគ្រុប នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់ ដោយផ្អែកលើពិន្ទុរបស់ពួកគេ។
7. "ការប្រកួតនឹងមានរយៈពេលយូរប៉ុណ្ណា"។ អតិថិជនគួរទស្សទាយថាតើការប្រកួតនឹងមានរយៈពេលច្រើនឬតិចជាងរយៈពេលដែលបានដកស្រង់ជានាទី។ រយៈពេលសរុបត្រូវបានគណនាដោយបូកបញ្ចូលគ្នា នូវរយៈពេលនៃសេតទាំងអស់នៅក្នុងការប្រកួត ដោយយោងទៅតាមកំណត់ត្រាការប្រកួតផ្លូវការ។
8. "ការប្រណាំងយក 3 (5 ។ល។) ពិន្ទុ"។ អតិថិជនគួរទស្សទាយថាក្រុមមួយណា ដែលនឹងរកបានមុនដំបូងគេនូវចំនួនពិន្ទុដែលបានបញ្ជាក់នៅក្នុងសេតមួយ។ ប្រសិនបើអ្នកចូលរួមណាម្នាក់បដិសេធមិនបន្ត

ដោយសារមូលហេតុណាមួយ មុនពេលពួកគេឬគូប្រជែងរបស់ពួកគេ រកបានពិន្ទុដែលដកស្រង់ នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។

9. "ពិន្ទុបន្ថែម"។ អតិថិជនគួរតែទស្សន៍ទាយថាតើនឹងមានពិន្ទុបន្ថែមនៅក្នុងសេតដៃរឬទេ។ ការភ្នាល់ "ពិន្ទុបន្ថែមក្នុងសេត – បាទ/ចាស" នឹងឈ្នះ ប្រសិនបើក្រុមណាមួយឈ្នះសេត បន្ទាប់ពិន្ទុគឺ 24:24 ។
10. "កាត់ក្តីពិន្ទុស្មើគ្នា – បាទ/ទេ"។ អតិថិជនគួរតែទស្សន៍ទាយថាតើ នឹងមានសេតទីប្រាំដៃរឬទេ។ ការភ្នាល់ "កាត់ក្តីពិន្ទុស្មើគ្នា – បាទ/ចាស" នឹងឈ្នះ ប្រសិនបើមានសេតទីប្រាំ។
11. "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត តូតាល់ (មិនរាប់បញ្ចូលសេតទីប្រាំ)"។ ឧទាហរណ៍ ការភ្នាល់ "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត តូតាល់អាន់ឌ័រ 47.5" នឹងចាញ់ ប្រសិនបើពិន្ទុ (25:23, 26:24, 23:25, 23:25, 18:16)។
12. "អំឡុងពេលដែលមានពិន្ទុតិចបំផុតតូតាល់ (រាប់បញ្ចូលសេតទីប្រាំ)"។ ឧទាហរណ៍ ការភ្នាល់ "អំឡុងពេលដែលមានពិន្ទុតិចបំផុត តូតាល់អាន់ឌ័រ 40.5" នឹងឈ្នះប្រសិនបើពិន្ទុ (25:23, 26:24, 23:25, 23:25, 18:16)។

10.13. បាល់គប់

1. ប្រាក់ភ្នាល់ត្រូវបានទូទាត់តាមលទ្ធផលចុងក្រោយ នៅពេលចប់ម៉ោងធម្មតា (ការលេង 60 នាទី រួមមានតង់ 30 នាទី ចំនួនពីរ)។
2. ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីនឹងត្រូវរាប់បញ្ចូលសម្រាប់ទីផ្សារខាងក្រោម៖ "ដើម្បីជាប់ជម្រុះ ទៅជុំបន្ទាប់",,"ដើម្បីជាប់ជម្រុះ ទៅលើគមួយផ្សេងទៀត",,"ឈ្នះ" និងស្រដៀងគ្នា។
3. ការភ្នាល់ពេលកំពុងលេង។ ប្រសិនបើការប្រកួតមិនត្រូវបានបញ្ចប់ វាល់ប្រាក់ភ្នាល់ទាំងអស់នៅលើនោះនឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានលក្ខខណ្ឌនៅពេលការប្រកួតត្រូវបានអាក់ខាន។
4. ការភ្នាល់លើទីផ្សារ "អ្នករកគ្រាប់បាល់បានច្រើនជាងគេ" ត្រូវបានទូទាត់ដោយរួមបញ្ចូលទាំងការថែមម៉ោង ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីទេ។
5. យោងតាមច្បាប់នៃការប្រកួតជើងឯកចិន China Championship ការប្រកួតនឹងត្រូវបញ្ចប់ ប្រសិនបើពិន្ទុខុសគ្នារហូតដល់ 15 ពិន្ទុ ហើយយ៉ាងហោចណាស់រយៈពេល 30 នាទីនៃការលេងបានកន្លងផុតទៅ (ច្បាប់អនុគ្រោះត្រូវបានអនុវត្ត)។
6. នៅក្នុងការភ្នាល់លើកាតលឿង អតិថិជនគួរទស្សន៍ទាយពីចំនួនកាតលឿងដែលផ្តល់ដល់កីឡាករ។
7. នៅក្នុងការភ្នាល់លើការទាត់បាល់ប៉េណាល់ទីប្រាំពីរម៉ែត្រ អតិថិជនគួរតែទស្សន៍ទាយចំនួននៃការស៊ុតបាល់ប៉េណាល់ទីបានសម្រេច (គ្រាប់)។
8. ការភ្នាល់ "ផ្អាករយៈពេល 2 នាទី"។ មានតែការផ្អាកពីរនាទីប៉ុណ្ណោះ ដែលត្រូវបានរាប់។ នាទីបាល់ប៉េណាល់ទី ដែលត្រូវបានផ្តល់មុនពេលចាប់ផ្តើមនៃអំឡុងពេលមួយ ឬបន្ទាប់ពីការបញ្ចប់ពាក់កណ្តាលតង់ (ការប្រកួត) ដែលត្រូវបានបញ្ចូលក្នុងកំណត់ត្រាប្រកួតចុងក្រោយ ត្រូវបានរាប់នៅពេលការភ្នាល់ត្រូវ

បានទូទាត់។ ក្រុមហ៊ុនភ្នាល់ផ្តល់ជូននូវការភ្នាល់ដូចខាងក្រោម៖ "ផ្អាករយៈពេល 2 នាទីដំបូង" "ផ្អាករយៈពេល 2 នាទីចុងក្រោយ" និង "តូតាល់ផ្អាករយៈពេល 2 នាទី"/"តូតាល់ផ្អាករយៈពេល 2 នាទី (តាមក្រុម)"។

9. "ការប្រកួតជម្រើសជំនួស""។ នេះរួមបញ្ចូលទាំងការភ្នាល់លើការប្រកួត នៃក្រុមដែលការប្រកួតត្រូវបានចាក់ផ្សាយផ្ទាល់។ ប្រសិនបើការប្រកួតត្រូវបានលុបចោល នោះប្រាក់ភ្នាល់លើការប្រកួតជម្រើសផ្សេងនឹងត្រូវទូទាត់តាមហាងឆេង 1 (ប្រាក់ភ្នាល់នឹងត្រូវបានបង្វិលសងវិញ)។
10. "បាល់គប់។ ស្ថិតិ"។ ប្រាក់ភ្នាល់ ត្រូវបានទូទាត់ដោយរួមបញ្ចូលទាំងការថែមម៉ោង ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីទេ។

10.14. វាយកូនហ្គោល

1. ធូណាមិនកីឡាវាយកូនហ្គោលសំខាន់ៗអាចមានរយៈពេលបីឬបួនថ្ងៃ ហើយចំនួនរន្ធសរុបគឺជាធម្មតាមានចំនួន 72 ។
2. កីឡាករត្រូវតែចាប់ផ្តើមវាយកូនហ្គោល ដើម្បីត្រូវបានចាត់ទុកថាជាអ្នកចូលរួមលេង។ ប្រសិនបើកីឡាការវាយកូនហ្គោលបដិសេធមិនបន្ត នោះការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកថាចាញ់។
3. **"នឹងឈ្នះធូណាមិន"។** កីឡាករវាយកូនហ្គោល ដែលទទួលបានចំណាត់ថ្នាក់លេខមួយនៅក្នុងការប្រកួតនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ អ្នកឈ្នះត្រូវបានកំណត់ បន្ទាប់ពីការប្រកួតផ្តាច់ព្រាត់ ប្រសិនបើដំណាក់កាលបែបនេះត្រូវបានកំណត់ដោយច្បាប់នៃធូណាមិន។
4. ប្រសិនបើអ្នកប្រកួតប្រជែងនាំមុខពីរ (ឬច្រើន) នាក់មានពិន្ទុស្មើគ្នា នៅចុងបញ្ចប់នៃពេលវេលាធម្មតា – រន្ធចំនួន 72 នោះច្បាប់នៃការប្រកួតយកឈ្នះចាញ់ត្រូវបានអនុវត្តជាធម្មតា នៅការប្រកួតផ្តាច់ព្រាត់។ នៅក្នុងករណីនេះ អ្នកឈ្នះនៃការប្រកួតផ្តាច់ព្រាត់នឹងត្រូវបានប្រកាស អ្នកឈ្នះនៃធូណាមិននិងអ្នកឈ្នះសម្រាប់គោលបំណងការភ្នាល់។ កីឡាករវាយកូនហ្គោលផ្សេងទៀតនឹងត្រូវបានចាត់ទុកជាអ្នករងជើងឯក។
5. **"ការប្រកួត"**។ កីឡាករដែលមានចំណាត់ថ្នាក់ខ្ពស់ជាងគេនៅចុងបញ្ចប់នៃធូណាមិន រួមទាំងរាល់ការប្រកួតផ្តាច់ព្រាត់ នឹងក្លាយទៅជាអ្នកឈ្នះ។ ប្រសិនបើកីឡាករម្នាក់បរាជ័យក្នុងការកាត់ កីឡាករម្នាក់ទៀតត្រូវបានគេចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករទាំងពីរបរាជ័យក្នុងការកាត់ នោះប្រាក់ភ្នាល់ត្រូវបានទូទាត់ដោយផ្អែកលើពិន្ទុទាបបំផុត បន្ទាប់ពីការកាត់នោះត្រូវបានធ្វើឡើង។ ប្រសិនបើកីឡាករម្នាក់ត្រូវបានគេដកសិទ្ធិ មុនពេលបញ្ចប់នៃការប្រកួតពីរជុំ ឬបន្ទាប់ពីកីឡាករវាយកូនហ្គោលទាំងពិរបានបរាជ័យក្នុងការកាត់ នោះកីឡាករដែលនៅសល់ត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករម្នាក់ត្រូវបានគេដកសិទ្ធិក្នុងជុំទីបីឬទីបួន បន្ទាប់ពីគូប្រជែងរបស់ពួកគេបានបរាជ័យក្នុងការកាត់ នោះកីឡាករដែលធ្លាក់ជម្រុះនោះនឹងត្រូវចាត់ទុកជាអ្នកឈ្នះ។ ប្រសិនបើមិនមានហាងឆេងលើការស្មើគ្នាដែលត្រូវបានផ្តល់ជូនទេ នោះប្រាក់ភ្នាល់លើកីឡាករដែលមានចំណាត់ថ្នាក់ដូចគ្នានឹងត្រូវបានទូទាត់តាមហាងឆេង 1 ។

6. **"ឈ្នះគ្រាប់ត"**។ កីឡាករចាប់ផ្តើមជាមួយនឹងគ្រាប់ត ដែលត្រូវអនុវត្តចំពោះពិន្ទុចុងក្រោយរបស់ពួកគេ។ ការភ្នាល់លើកីឡាករដែលបានបរាជ័យក្នុងការកាត់ បានដកខ្លួនចេញឬបានធ្លាក់ជម្រុះ ត្រូវបានចាត់ទុកថាចាញ់។ ប្រសិនបើកីឡាករទាំងពីរបរាជ័យក្នុងការកាត់ នោះគ្រាប់តត្រូវបានអនុវត្តចំពោះពិន្ទុរបស់ពួកគេនៅពេលការកាត់នោះបានកើតឡើង។ ការភ្នាល់នឹងត្រូវបានលុបចោល នៅពេលដែលកីឡាករទាំងពីរដកខ្លួនចេញឬធ្លាក់ជម្រុះ ឬក៏កីឡាករណាមួយខកខានការចាប់ផ្តើមវាយកូនហ្គោល។ ប្រសិនបើការប្រកួតមិនបានលេងអស់ជុំទេ ប្រាក់ភ្នាល់លើទីផ្សារគ្រាប់តនឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែ លទ្ធផលនៃការប្រកួតត្រូវបានកំណត់រួចហើយ។
7. **"ការភ្នាល់តាមក្រុម"/"កីឡាកចក្រភពអង់គ្លេសកំពូលៗ"** ។ល។ កីឡាករដែលមានចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ កីឡាករណា ដែលបរាជ័យក្នុងការកាត់ នឹងត្រូវបានចាត់ទុកថាចាញ់។ ប្រសិនបើកីឡាករទាំងអស់បរាជ័យក្នុងការកាត់ ពិន្ទុទាបបំផុតបន្ទាប់ពីការកាត់នោះត្រូវបានកើតឡើងនឹងកំណត់ការទូទាត់។ កីឡាករត្រូវបានដាក់ជាក្រុមរួមគ្នាសម្រាប់គោលបំណងការភ្នាល់តែប៉ុណ្ណោះ។ ប្រសិនបើកីឡាករមិនចាប់ផ្តើមវាយកូនហ្គោល ការភ្នាល់លើកីឡាករនេះនឹងត្រូវលុបចោល។ ច្បាប់ទី 4 ត្រូវបានអនុវត្តចំពោះការភ្នាល់លើកីឡាករផ្សេងទៀត។ វិធាននៃការយកឈ្នះចាញ់នឹងត្រូវបានអនុវត្ត នៅពេលទូទាត់ការភ្នាល់ លើកលែងតែអ្នកឈ្នះត្រូវបានកំណត់ដោយ ការប្រកួតផ្តាច់ព្រាត់។
8. **"ការភ្នាល់ក្រុមគ្រាប់ត"**។ កីឡាកររនៅក្នុងក្រុមនឹងត្រូវបានបែងចែកសម្រាប់គ្រាប់ត។ អ្នកឈ្នះនៃក្រុម នឹងត្រូវបានកំណត់ដោយផ្អែកលើពិន្ទុចុងក្រោយ នៅពេលដែលគ្រាប់តត្រូវបានអនុវត្ត។ កីឡាកររវាយកូនហ្គោលណា ដែលបានបរាជ័យក្នុងការកាត់ នឹងត្រូវបានចាត់ទុកថាចាញ់។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើចំនួនកីឡាករមិនគ្រប់គ្រាន់ដែលធ្វើការកាត់ សម្រាប់ទីផ្សារដែលបានដាក់ភ្នាល់ ការដាក់ភ្នាល់ដែលនៅសល់នឹងត្រូវបានបែងចែកសម្រាប់កីឡាករដែលបរាជ័យក្នុងការកាត់ ដោយផ្អែកលើពិន្ទុចុងក្រោយរបស់ពួកគេ នៅពេលដែលគ្រាប់តត្រូវបានអនុវត្ត។
9. នៅក្នុងធូណាមិន ជាក់លាក់ជាផ្លូវការអាចស្នើអ្នកប្រកួតគួរតែលេងរន្ធបន្ថែម។ នៅក្នុងករណីបែបនេះ កីឡាករដែលមានពិន្ទុទាបបំផុត បន្ទាប់ពីពួកគេបានលេងចំនួនរន្ធដែលបានបញ្ជាក់ នឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ ហើយអ្នកប្រកួតរជែងផ្សេងទៀតនឹងត្រូវបានចាត់ទុកជាអ្នកឈ្នះបន្ទាប់។
10. **"ការភ្នាល់រន្ធ 18"**។ កីឡាករដែលមានពិន្ទុទាបក្រោយពីលេងបាន 18 រន្ធ ត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ក្នុងករណីដែលបាល់ 2 ឬ 3 ត្រូវបានរៀបចំឡើងវិញ ឬបង្ហាញខុសគ្នាដោយយើង ការភ្នាល់ដែលទទួលយកនឹងមានសុពលភាពលើការចាត់ក្រុមដែលបានបង្ហាញនៅពេលការភ្នាល់បានដាក់រួចរាល់។ ប្រសិនបើកីឡាករណាម្នាក់ខកខានមិនបានចាប់ផ្តើមវាយកូនហ្គោល នោះការភ្នាល់លើបាល់ 2 ឬ 3 នោះនឹងត្រូវចាត់ទុកជាមោយ:។ ក្នុងការភ្នាល់បាល់ 2 ប្រសិនបើកីឡាកររវាយកូនហ្គោលទាំងពីរទទួលបានពិន្ទុស្មើ ហើយមិនមានតម្លៃស្មើត្រូវបានផ្តល់ជូន នោះប្រាក់ភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ក្នុងការភ្នាល់បាល់ 3 ប្រសិនបើកីឡាករទាំងអស់មានពិន្ទុស្មើគ្នា នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ក្នុងការភ្នាល់បាល់ 3 ប្រសិនបើកីឡាកររនាក់ទទួលបានពិន្ទុស្មើគ្នា នោះច្បាប់យកឈ្នះចាញ់នឹងត្រូវអនុវត្ត។ នៅពេលការភ្នាល់ពិសេសត្រូវបានផ្តល់ជូន ក្រុមដែលមានកីឡាករច្រើនជាងបីនាក់ក្នុងមួយជុំ នោះច្បាប់នៃការយកឈ្នះចាញ់នឹងត្រូវបានអនុវត្ត។ ការភ្នាល់លើអ្នកមិនចាប់ផ្តើមនឹងត្រូវបាន

លុបចោល។

11. **"នឹងធ្វើ/បរាជ័យក្នុងការកាត់"**។ ប្រសិនបើកីឡាករវាយកូនហ្គោលមួយដកខ្លួនចេញឬត្រូវបានជម្រុះចេញមុនពេលការកាត់ត្រូវបានធ្វើឡើង នោះការភ្នាល់នឹងត្រូវចាញ់។ ប្រសិនបើកីឡាករមួយដកខ្លួនចេញឬត្រូវបានជម្រុះចេញ បន្ទាប់ពីការកាត់ត្រូវបានធ្វើឡើង នោះការភ្នាល់នឹងត្រូវឈ្នះ។ ប្រសិនបើកីឡាករមិនចូលរួមធ្ងណាមិន ការភ្នាល់នោះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
12. "នឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ"។ អតិថិជនគួរទស្សន៍ទាយថាតើកីឡាករមួយណា ក្នុងចំណោមកីឡាករទាំងពីរដែលបានចុះបញ្ជី នឹងលេងល្អជាងគេ។ កីឡាករដែលបានបញ្ចប់ 18 រន្ធ ដោយមានពិន្ទុទាបជាងគេ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ក្នុងការភ្នាល់បាល់ 2 ប្រសិនបើកីឡាករទាំងពីរមានពិន្ទុស្មើគ្នា ហើយមិនមានតម្លៃស្មើត្រូវបានផ្តល់ជូន នោះប្រាក់ភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ក្នុងការភ្នាល់បាល់ 3 ប្រសិនបើកីឡាករទាំងអស់មានពិន្ទុស្មើគ្នា នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
13. ប្រសិនបើកីឡាករដកខ្លួនចេញ បន្ទាប់ពីខកខានមិនបានចាប់ផ្តើមវាយកូនហ្គោល ដោយមិនបានលេងរន្ធទាំង 18 ទេ នោះពួកគេនឹងចាញ់ដោយមិនគិតពីពិន្ទុ។ ហ្គេមចាប់ផ្តើម ដោយការវាយលើកដំបូងឆ្ពោះទៅរន្ធមួយ។ ប្រសិនបើកីឡាករម្នាក់ដកខ្លួនចេញ មុនពេល ខកខានមិនបានចាប់ផ្តើមវាយកូនហ្គោល ប្រាក់ភ្នាល់លើកីឡាករផ្សេងទៀតទាំងអស់នៅក្នុងក្រុមនេះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
14. ប្រសិនបើធ្ងណាមិនមួយត្រូវបានប៉ះពាល់ដោយលក្ខខណ្ឌអាកាសធាតុអាក្រក់ ប្រាក់ភ្នាល់នឹងត្រូវបានទូទាត់តាមលទ្ធផលបច្ចុប្បន្ន ទោះយ៉ាងណាយ៉ាងហោចក៏មានរន្ធចំនួន 36 ដៃត្រូវតែបានលេង។ នេះមិនត្រូវបានអនុវត្ត នៅពេលដែលធ្ងណាមិនកើតឡើងជុតវគ្គជាច្រើនហើយនោះទេ។
15. ការភ្នាល់លើការប្រកួត Ryder Cup និង Presidents Cup។ ពិន្ទុនឹងត្រូវរកបានដូចខាងក្រោម៖ ឈ្នះ – 1 ពិន្ទុ; ស្មើ – 0.5 ពិន្ទុ។

10.15. គប់ព្រួញ

1. "ការភ្នាល់លើការប្រកួត"។ ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ កីឡាករដែលឈានទៅជុំបន្ទាប់នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ទោះយ៉ាងណា ការភ្នាល់លើសេត ជើង និងគ្រាប់តជាក់លាក់មួយ ក៏ដូចជាការភ្នាល់ពិសេស នឹងត្រូវទុកជាមោយ: ដរាបណាលទ្ធផលជាក់លាក់នៃការភ្នាល់ជាក់លាក់មួយត្រូវបានកំណត់រួចហើយ។
2. គ្រាប់តនិងតូតាល់ក្នុងការប្រកួតគប់ព្រួញត្រូវបានបញ្ជាក់ជាសេត លើកលែងតែមានចែងក្នុងផ្នែក "កីឡា"។ 180 គឺជាពិន្ទុខ្ពស់បំផុតពីព្រួញចំនួនបី ដែលគប់ក្នុងមួយដងទៅកាន់ក្តារព្រួញ។
3. "ពិន្ទុឆែកអៅសរុបចុងក្រោយ 40 ឬតិចជាង/(41 ឬច្រើនជាង)"។ ការឆែកអៅ គឺជាចំនួនពិន្ទុដែលកីឡាករត្រូវការរកឱ្យបាន ដើម្បីបញ្ចប់ការប្រកួត។ ពាក្យនេះអនុវត្តចំពោះហ្គេមគប់ព្រួញ នៅពេលដែលកីឡាករចាប់ផ្តើមដោយពិន្ទុថេរ (301 ឬ 501) ហើយគោលដៅគឺត្រូវលេងរហូតដល់សូន្យ។ តាមទ្រឹស្តី នៅពេលដែលពិន្ទុរបស់អ្នកលេងគឺ 170 ពួកគេអាចបញ្ចប់ការប្រកួតបាន ប្រសិនបើពួកគេរកបាន 170 ពិន្ទុ នៅពេល

ដល់វេនរបស់ពួកគេ។

10.16. ឃើលលីង

1. ការភ្នាល់លើការប្រកួតឃើលីងត្រូវបានទទួលយក រួមទាំងការបន្ថែមម៉ោង លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ ហ្គេមមួយមានចំនួន 10 ជុំ។ ប្រសិនបើក្រុមត្រូវបានស្មើគ្នា បន្ទាប់ពី 10 ជុំ ជុំបន្ថែមនឹងត្រូវបានលេង។ អ្នកឈ្នះនៃជុំបន្ថែមត្រូវបានប្រកាសជាអ្នកឈ្នះនៃការប្រកួត។
2. នៅពេលដែលគ្មានគ្រាប់ទៅដល់ទី ឬនៅពេលដែលគ្រាប់ពីររបស់ក្រុមគូប្រជែង ដែលជិតកណ្តាលទីបំផុត ឈប់នៅចម្ងាយដូចគ្នាពីកណ្តាលទី នោះពិន្ទុនៃជុំនោះនឹងមាន 0:0 ។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ វាល់ប្រាក់ភ្នាល់ទាំងអស់នៅលើការប្រកួតនឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានអាក់ខាន។
4. ការភ្នាល់ទាំងអស់ មានសុពលភាព បើយ៉ាងហោចណាស់មានការលេងបានចំនួនប្រាំជុំពេញ។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលនៅពេលការប្រកួតត្រូវបានបញ្ឈប់។
5. ក្រុមនឹងចាញ់ ដោយមិនខ្វល់ពីពិន្ទុឡើយ ប្រសិនបើពួកគេខកខានមិនបានបញ្ចេញគ្រាប់របស់ពួកគេទាន់ពេលទេ (ក្រុមជ្រើសរើសដើម្បីបញ្ជូនគ្រាប់ចំនួនប្រាំបីដុំ ក្នុងមួយជុំ)។
6. ប្រាក់ភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមលទ្ធផលផ្លូវការនៃការប្រកួត រួមទាំងជុំបន្ថែម (លើកលែងតែការភ្នាល់ដែលបានធ្វើឡើងលើផ្នែកខ្លះនៃការប្រកួត)។

10.17. គ្រីឃីត

1. ប្រាក់ភ្នាល់ត្រូវបានទូទាត់ដោយផ្អែកលើលទ្ធផលផ្លូវការ ដែលប្រកាសដោយគណៈគ្រប់គ្រងនៃការប្រកួត ឬធួណាមិននោះ។
2. ប្រសិនបើការប្រកួតត្រូវបានអាក់ខាន ហើយមិនបានបញ្ចប់ នោះប្រាក់ភ្នាល់នឹងត្រូវទូទាត់តាមហាងឆេង 1 ។
3. ធួណាមិនគ្រីឃីតមានច្រើនប្រភេទ៖
    - កម្មវិធីប្រកួត Twenty20 International គឺជាទម្រង់នៃគ្រីឃីត ដែលហ្គេមមានរយៈពេលជាមធ្យមបីម៉ោងកន្លះ។
    - កម្មវិធីប្រកួត One Day International (ODI) គឺជាទម្រង់នៃគ្រីឃីត ដែលហ្គេមមានរយៈពេលជាងប្រាំបីម៉ោង;
    - ការប្រកួតសាកល្បង គឺជាទម្រង់នៃគ្រីឃីតដែលអាចមានរយៈពេលរហូតដល់ប្រាំថ្ងៃ ដោយមានចំនួនអប្បបរមា 90 អូវ័រ ក្នុងមួយថ្ងៃ ដោយភាគីនីមួយៗទទួលបានឱកាសដើម្បីវាយពីរដង។

4. ប្រសិនបើបាត់លទ្ធផល ឬស្ថិតិការប្រកួតណាមួយ នោះគ្រប់ការភ្នាល់ទាំងអស់ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00 លើកលែងតែលទ្ធផលនៃការភ្នាល់ដែលបានកំណត់រួចជាស្រេចហើយ។
5. ប្រសិនបើព័ត៌មានណាមួយអំពីការប្រកួតដែលចេញពីប្រភពផ្លូវការ ត្រូវបានពន្យារពេល៖
    - ការភ្នាល់មុនការប្រកួត៖ ការភ្នាល់នឹងត្រូវទូទាត់សងនៅក្នុងរយៈពេល 48 ម៉ោង បន្ទាប់ពីព្រឹត្តិការណ៍នោះបានបញ្ចប់។
    - ការភ្នាល់ផ្សាយផ្ទាល់៖ ការភ្នាល់នឹងត្រូវទូទាត់សងនៅក្នុងរយៈពេល 12 ម៉ោង បន្ទាប់ពីព្រឹត្តិការណ៍នោះបានបញ្ចប់។
    - ការភ្នាល់លើព្រឹត្តិការណ៍ទាំងនេះ នឹងមិនត្រូវយកមកគណនាម្តងទៀតនោះទេ ប្រសិនបើប្រភពផ្លូវការកែតម្រូវទិន្នន័យណាមួយរបស់ខ្លួន
6. ប្រសិនបើលទ្ធផលផ្លូវការនៃការប្រកួតគឺស្មើគ្នា ហើយមិនមានការផ្តល់ជូននូវតម្លៃណាមួយសម្រាប់លទ្ធផលនេះ ការកាត់សេចក្តីណាមួយនឹងត្រូវបានរាប់ ឧទាហរណ៍ បលអោវ ស៊ុបពើអូរ័រ ។ល។ (បលអោវ និង ស៊ុបពើអូរ័រ មិនរាប់បញ្ចូលការទូទាត់នៃប្រាក់ភ្នាល់ផ្សេងទៀតទេ)។
7. នៅក្នុងការប្រកួតដែលមានចំនួនកំណត់អូរ័រ ការភ្នាល់នៅលើស្ថិតិសម្រាប់ក្រុមមួយ ឬការប្រកួតទាំងមូលនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើអូរ័រតិចជាង 80% នៃការប្រកួតរបស់ក្រុមណាមួយត្រូវបានលេងដោយសារកត្តាខាងក្រៅ រួមទាំងលក្ខខណ្ឌអាកាសធាតុមិនអំណោយផល លើកលែងតែករណីដែលលទ្ធផលត្រូវបានកំណត់រួចហើយនៅពេលបញ្ចប់ការប្រកួត។
8. "ក្រុមកំពូលកីឡាករកាន់ដំបងវាយកូនបាល់"។
    អ្នកឈ្នះគឺជាក្រុមកំពូលកីឡាករកាន់ដំបងវាយកូនបាល់ដែលរកពិន្ទុរត់បានច្រើនជាងគេបំផុត។ ការរត់បានពិន្ទុក្នុងស៊ុបពើអូរ័រមិនត្រូវបានរាប់បញ្ចូលទេ។ ប្រសិនបើកីឡាករពីរនាក់ ឬច្រើននាក់បានពិន្ទុដូចគ្នា នោះច្បាប់ "ដេតហីត (Dead Heat)" ត្រូវបានអនុវត្ត។
    ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់ដកខ្លួនដោយសាររបួស ប៉ុន្តែបន្ទាប់មកត្រឡប់មកទីលានវិញ នោះចំនួនសរុបនៃការរត់យកពិន្ទុដោយកីឡាករកាន់ដំបងវាយកូនបាល់រូបនេះក្នុងការប្រកួតត្រូវរាប់បញ្ចូល។ ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់មិនត្រលប់ទៅទីលានវិញទេ នោះពិន្ទុសរុបរបស់ពួកគេគឺជាចំនួននៃការរត់ដែលពួកគេរកពិន្ទុមុនពេលដកខ្លួនចេញពីការប្រកួត។
    ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់មិនបង្ហាញខ្លួនក្នុងការចាប់ផ្តើម XI របស់ក្រុម ការភ្នាល់លើពួកគេនឹងត្រូវចាត់ទុកជាមោឃៈ។ ការភ្នាល់លើកីឡាករកាន់ដំបងវាយកូនបាល់ដែលមិនបានវាយបាល់ ឬមិនចូលលេងនឹងត្រូវចាត់ទុកថាការភ្នាល់នោះចាញ់។
    នៅក្នុងការប្រកួតដែលមានចំនួនកំណត់អូរ័រ ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើអូរ័រតិចជាង 50% នៃការប្រកួតរបស់ក្រុមណាមួយត្រូវបានលេង ដោយសារកត្តាខាងក្រៅ រួមទាំងលក្ខខណ្ឌអាកាសធាតុមិនអំណោយផល លើកលែងតែករណីដែលលទ្ធផលត្រូវបានកំណត់រួចហើយនៅពេលបញ្ចប់ការប្រកួត។
9. កីឡាករគប់កូនបាល់ល្អបំផុតរបស់ក្រុម កីឡាករវាយកូនបាល់ល្អបំផុតរបស់ក្រុមគឺជាកីឡាករដែលមានរកពិន្ទុច្រើនជាងគេក្នុងការប្រកួតនីមួយៗ។ ការភ្នាល់លើកីឡាករដែលមិនបានគប់បាល់ ឬមិនចូលលេងនឹងត្រូវចាត់ទុកថាការភ្នាល់នោះចាញ់។ នៅក្នុងព្រឹត្តិការណ៍ដែលកីឡាកពីរនាក់ឬច្រើននាក់បានបញ្ចប់

ការប្រកួតជាមួយនឹងចំនួនវីកឃីតដូចគ្នា កីឡាករដែលមានចំនួនតិចបំផុតដែលបានពិន្ទុទល់នឹងពួកគេនឹងត្រូវបានចាត់ទុកថាជាកីឡាករគប់កូនបាល់ល្អបំផុត។ ប្រសិនបើកីឡាករពីរនាក់ ឬច្រើននាក់ពិន្ទុស្មើគ្នាទាំងវីឃីតនោះច្បាប់ "ដេតហីត (Dead Heat)" ត្រូវបានអនុវត្ត។ ប្រសិនបើគ្មានកីឡាករគប់កូនបាល់ទេនោះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមហាងឆេង 1.00 ។ ការភ្នាល់ដែលដាក់លើកីឡាករណាដែលមិនបានបង្ហាញខ្លួនក្នុងជម្រើស 11 នាក់ដំបូង ឬកីឡាករដែលបង្ហាញខ្លួនជាអ្នកជំនួសនឹងត្រូវចាត់ទុកជាមោឃៈ។ វីកឃីតដែលបានយកស៊ុបពើអូវ័រមិនត្រូវបានរាប់បញ្ចូលទេ។ ប្រសិនបើអ្នកលេងបង្ហាញខ្លួនក្នុងជម្រើស 11 នាក់ដំបូង ហើយត្រូវបានប្តូរចេញជាបន្តបន្ទាប់ កីឡាករទាំងនេះនិងកីឡាករដែលជំនួសពួកគេនឹងត្រូវរាប់បញ្ចូល។ ភ្នាល់លើការប្រកួតដែលមានចំនួនកំណត់អូវ័រ ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើអូវ័រតិចជាង 80% នៃការប្រកួតដែលបានកំណត់ពេលរបស់ក្រុមត្រូវបានលេង ដោយសារកត្តាខាងក្រៅ រួមទាំងអាកាសធាតុមិនល្អ លើកលែងតែករណីដែលលទ្ធផលត្រូវបានបង្កើតឡើងមុនពេលការភ្នាល់ត្រូវបានរំខាន។

10. ការភ្នាល់លើកីឡាករណា ដែលមិនបានចុះបញ្ជីជាអ្នកចាប់ផ្តើមទាំង 11 នាក់ នឹងត្រូវចាត់ទុកជាមោឃៈ។ ការភ្នាល់លើកីឡាករណា ដែលត្រូវបានជ្រើសរើសសម្រាប់ការចាប់ផ្តើម ប៉ុន្តែមិនត្រូវលេងវាយដំបងនោះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
11. "រត់នៅពេលវីឃីតធ្លាក់"។ ការភ្នាល់នឹងត្រូវបានទូទាត់ជាលទ្ធផលឈ្នះ ប្រសិនបើលក្ខខណ្ឌដែលបានបញ្ជាក់ត្រូវបានទាយ៖ ទទួលយកការភ្នាល់និងវីឃីតរត់សរុប។ ប្រសិនបើវីឃីតមិនត្រូវបានគេយកទេ ហើយចំនួនសរុបបានលើសពីចំនួនអប្បបរមាដែលបានបញ្ជាក់ នោះការភ្នាល់ត្រូវចាត់ទុកជាការចាញ់។ ប្រសិនបើវីឃីតមិនត្រូវបានគេយកទេ ហើយចំនួនរត់សរុបបានលើសពីចំនួនអតិបរមាដែលបានបញ្ជាក់ នោះការភ្នាល់នឹងត្រូវបានសងប្រាក់វិញ។
12. ការប្រកួតដណ្តើមយក 10 ពិន្ទុមុន។ ការភ្នាល់នៅតែមានសុពលភាព បើទោះបីជាកីឡាករដែលបានចុះបញ្ជីមិនបានកាន់ដំបងវាយកូនបាល់មុនគេក៏ដោយ ក្នុងករណីនេះការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ។ ការភ្នាល់មានសុពលភាព ដោយមិនគិតថាតើកីឡាករណាដែលបានចុះបញ្ជីកាន់ដំបងវាយកូនបាល់មុនដំបូងឡើយ។ ប្រសិនបើគ្មានកីឡាករណាម្នាក់រត់បាន 10 ពិន្ទុទេ ការភ្នាល់លើលទ្ធផល "គ្មានទាំងពីរ" នឹងឈ្នះ។ នៅក្នុងការប្រកួតដែលរងផលប៉ះពាល់ដោយសារអាកាសធាតុ ប្រសិនបើមិនមានកីឡាករកាន់ដំបងវាយកូនបាល់ណាមួយ អាចរកបាន 10 ពិន្ទុមុនទេហើយពួកគេទាំងពីរបានចាញ់ នោះការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ។ ប្រសិនបើគ្មានកីឡាករកាន់ដំបងវាយកូនបាល់ណាមួយរកបាន 10 ពិន្ទុទេ ហើយកីឡាករទាំងពីរត្រូវបានចាញ់ នោះការភ្នាល់លើលទ្ធផល "គ្មានទាំងពីរ" នឹងឈ្នះ។
13. "() តូតាល់ឯកត្តជនរត់ដំបូង () អូវ័រ/អាន់ឌ័រ ()"។
    ការពិន័យដែលត្រូវបានផ្តល់ជូនបន្ទាប់ពីជុំបានបញ្ចប់ មិនត្រូវបានរាប់បញ្ចូលទៅក្នុងចំនួនពិន្ទុនៅក្នុងជុំទាំងនោះឡើយ។
    ប្រសិនបើចំនួនភ្នាល់អូវ័រដែលបានជ្រើសរើស មិនត្រូវបានលេងដោយសារតែកត្តាខាងក្រៅ ឬលក្ខខណ្ឌអាកាសធាតុមិនអំណោយផល ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែក្នុងករណីដែលលទ្ធផលត្រូវបានកំណត់រួចហើយ។

ប្រសិនបើចំនួនភ្នាល់អូវ័រដែលបានជ្រើសរើស មិនត្រូវបានលេងក្នុងអឺនីង (ឧ. ដោយសារតែក្រុមទាំងមូលត្រូវបានគបបាល់ចេញ ឬឈានដល់ចំនួននៃការរត់ដែលត្រូវការ មុនពេលចំនួនអូវ័រដែលបានជ្រើសរើសត្រូវបានលេង) នោះការភ្នាល់នៅតែមានសុពលភាព។

ការរត់បន្ថែមត្រូវបានរួមបញ្ចូលនៅពេលទូទាត់ភ្នាល់ ដោយមិនគិតពីហេតុផលដែលពួកគេត្រូវបានទទួលអ្វីនោះទេ។

នៅក្នុងការប្រកួតសាកល្បង ចំនួនសរុបអូវ័រដែលបានបញ្ជាក់ត្រូវតែលេងពេញសម្រាប់ការភ្នាល់ដើម្បីនៅបន្ត លើកលែងតែករណីដែលក្រុមទាំងមូលត្រូវបានគប់បាល់ចេញ ឬឈានដល់ចំនួននៃការរត់ដែលត្រូវការក្នុងរយៈពេលតិចជាងការបញ្ជាក់។

14. ការរត់សរុបជាក្រុម (ការរត់សរុបជាបុគ្គល)។ ការពិន័យដែលត្រូវបានផ្តល់ជូនបន្ទាប់ពីជុំបានបញ្ចប់ មិនត្រូវបានរាប់បញ្ចូលទៅក្នុងចំនួនពិន្ទុនៅក្នុងជុំទាំងនោះឡើយ។ ការភ្នាល់នៅលើទីផ្សារនេះ ត្រូវបានទូទាត់ដោយផ្អែកទៅលើពិន្ទុចុងក្រោយរបស់ក្រុមកាន់ដំបងវាយកូនបាល់។ ប្រសិនបើលទ្ធផលស្មើ ហើយការភ្នាល់បន្ថែមត្រូវបានលេង (ស៊ុបពើអូវ័រ ឬបាល់មាស) ការភ្នាល់លើលទ្ធផលនៃការប្រកួតនោះត្រូវបានទូទាត់ដោយផ្អែកទៅលើចំនួននៃការរត់រកពិន្ទុក្នុងពេលធម្មតា។ ការភ្នាល់លើការប្រកួតដែលមានចំនួនកំណត់លើសត្រូវបានលុបចោល ប្រសិនបើតិចជាង 80% នៃការប្រកួតដែលបានគ្រោងទុករបស់ក្រុម ត្រូវបានលេងដោយសារកត្តាខាងក្រៅ រួមទាំងអាកាសធាតុមិនអំណោយផល លើកលែងតែក្នុងករណីដែលលទ្ធផលត្រូវបានសម្រេចឡើងមុនពេលការប្រកួតត្រូវបានអាក់ខាន។ ការភ្នាល់លើការប្រកួតសាកល្បងត្រូវបានលុបចោលក្នុងករណីមានលទ្ធផលស្មើ ផ្តល់ការភ្នាល់តិចជាង 60 ដង លើកលែងតែករណីដែលការភ្នាល់ត្រូវបានទូទាត់រួចហើយ។
15. ពិន្ទុឯកត្តជនខ្ពស់បំផុត (ពិន្ទុរបស់កីឡាករ); ពិន្ទុសរុបរបស់កីឡាករ; ចំនួនពិន្ទុរបស់កីឡាករ។ នៅក្នុងការប្រកួតសាកល្បង Test Match ការភ្នាល់បែបនេះត្រូវបានទូទាត់ដោយផ្អែកលើចំនួនពិន្ទុខ្ពស់បំផុតនៃតង់នោះ។ ពិន្ទុរកបានពីតង់ទាំងពីរ មិនត្រូវបានបូកបញ្ចូលជាមួយគ្នាទេ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។
16. ជុំ, ការគប់បញ្ជូនកូនបាល់, ពិន្ទុសរុបរបស់ក្រុម 1/2 ។ សម្រាប់គោលបំណងទូទាត់ការភ្នាល់ ការគប់បញ្ជូនកូនបាល់ដែលត្រូវបានគប់កូនបាល់ជាថ្មីឡើងវិញ – និងពិន្ទុបន្ថែមណាមួយសម្រាប់ពួកគេត្រូវបានគេរាប់បញ្ចូល។ ឧទាហរណ៍ ប្រសិនបើជុំចាប់ផ្តើមដោយ៖ បាល់ឆ្ងាយ/ខ្ពស់វាយមិនបាន – គ្រាប់បាល់ខូច – ការវាយបានបួនពិន្ទុ, ដូចនេះ "ការវាយបានបួនពិន្ទុ" ត្រូវបានគេចាត់ទុកថាជាការគប់បញ្ជូនកូនបាល់ទីបីនៅក្នុងជុំនោះ។
17. ទីផ្សារមួយចំនួនអាចត្រូវបានទូទាត់ លុះត្រាតែបន្ទាប់ពីស្ថិតិទាំងអស់ត្រូវបានផ្សព្វផ្សាយដោយប្រភពផ្លូវការ ដែលអាចចំណាយពេលពី 10–12 ម៉ោង។
18. "កំពូលកីឡាករកាន់ដំបងវាយកូនបាល់"។ ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់ពីរឬច្រើននាក់ទទួលបានពិន្ទុស្មើគ្នា នោះការភ្នាល់លើកីឡាករបែបនេះនឹងត្រូវទូទាត់តាមហាងឆេង 1 ។

ប្រសិនបើកីឡាករត្រូវបានចុះបញ្ជីជាអ្នកចាប់ផ្តើមទាំង 11 នាក់ ប៉ុន្តែមិនបានចូលក្នុងទីលានលេងទេ នោះការភ្នាល់ "កំពូលកីឡាករកាន់ដំបងវាយកូនបាល់" នឹងត្រូវចាញ់។
19. កីឡាករកាន់ដំបងវាយកូនបាល់ដ៏ល្អបំផុតក្នុងការប្រកួត៖

កីឡាករកាន់ដំបងវាយកូនបាល់ដ៏ល្អបំផុតក្នុងការប្រកួត គឺជាកីឡាករដែលរកពិន្ទុបានច្រើនជាងគេ។ ពិន្ទុដែលរកបានក្នុងស៊ុបភើអូវ័រ មិនត្រូវបានរាប់បញ្ចូលទេ។ ប្រសិនបើកីឡាករពីរនាក់ ឬច្រើននាក់បានពិន្ទុដូចគ្នា នោះច្បាប់លទ្ធផលស្មើគ្នា Dead Heat ត្រូវបានអនុវត្ត។

ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់ដកខ្លួនចេញដោយសារតែមានរបួសប៉ុន្តែបន្ទាប់មកវិលត្រឡប់មកទីលានវិញ នោះចំនួនពិន្ទុសរុបដោយកីឡាករកាន់ដំបងវាយកូនបាល់រូបនេះមានឱកាសត្រូវបានរាប់បញ្ចូល។ ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់មិនវិលត្រលប់មកទីលានវិញទេ នោះពិន្ទុសរុបរបស់ពួកគេនឹងជាចំនួននៃពិន្ទុដែលពួកគេរកបាន មុនពេលកីឡាករដកខ្លួនចេញពីការប្រកួត។

ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់មិនបង្ហាញខ្លួនក្នុងជម្រើស ១១នាក់ដំបូងនោះទេ ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ។ ការភ្នាល់លើកីឡាករកាន់ដំបងវាយកូនបាល់ដែលបង្ហាញខ្លួនក្នុងក្រុម ប៉ុន្តែមិនវាយកូនបាល់ នឹងលទ្ធផលត្រូវទូទាត់ជាការចាញ់។

នៅក្នុងការប្រកួតដែលមានចំនួនកំណត់នៃការភ្នាល់ច្រើន ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើចំនួនភ្នាល់ដែលបានបញ្ជាក់តិចជាង 50% ត្រូវបានលេងដោយក្រុមទាំងសងខាង ដោយសារកត្តាពីខាងក្រៅ ដូចជាអាកាសធាតុមិនអំណោយផលល្អ លើកលែងតែករណីដែលការភ្នាល់ត្រូវបានទូទាត់រួចហើយ។

20. ទីផ្សារទាំងនេះប្រើប្រព័ន្ធដាក់ពិន្ទុដែលផ្អែកលើពិន្ទុ ដើម្បីកំណត់លទ្ធផលរបស់ពួកគេ។ តារាងពិន្ទុមានដូចខាងក្រោម៖ 1 ពិន្ទុក្នុងការរត់មួយ 20 ពិន្ទុក្នុងវីឃីតមួយ 10 ពិន្ទុក្នុងការចាប់មួយ 25 ពិន្ទុក្នុងការចំបង្គោលឈើមួយ។
    - ទឹកប្រាក់ភ្នាល់នឹងបង្វិលសងវិញ លើកីឡាករដែលមិនបានជ្រើសរើស។ ប្រសិនបើកីឡាករមិនត្រូវបានដាក់ឱ្យចូលលេងនៅក្នុងជម្រើសដំបូងទេ តែត្រូវបានដាក់ឱ្យចូលលេងក្នុងការប្រកួតនោះក្នុងនាមជាកីឡាករប្តូរចូល នោះលទ្ធផលរបស់ពួកគេនឹងត្រូវធ្វើការគណនាផ្អែកលើចំនួនពិន្ទុដែលពួកគេរកបាន ដោយមិនគិតពីពេលវេលាដែលពួកគេបានចូលលេងក្នុងការប្រកួតនោះទេ។
    - នៅក្នុងការប្រកួត One Day ក្រុមទាំងពីរត្រូវប្រឈមមុខគ្នាយ៉ាងតិច 40 ដង ក្នុងមួយប្រកួត បើមិនដូច្នេះទេការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែការទូទាត់ការភ្នាល់ត្រូវបានកំណត់រួចហើយ។
    - នៅក្នុងការប្រកួតសាកល្បងនិងថ្នាក់ទីមួយ ការប្រកួតទាំងមូលត្រូវបានរាប់។ នៅក្នុងការប្រកួតដែលស្មើគ្នា យ៉ាងតិចចំនួន 200 អូវ័រ ត្រូវឱ្យបាន បើមិនដូច្នេះទេការភ្នាល់នឹងត្រូវទុកជាមោឃៈ លុះត្រាតែការទូទាត់នៃការភ្នាល់ត្រូវបានកំណត់រួចហើយ។ នៅក្នុងការប្រកួត Twenty20 ការប្រកួតត្រូវតែកំណត់ពេលពេញ 20 អូវ័រ ហើយត្រូវតែមានលទ្ធផលជាផ្លូវការ លើកលែងតែការទូទាត់ការភ្នាល់ ត្រូវបានកំណត់រួចហើយ។
21. ប្រសិនបើកីឡាករណាម្នាក់ត្រូវបានប្តូរចេញ ហើយពុំត្រឡប់ចូលលេងវិញទេ នោះលទ្ធផលចុងក្រោយរបស់ពួកគេ នឹងត្រូវកំណត់ផ្អែកលើលទ្ធផលរបស់ពួកគេគិតត្រឹមពេលដែលពួកគេត្រូវបានប្តូរចេញ។ ដូចគ្នានេះដែរ កីឡាករណាម្នាក់ដែលបានចូលលេងក្នុងការប្រកួតក្នុងនាមជាកីឡាករប្តូរចូល ក៏នឹងត្រូវធ្វើការគណនាលទ្ធផលរបស់ពួកគេផ្អែកលើពិន្ទុដែលពួកគេរកបានផងដែរ។
22. វីឃីតសរុបដែលបានបាត់ក្នុង X ពិន្ទុ។ ការភ្នាល់ត្រូវបានទូទាត់ផ្អែកលើចំនួនវីឃីតដែលបានបាត់

នៅពេលរកបានចំនួនពិន្ទុដូចបានកំណត់។ វីឃីតដែលបានបាត់បន្ទាប់ពីរកបានចំនួនពិន្ទុដែលចាំបាច់
មិនត្រូវបានរាប់បញ្ចូលនោះទេ។
ឧទាហរណ៍៖ ក្រុម 2, វីឃីតសរុបដែលបានបាត់ក្នុង 50 ពិន្ទុ — អាន់ឌ័រ 1.5។ ប្រសិនបើក្រុមរកបាន 50 ពិន្ទុ
ហើយបាត់វីឃីតអស់ 1 នៅក្នុងជុំទី19 ហើយរកបាន 50 ពិន្ទុ និងបាត់វីឃីតអស់ 2 ក្នុងជុំទី20 នោះការភ្នាល់
នឹងត្រូវចាត់ទុកថាឈ្នះ ដោយសារពិន្ទុ 50 ដែលរកបាននោះ បាត់អស់វីឃីតតែ 1 ប៉ុណ្ណោះ។
ប្រសិនបើចំនួនវីឃីតដែលបានបញ្ជាក់នៅក្នុងការភ្នាល់បានបាត់នៅមុនពេលដែលក្រុមរកបានចំនួនពិន្ទុ
ដែលត្រូវការចាំបាច់ នោះការភ្នាល់នឹងត្រូវទូទាត់សងផ្អែកតាមចំនួនវីឃីតបច្ចុប្បន្ន។
ឧទាហរណ៍៖ ក្រុម 2, វីឃីតសរុបដែលបានបាត់ក្នុង 50 ពិន្ទុ — អាន់ឌ័រ 1.5។ នៅពេលដែលរកបាន 40 ពិន្ទុ
ប្រសិនបើក្រុមបានបាត់វីឃីតអស់ 2 នោះការភ្នាល់នឹងត្រូវចាត់ទុកថាចាញ់។
នៅក្នុងការប្រកួតសាកល្បង ប្រសិនបើក្រុមមួយប្រកាស ឬការប្រកួតបញ្ចប់ដោយស្មើគ្នា ឬ
ប្រសិនបើបានសម្រេចគោលដៅហើយ នោះចំនួនពិន្ទុនិងវីឃីតបច្ចុប្បន្ន នឹងត្រូវចាត់ទុកជាលទ្ធផលចុង
ក្រោយ ហើយនឹងត្រូវប្រើដើម្បីទូទាត់សងការភ្នាល់។

23. ការនាំមុខក្នុងតង់ដំបូងៗ / គ្រាប់ត។ ការភ្នាល់លើទីផ្សារនេះ ពាក់ព័ន្ធនឹងការកំណត់ភាពខុសគ្នារវាងពិន្ទុ
ដែលក្រុមពីររកបាននៅក្នុងតង់ដំបូងៗរបស់ពួកគេនៅក្នុងការប្រកួតសាកល្បង។
ប្រសិនបើការប្រកួតមួយបញ្ចប់ទៅក្នុងលទ្ធផលស្មើគ្នា ហើយក្រុមនីមួយៗលេងបានតិចជាង 200 ជុំ នោះ
ការភ្នាល់នឹងត្រូវទូទាត់សងនៅហាងឆេង1.00។ចំណុចនេះពុំរាប់បញ្ចូលករណីដែលលទ្ធផលនៃការភ្នាល់
ត្រូវបានកំណត់នៅចុងបញ្ចប់នៃតង់ដំបូងៗឡើយ។ ប្រសិនបើមានការប្រកាសនៅក្នុងតង់ដំបូងៗ
ការភ្នាល់នឹងត្រូវទូទាត់សងយោងទៅតាមលទ្ធផលនៅពេលដែលមានការប្រកាសនោះ។
24. បាល់ដំបូង។ ការភ្នាល់លើលទ្ធផលនៃការបញ្ជូនដំបូងដោយក្រុមមួយ/ក្នុងការប្រកួតមួយ។ ប្រសិនបើការ
បញ្ជូនដំបូងគឺជាការវាយសេរី នោះលទ្ធផលទាំងអស់នៃការវាយសេរីនឹងត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ។
រាល់ការបញ្ជូនដែលមានលទ្ធផលបន្ថែមនឹងត្រូវយកមកគិតនៅពេលទូទាត់ការភ្នាល់។ ប្រសិនបើការ
បញ្ជូនមានលទ្ធផលបន្ថែម ក៏ដូចជាលទ្ធផលផ្សេងទៀត នោះការបន្ថែមនឹងមានអាទិភាពនៅពេលទូទាត់
ការភ្នាល់ លើកលែងតែមានការបញ្ជាក់ផ្សេងទៀត។ សម្រាប់ការបញ្ជូនដែលនាំឱ្យមានការបន្ថែម ឬពិបាក
ដោះស្រាយ នោះការរត់បន្ថែមណាមួយនឹងមិនត្រូវបានយកមកគិតទេ លើកលែងតែមានការបញ្ជាក់ផ្សេង
ពីនេះប៉ុណ្ណោះ។
25. "អ្នកណានឹងធ្វើការរត់-អារីយ៉ាងច្រើន?", "ក្រុម, ចំនួនសរុបរត់-អារី។" ការគណនាត្រូវបានធ្វើនៅលើចំនួន
រត់-អារីដែលក្រុមប៉ះបានធ្វើក្នុងការប្រកួតរបស់ពួកគេ, ដោយយោងទៅលើស្ថិតិផ្លូវការរបស់ការប្រកួត។

Chennai daily cricket ហ្គោលលីគ គឺជាលីគក្នុងតំបន់ ដែលត្រូវបានលេងស្របតាមច្បាប់កីឡាគ្រីឃីត
នៅក្នុងសាល។ ក្រុមត្រូវតែលេងឲ្យគ្រប់ទៅតាមកាលវិភាគដែលបានកំណត់ ឬរហូតដល់បង្គោលវីឃីតដួល 5
ដង។

1. ច្បាប់ដាក់ពិន្ទុ៖
    - ប្រសិនបើកូនបែល ត្រូវបានធ្លាក់ចេញពីបង្គោលវីឃីត ដោយសារកីឡាករគប់កូនបាល់ដោយផ្ទាល់

នោះកីឡាករកាន់ដំបងវាយកូនបាល់នឹងត្រូវចាញ់

- ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់ មិនបានវាយត្រូវចំកូនបាល់បន្ទាប់ពីកូនបាល់ត្រូវបានគប់ទៅ ហើយអ្នកចាំទីវីឃីតចាប់កូនបាល់នោះបាន (ចាប់មិនបាន) នោះកីឡាករកាន់ដំបងវាយកូនបាល់នឹងទទួលបាន 0 ពិន្ទុ។
- ប្រសិនបើកីឡាករកាន់ដំបងបានវាយត្រូវចំកូនបាល់ ហើយអ្នកចាំកូនបាល់ឬអ្នកចាំទីវីឃីតចាប់កូនបាល់បានដោយកូនបាល់មិនប៉ះនឹងដី នោះកីឡាករកាន់ដំបងវាយកូនបាល់នឹងត្រូវចាញ់
- ប្រសិនបើកីឡាករកាន់ដំបងបានវាយត្រូវចំកូនបាល់ហើយបាល់ប៉ះនឹងដី ក្នុងករណីនេះបើកីឡាករកាន់ដំបងវាយកូនបាល់ឬខ្សែប្រយុទ្ធ មិនបានទៅដល់ព្រំដែន (ទឹកដី) វៀងខ្លួនទេ នោះក្រុមកីឡាករកាន់ដំបងវាយកូនបាល់នឹងត្រូវចាញ់ ប្រសិនបើក្រុមដែលចាប់កូនបាល់ប្រើកូនបាល់នោះផ្តួលកូនបៃលចេញពីវីឃីត
- នៅពេលដែលកីឡាករកាន់ដំបងបានវាយត្រូវចំកូនបាល់ ហើយកូនបាល់នោះចូលទៅក្នុងតំបន់ជាក់លាក់ណាមួយ ពួកគេនឹងទទួលបានពិន្ទុដូចខាងក្រោះ
  - A – 0 ពិន្ទុ
  - B,C (រហូតដល់ពាក់កណ្តាលទីលាន) – 1 ពិន្ទុ
  - B,C (ឆ្លងកាត់ពាក់កណ្តាលទីលានរហូតដល់តំបន់ D) – 2 ពិន្ទុ
  - D (ដោយមិនប៉ះនឹងដី) – 6 ពិន្ទុ, ឬកូនបាល់ប៉ះនឹងដី – 4 ពិន្ទុ។

2. ប្រសិនបើកូនបាល់ធ្លាក់នៅក្នុងតំបន់ B,C ដោយឆ្លងកាត់ពាក់កណ្តាលទីលាន (2 ពិន្ទុ) ហើយបន្ទាប់មកបន្តទៅធ្លាក់នៅក្នុងតំបន់ D (1 ពិន្ទុទៀត) ក្រុមនោះទទួលបានពិន្ទុសរុប 3 ពិន្ទុ។ ប្រសិនបើកូនបាល់ធ្លាក់នៅក្នុងតំបន់ B,C រហូតដល់ពាក់កណ្តាលទីលាន (1 ពិន្ទុ) ហើយបន្ទាប់មកបន្តទៅធ្លាក់នៅក្នុងតំបន់ B,C ដោយឆ្លងកាត់ពាក់កណ្តាលទីលាន នោះនឹងត្រូវបានផ្តល់ជូនជាពិន្ទុសរុប 2 ពិន្ទុ។
3. ចំពោះករណីកូនបាល់ស្អុយ (នៅពេលដែលកូនបាល់ត្រូវបានបោះ និងរាប់បញ្ចូលទាំងខ្សែកណ្តាល) នឹងត្រូវផ្តល់ជូន 0 ពិន្ទុ ហើយកូនបាល់នោះត្រូវគប់ម្តងទៀត។ ប្រសិនបើកូនបាល់បន្ទាប់ក៏ជាគ្រាប់កូនបាល់ស្អុយដែរ នោះកីឡាករកាន់ដំបងវាយកូនបាល់ត្រូវទទួលបាន 5 ពិន្ទុ។
4. ចំពោះករណីការរំខានផ្នែករាងកាយលើកីឡាករកាន់ដំបងវាយកូនបាល់ នោះកីឡាករកាន់ដំបងវាយកូនបាល់នឹងត្រូវទទួលបាន 5 ពិន្ទុ។
5. ចំពោះករណីកូនបាល់ល្អ (នៅពេលដែលកូនបាល់ត្រូវបានគេគប់នៅលើទីលានវាយកូនបាល់ ដោយមិនប៉ះជាមួយនឹងកីឡាករកាន់ដំបងវាយកូនបាល់) នឹងត្រូវបានផ្តល់ជូន 0 ពិន្ទុ។
6. ចំពោះករណីកូនបាល់ឆ្ងាយ/ខ្ពស់វាយមិនបាន (នៅពេលដែលកូនបាល់ត្រូវបានគប់នៅខាងក្រៅទីលានវាយកូនបាល់ ឬឆ្លងកាត់ព្រំដែននៃដំបងវាយកូនបាល់) កីឡាករកាន់ដំបងវាយកូនបាល់នឹងទទួលបាន 2 ពិន្ទុ។
7. ចំពោះកូនបាល់ប៉ះត្រូវខ្លួន(នៅពេលដែលកូនបាល់ប៉ះត្រូវរាងកាយរបស់កីឡាករកាន់ដំបងវាយកូនបាល់) នឹងត្រូវបានផ្តល់ជូន 0 ពិន្ទុនឹហើយហ្គេមនោះនៅតែបន្ត។ ប្រសិនបើកីឡាករកាន់ដំបងវាយកូនបាល់និងកីឡាករមិនមែនខ្សែប្រយុទ្ធបានផ្លាស់ប្តូរទីកន្លែងនឹងត្រូវបានផ្តល់ជូន 1 ពិន្ទុ។
8. ចំពោះករណីគ្រាប់កូនបាល់ខូច (នៅពេលកីឡាករគប់កូនបាល់ ជាន់ហួសខ្សែបន្ទាប់គប់កូនបាល់ នោះ

កូនបាល់ត្រូវបានគេគប់រំលងពីលើបង្គោលវីយឺតដោយត្រង់មិនប៉ះដី កូនបាល់ត្រូវបានគេគប់និងលោតពីដីដល់កម្ពស់ស្មា និងកូនបាល់ត្រូវបានគេគប់ចេញពីទីលាន) នោះកីឡាករកាន់ដំបងវាយកូនបាល់នឹងទទួលបាន 2 ពិន្ទុ។

គ្រីឃីត 24. សាយប័រលីគ សាយប័រលីគឥណ្ឌា 24

1. ច្បាប់នៃហ្គេមនេះគឺដូចគ្នាបេះបិទទៅនឹងកីឡាគ្រីឃីត៖ ក្រុមនីមួយៗលេងក្នុងមួយអ៊ីនីងនៃ 20 អូវ័រ។
2. ច្បាប់ការទូទាត់សងការភ្នាល់៖
    - ការភ្នាល់ "អ្នកឈ្នះការប្រកួត" ត្រូវបានទូទាត់ដោយគិតគូរពីលទ្ធផលនៃការប្រកួតស៊ុបពើអូវ័រ។
    - ការភ្នាល់ "អូវ័រ ពិន្ទុសរុបក្រុម" ត្រូវបានទូទាត់ដោយផ្អែកលើចំនួននៃពិន្ទុដែលបានរកបានដោយក្រុម រួមទាំងការបន្ថែម។ ក្នុងករណីដែលការប្រកួតអូវ័រក្នុងសំណូរមិនត្រូវបានលេង ការភ្នាល់លើវានឹងត្រូវបានសងប្រាក់វិញ។
    - ការភ្នាល់ "តូតាល់" "តូតាល់ ឯកត្តជន" "ពិន្ទុតូតាល់អូវ័រ" និង "ពិន្ទុតូតាល់ឯកត្តជនក្នុងការប្រកួតលើកដំបូង" ត្រូវបានទូទាត់ដោយផ្អែកលើចំនួននៃការរត់ដែលបានស៊ុតបញ្ចូលទីដោយក្រុម រួមទាំងការបន្ថែម ប៉ុន្តែមិនរាប់បញ្ចូលស៊ុបពើអូវ័រ។
    - ការភ្នាល់ "ពិន្ទុសរុបក្នុងមួយការបញ្ជូន" ត្រូវបានទូទាត់ដោយផ្អែកលើចំនួននៃពិន្ទុដែលបានរកបានដោយក្រុម រួមទាំងការបន្ថែម (ប្រសិនបើការបន្ថែមត្រូវបានបន្ថែមទៅតូតាល់)។ ក្នុងករណីដែលការប្រកួតអូវ័រក្នុងសំណូរមិនត្រូវបានលេង ការភ្នាល់លើវានឹងត្រូវបានសងប្រាក់វិញ។
    - ការភ្នាល់ "តើវីយឺតនឹងដួល អូវ័រដែរឬទេ" ត្រូវបានទូទាត់ដោយផ្អែកលើលទ្ធផលនៃការភ្នាល់អូវ័រក្នុងសំណូរ។ ប្រសិនបើដែលការប្រកួតអូវ័រក្នុងសំណូរមិនត្រូវបានលេង ការភ្នាល់លើវានឹងត្រូវបានសងប្រាក់វិញ។
    - ការភ្នាល់ "ភាពជាដៃគូបើកចំហខ្ពស់បំផុត" ត្រូវបានទូទាត់ដោយផ្អែកលើចំនួននៃពិន្ទុដែលរកបានដោយភាពជាដៃគូបើកក្រុមនីមួយៗ។
    - ការភ្នាល់ "បាល់ទីមួយ នឹងក្លាយជាដុតបិលមួយ ដែលគ្មានពិន្ទុ" ការភ្នាល់ត្រូវបានទូទាត់លើលទ្ធផលនៃការប្រកួតដំបូង ដោយមិនគិតពីក្រុមណា និងរួមបញ្ចូលការភ្នាល់បន្ថែម។
    - "ពិន្ទុតូតាល់មុនពេលវីយឺតដួល" និង "ពិន្ទុសរុបនៅពេលវីយឺតដួល" ការភ្នាល់ត្រូវបានទូទាត់តាមវិធីខាងក្រោម៖
        - B ការភ្នាល់ទាំងនេះឈ្នះ ប្រសិនបើអថេរទាំងពីរ (វីយឺតដួល និងតូតាល់) ត្រូវបានទស្សន៍ទាយត្រឹមត្រូវ
        - ការភ្នាល់បែបនេះត្រូវបានបង្វិលសងប្រាក់វិញក្នុងហាងឆេង 1.00 ប្រសិនបើចំនួនសរុបត្រូវបានទស្សន៍ទាយត្រឹមត្រូវ ប៉ុន្តែមិនមានការភ្នាល់វីយឺតណាមួយដួលឡើយ។
        - ការភ្នាល់បែបនេះចាញ់នៅក្នុងករណីផ្សេងទៀតទាំងអស់
    - ការភ្នាល់ "ស៊ុបភើអូវ័" ត្រូវបានទូទាត់ជាការឈ្នះ ប្រសិនបើការប្រកួតស៊ុបភើអូវ័ត្រូវបានលេង។ បើមិនដូច្នោះទេការភ្នាល់ទាំងនេះនឹងត្រូវចាត់ទុកថាចាញ់។

- ការភ្នាល់ "លទ្ធផលបន្ទាប់ពីលើកទីមួយអូវ័រ" ត្រូវបានទូទាត់ដោយផ្អែកលើចំនួននៃពិន្ទុដែលទទួលបានដោយក្រុមនីមួយៗ រហូតដល់ការភ្នាល់ដែលបានបញ្ឈប់។
- ការភ្នាល់ "ពិន្ទុតូតាល់ខ្ពស់បំផុតក្នុងមួយប្រកួត" ត្រូវបានទូទាត់ដោយផ្អែកលើចំនួនពិន្ទុខ្ពស់បំផុតដែលរកបានដោយក្រុមក្នុងមួយលើក រួមទាំងពិន្ទុបន្ថែម។
- ការភ្នាល់ "តើនរណានឹងបាត់រីឃីតអស់ច្រើនជាង" "រីឃីតសរុប" និង "តូតាល់ក្រុមចាញ់រីឃីត" ត្រូវបានទូទាត់ដោយផ្អែកលើចំនួន រីឃីត ដោយមិនរាប់បញ្ចូលស៊ុបពើអូវ័រនោះទេ។
- ការភ្នាល់ "ស៊ុបពើអូវ័ឈ្នះ" ត្រូវបានទូទាត់ជាការឈ្នះ ប្រសិនបើការប្រកួតស៊ុបពើអូវ័ត្រូវបានលេង ហើយក្រុមណាមួយឈ្នះ។
- "តើពិន្ទុបន្ថែមនឹងត្រូវបានផ្តល់រង្វាន់នៅពេលអូវ័រឬទេ" ការភ្នាល់សំដៅទៅលើពិន្ទុបន្ថែមដែលបានបន្ថែមទៅក្នុងពិន្ទុរបស់ក្រុមវាយកូនបាល់ ដោយសារតែការបញ្ជូនបាល់ខុសច្បាប់ដោយអ្នកគប់បាល់។
  បន្ទាប់ពីទទួលបានពិន្ទុបន្ថែម ការផ្តល់បន្ថែមមួយនឹងត្រូវបានផ្តល់ជាគប់បាល់ ប្រសិនបើក្រុមនៅតែរត់រកពិន្ទុ។

10.18. បាល់គប់នៅលើខ្សាច់

1. រាល់ការភ្នាល់ទាំងអស់នឹងត្រូវទូទាត់ដោយផ្អែកលើលទ្ធផល នៅពេលចប់ម៉ោងធម្មតា (ការលេង 20 នាទី ដែលមានពីរតង់ដោយមួយតង់ៗមាន 10 នាទី)។
2. ការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់សម្រាប់ការភ្នាល់លើ "ឈ្នះនៅក្នុងការប្រកួត", "ដើម្បីជាប់ជម្រុះ ទៅជុំបន្ទាប់" "ឈ្នះនៅក្នុងធូណាមិន" និងទីផ្សារស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតមួយត្រូវបានអាក់ខាននិងពន្យាពេល នោះរាល់ប្រាក់ភ្នាល់ទាំងអស់នឹងមានសុពលភាព រហូតដល់ការប្រកួតត្រូវបានចាប់ផ្តើម អ្នកចូលរួមណាមួយដកខ្លួនចេញ ឬធូណាមិនដែលលក្ខណៈពិសេសនៃការប្រកួតត្រូវបានបញ្ចប់។
4. ការប្រកួតនឹងត្រូវបានប្រកាសបញ្ចប់ សម្រាប់គោលបំណងការភ្នាល់ ប្រសិនបើការលេងយ៉ាងហោចណាស់ 18 នាទី បានកន្លងផុតទៅ។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផលនៅពេលការប្រកួតត្រូវបានបញ្ឈប់។
5. ប្រសិនបើនៅចុងបញ្ចប់នៃតង់មួយ ពិន្ទុគឺស្មើគ្នា លក្ខខណ្ឌ គ្រាប់បាល់មាស នឹងត្រូវបានប្រើ ដើម្បីកំណត់អ្នកឈ្នះ ឧទាហរណ៍ ក្រុមដែលរកបានគ្រាប់បាល់ដំបូងនឹងត្រូវប្រកាសថាជាអ្នកឈ្នះ។ ប្រសិនបើតង់ទាំងពីរត្រូវបានឈ្នះដោយក្រុមតែមួយ នោះក្រុមនេះនឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ ជាមួយនឹងពិន្ទុ 2:0 ។
6. ប្រសិនបើក្រុមទាំងពីរឈ្នះមួយតង់ម្នាក់ នោះនឹងមានលទ្ធផលស្មើគ្នា។ បន្ទាប់មកការប្រកួតត្រូវបានសម្រេចដោយ "ការស៊ុតកាត់សេចក្តី" ដែលកីឡាករនៅទីវាលនឹងប៉ះនឹងគូប្រកួតអ្នកចាំទី។

10.19. បាល់ទាត់នៅលើខ្សាច់

1. រាល់ការភ្នាល់ទាំងអស់នឹងត្រូវទូទាត់ដោយផ្អែកលើលទ្ធផល នៅពេលចប់ម៉ោងធម្មតា (ការលេង 36 នាទី ដែលមានបីតង់ដោយមួយតង់ៗមាន 12 នាទី)។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួតឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "ផ្សាយផ្ទាល់" ឬ "កីឡា" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. រយៈពេលបន្ថែមនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់សម្រាប់ការភ្នាល់លើ "ឈ្នះ" "ដើម្បីជាប់ជម្រុះ ទៅជុំបន្ទាប់" "ឈ្នះនៅក្នុងធូណាមិន" និងទីផ្សារស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានបញ្ឈប់។
4. ការប្រកួតត្រូវតែលេងយ៉ាងហោចណាស់ឱ្យបាន 30 នាទី ដើម្បីឱ្យការភ្នាល់មានសុពលភាព។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផល នៅពេលការប្រកួតត្រូវបានបញ្ឈប់។

10.20. បាល់ឱប

1. ការភ្នាល់ទាំងអស់ត្រូវបានទូទាត់ដោយផ្អែកលើលទ្ធផលនៃការប្រកួតនៅចុងបញ្ចប់នៃម៉ោងធម្មតា។ សម្រាប់ការភ្នាល់បន្ត យ៉ាងហោចណាស់ 90% នៃការប្រកួតត្រូវតែត្រូវបានលេង លុះត្រាតែការភ្នាល់ត្រូវបានទូទាត់រួចនៅពេលការប្រកួតត្រូវបោះបង់ចោល។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួតឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "ផ្សាយផ្ទាល់" ឬ "កីឡា" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់សម្រាប់ការភ្នាល់លើទីផ្សារ "ដើម្បីជាប់ជម្រុះ ទៅជុំបន្ទាប់" និង "ឈ្នះនៅក្នុងធូណាមិន"។

10.21. ការប្រណាំងសេះ

1. ប្រសិនបើការប្រណាំងត្រូវបានពន្យារពេលទៅថ្ងៃផ្សេងទៀត ហើយវាត្រូវបានបញ្ជាក់នៅក្នុងប្រភពផ្លូវការនោះរាល់ការភ្នាល់ទាំងអស់នឹងមានសុពលភាព។ ទោះយ៉ាងណា ការភ្នាល់ទោលនឹងត្រូវចាត់ទុកជាមោឃៈ ហើយជើងនីមួយៗនឹងត្រូវបានដកពីការភ្នាល់បក ប្រសិនបើ៖
   - ការប្រណាំងត្រូវបានបញ្ឈប់;
   - ការប្រណាំងត្រូវបានប្រកាសជាមោឃៈ;
   - លក្ខខណ្ឌនៃការប្រណាំងត្រូវបានផ្លាស់ប្តូរ បន្ទាប់ពីការភ្នាល់ត្រូវបានធ្វើឡើង (យោងទៅតាមច្បាប់

);

- ផ្លូវប្រណាំងត្រូវបានផ្លាស់ប្តូរ;
- ផ្ទៃផ្លូវត្រូវបានផ្លាស់ប្តូរ (ឧទាហរណ៍ ស្មៅត្រូវបានជំនួសដោយដីឬផ្ទៃសិប្បនិម្មិត ឬផ្ទុយមកវិញ)។

2. ប្រសិនបើការប្រណាំងត្រូវបានលុបចោល នោះរាល់ការភ្នាល់លើការប្រណាំងនឹងត្រូវបានចាត់ទុកជាមោឃៈ។ ប្រសិនបើការប្រណាំងត្រូវបានពន្យារពេលទៅពេលក្រោយនៅថ្ងៃដដែល នោះការភ្នាល់ទាំងអស់នឹងនៅតែមានសុពលភាព។
3. "អ្នកចូលរួមនឹងស្ថិតក្នុងលំដាប់កំពូលទាំង 3"។ ការភ្នាល់នៅលើទីផ្សារនេះនឹងឈ្នះ ប្រសិនបើសេះបញ្ចប់ក្នុងចំណោមអ្នកដែលទទួលបានចំណាត់ថ្នាក់បីលេខដំបូង។
4. "ឈ្នះ (សងប្រាក់វិញ ប្រសិនបើបានដាក់ភ្នាល់)"។ ឧទាហរណ៍ ការភ្នាល់ "ឈ្នះ (សងប្រាក់វិញ ប្រសិនបើបានដាក់ការភ្នាល់ 2)" នឹងឈ្នះប្រសិនបើសេះបញ្ចប់មុនគេ ប៉ុន្តែប្រសិនបើសេះបញ្ចប់ទីពីរ ប្រាក់ភ្នាល់នឹងសងវិញ (ការភ្នាល់នឹងត្រូវទូទាត់តាមហាងឆេង 1)។
5. "ឈ្នះដោយគ្មានអ្នកនាំមុខ"។ ការភ្នាល់ "លេខ 1 Brice Canyon នឹងឈ្នះដោយគ្មានលេខ 3 Clonusker" នឹងឈ្នះ ប្រសិនបើលេខ 3 Clonusker បញ្ចប់ក្នុងការប្រណាំងមុនគេ ហើយលេខ 1 Brice Canyon បញ្ចប់នៅលេខពីរ។
6. ការភ្នាល់មុនបើកទីផ្សារលើការប្រណាំងសេះ។ បញ្ជីឈ្មោះសេះរត់ប្រណាំងដែលត្រូវបានអាប់ដេតនឹងត្រូវប្រកាសមួយថ្ងៃ ឬពីរថ្ងៃមុនការប្រណាំង អាស្រ័យលើថ្នាក់។ ការភ្នាល់មុនបើកទីផ្សារលើការប្រណាំងបិទភ្លាមៗ នៅពេលដែលហាងឆេងត្រូវបានប្រកាសនៅថ្ងៃប្រណាំង។ សេះដែលដកខ្លួនចេញពីការប្រណាំងនៅក្នុងការភ្នាល់មុនបើកទីផ្សារ នឹងមិនបង្ហាញក្នុងបញ្ជីឈ្មោះសេះរត់ប្រណាំងដែលបានអាប់ដេត នោះត្រូវបានចាត់ទុកថាចាញ់។
   ប្រសិនបើការប្រណាំងត្រូវបានកំណត់ឡើងវិញនៅថ្ងៃបន្ទាប់ ដោយសារលក្ខខណ្ឌអាកាសធាតុ ការភ្នាល់មុនបើកទីផ្សារនឹងបើករហូតដល់ការប្រណាំងចាប់ផ្តើម។ ប្រសិនបើការប្រណាំងត្រូវបានលុបចោលទាំងស្រុង ប្រាក់ភ្នាល់មុនបើកទីផ្សារត្រូវបានបង្វិលសងវិញ។ ការភ្នាល់ក្នុងថ្ងៃប្រណាំងលើព្រឹត្តិការណ៍នឹងត្រូវបានទូទាត់ជាមុន បន្ទាប់មកដោយការភ្នាល់មុនបើកទីផ្សារប្រកាស។
   នៅក្នុងព្រឹត្តិការណ៍ដែលត្រូវបានសម្គាល់ថា "គ្មានការប្រណាំង គ្មានការភ្នាល់" (NRNB) ការភ្នាល់មុនបើកទីផ្សារលើសេះ នឹងត្រូវបានទូទាត់នៅហាងឆេង 1.00 ។
7. SP (តម្លៃចាប់ផ្តើម) គឺជាហាងឆេងចាប់ផ្តើមចុងក្រោយនៅលើសេះមួយ។ តម្លៃចាប់ផ្តើមត្រូវបានគណនាដោយផ្អែកលើហាងឆេងជាមធ្យម ដែលផ្តល់ដោយក្រុមហ៊ុនភ្នាល់ក្នុងពេលបិទការប្រណាំង។ ប្រសិនបើសេះត្រូវបានដកចេញ មុនពេលចាប់ផ្តើមប្រណាំង ឬត្រូវបានប្រកាសថាមិនមែនជាសេះប្រណាំង (យោងតាមកំណត់ត្រាផ្លូវការ) ហើយទីផ្សារ SP ថ្មីមិនទាន់ត្រូវបានបង្កើតឡើងទេ នោះការភ្នាល់លើសេះដែលបានដកចេញនោះនឹងត្រូវបានទូទាត់តាមហាងឆេង "1"។

10.22. ស្ព័រស្ស

1. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនត្រូវបានបញ្ចប់ដោយហេតុផលណាមួយ (ឧទាហរណ៍ ប្រសិនបើកីឡាករឈប់ឬត្រូវបានជម្រុះចេញ) លទ្ធផល ដែលត្រូវបានកំណត់ដោយគ្មានលក្ខខណ្ឌរួចហើយ នៅពេលការប្រកួតត្រូវបានអាក់ខាន (ឧទាហរណ៍ លទ្ធផលនៃការប្រកួតលើកដំបូង សរុបហ្គេមលើកដំបូង។ល។) នឹងរាប់បញ្ចូលក្នុងការទូទាត់។ រាល់ការភ្នាល់ផ្សេងទៀតនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
2. ប្រសិនបើការប្រកួតមួយត្រូវបានអាក់ខាន ដោយសារតែការដកចេញ ឬដកសិទ្ធិរបស់ក្រុមណាមួយ ការប្រកួត/សេតដំបូងដាច់ខាតត្រូវតែបានបញ្ចប់ ដើម្បីឱ្យការភ្នាល់លើអ្នកឈ្នះនៃការប្រកួតមានសុពលភាព បើមិនដូច្នេះទេ រាល់ការភ្នាល់លើលទ្ធផលនេះនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ក្នុងករណីមានការដកខ្លួនឬការដកសិទ្ធិកីឡាករ នោះការដកហូតនឹងត្រូវបានប្រកាស។
3. តាមសេចក្តីសម្រេចរបស់ស្ថាប័នដែលរៀបចំព្រឹត្តិការណ៍ ចំនួនហ្គេមក្នុងការប្រកួតអាចប្រែប្រួលពីបីទៅប្រាំ ហើយការប្រកួតនឹងបន្ត រហូតដល់បីប្រកួតបានឈ្នះ។
4. ការប្រកួតនីមួយៗនឹងបន្តរហូតដល់ 11 ពិន្ទុ។ កីឡាដែលទទួលបាន 11 ពិន្ទុដំបូងគេនឹងត្រូវប្រកាសថាជាអ្នកឈ្នះ លើកលែងតែពិន្ទុ 10:10 ។ នៅក្នុងករណីនេះ ហ្គេមនឹងបន្តរហូតដល់ពិន្ទុខុសគ្នាមានដល់ចំនួនពីរពិន្ទុ។ កីឡាករដែលយកឈ្នះគូប្រកួតដោយពីរពិន្ទុ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។

10.23. ស្នុកគ័រ

1. ការភ្នាល់លើការប្រកួត។ ប្រសិនបើការប្រកួតត្រូវបានអាក់ខាន កីឡាករ ដែលបានជាប់ជម្រុះសម្រាប់វគ្គបន្ទាប់ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ ដរាបណាមានហ្គេមមួយត្រូវបានបញ្ចប់។
2. ការភ្នាល់លើប្រេម ការភ្នាល់គ្រាប់ត ពិសេស។ រាល់ប្រេមទាំងអស់ ដែលត្រូវការដើម្បីកំណត់អ្នកឈ្នះនៃការប្រកួត ត្រូវតែបានបញ្ចប់ ដើម្បីឱ្យការភ្នាល់ត្រូវបានទូទាត់។ ប្រសិនបើអ្នកឈ្នះត្រូវបានកំណត់មុនពេលការប្រកួតចប់ ដោយហេតុផលណាមួយ រាល់ការភ្នាល់ទាំងអស់នៅលើប្រេម និងគ្រាប់ត ហើយនិងការភ្នាល់ពិសេស នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែការភ្នាល់ដែលបានកំណត់ដោយគ្មានលក្ខខណ្ឌ។
3. ប្រសិនបើកីឡាករណាម្នាក់ចាញ់នៅក្នុងប្រេមណាមួយ គ្រាប់តនិងការភ្នាល់សរុបនៅក្នុងប្រេមនេះនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
4. "ដើម្បីជាប់ជម្រុះ"។ អតិថិជនគួរទស្សន៍ទាយថាតើកីឡាករមួយណា ក្នុងចំណោមកីឡាករទាំងពីរដែលបានចុះបញ្ជី នឹងឈានទៅមុខបន្តទៀត នៅក្នុងស៊េរីនៃធ្នូណាមិន។ ប្រសិនបើកីឡាករទាំងពីរឈប់ពីធ្នូណាមិន អ្នកដែលឈានមុខបន្តបានឆ្ងាយជាងគេក្នុងការស៊េរីធ្នូណាមិន នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករទាំងពីរឈប់ក្នុងជុំដូចគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ប្រសិនបើកីឡាករមួយដកខ្លួនចេញពីធ្នូណាមិនមុនពេលចាប់ផ្តើមការប្រកួត នោះហាងឆេងដែលឈ្នះនឹងមានចំនួន 1 ។
5. "សតវត្សសរុប"។ អតិថិជនគួរទស្សន៍ទាយថា តើកីឡាករម្នាក់នឹងទទួលបានពិន្ទុ 100 ឬច្រើនជាងនេះ ក្នុង

ការទៅលេងមួយតាប។

6. "គ្រាប់បាល់ចូលឡដំបូង – ខៀវ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើបាល់ពណ៌ខៀវគឺជាបាល់ពណ៌ទីមួយ ដែលត្រូវបានបុកចូលឡដោយស្របច្បាប់ (ពណ៌មានពណ៌លឿង បៃតង ត្នោត ខៀវ ផ្កាឈូក ខ្មៅ)។

10.24. តេន្នីស

1. ប្រសិនបើកីឡាករដកខ្លួនចេញ (ឬត្រូវជម្រុះចេញ) មុនពេលការប្រកួតចាប់ផ្តើម នោះប្រាក់ភ្នាល់នឹងត្រូវបានសងមកវិញ។
2. ប្រសិនបើការចាប់ផ្តើមការប្រកួតត្រូវបានពន្យាពេល ឬប្រសិនបើការប្រកួតត្រូវបានពន្យារពេលដោយហេតុផលណាមួយ នោះប្រាក់ភ្នាល់ទាំងអស់នឹងមានសុពលភាព រហូតដល់ការបញ្ចប់នៃការប្រកួត ឬការបញ្ចប់នៃធ្នូណាមិនដែលវាជាផ្នែកមួយ។
3. នៅក្នុងព្រឹត្តិការណ៍ដែលកីឡាករត្រូវបានដកចេញ ឬដកសិទ្ធិ ឬប្រសិនបើការប្រកួតត្រូវបានបញ្ចប់មុនដោយហេតុផលកីឡាករណាមួយនោះ ការប្រកួត ត្រូវបានចាត់ទុកថាបញ្ចប់នៅពេលនៃពិន្ទុចុងក្រោយ ។ រាល់ការភ្នាល់ដែលធ្វើឡើងបន្ទាប់ពីម៉ោងនេះ គឺអាចសងប្រាក់វិញបាន។ ការភ្នាល់លើស្ថិតិ កីឡាករ (ស៊ីដោយសីរីស ស៊ីដោយសីរីសទ្វេដង កំហុសទ្វេដង បំបែក ។ល។) ត្រូវបានទូទាត់តាមលទ្ធផលនៅពេលការប្រកួតត្រូវបានបញ្ឈប់។
4. ការភ្នាល់នឹងមានសុពលភាព ក្នុងករណីដូចខាងក្រោម៖
    - ការផ្លាស់ប្តូរផ្ទៃលេងមួយ;
    - ការផ្លាស់ប្តូរទីកន្លែង;
    - ការផ្លាស់ប្តូរពីទីកន្លែងពីខាងក្នុងទៅខាងក្រៅ។
5. ប្រសិនបើការប្រកួតត្រូវបានអាក់ខាន ដោយសារតែការដកខ្លួនចេញឬការជម្រុះចេញនូវកីឡាករក្នុងសេតទីមួយ នោះរាល់ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែការភ្នាល់លើហ្គេមដែលបានបញ្ចប់រួចរាល់ ហើយនិងការភ្នាល់លើលទ្ធផលដែលបានកំណត់ដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
6. ប្រសិនបើការប្រកួតតេន្នីសត្រូវបានអាក់ខាន ដោយសារតែការដកខ្លួនចេញឬការជម្រុះចេញនូវកីឡាករម្នាក់ នោះការភ្នាល់លើអ្នកឈ្នះនៃការប្រកួតនឹងមានសុពលភាព ប្រសិនបើសេតទីមួយត្រូវបានបញ្ចប់។ បើមិនដូច្នោះទេ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ការភ្នាល់លើលទ្ធផលផ្សេងទៀតនឹងត្រូវបានលុបចោល (ទូទាត់តាមហាងឆេង 1) លើកលែងតែលទ្ធផលដែលត្រូវបានកំណត់ដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
    ក្នុងករណីមានការដកខ្លួនចេញឬការជម្រុះចេញ កីឡាករនោះនឹងត្រូវចាញ់។
    ឧទាហរណ៍ទី 1 ។ ការប្រកួត Rodriguez ទល់នឹង Herbert ត្រូវបានអាក់ខាន ដោយមានពិន្ទុ 1:0 (6:2, 0:3) ដោយសារតែការដកខ្លួនចេញរបស់ Rodriguez។ ការភ្នាល់ខាងក្រោមនឹងត្រូវបានទូទាត់តាមហាងឆេង 1 ៖ ហ្គេមគ្រាប់តទី 1 (–2.5) ហ្គេម, គ្រាប់តទី 2 (+2.5) ហ្គេម, ហ្គេមសរុប (21.5), ពិន្ទុសេត 2:0, 2:1 និង 1:2 ។

រាល់ការភ្នាល់ទាំងអស់លើសេតដំបូងនឹងត្រូវបានទូទាត់។ ការភ្នាល់ "W2" នៅលើការប្រកួត នឹងឈ្នះ។ ការភ្នាល់ “W1” លើការប្រកួត និង "ពិន្ទុសេត 0:2" នឹងចាញ់។

ឧទាហរណ៍ទី 2 ។ ការប្រកួត Benneteau ទល់នឹង Klein ត្រូវបានអាក់ខាន ដោយមានពិន្ទុ 1:1 (6:4, 0:6, 0:1) ដោយសារតែការដកខ្លួនចេញរបស់ Benneteau ។ ការភ្នាល់ "ហ្គេមតូតាល់អូវ័រ 21.5" នឹងឈ្នះ រីឯការភ្នាល់ "ហ្គេមតូតាល់អាន់ឌ័រ 21.5" នឹងចាញ់ នៅពេលដែលចំនួនអប្បបរមានៃហ្គេម ដែលអាចកំណត់អ្នកឈ្នះបាន ឥឡូវនេះគឺ 22 ៖ 1:2 (6:4, 0:6, 0:6)។ រាល់ការភ្នាល់ទាំងអស់លើសេតដំបូងនិងសេតទីពីរនឹងត្រូវបានទូទាត់។ ការភ្នាល់ "W2" នៅលើការប្រកួតនឹងឈ្នះ រីឯការភ្នាល់ "W1" នៅលើការប្រកួត និង "ពិន្ទុសេត 0:2 និង 2:0" នឹងចាញ់។ ការភ្នាល់ខាងក្រោមនឹងត្រូវបានទូទាត់តាមហាងឆេង 1 ៖ គ្រាប់តហ្គេម ពិន្ទុសេត 2:1, 1:2 ។

7. ក្នុងករណីមានការផ្លាស់ប្តូរទម្រង់ (ការផ្លាស់ប្តូរចំនួនសេត) ការភ្នាល់លើលទ្ធផលខាងក្រោមនឹងនៅមានសុពលភាពដដែល ហើយត្រូវបានទូទាត់តាមលទ្ធផលនៃការប្រកួត៖
   - អ្នកឈ្នះនៃការប្រកួត;
   - ជ័យជម្នះក្នុងសេតទីមួយ
   - គ្រាប់តហ្គេមក្នុងសេតទីមួយ
   - តូតាល់សេតទីមួយ
   - អ្នកចេញសេវាដំបងក្នុងការប្រកួត
   - នឹងឈ្នះហ្គេមដំបូងនៃការប្រកួត។
   - ការភ្នាល់លើលទ្ធផលផ្សេងទៀតនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
8. គ្រាប់តនិងតូតាល់ នៅក្នុងការប្រកួតតេន្នីស ត្រូវបានបញ្ជាក់នៅក្នុងហ្គេម។
9. ប្រសិនបើហ្គេម (ឧទាហរណ៍ ពីសេត) មិនត្រូវបានបញ្ចប់ ដោយហេតុផលណាមួយ (ឧទាហរណ៍ នៅពេលការប្រកួតត្រូវបានអាក់ខាននិងមិនបានបញ្ចប់ កីឡាករបដិសេធមិនបន្តឬត្រូវបានជម្រុះចេញ។ល។) ការភ្នាល់លើហ្គេមនេះ (ឧទាហរណ៍ ពីសេត) នឹងត្រូវទូទាត់តាមហាងឆេង 1 ។
10. នៅក្នុងសេតសម្រេចសេចក្តីនៃការប្រកួតតេន្នីស គ្រាប់តនិងតូតាល់ត្រូវបានទូទាត់ដោយផ្អែកលើពិន្ទុខណៈពេលដែលការភ្នាល់លើគ្រាប់តនិងតូតាល់នៃការប្រកួត សេតសម្រេចសេចក្តីត្រូវបានចាត់ទុកថាជាហ្គេមមួយ។

    ឧទាហរណ៍ Grönefeld/Peschke – Niculescu/Zakopalová។ តូតាល់អាន់ឌ័រ 21.5 ។ ពិន្ទុគឺ (6:3, 3:6, 4:10 ពិន្ទុ)។ សេតទីបីនឹងត្រូវបានចាត់ទុកថាជាហ្គេមមួយ។ តូតាល់នឹងមាន 6+3+3+6+1=19 ។ ការភ្នាល់ឈ្នះ។
11. ទាក់ទងនឹងការប្រកួតតេន្នីសដែលមានស្លាក **“champ. tie-break" ឬ "super tie-break”** គ្រាប់តនិងតូតាល់ក្នុងការប្រកួតនឹងត្រូវបានទូទាត់ រួមទាំងពិន្ទុនៅក្នុងការប្រកួតវគ្គផ្តាច់ព្រ័ត្រ។

    ឧទាហរណ៍ Grönefeld/Peschke ទល់នឹង Niculescu/Zakopalová (champ. tie-break)។ តូតាល់អាន់ឌ័រ 21.5 ។ ពិន្ទុនៃការប្រកួតគឺ (6:3; 3:6; **4:10 ពិន្ទុ**)។

    តូតាល់នៅទីនេះស្មើនឹង 6+3+3+6+**4+10**=32 ។ ការភ្នាល់ចាញ់។

    នៅក្នុងធូណាមិន super tie-break (champion tie-break) ត្រូវបានលេងជំនួសឱ្យសេតសម្រេចសេចក្តីចុងក្រោយ។ កីឡាករ (គូ) ដែលទទួលបាន 10 ពិន្ទុដំបូង នឹងត្រូវបានប្រកាសថាជាអ្នកឈ្នះនៃការប្រកួត

ប្រសិនបើពួកគេបានផ្គូផ្គងគូប្រជែងរបស់ពួកគេ ជាមួយគម្លាតពិន្ទុយ៉ាងហោចណាស់ពីរពិន្ទុ ។

12. "ពិន្ទុត្រឹមត្រូវ" (ពិន្ទុផ្អែកលើសេត)។ ការភ្នាល់នីមួយៗនៅក្នុងផ្ទៃក "កីឡា" មាន 2:0, 2:1 ។ល។
13. "ដើម្បីជាប់ជម្រុះ"។ អតិថិជនគួរទស្សន៍ទាយថា តើកីឡាករណាម្នាក់ក្នុងចំណោមកីឡាករទាំងពីរូប ដែលនឹងឈានទៅមុខបន្តទៀត នៅក្នុងស៊េរីនៃធ្នូណាមិន។ ប្រសិនបើកីឡាករទាំងពីរឈប់ពីការប្រកួត អ្នកដែលឈានមុខបន្តបានឆ្ងាយជាងគេក្នុងស៊េរីនៃការប្រកួតនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករទាំងពីរឈប់ពីជុំដូចគ្នា នោះហាងឆេងទឹកប្រាក់ឈ្នះនឹងមានចំនួន 1 ។ ប្រសិនបើកីឡាកដកខ្លួនចេញពីធ្នូណាមិន មុនពេលចាប់ផ្តើមការប្រកួត នោះហាងឆេងការឈ្នះនឹងមានដល់ចំនួន 1 ។
14. "អ្នកឈ្នះ"។ កីឡាករ (ក្រុម) ដែលទទួលបានចំណាត់ថ្នាក់លេខមួយក្នុងធ្នូណាមិន នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើកីឡាករដកខ្លួនមុនធ្នូណាមិនចាប់ផ្តើម ការភ្នាល់លើកីឡាកររនោះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
15. "ឈ្នះក្នុងហ្គេម"។ អតិថិជនគួរតែកំណត់ថា តើអ្នកណានឹងឈ្នះហ្គេមដែលបានបញ្ជាក់។ ហ្គេមនៅក្នុងសេតនីមួយៗ ត្រូវបានដាក់លេខរៀងគ្នា។ ឧទាហរណ៍ ប្រសិនបើសេតទី 2 បញ្ចប់ដោយពិន្ទុ 6:1 ការភ្នាល់លើ "ហ្គេមទី 8 សេតទី2" នឹងត្រូវបានទូទាត់តាមហាងឆេង 1 ព្រោះមិនមានហ្គេមទីប្រាំបីទេ។
16. ការប្រកួតយកឈ្នះចាញ់ នឹងត្រូវបានចាត់ទុកថាជាហ្គេមដាច់ដោយឡែកតែមួយ។
17. **"ពិន្ទុ"**។ ពិន្ទុ គឺជាលទ្ធផលនៃសឺរីសមួយ (សឺរីសចុងក្រោយនីមួយៗនាំឱ្យកីឡាករណាម្នាក់ឈ្នះពិន្ទុ – តាមរយៈការបរាជ័យបាល់ទៅមកឬការបង្កកំហុសទ្វេដង)។
    ឧទាហរណ៍ "ពិន្ទុ 4 (ហ្គេមទី 8) W2" (កីឡាករទីពីរ ឈ្នះពិន្ទុទី 4 (លើកទីបួនដែលគ្រាប់បាល់ត្រូវបានចេញសឺរីសនៅក្នុងហ្គេមទី 8)។ ដូច្នេះបើហ្គេមទី 8 ដំណើរការដូចខាងក្រោម៖
    - ពិន្ទុទី 1 ៖ 0–15 (កីឡាករទី 2 បានឈ្នះ)
    - ពិន្ទុទី 2 ៖ 15–15 (កីឡាករទី 1 បានឈ្នះ)
    - ពិន្ទុទី 3 ៖ 15–30 (កីឡាករទី 2 បានឈ្នះ)
    - ពិន្ទុទី 4 ៖ 15–40 (កីឡាករទី 2 បានឈ្នះ) – ការភ្នាល់ឈ្នះ។
18. "ពិន្ទុក្នុងសេតទី 1"។ សម្រាប់ការភ្នាល់នេះ ពិន្ទុត្រឹមត្រូវនៃសេតទីមួយគួរតែត្រូវបានទស្សន៍ទាយ។ ប្រសិនបើសេតទីមួយមិនត្រូវបានបញ្ចប់ ការភ្នាល់លើលទ្ធផលនេះនឹងត្រូវទូទាត់តាមហាងឆេង 1 ។
19. "ការប្រកួតយកឈ្នះ-ចាញ់"។ អតិថិជនគួរតែទស្សទាយថាតើ ការប្រកួតយកឈ្នះ-ចាញ់ នឹងមាននៅក្នុងការប្រកួតដែរឬទេ។ ប្រសិនបើការប្រកួតមិនត្រូវបានបញ្ចប់ ដោយហេតុផលណាមួយ និងការប្រកួតយកឈ្នះ-ចាញ់បានកើតឡើងរួចហើយ នោះការភ្នាល់ "ការប្រកួតយកឈ្នះ-ចាញ់ – បាទ/ចាស" នឹងឈ្នះ រីឯការភ្នាល់ "ការប្រកួតយកឈ្នះ-ចាញ់ – ទេ" នឹងចាញ់។ ប្រសិនបើការប្រកួតមួយមិនត្រូវបានបញ្ចប់ ដោយហេតុផលណាមួយ ហើយមិនមានការប្រកួតយកឈ្នះ-ចាញ់ នោះការភ្នាល់នៅលើទីផ្សារ "ការប្រកួតយកឈ្នះ-ចាញ់" នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
20. "កីឡាករដំបូងដែលនឹងតវ៉ាឱ្យមានការផ្លៀងផ្ទាត់ខ្សែ" ។ អតិថិជនគួរទស្សន៍ទាយថា តើកីឡាករណានឹងជាអ្នកដំបូងគេ ដែលប្រើសិទ្ធិរបស់ខ្លួនក្នុង ការប្រកួតប្រជែងការហៅតាមជួរ។ ប្រសិនបើគ្មានកីឡាករណាម្នាក់ប្រើសិទ្ធិរបស់ខ្លួន ដែលប្រើសិទ្ធិរបស់ខ្លួនក្នុង ការប្រកួតប្រជែងការហៅតាមជួរទេ នោះ

ការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។

21. គ្មានការភ្នាល់ណានឹងត្រូវបានលុបចោលដោយសារតែមានបញ្ហាក្នុងការដាក់ឈ្មោះកាត់របស់កីឡាករ /កីឡាការនីមិនត្រឹមត្រូវនោះទេ (ឧទាហរណ៍ D. Muller ជំនួសឱ្យ G. Muller)។ នៅក្នុងករណីនេះ ការភ្នាល់នឹងត្រូវមានសុពលភាព។
22. "ពិន្ទុយកឈ្នះ-ចាញ់ក្នុងសេត"។អតិថិជនគួរតែទស្សន៍ទាយនូវពិន្ទុត្រឹមត្រូវនៃការប្រកួតយកឈ្នះ-ចាញ់ ។

    ការប្រកួតយកឈ្នះ-ចាញ់ត្រូវបានលេង ដើម្បីកំណត់អ្នកឈ្នះនៃសេត នៅពេលដែលពិន្ទុនៅក្នុងសេត ឈានដល់ 6:6 ។ ការប្រកួតយកឈ្នះ-ចាញ់ត្រូវតែលេងរហូតដល់ 7 ពិន្ទុ (ពិន្ទុការយកឈ្នះ-ចាញ់អាចជា 7:5, 7:4 ។ល។)។
23. "W 1/2 ជាមួយនឹងពិន្ទុមួយផ្សេងទៀត"។ ការភ្នាល់នេះបង្កប់ន័យថា កីឡាកររនឹងឈ្នះការប្រកួតយកឈ្នះ -ចាញ់ បន្ទាប់ពីទទួលបានពិន្ទុ 6:6 (ឬប្រកួតស៊ុបពើយកឈ្នះ-ចាញ់ ក្រោយមានពិន្ទុ 9:9)។

    ឧទាហរណ៍ទី 1 ។ Klein (អូស្ត្រាលី) ទល់នឹង Klec (ស្លូវ៉ាគី)។ W1 ជាមួយនឹងពិន្ទុមួយផ្សេងទៀត។
    - បញ្ចប់ការប្រកួតយកឈ្នះ-ចាញ់ ដោយពិន្ទុ (7:3) – ការភ្នាល់ចាញ់។
    - បញ្ចប់ការប្រកួតយកឈ្នះ-ចាញ់ដោយពិន្ទុ (8:6) – ការភ្នាល់ឈ្នះ (ដោយកីឡាកររទី 1 បានឈ្នះ បន្ទាប់ពីពិន្ទុ 6:6)។
24. "ការប្រកួតយកឈ្នះ-ចាញ់"។ អតិថិជនគួរតែទស្សន៍ទាយនូវពិន្ទុត្រឹមត្រូវ នៃការប្រកួតយកឈ្នះ-ចាញ់។
25. ពិន្ទុការប្រកួតស៊ុបពើយកចាញ់-ឈ្នះនៃការប្រកួតត្រូវបានលេងរហូតដល់ 10 ពិន្ទុ (ពិន្ទុអាចមាន 10:8, 10:6 ។ល។)។
26. "ពិន្ទុប្រកួតយកឈ្នះ-ចាញ់។ មួយផ្សេងៗទៀត W1/W2"។ តើកីឡាករណានឹងឈ្នះការប្រកួតយកឈ្នះ-ចាញ់ ជាមួយពិន្ទុខុសគ្នាពីពិន្ទុដែលបានផ្តល់ជូននោះ?
27. ការភ្នាល់លើ "ពិន្ទុយកឈ្នះ-ចាញ់" នឹងត្រូវបានទូទាត់តាមហាងឆេង 1 ប្រសិនបើមិនមានការប្រកួតស្មើគ្នានៅក្នុងការប្រកួតឬនៅក្នុងសេត ឬប្រសិនបើការប្រកួតមិនបានបញ្ចប់ដោយហេតុផលណាមួយ។
28. "សេតនឹងបញ្ចប់ 6:0 (0:6) នៅក្នុងការប្រកួត – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើពិន្ទុនៃសេតណាមួយនៅក្នុងការប្រកួតនឹងមាន (6:0) ឬ (0:6)។
29. "កីឡាកររនឹងចាញ់សេតទី 1 ប៉ុន្តែវាយបកយកឈ្នះវិញ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើកីឡាករចាញ់សេតដំបូង ប៉ុន្តែបន្តយកឈ្នះការប្រកួត។
30. **"ពិន្ទុសេត"។ ឧទាហរណ៍ ការភ្នាល់ "សេតទី 1 > ទី 2"** នឹងឈ្នះ ប្រសិនបើមានការប្រកួតច្រើនក្នុងសេតទីមួយជាងសេតទីពីរ។
31. ស្ថិតិ (ចំនួនស៊ុដោយសីរីស ចំនួននៃកំហុសទ្វេដង ភាគរយសីរីសដំបូង ។ល។) ត្រូវបានដកស្រង់ ដោយផ្អែកលើព័ត៌មាននៅលើវេបសាយផ្លូវការរៀងៗខ្លួននៃធ្នូណាមិនជាក់លាក់។
32. ការភ្នាល់លើស្ថិតិជាក់លាក់ (ចំនួនស៊ុដោយសីរីស ចំនួននៃកំហុសទ្វេដង ភាគរយសីរីសដំបូង ។ល។) ត្រូវបានទូទាត់តាមរបៀបដូចខាងក្រោម នៅពេលដែលការប្រកួតមិនត្រូវបានបញ្ចប់ ដោយហេតុផលអ្វីក៏ដោយ។ លទ្ធផលដែលត្រូវបានកំណត់ ដោយគ្មានលក្ខខណ្ឌរួចហើយ នៅពេលការប្រកួតត្រូវបានអាក់

ខាន នឹងត្រូវរាប់បញ្ចូលក្នុងការទូទាត់ការភ្នាល់។ ការសងប្រាក់ លើការភ្នាល់ផ្សេងទៀត នឹងត្រូវធ្វើឡើងតាមហាងឆេង 1 ។

33. ពិន្ទុសម្រេចការប្រកួត គឺជាពិន្ទុមួយ ដែលប្រសិនបើឈ្នះដោយកីឡាករណាម្នាក់កីឡាកររនោះនឹងឈ្នះការប្រកួតនោះដែរ។
34. "បំបែកលេខ 1 – កីឡាករទី 1"។ ការភ្នាល់នឹងឈ្នះប្រសិនបើកីឡាករទី 1 យកឈ្នះហ្គេម នៅពេលទទួលសីរីស (ចំណុចបំបែកគឺជាចំណុច ដែលប្រសិនបើអ្នកឈ្នះទទួលបានគ្រាប់បាល់ នឹងឈ្នះពួកគេការប្រកួតនេះ។ នេះហៅថាការបំបែកសីរីស។)។
35. "ពិន្ទុសរុបនៅក្នុងហ្គេមដំបូងអូវ័រ (5.5)"។ នេះគឺជាការភ្នាល់លើចំនួនពិន្ទុនៅក្នុងហ្គេមដំបូង។ ឧទាហរណ៍ ប្រសិនបើហ្គេមត្រូវបានឈ្នះ បន្ទាប់ពីបានពិន្ទុ (40:30) មាន 6 ពិន្ទុ ហើយការភ្នាល់នឹងឈ្នះ។
36. នៅក្នុងទីផ្សារ "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត" មានតែសេតទីមួយនិងទីពីរប៉ុណ្ណោះដែលត្រូវបានយកមកពិចារណា។ ការភ្នាល់លើ "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – ស្មើ" នឹងឈ្នះ ប្រសិនបើឧទាហរណ៍ ពិន្ទុគឺ (6:3, 3:6, 6:4)។ ការភ្នាល់ "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – 1" និង "រយៈពេលដែលមានពិន្ទុខ្ពស់បំផុត – 2" នឹងចាញ់ ប្រសិនបើចំនួនហ្គេមនៅក្នុងសេតទីមួយស្មើគ្នានឹងចំនួនហ្គេមនៅក្នុងសេតទីពីរ។
37. "សេតដែលមានពិន្ទុខ្ពស់បំផុត (ទាបបំផុត) – តូតាល់"។ ការភ្នាល់លើទីផ្សារសរុប នឹងត្រូវបានទូទាត់យោងតាមច្បាប់ នៃការប្រកួតតេន្នីសរៀងៗខ្លួន (ឧទាហរណ៍ ប្រសិនបើកីឡាករ ត្រូវលេងរហូតដល់ពួកគេឈ្នះបាន 2 សេត ឬ 3 សេត)។
38. "អ្នកណានឹងបំបែកបានច្រើនជាង"។ មានលទ្ធផលបីនៅក្នុងទីផ្សារនេះ៖ កីឡាករទី 1 កីឡាករទី 2 និងស្មើ។ ប្រសិនបើកីឡាករមានចំនួនបំបែកស្មើគ្នាក្នុងការប្រកួត ជម្រើស "ស្មើ" នឹងត្រូវឈ្នះ។
39. "កីឡាកននឹងឈ្នះសីរីសរបស់ពួកគេ បន្ទាប់ពីទទួលបានពិន្ទុ 0:40 – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះប្រសិនបើកីឡាករចាញ់សីរីសហ្គេមរបស់ពួកគេ ជាមួយនឹងពិន្ទុ 0:40 ប៉ុន្តែបន្ទាប់មកបន្តដើម្បីយកឈ្នះហ្គេម។
40. "ហ្គេមយកឈ្នះ-ចាញ់ ឬហ្គេមបន្ថែម នៅក្នុងសេតចុងក្រោយ"។ សេតទី 3 ចុងក្រោយ (ប្រកួត "ល្អបំផុតក្នុងចំណោម 3") ឬសេតទី 5 (ប្រកួត "ល្អបំផុតក្នុងចំណោម 5 ប្រកួត") ត្រូវបានរាប់បញ្ចូល ដើម្បីទូទាត់ការភ្នាល់។
41. "ការហៅការប្រកួតប្រជែងតាមខ្សែរទីមួយ ដើម្បីទទួលបានជោគជ័យ – បាទ/ទេ"។ ប្រសិនបើកីឡាករទាំងពីរ មិនបានប្រើសិទ្ធិរបស់ខ្លួនក្នុង ការប្រកួតប្រជែងការហៅតាមជួរទេ នោះហាងឆេងដែលឈ្នះនឹងមានចំនួន 1 ។
42. ការប្រកួតតេន្នីស FAST4 អាចជាសេតល្អបំផុតទាំងបី (ពីរសេតត្រូវតែបានឈ្នះ) ឬសេតល្អបំផុតក្នុងចំណោមប្រាំសេត (បីសេតត្រូវតែបានឈ្នះ)។ សេតមួយនៅបន្ត រហូតដល់បួនហ្គេមបានឈ្នះ។ ប្រសិនបើពិន្ទុគឺ 3:3 ការប្រកួតយកឈ្នះ-ចាញ់ ត្រូវបានផ្តល់ជូន។ ការប្រកួតយកឈ្នះ-ចាញ់ គឺឈ្នះនៅពេលដែលកីឡាករឈានដល់ 5 ពិន្ទុប៉ុន្តែមិនចាំបាច់មានពីរពិន្ទុខុសគ្នាទេ មានន័យថាការប្រកួតយកឈ្នះ-ចាញ់ អាចបញ្ចប់ដោយពិន្ទុ 5:4 ។ ប្រសិនបើពិន្ទុក្នុងការប្រកួតយកឈ្នះ-ចាញ់គឺ 4:4 កីឡាករឬក្រុមដែលទទួលសីរីសនឹងជ្រើសរើសខាង (ខាងស្តាំឬខាងឆ្វេង) ដែលបាល់នឹងត្រូវបានចេញសីរីស។ កីឡាករ

នៅក្នុងការប្រកួតយកឈ្នះ-ចាញ់ នឹងការផ្លាស់ប្តូរនឹងបញ្ចប់ បន្ទាប់ពីការបានលេង 4 ពិន្ទុដំបូង។

10.25. ហ្គូរបល

1. ហ្គូរបល គឺជាប្រភេទកីឡាវាយកូនបាល់ហុកគីមួយដែលលេងក្នុងសាលនៅលើកម្រាលឥដ្ឋ ដោយប្រើគ្រាប់បាល់ប្លាស្ទិចដែលមានរន្ធនៅក្នុងវា។
2. រាល់ការភ្នាល់ទាំងអស់ គឺត្រូវទូទាត់ដោយផ្អែកលើលទ្ធផលនៅពេលចប់ម៉ោងធម្មតា (ការលេង 60 នាទី ដែលមានបីតង់ដោយមួយតង់ៗមាន 20 នាទី)។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួតឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
3. ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់បញ្ចូលសម្រាប់ទីផ្សារដូចតទៅនេះ៖ "ដើម្បីជាប់ជម្រុះ (ទៅជុំបន្ទាប់)" "អ្នកឈ្នះនៃធូណាមិន" និងស្រដៀងគ្នា។
4. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានល័ក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
5. យ៉ាងហោចណាស់ 50 នាទីនៃការលេងត្រូវតែកន្លងផុត ដើម្បីឱ្យការប្រកួតត្រូវប្រកាសជាផ្លូវការបាន។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់ ដោយផ្អែកលើលទ្ធផលនៅពេលការប្រកួតត្រូវបានបញ្ឈប់។
6. យោងទៅតាមការអនុញ្ញាតរបស់អ្នកដែលរៀបចំព្រឹត្តិការណ៍ រយៈពេលនៃការប្រកួតមួយអាចត្រូវបានបង្រួញទៅយ៉ាងហោចណាស់ពីរតង់ដែលមួយតង់ៗមានរយៈពេល 15 នាទី ដោយមានការផ្អាកមួយដងដែលត្រូវកំណត់ដោយអ្នករៀបចំ។ អតិថិជនគួរពិនិត្យមើលច្បាប់ នៃធូណាមិនពាក់ព័ន្ធពីប្រភពឯករាជ្យនានា។

10.26. បាល់ទាត់

1. ការភ្នាល់លើការប្រកួតបាល់ទាត់ (រាប់បញ្ចូលទាំងការប្រកួតពាន) ត្រូវបានទទួលយក តាមម៉ោងធម្មតាដែលបានចែងក្នុងច្បាប់ (ការលេង 90 នាទី ដែលមានពីរតង់ដោយមួយតង់ៗមាន 45 នាទី បូកនឹងពេលវេលារងរបួស) លើកលែងតែមានចែងក្នុងផ្នែក "កីឡា" ("ម៉ោងបន្ថែម")។
   ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់បញ្ចូលសម្រាប់តែទីផ្សារ "ដើម្បីជាប់ជម្រុះ (ទៅជុំបន្ទាប់)" "ប្រម៉ូសិន/ការកាត់ចេញពីលីគ" "អ្នកឈ្នះនៃធូណាមិន" និងស្រដៀងគ្នា។
2. យ៉ាងហោចណាស់ការលេងរយៈពេល 80 នាទីត្រូវតែកន្លងផុត ដើម្បីឱ្យការភ្នាល់អាចមានសុពលភាពបាន លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានលក្ខខណ្ឌ នៅពេលការប្រកួតត្រូវបាន

បញ្ឈប់។

3. ទ្រង់ទ្រាយនៃការប្រកួតមិត្តភាព។
   ច្បាប់របស់ FIFA ទាក់ទងនឹងរយៈពេលនៃការប្រកួតមិត្តភាពកម្រិតយុវជន៖
   - សម្រាប់ក្រុម U18, U17, U16, U15 – 80 នាទី (មានពីរតង់ដោយមួយតង់ៗមាន 40 នាទី)
   - ក្រុម U14 - 70 នាទី (មានពីរតង់ដោយមួយតង់ៗមាន 35 នាទី) ការលេងពេញ 70 នាទីត្រូវតែកន្លងផុត ដើម្បីឱ្យការភ្នាល់មានសុពលភាពបាន
   - ក្រុម U13 និង U12 – 60 នាទី (មានពីរតង់ដោយមួយតង់ៗមាន 30 នាទី) ការលេងពេញ 60 នាទីត្រូវតែកន្លងផុត ដើម្បីឱ្យការភ្នាល់មានសុពលភាពបាន
     ច្បាប់នៃការប្រកួតមិត្តភាពត្រូវបានកំណត់ មុនពេលធ្វណាមិនចាប់ផ្តើម។ អតិថិជនគួរពិនិត្យមើលច្បាប់ពីប្រភពព័ត៌មានឯករាជ្យ មុនពេលដាក់ការភ្នាល់លើការប្រកួតមិត្តភាព។
4. ចំនួនបាល់ជ្រុង នៅក្នុងការប្រកួតជើងឯកបាល់ទាត់រុស្ស៊ី (ព្រីមៀលីគរុស្ស៊ី) ត្រូវបានគណនានៅថ្ងៃទីបីបន្ទាប់ពីការបញ្ចប់ការប្រកួត។ ប្រសិនបើចំនួនបាល់ជ្រុងមិនត្រូវបានបញ្ជាក់នៅលើវេបសាយ ដែលបានចុះបញ្ជីជាប្រភពសំខាន់ៗនៃព័ត៌មានទេ នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
5. ការភ្នាល់លើទីផ្សារ "នឹងមានចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធ្វណាមិន" ទាក់ទងទៅនឹង ពានរង្វាន់ពិភពលោក និង ជើងឯកអឺរ៉ុប UEFA នឹងត្រូវបានទូទាត់ទៅតាមដំណាក់កាលដែលក្រុមឈានដល់។
6. ការភ្នាល់លើក្រុមដែលនឹងរកគ្រាប់បាល់បានច្រើនជាង និងក្រុមដែលស៊ុតចូលគេ (ត្រូវគេស៊ុតចូល) ច្រើនជាងគេ (តិចជាងគេ) ទាក់ទងទៅនឹង ពានរង្វាន់ពិភពលោក World Cup និងជើងឯកអឺរ៉ុប UEFA នឹងត្រូវបានទូទាត់រួមទាំងម៉ោងបន្ថែម ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីឡើយ។ ប្រសិនបើក្រុមបានស៊ុតចូលគេ (ឬត្រូវគេស៊ុតចូល) ក្នុងចំនួនគ្រាប់ស្មើគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
7. ការភ្នាល់លើការប្រកួតបាល់ទាត់ ដែលមានស្លាកថា "ម៉ោងបន្ថែម" នឹងត្រូវបានទូទាត់ដោយមិនរាប់បញ្ចូល ការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីឡើយ។ ការភ្នាល់លើការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីត្រូវបានទទួលយកដាច់ដោយឡែក។
8. "បាល់ជ្រុងទីមួយ – ក្រុម"។ តើក្រុមណានឹងក្លាយជាក្រុមដំបូងគេ ដែលទទួលបានបាល់ជ្រុង?
9. "បាល់ជ្រុងច្រើនជាង – ក្រុម"។ តើក្រុមណានឹងទទួលបានបាល់ជ្រុងច្រើនជាងគេក្នុងការប្រកួត?
10. "ចំនួនបាល់ជ្រុងសរុប អូវ័រ/អាន់ឌ័រ"។ អតិថិជនគួរទស្សន៍ទាយថា តើចំនួនបាល់ជ្រុងសរុបក្នុងការប្រកួតនឹងមានចំនួនតិចឬច្រើនជាងចំនួនដែលបានបញ្ជាក់។
11. **ទីផ្សារកាតលឿង (ដាក់ស្លាកថា "YC")** ។ មានតែការពិន័យចំពោះកីឡាករលើទីលាននិងអ្នកចាំទីប៉ុណ្ណោះ ដែលនឹងរាប់បញ្ចូលសម្រាប់ការភ្នាល់ លើចំនួនកាតលឿងសរុប និងចំនួនកាតលឿងសរុបជាមួយនឹងគ្រាប់ត។ គ្មានកាតលឿងទីពីរដែលបណ្តាលឱ្យមានការបណ្តេញចេញ នឹងត្រូវរាប់ក្នុងការគណនាចំនួនកាតលឿងនៅក្នុងការប្រកួតទេ។
12. ការភ្នាល់ផ្សាយផ្ទាល់លើកាតលឿង ក្នុងចន្លោះពេលវេលាជាក់លាក់មួយ ត្រូវបានទូទាត់ដោយមិនគិតពីម៉ោងបន្ថែមឡើយ។ ឧទាហរណ៍ ប្រសិនបើការភ្នាល់ត្រូវបានដាក់លើកាតលឿងមួយចន្លោះនាទី 85:00 និងនាទី 88:59 ហើយកាតលឿងមួយត្រូវបានបង្ហាញនៅនាទី 90+1 នោះការភ្នាល់នឹងត្រូវបានទូទាត់

ជាការចាញ់។

13. មិនមានកាតលឿងឬកាតក្រហមណា ដែលត្រូវបានបង្ហាញដល់កីឡាករឬអ្នកចាំទីបន្ទាប់ពីការផ្លុំកញ្ចែចុងក្រោយ នឹងត្រូវបានរាប់បញ្ចូលសម្រាប់ការភ្នាល់ឡើយ។ ប្រសិនបើកាតលឿងមួយត្រូវបានបង្ហាញដោយអាជ្ញាកណ្តាល ក្នុងពេលសម្រាកពាក់កណ្តាលតង់ សម្រាប់ការប្រព្រឹត្តបទល្មើសដែលបានប្រព្រឹត្តនៅក្នុងតង់ទីមួយ (ឧទាហរណ៍ កាតលឿងផ្តល់នៅពេលម៉ោងសម្រាក) កាតពិន័យនេះនឹងត្រូវរាប់សម្រាប់ការភ្នាល់នៅតង់ទីមួយ។ ប្រសិនបើអាជ្ញាកណ្តាលបង្ហាញកាតលឿងមួយ នៅចុងបញ្ចប់នៃការប្រកួតចំពោះការប្រព្រឹត្តបទកំហុសដែលបានប្រព្រឹត្តនៅក្នុងតង់ទីពីរ (ឧទាហរណ៍ កាតលឿងផ្តល់នៅពេលម៉ោងសម្រាក) កាតពិន័យនេះ នឹងត្រូវរាប់សម្រាប់ការភ្នាល់នៅតង់ទីពីរ។
14. **ការភ្នាល់លើ "កាតលឿង/កាតក្រហម" (ដែលត្រូវបានគេហៅថា YRC ឬកាត)** នឹងត្រូវបានទូទាត់តាមលក្ខណៈដូចតទៅនេះ៖ កាតលឿងត្រូវបានរាប់ជាកាតមួយ ហើយកាតក្រហមត្រូវបានរាប់ជាកាតលឿងពីរ។ កាតលឿងទីពីរសម្រាប់កីឡាករដដែល នឹងមិនត្រូវបានរាប់បញ្ចូលជាកាតលឿងឡើយ ហើយនឹងត្រូវបានចាត់ទុកថាជាកាតក្រហមមួយ។ នេះមានន័យថា កីឡាករម្នាក់អាចមានកាតពិន័យអតិបរិមាចំនួន 3 ក្នុងមួយប្រកួត។
15. ចំនួនកាតលឿងនិងក្រហម ការទាត់បាល់ជ្រុង និងការទាត់ប៉ះរបាទី/បង្គោលទី នឹងត្រូវបានកំណត់ដោយផ្អែកលើរូបភាពវីដេអូ។ ក្នុងករណីដែលកង្វះនៃរូបភាពវីដេអូ ឬការអាក់ខានរបស់វា នោះចំនួនកាតលឿងនិងកាតក្រហម និងការទាត់បាល់ជ្រុង នឹងត្រូវយកចេញពីប្រភពផ្លូវការ។ ការប្តូរកីឡាករធ្វើ ដែលឡើងនៅនាទី 46 យោងទៅតាមប្រភពផ្លូវការ នឹងត្រូវបានចាត់ទុកថាជាការប្តូរមួយដែលបានធ្វើឡើងនៅក្នុងពេលសម្រាកពាក់កណ្តាលតង់។ ការទាត់បាល់ជ្រុង ដែលត្រូវបានទាត់ឡើងវិញ នឹងត្រូវបានចាត់ទុកថាជាការទាត់បាល់ជ្រុងតែមួយ សម្រាប់គោលបំណងទូទាត់សងប្រាក់ភ្នាល់។ មានតែការទាត់បាល់ជ្រុង ដែលត្រូវបានទាត់រួចប៉ុណ្ណោះ នឹងត្រូវរាប់បញ្ចូលទៅក្នុងការទូទាត់សងប្រាក់ភ្នាល់លបាល់ជ្រុងសរុប។
16. **របាទីនិងបង្គោលទី។** មានតែពេលដែលបាល់ប៉ះរបាទី/បង្គោលទី ដែលត្រូវបានទាត់ដោយក្រុមគូប្រកួតហើយបាល់នៅតែបន្តលេងបានប៉ុណ្ណោះ នឹងរាប់បញ្ចូលសម្រាប់គោលបំណងនៃការភ្នាល់។ (ឧទាហរណ៍ ប្រសិនបើបាល់បានប៉ះ កីឡាករ អាជ្ញាកណ្តាល បង្គោលទីឬរបារទីមួយផ្សេងទៀត)។ របារទីឬបង្គោលទីនឹងមិនត្រូវរាប់បញ្ចូលក្នុងករណីដូចតទៅនេះ៖ ករណីការប្រកួតត្រូវបានអាក់ខាន មុនពេល បាល់ប៉ះនឹងបង្គោលទីឬរបារទី និងករណីបាល់ចេញក្រៅទីលានឬត្រូវបានទាត់បញ្ចូលទី (មួយគ្រាប់) បន្ទាប់ពីប៉ះបង្គោលទីឬរបារទី។
17. **ស៊ុតចំគោលដៅ។**ការស៊ុតបាល់ប៉ះលើបង្គោលទី/របារទី ឬត្រូវបានរារាំងប្តូក មិនត្រូវបានរាប់បញ្ចូលនៅពេលការភ្នាល់ត្រូវបានទូទាត់។
18. **ស៊ុតសំដៅទី។** សម្រាប់គោលបំណងទូទាត់សងប្រាក់ភ្នាល់ រាល់ការស៊ុតចំនិងខុសគោលដៅទាំងអស់នឹងត្រូវបានរាប់ចូល។
19. ការភ្នាល់នៅលើទីផ្សារស្ថិតិ អាចត្រូវបានទូទាត់សង ក្នុងរយៈពេលមួយម៉ោងបន្ទាប់ពីចប់ការប្រកួត។
20. ការភ្នាល់មុនការប្រកួត៖ "គ្រាប់ចូលទីក្នុងចន្លោះពេលសម្រាក" "ពេលគ្រាប់ចូលទីដំបូង" "ក្រុមដែលរកបានគ្រាប់ចូលទីដំបូងគេ/ចុងក្រោយគេ" រហូតដល់ () នាទី "ត្រូវបានទូទាត់ជាមួយនឹងម៉ោងសម្រាក

ដែលត្រូវយកមកពិចារណា លើកលែងតែមានចែងក្នុងផ្នែកកីឡា។

21. **ការភ្នាល់លើព្រឹត្តិការណ៍រហ័ស៖** "តូតាល់ ក្នុងចន្លោះពេលពីនាទី () ដល់នាទី ()" "គ្រាប់ត ក្នុងចន្លោះពេល ..." "លទ្ធផល ក្នុងចន្លោះពេល..."។ អតិថិជនគួរតែកំណត់ចំនួនគ្រាប់ ក្នុងចន្លោះពេលដែលបានបញ្ជាក់។
    - ក្នុងចន្លោះពេលពីនាទី 40:00 ដល់នាទី 44:59 ចំនួនគ្រាប់សរុបនឹងមិនត្រូវបានគណនា ដោយមិនរាប់បញ្ចូលម៉ោងបន្ថែមឡើយ។
    - ក្នុងចន្លោះពេលពីនាទី 40:00 ដល់នាទី 49:59 ចំនួនគ្រាប់សរុបនឹងត្រូវបានគណនា ដោយរាប់បញ្ចូលទាំងម៉ោងបន្ថែមដែរ។
    - ក្នុងចន្លោះពេលពីនាទី 85:00 ដល់នាទី 89:59 ចំនួនគ្រាប់សរុបនឹងត្រូវបានគណនា ដោយរាប់បញ្ចូលទាំងម៉ោងបន្ថែមដែរ។
    - ក្នុងចន្លោះពេលពីនាទី 10:00 ដល់នាទី 19:59 ប្រសិនបើគ្រាប់បាល់ត្រូវបានស៊ុតបញ្ចូលទីនៅនាទី 20 នោះវានឹងត្រូវរាប់បញ្ចូលសម្រាប់ការភ្នាល់ក្នុងចន្លោះពេលនេះ។
22. សកម្មភាពដែលនឹងកើតឡើងមុនគេ។ ការភ្នាល់នឹងត្រូវបានទូទាត់សងដូចតទៅនេះ៖
    សម្រាប់ការបោះបាល់ចូល បាល់ជ្រុង និងបាល់ទាត់ពីអ្នកចាំទី – ពេលវេលាដែលករណីនោះត្រូវបានអនុវត្តជាក់ស្តែង ត្រូវបានយក។
    សម្រាប់កំហុស កាតពិន័យ អកហ្សឹ និងគ្រាប់ – ពេលវេលាដែលករណីនោះបានកើតឡើង ត្រូវបានយក។
    សម្រាប់ចន្លោះពេលពីនាទី 41–45 និងនាទី 86–90 – ការប្រៀបធៀបស្ថិតិត្រូវបានធ្វើឡើង ដែលមិនគិតបញ្ចូលម៉ោងបន្ថែមឡើយ។
    សម្រាប់ទីផ្សារ សកម្មភាពដែលនឹងកើតឡើងមុនគេ/ក្រោយគេ – ប្រាក់ភ្នាល់ត្រូវបានទូទាត់សង ដោយរាប់បញ្ចូលទាំងម៉ោងបន្ថែមដែរ។
23. ទីផ្សារ 1 នាទី។ ការភ្នាល់នឹងត្រូវបានទូទាត់សងដូចតទៅនេះ៖
    សម្រាប់ការបោះបាល់ចូល បាល់ជ្រុង បាល់ទាត់ពីអ្នកចាំទី កាតពិន័យ ហ្វ្រីឃីក – ពេលវេលាដែលករណីនោះត្រូវបានផ្តល់ដោយអាជ្ញាកណ្តាល ត្រូវបានយក។
    សម្រាប់ចន្លោះពេលពីនាទី 41–45 និងនាទី 86–90 – ការប្រៀបធៀបស្ថិតិត្រូវបានធ្វើឡើង ដែលមិនគិតបញ្ចូលម៉ោងបន្ថែមឡើយ។
24. "នឹងរកបានគ្រាប់ដំបូង (David Villa)"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើកីឡាករដែលត្រូវលើកឈ្មោះ (David Villa) បង្ហាញខ្លួននៅលើទីលាន ហើយរកបានគ្រាប់បាល់ស៊ុតបញ្ចូលទីដំបូង។ មិនរាប់បញ្ចូលគ្រាប់បាល់ចូលទីដោយខ្លួនឯងទេ។
    ការភ្នាល់មុនការប្រកួត។ ប្រសិនបើកីឡាករូបនោះ ខកខានមិនបានចូលលេងលើទីលានទេ នោះប្រាក់ភ្នាល់នឹងត្រូវបានបង្វិលសងវិញ (ប្រាក់ភ្នាល់នឹងត្រូវទូទាត់សងតាមហាងឆេង 1)។ ការភ្នាល់នៅលើទីផ្សារនេះ នឹងមានសុពលភាពសម្រាប់តែ កីឡាករក្នុងចំណោម 11 នាក់ដំបូងប៉ុណ្ណោះ (ប្រសិនបើកីឡាករមួយរូប ត្រូវបានណែនាំជាកីឡាករប្តូរចូល ហើយបើកឲ្យមានការភ្នាល់លើកីឡាករូបនោះ ការភ្នាល់បែបនេះនឹងត្រូវទូទាត់សងតាមហាងឆេង 1)។
    ការភ្នាល់ផ្សាយផ្ទាល់។ ប្រសិនបើកីឡាករម្នាក់ចូលក្នុងទីលានប្រកួត ហើយបើកឲ្យមានការភ្នាល់ "អាច

រកបានមួយគ្រាប់" លើអ្នកលេងនោះ ដូច្នេះ ការភ្នាល់បែបនេះត្រូវបានទូទាត់ស្របទៅតាមការបញ្ចេញ សមត្ថភាពរបស់កីឡាករ។

25. "នឹងរកបានគ្រាប់ដំបូង (David Villa)"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើកីឡាករដែលត្រូវលើកឈ្មោះ (David Villa) បង្ហាញខ្លួននៅលើទីលាន ហើយរកបានគ្រាប់បាល់ស៊ុតបញ្ចូលទីដំបូង។ មិនរាប់បញ្ចូលគ្រាប់បាល់ចូលទីខ្លួនឯងទេ។ ប្រសិនបើកីឡាករចូលរួមក្នុងទីលានលេង បន្ទាប់ពីគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី ឬមិនបានចូលទីលានទាល់តែសោះ នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។ ការភ្នាល់នៅលើទីផ្សារនេះនឹងមានសុពលភាពសម្រាប់តែកីឡាករក្នុងចំណោម 11 នាក់ដំបូងប៉ុណ្ណោះ (ប្រសិនបើកីឡាកររូបនោះត្រូវបានណែនាំជាកីឡាកររំប្ដូរចូល ហើយការភ្នាល់លើកីឡាកររូបនោះត្រូវបានផ្តល់ជូន នោះការភ្នាល់បែបនេះនឹងត្រូវទូទាត់សងតាមហាងឆេង 1)។
26. "កីឡាករដែលនឹងរកបានគ្រាប់បាល់បាន អូវ័រ/អាន់ឌ័រ 0.5"។ ការភ្នាល់នេះនឹងមានសុពលភាព សម្រាប់តែកីឡាករក្នុងចំណោម 11 នាក់ដំបូងប៉ុណ្ណោះ (ប្រសិនបើកីឡាកររូបនោះត្រូវបានណែនាំជាកីឡាកររំប្ដូរចូល ហើយការភ្នាល់លើកីឡាកររូបនោះត្រូវបានផ្តល់ជូន នោះការភ្នាល់បែបនេះនឹងត្រូវទូទាត់សងតាមហាងឆេង 1)។
27. "គ្រាប់ដំបូង/ចុងក្រោយបង្អស់នៃការប្រកួត – ចន្លោះពេល"។ ការភ្នាល់លើគ្រាប់បាល់ដំបូងដែលត្រូវបានស៊ុតបញ្ចូលទី ក្នុងចន្លោះពេលដែលបានបញ្ជាក់ ឧទាហរណ៍ ពីនាទី 1 ដល់ 30 នឹងចាញ់ ប្រសិនបើការប្រកួតត្រូវបានអាក់ខានជាមួយពិន្ទុនៅ 0:0 បន្ទាប់ពីចន្លោះពេលដែលបានបញ្ជាក់។
28. "កីឡាករម្នាក់ដែលរកបានបាល់ពីរគ្រាប់" (ឬហៅថា "ប្រេស")/"ហាតទ្រីគ"។ អតិថិជនគួរទស្សន៍ទាយថា តើនឹងមានកីឡាករម្នាក់ប្រាកដជារកគ្រាប់បាល់ស៊ុតបញ្ចូលទីបានពីរគ្រាប់គត់ (ប្រេស) ឬបីគ្រាប់គត់ (ហាតទ្រីគ) នៅក្នុងការប្រកួតតែមួយឬអត់។ មិនរាប់បញ្ចូលគ្រាប់បាល់ចូលទីខ្លួនឯងទេ។ ប្រសិនបើមានការស៊ុតបាល់បញ្ចូលទីហាតទ្រីគ នោះការភ្នាល់ថា "កីឡាករម្នាក់ស៊ុតបាល់បញ្ចូលទីពីរគ្រាប់ – បាទ/ចាស" នឹងត្រូវចាញ់។
29. "ប៉ែណាល់ទីត្រូវបានផ្តល់ – បាទ/ទេ"។ អតិថិជនគួរទស្សន៍ទាយថា តើការទាត់បាល់ប៉ែណាល់ទីនឹងត្រូវបានផ្តល់ជូនក្នុងការប្រកួតដែរឬទេ។
30. "ប៉ែណាល់ទីត្រូវបានផ្តល់ និងមានការបណ្តេញចេញ – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើមានការទាត់បាល់ប៉ែណាល់ទីនិងការបណ្តេញចេញនៅក្នុងការប្រកួត។
31. "តង់៖ 1x2"។ ការភ្នាល់ត្រូវបានធ្វើឡើងនៅតង់ទីមួយ។ ឧទាហរណ៍ "ក្រុមទី 2 នឹងយកឈ្នះតង់ទីមួយ – បាទ/ចាស"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើក្រុមទី 2 ឈ្នះនៅតង់ទីមួយ។
32. "ពហុបាល់ជ្រុង"។ ចំនួនបាល់ជ្រុងនៅតង់ទីមួយ គុណនឹងចំនួនបាល់ជ្រុងនៅតង់ទីពីរ។ ឧទាហរណ៍៖ មានបាល់ជ្រុងចំនួនប្រាំនៅតង់ទីមួយ និងបាល់ជ្រុងចំនួនប្រាំពីរនៅតង់ទីពីរ។ ដូច្នោះហើយ លទ្ធផលគឺ 5x7=35 ។
33. **"ការទាត់បាល់ប៉ែណាល់ទីកាត់សេចក្តី ឈ្នះ 2 – បាទ/ចាស"**។ ការទាត់បាល់ប៉ែណាល់ទីកាត់សេចក្តីដាច់ខាតត្រូវតែកើតឡើង ហើយក្រុមទី 2 ត្រូវតែយកឈ្នះ ដើម្បីឱ្យការភ្នាល់នេះឈ្នះ។ ការភ្នាល់នឹងចាញ់ ប្រសិនបើគ្មានការទាត់បាល់ប៉ែណាល់ទីកាត់សេចក្តីទេ ឬក្រុមទី 2 ចាញ់ការទាត់បាល់ប៉ែណាល់ទី

កាត់សេចក្តីនោះ។

34. "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត"។
"អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – តង់ទី 1″ – ការភ្នាល់ថាចំនួនគ្រាប់បាល់សរុបក្នុងតង់ទីមួយគឺលើសចំនួនគ្រាប់បាល់សរុបនៅតង់ទីពីរ។
"អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – តង់ទី 2″ – ការភ្នាល់ថាចំនួនគ្រាប់បាល់សរុបក្នុងតង់ទីពីរគឺលើសចំនួនគ្រាប់បាល់សរុបនៅតង់ទីមួយ។
"អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – ស្មើគ្នា″ – ការភ្នាល់ថាចំនួនគ្រាប់បាល់សរុបក្នុងតង់ទីពីរគឺស្មើនឹងចំនួនគ្រាប់បាល់សរុបនៅតង់ទីមួយ។
35. "កីឡាករក្រុម 1/2 បានបាល់នៅពេលផ្លុំកញ្ចែបញ្ចប់ការប្រកួត″។ អតិថិជនត្រូវទស្សន៍ទាយថា តើកីឡាករម្នាក់ពីក្រុមណាដែលនឹងកាន់កាប់បាល់ នៅពេលផ្លុំកញ្ចែបញ្ចប់ការប្រកួត។
36. ការភ្នាល់លើកីឡាករជាក់លាក់ "**សកម្មភាពដែលនឹងកើតឡើងមុនគេ**"៖ (Costa D.) នឹងរកបានគ្រាប់បាល់ប៉ែណាល់ទី; (Costa D.) នឹងទទួលបានកាតក្រហម/លឿង; (Costa D.) នឹងត្រូវបានប្តូរចេញ; (Costa D.) នឹងរកបានមួយគ្រាប់″។
ប៊ិងភ្នាល់មួយ ដែលលទ្ធផលដំបូងបង្អស់ត្រូវបានបញ្ជាក់លើនោះ នឹងត្រូវឈ្នះ។ ឧទាហរណ៍ កាតលឿងត្រូវបានបង្ហាញដល់ Costa D. នៅនាទីទី 15 គាត់រកបានគ្រាប់បាល់នៅនាទីទី 30 ហើយបន្ទាប់មកត្រូវបានប្តូរចេញនៅនាទីទី 40។ ការភ្នាល់ថា "(Costa D.) នឹងទទួលបានកាតក្រហម/លឿង″ នឹងត្រូវឈ្នះ ខណៈពេលដែលការភ្នាល់លើលទ្ធផលផ្សេងទៀតនឹងត្រូវចាញ់។ ប្រសិនបើ Costa D. ខកខានមិនបានចូលរួមក្នុងការលេង នោះរាល់ប្រាក់ដាក់ភ្នាល់ទាំងអស់នឹងត្រូវបានសងមកវិញ (ប្រាក់ភ្នាល់នឹងត្រូវទូទាត់សងតាមហាងឆេង 1)។
37. **បាល់ទាត់។ ពិសេស។ "ការចូលនិវត្តន៍របស់អ្នកចាត់ការបន្ទាប់"** ។ ប្រសិនបើអ្នកចាត់ការលើសពីម្នាក់ចូលនិវត្តន៍នៅថ្ងៃដូចគ្នា នោះការចូលនិវត្តដែលត្រូវបានប្រកាសមុនគេនៅលើវេបសាយផ្លូវការរបស់ក្រុមបាល់ទាត់ នឹងត្រូវបានចាត់ទុកថាជាអ្នកចូលនិវត្តន៍ដំបូងគេ។ រាល់ប្រាក់ភ្នាល់ទាំងអស់ ដែលបានធ្វើឡើងបន្ទាប់ពីការចូលនិវត្តន៍របស់អ្នកចាត់ការនោះ នឹងត្រូវទូទាត់សងតាមហាងឆេង 1 ។ ពេលវេលានិងកាលបរិច្ឆេទនៃការចូលនិវត្តនឹងត្រូវផ្អែកលើព័ត៌មាននៅលើវេបសាយរបស់ក្រុមបាល់ទាត់ ដែលបានបញ្ចប់កិច្ចសន្យារបស់ពួកគេជាមួយនឹងអ្នកចាត់ការនោះ។
38. **បាល់ទាត់។ "អ្នកចាត់ការ"**។ គ្មានអ្នកចាត់ការបណ្តោះអាសន្នណា (បុគ្គលម្នាក់ដែលត្រូវបានតែងតាំងឱ្យបំពេញមុខងារជាអ្នកចាត់ការ) នឹងត្រូវរាប់បញ្ចូលក្នុងការភ្នាល់ទេ។ ប្រសិនបើអ្នកចាត់ការម្នាក់ ដែលមិនមានឈ្មោះក្នុងបញ្ជី ត្រូវបានតែងតាំង នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោយ:។ ប្រសិនបើក្លឹបតែងតាំងនាយកមួយរូប នោះពួកគេនឹងមិនរាប់បញ្ចូលទៅក្នុងការទូទាត់សងប្រាក់ភ្នាល់នៅលើទីផ្សារអ្នកចាត់ការអចិន្ត្រៃយ៍ទេ។
39. **បាល់ទាត់។ "កីឡាករ"** ។ ប្រាក់ភ្នាល់នៅលើទីផ្សារនេះនឹងត្រូវបានទូទាត់សង ដោយមិនគិតកីឡាករខ្វិនជើងទេ លើកលែងតែមានចែងក្នុងផ្នែក "កីឡា″ ("រួមទាំង ការខ្វិនជើង″)។ ប្រសិនបើកីឡាករមិនបានចាកចេញពីក្លឹបបាល់ទាត់ នៅក្នុងអំឡុងពេលបើកការដោះដូរដែលបានបញ្ជាក់ទេនោះរាល់ប្រាក់ភ្នាល់ទាំងអស់នឹងត្រូវបានទុកជាមោយ:។ ប្រសិនបើកីឡាករចុះកិច្ចសន្យាជាមួយក្លឹប ដែលមិនត្រូវបានផ្តល់

តម្លៃជូនទេ នោះការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោយ:។ ប្រសិនបើកិច្ចសន្យាបឋមទាំងអស់ ឬកិច្ចព្រមព្រៀងស្រដៀងគ្នាផ្សេងទៀត ដែលបញ្ជាក់ថាការកិច្ចព្រមព្រៀងត្រូវបានបញ្ចប់យឺតជាងកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងទីផ្សារ នោះពួកគេនឹងមិនរាប់បញ្ចូលក្នុងការទូទាត់សងប្រាក់ភ្នាល់ទេ។

40. **ការភ្នាល់លើការទាត់បាល់ប៉ែណាល់ទីកាត់សេចក្តី** ។ ប្រសិនបើការទាត់បាល់ប៉ែណាល់ទីទីប្រាំមិនត្រូវបានទាត់ នៅក្នុងវគ្គទាត់បាល់ប៉ែណាល់ទីកាត់សេចក្តីទេនោះ ទីផ្សារខាងក្រោមនឹងត្រូវបានបង្វិលសងវិញ៖

"ក្រុមទី 2 នឹងរកបានគ្រាប់បាល់ប៉ែណាល់ទី 5 របស់ពួកគេ – ទេ";

"ក្រុមទី 2 នឹងរកបានគ្រាប់បាល់ប៉ែណាល់ទី 5 របស់ពួកគេ – បាទ/ចាស"។

41. **"កីឡាករនឹងរកបានគ្រាប់បាល់ដំបូង ហើយក្រុមនឹងឈ្នះដោយគ្រាប់បាល់នោះ"។**

អតិថិជនគួរទស្សន៍ទាយថាតើកីឡាករមួយណាដែលនឹងរកគ្រាប់បាល់ដំបូង ហើយស៊ុតបញ្ចូលទីនៅចុងបញ្ចប់នៃម៉ោងធម្មតា (រាប់បញ្ចូលទាំងពម៉ោងបន្ថែម)។ ប្រសិនបើកីឡាករម្នាក់មិនបានចូលរួមក្នុងការប្រកួត ឬត្រូវបានណែនាំជាកីឡាករប្តូរចូល បន្ទាប់ពីគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។ ប្រសិនបើគ្រាប់បាល់ទីមួយជាគ្រាប់បាល់ចូលទីខ្លួនឯង (កីឡាករស៊ុតចូលនៅក្នុងសំណាញ់ក្រុមរបស់ខ្លួនឯង) នោះការភ្នាល់លើកីឡាករដែលបានស៊ុតបាល់បញ្ចូលទី នឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។ ប្រសិនបើការប្រកួតត្រូវបានបង្អាក់ បន្ទាប់ពីការរកគ្រាប់បាល់ដំបូងត្រូវបានស៊ុតបញ្ចូលទី ហើយមិនត្រូវបានបញ្ចប់ក្នុងរយៈពេលដែលមានចែងក្នុងច្បាប់ នោះការភ្នាល់លើកីឡាករដែលបានស៊ុតបាល់បញ្ចូលទីគ្រាប់នេះ នឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។

ការភ្នាល់ទី 1 " Adam Lallana នឹងរកបានគ្រាប់បាល់ដំបូង ហើយក្រុមទី 1 នឹងឈ្នះដោយការស៊ុតបញ្ចូលទី 1–0 – បាទ/ចាស"

ការភ្នាល់ទី 2 "Dejan Lovren នឹងរកបានគ្រាប់បាល់ដំបូង ហើយក្រុមទី 1 ដើម្បីឈ្នះដោយការស៊ុតបញ្ចូលទី 1–0 – បាទ/ចាស"

ឧទាហរណ៍ទី 1 ។

Adam Lallana រកបានគ្រាប់បាល់ដំបូង ហើយក្រុមទី 1 បានឈ្នះដោយលទ្ធផល 1–0 ៖

ការភ្នាល់ទី 1 ឈ្នះ។

ការភ្នាល់ 2 ចាញ់។

ឧទាហរណ៍ទី 2 ។

Adam Lallana មិនបានចូលទីលានលេងទេ ហើយក្រុមទី 1 បានឈ្នះដោយលទ្ធផល 1–0 ៖

ប្រាក់ដាក់ភ្នាល់នៃការភ្នាល់ 1 ត្រូវបានបង្វិលសងវិញ។

ការភ្នាល់ 2 ចាញ់។

42. **លទ្ធផលជម្រើសជំនួស។ "ពិន្ទុសរុប សម្រាប់កាតពិន័យ"**។ អតិថិជនគួរទស្សន៍ទាយចំនួនពិន្ទុដែលទទួលបានដោយក្រុម/ក្រុមនានា សម្រាប់កាតពិន័យនៅក្នុងការប្រកួត។ ការភ្នាល់ត្រូវបានទទួលយកតាមម៉ោងធម្មតា។

- គ្មានកាតពិន័យណាមួយត្រូវបានរាប់បញ្ចូលឡើយ លុះត្រាតែវាត្រូវបានបង្ហាញដល់កីឡាករនៅលើទីលាន;
- កាតលឿងមួយមានតម្លៃ 10 ពិន្ទុ;
- កាតក្រហមមួយមានតម្លៃ 25 ពិន្ទុ;
- ចំនួនពិន្ទុអតិបរមា ដែលត្រូវបានផ្តល់ឱ្យសម្រាប់ការពិន័យកាតលឿងជាលើកទីពីរដែលបណ្តាលឱ្យមានកាតក្រហម គឺ 25 ។ ពិន្ទុទាំងនេះនឹងត្រូវផ្តល់ជូន ល្អិតណាកាតក្រហមត្រូវបានបង្ហាញភ្លាម ។ បន្ទាប់ពីកាតលឿង។

43. **លទ្ធផលជម្រើសជំនួស។ "ពិន្ទុ" (គុណផលរបស់ក្រុម)**។ អតិថិជនគួរទស្សន៍ទាយចំនួនពិន្ទុដែលក្រុមរកបាន ក្នុងអំឡុងពេលប្រកួត។ ការភ្នាល់ត្រូវបានទទួលយកតាមម៉ោងធម្មតា។ គ្មានកាតក្រហមណាមួយត្រូវបានរាប់បញ្ចូលឡើយ លុះត្រាតែវាត្រូវបានបង្ហាញដល់កីឡាករនៅលើទីលាន។ ការទាត់បាល់ជ្រុងដែលត្រូវទាត់បាល់ឡើងវិញ នឹងមិនត្រូវបានចាត់ទុកថាជាការទាត់បាល់ជ្រុងទីពីរទេ ដូច្នេះហើយនឹងមិនទទួលបាន 3 ពិន្ទុបន្ថែមឡើយ។
ពិន្ទុនឹងត្រូវផ្តល់ជូនដូចខាងក្រោម៖
   - 10 ពិន្ទុ សម្រាប់គ្រាប់នីមួយៗ។
   - 5 ពិន្ទុ សម្រាប់ការឈ្នះទល់នឹងសូន្យ;
   - 3 ពិន្ទុ សម្រាប់បាល់ជ្រុងនីមួយៗ។
   - – (ដក) 10 ពិន្ទុ សម្រាប់កាតក្រហមនីមួយៗ។
44. **លទ្ធផលជម្រើសជំនួស។ "ពិន្ទុក្នុងរយៈពេលប្រាំនាទីដំបូង"**។ ការភ្នាល់ដែលធ្វើឡើងក្នុងរយៈពេលប្រាំនាទីដំបូងនៃការលេង នឹងត្រូវបានទូទាត់សង ដោយផ្អែកលើអ្វីដែលកើតឡើងក្នុងចន្លោះពេលចាប់ពីនាទី 0:00 ដល់ 4:59 ។
   - ការទាត់បាល់ជ្រុងដែលត្រូវបានទាត់បាល់ឡើងវិញ នឹងត្រូវរាប់ជាការទាត់បាល់ជ្រុងម្តង;
   - ការទាត់បាល់ប៉ះណាល់ទីដែលត្រូវទាត់ឡើងវិញ តាមការសម្រេចចិត្តរបស់អាជ្ញាកណ្តាល នឹងត្រូវរាប់ជាការពិន័យម្តង។
   - រហូតដល់ទៅ 10 ពិន្ទុអាចរកបានដោយកីឡាករម្នាក់ដែលបានប្រព្រឹត្តខុសចំនួនពីរលើក ទោះបីកាតលឿងត្រូវបានផ្តល់ជូនក្រោយកាតក្រហមក៏ដោយ។ កាតពិន័យណាមួយត្រូវបានរាប់បញ្ចូលលុះត្រាតែវាត្រូវបានបង្ហាញដល់កីឡាកររនោះនៅលើទីលានប៉ុណ្ណោះ។
   ពិន្ទុនឹងត្រូវផ្តល់ជូនដូចខាងក្រោម៖
   - 10 ពិន្ទុ សម្រាប់គ្រាប់នីមួយៗ។
   - 3 ពិន្ទុ សម្រាប់បាល់ជ្រុងនីមួយៗ។
   - 10 ពិន្ទុ សម្រាប់បានប៉ះណាល់ទីនីមួយៗ។
   - 5 ពិន្ទុ សម្រាប់កាតពិន័យនីមួយៗ។
45. **លទ្ធផលជម្រើសជំនួស។ "ពិន្ទុសរុបក្នុងអំឡុងពេលប្រកួត"** ។ អតិថិជនគួរទស្សន៍ទាយចំនួនពិន្ទុដែលក្រុមរកបាន ក្នុងអំឡុងពេលប្រកួត។
   - ការទាត់បាល់ជ្រុងដែលត្រូវបានទាត់បាល់ឡើងវិញ នឹងត្រូវរាប់ជាការទាត់បាល់ជ្រុងម្តង;

- ការទាត់បាល់ប៉ៃណាល់ទីដែលត្រូវទាត់ឡើងវិញ តាមការសម្រេចចិត្តរបស់អាជ្ញាកណ្តាល នឹងត្រូវរាប់ជាការពិន័យម្តង។
- រហូតដល់ទៅ 13 ពិន្ទុអាចរកបានដោយកីឡាករម្នាក់ដែលបានប្រព្រឹត្តខុសចំនួនពីរលើក ទោះបីកាតលឿងត្រូវបានផ្តល់ជូនក្រោយកាតក្រហមក៏ដោយ។ កាតពិន័យណាមួយត្រូវបានរាប់បញ្ចូលលុះត្រាតែវាត្រូវបានបង្ហាញដល់កីឡាកររនោះនៅលើទីលានប៉ុណ្ណោះ។
  ពិន្ទុនឹងត្រូវផ្តល់ជូនដូចខាងក្រោម៖
- 10 ពិន្ទុ សម្រាប់គ្រាប់នីមួយៗ។
- 3 ពិន្ទុ សម្រាប់បាល់ជ្រុងនីមួយៗ។
- 10 ពិន្ទុ សម្រាប់បានប៉ៃណាល់ទីនីមួយៗ។
- 3 ពិន្ទុ សម្រាប់កាតលឿងនីមួយៗ;
- 10 ពិន្ទុ សម្រាប់កាតក្រហមនីមួយៗ។

46. **កាតពិន័យ។ ស្ថិតិ** ។ ការភ្នាល់នឹងត្រូវបានទូទាត់សង ដោយផ្អែកលើព្រឹត្តិការណ៍ទាំងឡាយ ក្នុងអំឡុងម៉ោងធម្មតា។ គ្មានកាតពិន័យណាមួយត្រូវបានរាប់បញ្ចូលឡើយ លុះត្រាតែវាត្រូវបានបង្ហាញដល់កីឡាកររនៅលើទីលាន។
កាតពិន័យដំបូង។ ការភ្នាល់នឹងត្រូវបានទូទាត់សង ផ្អែកលើអ្វីដែលបានកើតឡើងក្នុងចន្លោះពេលនៃការប្រកួតដែលបានកំណត់។ កាតក្រហមឬលឿងត្រូវតែបង្ហាញក្នុងចន្លោះពេលដែលបានកំណត់។ គ្មានកាតពិន័យណាមួយនឹងត្រូវរាប់បញ្ចូលឡើយ ប្រសិនបើការបង្កកំហុសណាមួយដែលបណ្តាលឱ្យមានការព្រមាន (ឬការបណ្តេញចេញ) បានកើតឡើងក្នុងចន្លោះពេលដែលបានកំណត់ ប៉ុន្តែកាតពិន័យត្រូវបានបង្ហាញបន្ទាប់ពីចន្លោះពេលដែលបានកំណត់។
កាតពិន័យសរុប។ ការភ្នាល់នឹងត្រូវបានទូទាត់សង រួមទាំងម៉ោងបន្ថែម (បញ្ឈប់)។ ម៉ោងបន្ថែមនឹងមិនត្រូវបានរាប់បញ្ចូលទេ លុះត្រាតែមានការបញ្ជាក់ផ្សេងពីនេះ។ មានតែកាតពិន័យមួយប៉ុណ្ណោះដែលត្រូវបានរាប់បញ្ចូល សម្រាប់កំហុសដែលអាចកត់ទុកបានជាលើកទីពីរ។ នេះមានន័យថា ប្រសិនបើកាតលឿងត្រូវបានបន្តពីក្រោយភ្លាមៗដោយកាតក្រហម មានតែកាតពិន័យមួយប៉ុណ្ណោះដែលត្រូវបានរាប់សម្រាប់ការភ្នាល់។ ដូច្នោះហើយកីឡាករម្នាក់មិនអាចទទួលបានកាតពិន័យច្រើនជាងពីរកាតក្នុងមួយប្រកួតឡើយ។
កាតពិន័យចុងក្រោយ។ ប្រសិនបើមិនមានកាតពិន័យក្នុងការប្រកួត នោះជម្រើស "គ្មានកាតពិន័យ" នឹងត្រូវឈ្នះ។ រាល់ការភ្នាល់ទាំងអស់ផ្សេងទៀតនឹង ចាញ់។ ប្រសិនបើកីឡាកររពីរឬច្រើននាក់ចូលរួមក្នុងឧប្បត្តិហេតុតែមួយ នោះទីផ្សារនឹងត្រូវបានទូទាត់សងដោយផ្អែកលើកាតពិន័យចុងក្រោយដែលបានបង្ហាញ។

47. **បាល់ទាត់ ជាមួយកីឡាករ ៨ នាក់ក្នុងក្រុមនីមួយៗ។** ការប្រកួតមួយមានពីរតង់ដែលមួយតង់ៗមាន 30 នាទី (លុះត្រាតែអាជ្ញាកណ្តាលនិងក្រុមគូប្រកួតបានយល់ព្រមតាមទ្រង់ទ្រាយផ្សេង)។ ភាគីទាំងអស់ត្រូវតែឈានដល់កិច្ចព្រមព្រៀងមួយ (ឧទាហរណ៍ថា រាល់តង់នីមួយៗគួរតែមានរយៈពេល 25 នាទី ដោយសារភ្លើងបំភ្លឺមិនល្អ) មុនពេលការប្រកួតចាប់ផ្តើម ហើយកិច្ចព្រមព្រៀងបែបនេះត្រូវតែគោរពតាមច្បាប់នៃធ្លណាមិន ។

- ការសម្រាក-ពាក់កណ្តាលម៉ោង មិនត្រូវលើសពី 10 នាទីឡើយ។ រយៈពេលនៃការសម្រាក-ពាក់កណ្តាលម៉ោងអាចត្រូវបានផ្លាស់ប្តូរដោយការព្រមព្រៀងទៅវិញទៅមក រវាងក្រុមបាល់ទាត់ និងអាជ្ញាកណ្តាល។
- មានតែអាជ្ញាកណ្តាលទេដែលអាច កំណត់រយៈពេលបន្ថែមម៉ោងបាន;
- ម៉ោងបន្ថែមត្រូវបានបម្រុងទុក ដើម្បីបង្កើត ការទាត់ 10-ម៉ែត្រ ដែលផ្តល់ជូននៅចុងបញ្ចប់នៃពាក់កណ្តាលតង់ណាមួយ ក្នុងម៉ោងធម្មតា ឬក្នុងម៉ោងបន្ថែម;
- **ម៉ោងបន្ថែម** ។ ច្បាប់នេះអាចចែងនូវរយៈពេលម៉ោងបន្ថែមស្មើគ្នាពីរ។

48. **ការប្រកួតជម្រើសជំនួសនានា** ។ នេះជាកន្លែងដែលការប្រកួតជម្រើសជំនួស ត្រូវបានបង្កើតឡើងពីក្រុមដែលចូលរួមក្នុងការប្រកួតស្រ្តីមផ្សាយផ្ទាល់។ ប្រសិនបើមានការចាញ់នៅក្នុងការប្រកួតមួយនៃការប្រកួតជាក់ស្តែង នោះការភ្នាល់លើការប្រកួតជម្រើសជំនួស នឹងត្រូវបានទូទាត់សងតាមហាងឆេង "1" (លើកលែងតែករណីដែលលទ្ធផលនៃការភ្នាល់ត្រូវបានដឹងរួចហើយ នៅពេលការប្រកួតបានបញ្ឈប់)។ ឧទាហរណ៍។ ការប្រកួតជម្រើសជំនួសនានា៖ U.C. Sampdoria – Hellas Verona W1។ ការប្រកួតជាក់ស្តែង៖ U.C. Sampdoria – Internazionale 2:0, Udinese Calcio – Hellas Verona 0:2 ។ គ្រាប់ស៊ុតនៃការប្រកួតជម្រើសជំនួសU.C. Sampdoria – Hellas Verona គឺ 2:2 ។ ការភ្នាល់ចាញ់ នៅពេលការប្រកួតជម្រើសជំនួសត្រូវបានបញ្ចប់នៅក្នុងលទ្ធផលស្មើគ្នា។
ការប្រកួតជម្រើសជំនួសទ្វេដង។ ក្រុមទាំងអស់ដែលបានចុះបញ្ជីនៅក្នុងទីផ្សារនេះ ត្រូវលេងដំណាលគ្នា។ ការភ្នាល់នឹងត្រូវបានទូទាត់សង ផ្អែកតាមគ្រាប់បាល់នៃការប្រកួតរវាងក្រុមដែលបានបញ្ជាក់។
ឧទាហរណ៍។

Eintracht Braunschweig/Borussia Dortmund – FC Schalke 04/TSG 1899 Hoffenheim – តួតាល់ អូវ័រ 2.5

Eintracht Braunschweig – FC Schalke 04 បានបញ្ចប់ដោយគ្រាប់បាល់ 0:0 ។ Borussia Dortmund – TSG 1899 Hoffenheim បានបញ្ចប់ដោយគ្រាប់បាល់ 2:1 ។ គ្រាប់បាល់រួមបញ្ចូលគ្នារបស់ Eintracht Braunschweig/Borussia Dortmund គឺ 0+2=2 ។ គ្រាប់បាល់រួមបញ្ចូលគ្នារបស់ FC Schalke 04/TSG 1899 Hoffenheim គឺ 0+1=1 ។ គ្រាប់បាល់រួមបញ្ចូលគ្នានៃការប្រកួតទ្វេដង Eintracht Braunschweig/Borussia Dortmund – FC Schalke 04/TSG 1899 Hoffenheim គឺ 2:1 ។ គូទីមួយយកឈ្នះគូទីពីរដោយខុសគ្នាមួយគ្រាប់។ សរុបនៃការប្រកួតទ្វេដងជម្រើសជំនួសគឺ 3 គ្រាប់ ដូច្នេះការភ្នាល់នឹងត្រូវឈ្នះ។

49. FIFA ប្រធានបន្ទាប់។ ប្រធានស្តីទីរបស់ FIFA នឹងមិនរាប់បញ្ចូលសម្រាប់ការភ្នាល់ទេ។

50. **បាល់ទាត់។ ក្រុម។ ការភ្នាល់ពិសេស ។ កីឡាករ។** ការភ្នាល់លើស្ថិតិរបស់កីឡាករនឹងត្រូវរាប់បញ្ចូលបានលុះត្រាតែកីឡាកររនោះបង្ហាញខ្លួនហើយលេងនៅក្នុងការប្រកួតសម្រាប់ក្រុមដែលបានបញ្ជាក់តែប៉ុណ្ណោះ។ កីឡាករត្រូវតែចូលរួម យ៉ាងហោចណាស់ការប្រកួតមួយ។
ឧទាហរណ៍។ បាល់ទាត់។ Liverpool ។ រដូវកាល 2015/16 ។ ព្រីមៀលីគ។ កីឡាករ។ កាតលឿងសរុប ។ មានតែកាតលឿងដែលត្រូវបានបង្ហាញដល់កីឡាករ ខណៈដែលនៅក្នុងជួរក្រុមកីឡាកររបស់ Liverpool FC ប៉ុណ្ណោះ នឹងត្រូវរាប់បញ្ចូលក្នុងការភ្នាល់។ កីឡាករត្រូវតែចូលរួម យ៉ាងហោចណាស់

ការប្រកួតមួយ។

51. បាល់ទាត់។ ស្ថិតិនៃជើងទីមួយនិងជើងទីពីរ។ លទ្ធផលត្រូវបានផ្តល់ឱ្យផ្អែកលើលទ្ធផលនៃជើងទាំងពីរ។ ការភ្នាល់នឹងត្រូវបានទូទាត់ នៅពេលដែលជើងទីពីរបញ្ចប់។
52. **វិធីស៊ុតគ្រាប់បាល់បញ្ចូលទី** ។ ច្បាប់ខាងក្រោមត្រូវបានអនុវត្ត៖
    - គ្រាប់បាល់ចូលទីខ្លួនឯង – ការភ្នាល់នឹងឈ្នះ ប្រសិនបើគ្រាប់បាល់មួយត្រូវបានស៊ុតបញ្ចូលទីខ្លួនឯង។
    - ពីបាល់ប្រ្វីយឺកផ្ទាល់ – ការភ្នាល់នឹងឈ្នះ ប្រសិនបើរកបានគ្រាប់បាល់ដោយការទាត់បាល់ប្រ្វីយឺកផ្ទាល់ដោយកីឡាករដែលទាត់បាល់ប្រ្វីយឺកនោះ ឬរកបានគ្រាប់បាល់ពីការទាត់បាល់ជ្រុងផ្ទាល់។
    - ប៉េណាល់ទី – ការភ្នាល់នឹងឈ្នះ ប្រសិនបើរកបានគ្រាប់បាល់ពីការស៊ុតបាល់ប៉េណាល់ទីដោយកីឡាករទាត់បាល់ប៉េណាល់ទីនោះ។
    - ជាមួយនឹងការតែត (តែតគ្រាប់បាល់បញ្ចូលទី) – ការភ្នាល់នឹងឈ្នះ ប្រសិនបើគ្រាប់បាល់មួយត្រូវបានស៊ុតដោយបាល់ប៉ះចំក្បាលរបស់កីឡាករ។ គ្រាប់បាល់ចូលទីខ្លួនឯងនឹងមិនត្រូវបានរាប់បញ្ចូលសម្រាប់ការភ្នាល់ទេ។
    - ដោយការទាត់ – ការភ្នាល់នឹងឈ្នះ ប្រសិនបើមានគ្រាប់បាល់ស៊ុតបញ្ចូលទីចេញពីការទាត់បាល់។ គ្រាប់បាល់ពីបាល់ប្រ្វីយឺកផ្ទាល់ ប៉េណាល់ទី ឬបាល់ចូលទីខ្លួនឯង មិនត្រូវបានរាប់បញ្ចូលសម្រាប់ការភ្នាល់ទេ។ ប្រសិនបើគ្រាប់បាល់ត្រូវបានស៊ុតបញ្ចូលទីដោយផ្នែកណាមួយនៃរាងកាយរបស់កីឡាករក្រៅពីក្បាល នោះគ្រាប់បាល់នោះនឹងត្រូវបានគិតថាត្រូវបានស៊ុតបញ្ចូលទីដោយការទាត់ ។
    - គ្មានគ្រាប់ស៊ុតបញ្ចូលទី – ការភ្នាល់នឹងឈ្នះ លុះត្រាតែគ្រាប់បាល់ដំបូង (ឬបន្ទាប់) ត្រូវបានស៊ុតបញ្ចូលទី។
53. "ដំណែងរបស់អ្នករកគ្រាប់បាល់"។ ការភ្នាល់នៅលើទីផ្សារនេះ នឹងត្រូវទូទាត់ដោយផ្អែកលើដំណែងផ្លូវការរបស់កីឡាករ។ ដំណែងត្រូវបានកំណត់យោងទៅតាមព័ត៌មាន "ដំណែង" នៅលើ http://www.transfermarkt.co.uk/ ។ សម្រាប់ការប្រកួតរវាងក្រុមជម្រើសជាតិ ដំណែងកីឡាករនឹងត្រូវបានកំណត់យោងតាមបញ្ជីកីឡាករចាប់ផ្តើម នៅលើវេបសាយផ្លូវការនៃធូណាមិន។
54. កីឡាករ ការប្រកួតដោយគ្រាប់ស៊ុតបញ្ចូលទី។ ការភ្នាល់នៅលើទីផ្សារនេះត្រូវបានទូទាត់សងតាមលទ្ធផលនៅពេលចប់ម៉ោងធម្មតា។ ប្រសិនបើកីឡាករដែលជ្រើសរើសមិននៅក្នុងចំណោមនៃឈុតកីឡាករចាប់ផ្តើមលេងទាំង11 នាក់ទេនោះ ការភ្នាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង "1"។
55. ស្ថិតិក្រុមជម្រើសជាតិក្នុងវគ្គចែកពូល។ ទីផ្សារទាំងនេះនឹងត្រូវតូទាត់សងតាមលទ្ធផលនៃការប្រកួតផ្លូវការ ដែលធ្វើឡើងក្នុងពូល។
56. ក្រុមគ្រូពេទ្យត្រូវចាត់ទុកថាបានចូលក្នុងទីលាន តែក្នុងករណីដែលទទួលបានការអនុញ្ញាតពីអាជ្ញាកណ្តាលប៉ុណ្ណោះ និងក្នុងករណីដែលពិតជាត្រូវការផ្តល់ការពិនិត្យ/ព្យាបាលដល់កីឡាករនៅលើទីលាននោះប្រាកដមែនតែប៉ុណ្ណោះ (ការរំរបួស ការធ្វើរោគវិនិច្ឆ័យឃើញថាមានបញ្ហាគាំងបេះដូង ភ្លាម។ ការសង្គ្រោះបឋមដោយការធ្វើចលនាបេះដូង ការវាយតម្លៃវេជ្ជសាស្ត្រ ។ល។)។ ការបង្ហាញខ្លួនរបស់ក្រុមគ្រូពេទ្យ និងការអនុញ្ញាតរបស់អាជ្ញាកណ្តាល នឹងត្រូវធ្វើការបញ្ជាក់តាមការចាក់ផ្សាយតាម

វីដេអូ។ ការដែលអាជ្ញាកណ្តាលហៅក្រុមគ្រូពេទ្យពីរក្រុមក្នុងពេលតែមួយសម្រាប់ក្រុមផ្សេងគ្នា រាប់ជាការបង្ហាញខ្លួនតែមួយលើកដោយក្រុមគ្រូពេទ្យ។កីឡាករដែលត្រូវអមដំណើរដោយក្រុមគ្រូពេទ្យចេញក្រៅទីលាន ក្រុមគ្រូពេទ្យដែលមានវត្តមាននៅក្បែរកីឡាករណាម្នាក់ ដោយពុំមានពិនិត្យ/ព្យាបាលអ្វីទេ រួមនឹងការពិនិត្យ/ព្យាបាលដល់កីឡាករនៅខាងក្រៅទីលាន មិនត្រូវយកមកគិតពិចារណានោះទេ។

57. នៅក្នុងទីផ្សារ "ចម្ងាយគ្របដណ្តប់ដោយកីឡាករម្នាក់" និង "ចម្ងាយគ្របដណ្តប់ដោយក្រុមមួយ" ចម្ងាយត្រូវបានបញ្ជាក់ជាគីឡូម៉ែត្រ ហើយត្រូវបានកំណត់ដោយមិនរាប់បញ្ចូលម៉ោងបន្ថែម និងមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីឡើយ។ ចម្ងាយដែលគ្របដណ្តប់ដោយកីឡាករម្នាក់ (ឬក្រុមមួយ) គួរតែត្រូវបានបង្គត់ទៅខ្ទង់រយគីឡូម៉ែត្រដែលជិតបំផុត។
58. កីឡាករល្អបំផុតប្រចាំការប្រកួត។ ប្រសិនបើកីឡាករមិននៅក្នុងឈុតកីឡាករចាប់ផ្តើមលេងទេ ប៉ុន្តែចូលលេងក្នុងអំឡុងពេលនៃការប្រកួត នោះការភ្នាល់ទាំងអស់លើកីឡាកររនេះនឹងត្រូវមានសុពលភាព។ ប្រសិនបើកីឡាករមិនចូលរួមក្នុងការប្រកួតទេ រាល់ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់សងតាមហាងឆេង 1.00 ។ ក្នុងករណីដែលបាត់ព័ត៌មានពីវេបសាយធូណាមិនផ្លូវការ ការភ្នាល់នឹងត្រូវបានទូទាត់សងដោយយោងតាមព័ត៌មានដែលបានចេញផ្សាយនៅលើគេហទំព័រ https://whoscored.com ។
59. ស្ថិតិក្រុមជម្រើសជាតិក្នុងកម្មវិធីប្រកួត។ ទីផ្សារទាំងនេះនឹងត្រូវបានទូទាត់តាមលទ្ធផលនៃការប្រកួតផ្លូវការ រួមទាំងម៉ោងបន្ថែម (មិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីនិងបាល់ចូលទីខ្លួនឯង) ដែលធ្វើឡើងនៅវគ្គជម្រុះតាមពូលនិងវគ្គជម្រុះ។ ទីផ្សារស្ថិតិរបស់កីឡាករនៅក្នុងការប្រកួត នឹងត្រូវបានទូទាត់សងរួមទាំងម៉ោងបន្ថែម។
60. **"អាជ្ញាកណ្តាលក្នុងទីលាននឹងមើលវីដេអូ – បាទ/ទេ"** – អាជ្ញាកណ្តាលពិចារណាលើអេក្រង់ VAR ។ **"VAR នឹងត្រូវប្រើ – បាទ/ទេ"** ។ ការប្រើប្រាស់ការពិនិត្យមើលវីដេអូ ត្រូវបានកំណត់ដោយផ្អែកលើការចាក់ផ្សាយស្ទ្រីមវីដេអូ ប្រសិនបើមានរឿងណាមួយកើតឡើងដូចខាងក្រោមនេះ៖
    - អាជ្ញាកណ្តាលធ្វើការពិនិត្យវីដេអូឡើងវិញដោយឱ្យសញ្ញាជា (ចតុកោណ);
    - អាជ្ញាកណ្តាលពិចារណាលើអេក្រង់ VAR;
61. **លទ្ធផល។ ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន (កីឡាករ)**។ ទីផ្សារនេះនឹងត្រូវទូទាត់សងដោយផ្អែកលើទិន្នន័យដែលផ្តល់ដោយវេបសាយធូណាមិនផ្លូវការ (រាប់បញ្ចូលទាំងម៉ោងបន្ថែម ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីនិងស៊ុតចូលទីខ្លួនឯង)។
62. **ចំនួនគ្រាប់បាល់ដែលរកបានដោយកីឡាករ (ក្នុងរដូវកាល សេរី)**។ នៅពេលដែលកីឡាករម្នាក់ត្រូវបានផ្ទេរទៅកម្មវិធីប្រកួតជើងឯកផ្សេងទៀត ការភ្នាល់ដែលបានធ្វើរួចហើយនឹងត្រូវទូទាត់តាមហាងឆេង 1 ។ ប្រសិនបើកីឡាករមិនត្រូវបានប្រកាស នៅក្នុងឈុតកីឡាកររផ្តើមលេងទាំង១១នាក់នៃការប្រកួតណាមួយទេ នោះការភ្នាល់លើកីឡាកររនេះនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
63. **លទ្ធផល។ ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន (ក្រុម)**។ លក្ខណៈវិនិច្ឆ័យបន្តបន្ទាប់ខាងក្រោមនឹងត្រូវអនុវត្ត៖ ដំណាក់កាលជម្រុះ ចំណាត់ថ្នាក់ក្នុងគ្រុប ពិន្ទុដែលទទួលបាននៅក្នុងគ្រុប គម្លាតគ្រាប់បាល់នៅទូទាំងធូណាមិន គ្រាប់បាល់ស៊ុតបញ្ចូលទីពេញមួយការប្រកួត (រាប់បញ្ចូលទាំងម៉ោងបន្ថែម ប៉ុន្តែមិនរាប់បញ្ចូលប៉េណាល់ទីកាត់សេចក្តី)។
64. ទីផ្សារ "កីឡាករដែលនឹងរកគ្រាប់បាល់បានច្រើនជាង" (សម្រាប់ធូណាមិនឬជើងឯកមួយ) នឹងត្រូវបាន

ទូទាត់រួមទាំងម៉ោងបន្ថែម ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តីឡើយ។

65. "ក្រុមដែលរកបានគ្រាប់បាល់ដំបូងគេបំផុត"។ អតិថិជនគួរទស្សន៍ទាយថាតើក្រុមមួយណាដែលនឹងរកគ្រាប់បាល់ដំបូងរបស់ពួកគេមុនគេក្នុងចំណោមក្រុមទាំងអស់ ដែលលេងនៅថ្ងៃដែលបានកំណត់។ ប្រសិនបើពេលវេលានៃគ្រាប់បាល់ដំបូងគឺដូចគ្នាៗសម្រាប់ក្រុមជាច្រើន នោះរាល់ការភ្នាល់ទាំងអស់លើក្រុមបែបនេះនឹងត្រូវឈ្នះ។
66. "នឹងត្រូវបញ្ជូនទៅកន្លែងឈរជើង"។ អតិថិជនគួរទស្សន៍ទាយថាតើអាជ្ញាកណ្តាលនឹងបញ្ជូនអ្នកចាត់ការដែលបានបញ្ជាក់ទៅកន្លែងឈរជើងដែរឬទេ។
67. "កីឡាករ ទល់នឹង ក្រុម"។ ទីផ្សារនេះនឹងត្រូវបានទូទាត់តាមលទ្ធផលនៃការប្រកួតផ្លូវការ។ ប្រសិនបើកីឡាករខកខានមិនបានចូលរួមក្នុងការប្រកួត ឬមិនត្រូវបានរាប់បញ្ចូលក្នុងឈុតកីឡាករផ្តើមលេងទាំង 11 នាក់ទេ នោះប្រាក់ដាក់ភ្នាល់នឹងត្រូវបានបង្វិលសងវិញ។ ប្រសិនបើកីឡាករត្រូវបានបណ្តេញចេញឬប្តូរចេញក្នុងអំឡុងពេលប្រកួត នោះការភ្នាល់ទាំងអស់នឹងនៅតែមានសុពលភាព។
68. ការភ្នាល់ "ស្ថិតិ. តើក្រុមមួយណានឹងមានចំនួនគ្រាប់បាល់ច្រើនជាងគេ" នឹងត្រូវទូទាត់សងដោយហាងឆេងស្មើនឹង "1" ប្រសិនបើចំនួនស្មើគ្នានៃគ្រាប់បាល់ត្រូវបានរកបាននៅក្នុងក្រុមនីមួយៗ។
69. "គ្រាប់បាល់សេតភីស"។ គ្រាប់បាល់សេតភីសមួយត្រូវបានស៊ុតចូល ប្រសិនបើកីឡាករមកពីក្រុមទាំងពីរប៉ះបាល់មិនលើសពីពីរដង (រាប់បញ្ចូលទាំងការទាត់បាល់ចាប់ផ្តើម) ពីពេលដែលបាល់ត្រូវបានត្រលប់ទៅការលេង នៅពេលដែលគ្រាប់បាល់ត្រូវបានស៊ុតបញ្ចូលទី។ ការប៉ះដោយអ្នកចាំទីខាងការពារមិនត្រូវបានរាប់បញ្ចូលទេ។ សេត សេតភីសក្នុងបាល់ទាត់រួមមាន ការទាត់បាល់ចេញពីចំនុចកណ្តាលទីលាន ការបោះបាល់ចូលពីខ្សែរជាប់ ការទាត់បាល់ប្រឌីឃីកដោយផ្ទាល់ ការទាត់បាល់ប្រឌីឃីកដោយប្រយោល ការទាត់បាល់ជ្រុង ការទាត់បាល់ប៉េណាល់ទី និងបាល់ដែលបានទម្លាក់។
70. "គ្រាប់បាល់ពីខាងក្រៅតំបន់ប៉េណាល់ទី"។ មានតែគ្រាប់បាល់ពីការលេងបើកចំហប៉ុណ្ណោះដែលនឹងរាប់។
71. ការភ្នាល់លើចំនួនគ្រាប់បាល់ជើងឆ្វេង គ្រាប់បាល់ជើងខាងស្តាំ និងគ្រាប់បាល់តែត។ មិនមានគ្រាប់បាល់ចូលទីខ្លួនឯងនឹងត្រូវបានរាប់ទេ។
72. សម្រាប់ទីផ្សារ "**បាល់ប្រឌីឃីក**" ទាំងបាល់ប្រឌីឃីកដោយផ្ទាល់និងដោយប្រយោលគឺមានសុពលភាពទាំងអស់ (រាប់បញ្ចូលទាំងបាល់ប្រឌីឃីក បន្ទាប់ពីបាល់អកហ្សឺ)។
73. **បាល់ទាត់ក្នុងសាល (បាល់បង្ហាញ)** គឺជាប្រភេទបាល់ទាត់ដែលលេងនៅលើទីលានក្នុងសាល ដែលមានព័ទ្ធជុំវិញដោយស្មៅសិប្បនិម្មិត។ ការប្រកួតមានពីរតង់ ដោយតង់នីមួយៗមានចំនួន 20 នាទី ឬបួនតង់ដោយតង់នីមួយៗមានចំនួន 15 នាទី អាស្រ័យលើកិច្ចព្រមព្រៀងរវាងក្រុមនឹងក្រុម។ ប្រសិនបើការប្រកួតមួយបញ្ចប់ដោយស្មើគ្នាក្នុងម៉ោងធម្មតា នោះការថែមម៉ោងអាចនឹងត្រូវបានផ្តល់ជូន។ ការភ្នាល់ទាំងអស់ត្រូវបានទទួលយកតាមម៉ោងធម្មតា។
74. **ពហុគ្រាប់។** វាចាំបាច់ក្នុងការទស្សន៍ទាយចំនួនគ្រាប់ដែលរកបាន ក្នុងអំឡុងពេលប្រកួត ដោយផ្អែកលើជួរខុសៗគ្នាដែលបានផ្តល់។ ឧទាហរណ៍ ពហុគ្រាប់ 2-4 ។ ការភ្នាល់នឹងឈ្នះ ប្រសិនបើគ្រាប់បាល់ 2 3 ឬ 4 ត្រូវបានរកបាននៅក្នុងការប្រកួត។
75. **គ្រាប់បាល់បន្ទាប់ គ្រាប់ត** ។ វាចាំបាច់ក្នុងការទស្សន៍ទាយថា តើក្រុមមួយណានឹងរកបានគ្រាប់បាល់បន្ទាប់។ ប្រសិនបើមិនមានគ្រាប់បាល់បន្ទាប់នៅក្នុងការប្រកួត នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់សង

តាមហាងឆេង 1 ។

76. កំណត់ត្រាប៉ះគ្នាពីមុន របស់កីឡាករ។ ម៉ោងបន្ថែមគឺត្រូវបានរាប់បញ្ចូល នៅពេលដែលទូទាត់សងប្រាក់ភ្នាល់លើគ្រាប់បាល់ដែលរកបានដោយកីឡាករដែលបានជ្រើសរើស។ នេះមិនរាប់បញ្ចូលពេលម៉ោងបន្ថែមទេ។ ក្នុងករណីដែលយ៉ាងហោចណាស់ មានកីឡាករម្នាក់មិនបានចូលទីលាន កំណត់ត្រាប៉ះគ្នាពីមុននៃកីឡាកររនេះ នឹងត្រូវទូទាត់សងតាមហាងឆេង 1.00 ។ ការភ្នាល់អនុវត្តចំពោះតែឈុតកីឡាករផ្តើមលេងប៉ុណ្ណោះ។
77. ការតទល់គ្នាដែលនាំឱ្យមានការបណ្តេញចេញ។ ការភ្នាល់លើការបណ្តេញកីឡាករចេញត្រូវបានទូទាត់សងរួមទាំងម៉ោងបង្គ្រប់ តែមិនរាប់បញ្ចូលម៉ោងបន្ថែមឡើយ។ ការភ្នាល់លើការបណ្តេញចេញ គឺមានសុពលភាពសម្រាប់កីឡាករដែលបានបញ្ជាក់ប៉ុណ្ណោះ មិនមែនក្រុមទាំងអស់ទេ (លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ)។ BC ផ្តល់លទ្ធផល៖ កីឡាករទល់នឹងកីឡាករ កីឡាករទល់នឹងក្រុម។
78. អំឡុងពេលវេលាដែលគ្មានគ្រាប់បាល់ (មិនរាប់បញ្ចូលពេលម៉ោងបន្ថែម)។ អំឡុងពេលនៃចន្លោះពេលនេះ ត្រូវបានគណនាជាភាពខុសគ្នារវាងនាទីនៃគ្រាប់បាល់ទីមួយ និងការចាប់ផ្តើមនៃការប្រកួត ភាពខុសគ្នានៃនាទីនៃគ្រាប់បាល់បន្ទាប់ណាមួយ និងភាពខុសគ្នារវាងនាទីនៃគ្រាប់បាល់ចុងក្រោយ និងចុងបញ្ចប់នៃការប្រកួត។ ប្រសិនបើគ្មានគ្រាប់បាល់ស៊ុតបញ្ចូលទីក្នុងការប្រកួត នោះរយៈពេលដែលគ្មានគ្រាប់បាល់ស៊ុតបញ្ចូលទីក្នុងការប្រកួតនឹងត្រូវបានគណនាជា 90 នាទី។
    សម្រាប់ការភ្នាល់តាមរយៈពេលដែលគ្មានគ្រាប់បាល់ស៊ុតបញ្ចូលទី ពេលវេលារបស់ក្រុមណាមួយក្នុងការនាំមុខ និងរយៈពេលស្មើគ្នា នោះមានតែនាទីដែលបានបញ្ចប់ប៉ុណ្ណោះត្រូវបានគេយកមកគិតពិចារណា។ ឧទាហរណ៍៖ ប្រសិនបើគ្រាប់បាល់ទីមួយត្រូវបានស៊ុតបញ្ចូលទីនៅម៉ោង 11:01 ហើយគ្រាប់បាល់ទីពីរត្រូវបានស៊ុតបញ្ចូលទីនៅម៉ោង 15:59 នោះ ពេលវេលាដែលគ្មានគ្រាប់បាល់គឺ 3 នាទី (នាទីទី 13 នាទីទី 14 និងនាទីទី 15)។
    ឧទាហរណ៍ទី 2៖ ប្រសិនបើគ្រាប់បាល់មួយគ្រាប់ត្រូវបានស៊ុតបញ្ចូលក្នុងម៉ោងបន្ថែម គ្រាប់បាល់នោះនឹងត្រូវបានគេចាត់ទុកថាត្រូវបានស៊ុតបញ្ចូលទីនៅនាទីទី 90 ហើយនឹងផ្តល់លទ្ធផលក្នុងរយៈពេលពីរតង់ដោយគ្មានគ្រាប់បាលស៊ុតបញ្ចូលទី៖ 89 នាទីពេញលេញ (0–90) និង 0 នាទីពេញលេញ (90 – 90)
79. ការដណ្តើមបាល់។ ដើម្បីទូទាត់សងប្រាក់ភ្នាល់ប្រភេទនេះ ស្ថិតិដែលបានចេញផ្សាយនៅលើគេហទំព័រ https://whoscored.com ត្រូវបានគេយកមកពិចារណា។
80. "ការបណ្តើរបាល់" និង "លោតតែតដណ្តើមបាល់"។ ការភ្នាល់ត្រូវបានទូទាត់ដោយផ្អែកលើទិន្នន័យដែលបានផ្តល់ដោយ whoscored.com ចំណែកឯការទទួលបានជោគជ័យក្នុងការបណ្តើរបាល់និងការឈ្នះលើការលោតតែតដណ្តើមបាល់ត្រូវយកមកបានពិចារណា។
81. **ការតទល់របស់អាជ្ញាកណ្តាល** ។ ការភ្នាល់និងហាងឆេង គឺផ្អែកលើចំនួនពិន្ទុដែលបានកំណត់ចំពោះរាល់ការសម្រេចចិត្ត ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្តាល។
    ពិន្ទុត្រូវបានកំណត់ដូចខាងក្រោម៖
    1 ពិន្ទុ សម្រាប់កាតលឿងមួយ។
    កាតក្រហម ដែលត្រូវបានផ្តល់ជូនបន្ទាប់ពីកាតលឿងចំនួនពីរ មិនត្រូវបានបញ្ចូលទៅពិន្ទុទេ (YC + YC = RC = 2 ពិន្ទុ)។

2 ពិន្ទុ សម្រាប់កាតក្រហមមួយ
0.5 ពិន្ទុ សម្រាប់ការហៅអកហ្សឺមួយ
3 ពិន្ទុ សម្រាប់ប៉េណាល់ទីដែលបានផ្តល់ជូនមួយ
ក្នុងករណីអាជ្ញាកណ្តាលត្រូវបានជំនួស ឬការប្រកួតបានចាប់ផ្តើម ក៏ប៉ុន្តែមិនត្រូវបានបញ្ចប់ (លើកលែងតែលទ្ធផលនៃការភ្នាល់ត្រូវបានកំណត់រួចហើយ នៅពេលដែលការប្រកួតត្រូវបានបញ្ឈប់) ប្រាក់ភ្នាល់អាចត្រូវបានបង្វិលសងវិញ។

82. ការភ្នាល់លើទីផ្សារ "រួមបញ្ចូលទាំងកីឡាករប្តូរជំនួស" នឹងត្រូវចាត់ទុកថាឈ្នះ ប្រសិនកីឡាករដែលបានបញ្ជាក់ ឬ កីឡាករណាម្នាក់ ដែលប្តូរជំនួសកីឡាករទាំងនោះ ក្នុងអំឡុងការប្រកួត (រួមបញ្ចូលទាំងកីឡាករប្តូរជំនួសបន្ទ បន្ទាប់ទាំងអស់ផងដែរ) បំពេញតាម លក្ខខណ្ឌដែលបានផ្តល់ជូន។
ឧទាហរណ៍៖
ការភ្នាល់ត្រូវបានដាក់លើទីផ្សារ "កីឡាករ Gift Orban នឹងស៊ុតបញ្ចូលទី ដោយរួមបញ្ចូលទាំងកីឡាករប្តូរជំនួសផង៖ មែន។"
ក្នុងអំឡុងការប្រកួតនេះ កីឡាករ Gift Orban ត្រូវបានប្តូរជំនួសដោយកីឡាករ Alexander Prass ហើយកីឡាករ Prass ស៊ុតបញ្ចូលទីបាន មួយគ្រាប់។ ការភ្នាល់នឹងត្រូវចាត់ទុកថាឈ្នះ។
   - ការភ្នាល់នេះ រួមបញ្ចូលព្រឹត្តិការណ៍ដែលកើតឡើងក្នុងអំឡុងម៉ោងប្រកួតធម្មតា ដោយរួមបញ្ចូលម៉ោងបន្ថែមរបស់អាជ្ញាកណ្តាលផងដែរ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ ។
   - ប្រសិនបើអ្នកលេងដែលបានបញ្ជាក់ ពុំបានចាប់ផ្តើមការប្រកួតទេ នោះការភ្នាល់ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00។
   - សម្រាប់ការភ្នាល់លើទីផ្សារ "កីឡាករនឹងស៊ុតបញ្ចូលទី ដោយរួមបញ្ចូលទាំងកីឡាករប្តូរជំនួស" មិនរាប់បញ្ចូលគ្រាប់បាល់ចូលទីខ្លួនឯងនោះទេ។
83. ទីផ្សារ "ការប៉ះបាល់លើកដំបូង បន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយ"។ ការភ្នាល់ត្រូវទូទាត់សងដូចខាងក្រោម៖
ទីផ្សារ "ការប៉ះបាល់លើកដំបូង បន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយ - W1/W2” នឹងត្រូវប្រកាសលទ្ធផលថាឈ្នះ ប្រសិនបើការប៉ះបាល់លើកដំបូងបន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយ ត្រូវបានធ្វើឡើងដោយកីឡាម្នាក់ពីក្រុមប្រកួតណាមួយ។ ប្រសិនបើអាជ្ញាកណ្តាលផ្លុំកញ្ចែពិន័យ បន្ទាប់ពីការទាត់បាល់ជ្រុង ដូច្នេះ ការប៉ះបាល់នឹងត្រូវផ្តល់ទៅឱ្យក្រុមដែលអ្នកលេងរបស់ខ្លួនជាអ្នកដាក់កែបាល់ឱ្យលេង។
ទីផ្សារ "ការប៉ះបាល់លើកដំបូង បន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយ – មិនមែនទាំងពីរ″ នឹងត្រូវប្រកាសលទ្ធផលថាឈ្នះ ប្រសិនបើបន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយរួច បាល់នោះមិនត្រូវបានកីឡាណាម្នាក់ប៉ះ ហើយបាល់នោះចេញពីទីលាន។ទីផ្សារ "ការប៉ះបាល់លើកដំបូង បន្ទាប់ពីការទាត់បាល់ជ្រុងលើកទីមួយ - W1/W2/មិនមែនទាំងពីរ″ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00 ប្រសិនបើគ្មានការទាត់បាល់ជ្រុងក្នុងអំឡុងការប្រកួតទេ។

10.27. ហ្វូតសាល់

1. ប្រាក់ភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមលទ្ធផលចុងក្រោយ នៅពេលចប់ម៉ោងធម្មតា (ការលេង 40 នាទី ដែលមានពីរតង់ ដោយតង់នីមួយៗមាន 20 នាទី)។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួត ឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញ ប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី ពីសញ្ញាសំគាល់ចម្ងាយ 6 ម៉ែត្រ នឹងត្រូវរាប់បញ្ចូលសម្រាប់ទីផ្សារដូចតទៅនេះ៖ ការជម្រុះទៅជុំបន្ទាប់ អ្នកឈ្នះនៃធូណាមិន និងស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានល័ក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
4. យ៉ាងហោចណាស់ 35 នាទីនៃការលេងត្រូវតែកន្លងផុត ដើម្បីឱ្យការប្រកួតត្រូវប្រកាសជាផ្លូវការបាន។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផល នៅពេលការប្រកួតត្រូវបានបញ្ឈប់ ។

10.28. ហុកគីលើទឹកាល

1. ប្រាក់ភ្នាល់ទាំងអស់ត្រូវបានទូទាត់តាមលទ្ធផលចុងក្រោយ នៅពេលចប់ម៉ោងធម្មតា (2 ពាក់កណ្តាលនៃ 35 នាទីឬ 4 ពាក់កណ្តាលនៃ 15 នាទី។)។
   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួត ឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញ ប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. ការថែមម៉ោងនិងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី នឹងត្រូវរាប់បញ្ចូលសម្រាប់ទីផ្សារដូចតទៅនេះ៖ ការជម្រុះទៅជុំបន្ទាប់ អ្នកឈ្នះនៃធូណាមិន និងស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានល័ក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
4. យ៉ាងហោចណាស់ 60 នាទីនៃការលេងត្រូវតែកន្លងផុត ដើម្បីឱ្យការប្រកួតត្រូវប្រកាសជាផ្លូវការបាន។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផល នៅពេលការប្រកួតត្រូវបានបញ្ឈប់ ។
5. ហុកគីក្នុងសាល គឺជាទម្រង់ផ្សេងទៀតនៅក្នុងសាលរបស់ហុកគី។ ការប្រកួតមួយមាន 2 តង់ ហើយតង់នីមួយៗមាន20 នាទី។

10.29. បេនឌី

1. ប្រាក់ភ្នាល់ទាំងអស់ត្រូវបានទូទាត់សងតាមលទ្ធផលចុងក្រោយ នៅពេលចប់ម៉ោងធម្មតា (ការលេង 90 នាទី មានពីរតង់ ដោយតង់នីមួយៗមានចំនួន 45 នាទី ឬមានបីតង់ ដោយតង់នីមួយៗមានចំនួន 30 នាទី)។

   ក្រុមហ៊ុនភ្នាល់ មិនទទួលខុសត្រូវចំពោះការប្រកាសមិនត្រឹមត្រូវណាមួយ អំពីរយៈពេលនៃការប្រកួតឡើយ។ ព័ត៌មានលម្អិត ដែលបង្ហាញនៅក្នុងផ្នែក "កីឡា" និង "ផ្សាយផ្ទាល់" គ្រាន់តែជាការចង្អុលបង្ហាញប៉ុណ្ណោះ។ អតិថិជនគួរតែពិនិត្យមើលច្បាប់ពីប្រភពផ្លូវការ ។
2. ការថែមម៉ោងនឹងត្រូវរាប់បញ្ចូលសម្រាប់ទីផ្សារដូចតទៅនេះ៖ ដើម្បីជាប់ជម្រុះ ទៅជុំបន្ទាប់ នឹងជាប់ជម្រុះទៅលើគម្ងួយផ្សេងទៀត អ្នកឈ្នះនៃធូណាមិន និងស្រដៀងគ្នា។
3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះ នឹងត្រូវបានទូទាត់តាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយដោយគ្មានល័ក្ខខណ្ឌ នៅពេលការប្រកួតត្រូវបានអាក់ខាន។
4. យ៉ាងហោចណាស់ 80 នាទីនៃការលេងត្រូវតែកន្លងផុត ដើម្បីឱ្យការប្រកួតត្រូវប្រកាសជាផ្លូវការបាន។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផល នៅពេលការប្រកួតត្រូវបានបញ្ឈប់ ។
5. ហុកគីអីនឡាញ គឺជាកីឡាជាក្រុមដែលកីឡាករពាក់សំលៀកបំពាក់ជិះស្គី និងប្រើគ្រាប់ហុកគីឬបាល់។ ការប្រកួតមានរយៈពេលបួនតង់ ដោយតង់នីមួយៗមានចំនួន 12 នាទី។

10.30. ហុកគីលើទឹកកក

1. ការភ្នាល់នៅលើទីផ្សារក្នុងផ្នែក "កីឡា" ត្រូវបានទទួលយកតាមម៉ោងធម្មតា (ការលេង 60 នាទី ដែលមាន 3 តង់ ដោយតង់នីមួយៗមាន 20 នាទី) លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ (រួមទាំងម៉ោងបន្ថែម បើមានស្លាក "ជាមួយម៉ោងបន្ថែម" ឬរាប់បញ្ចូលទាំងការថែមម៉ោងនិងការទាត់បាល់ប៉េណាល់ទីកាត់សេចក្តី បើមានស្លាក "រួមបញ្ចូលទាំងម៉ោងបន្ថែម និងការទាត់បាល់ប៉េណាល់ទី") ។
2. ការភ្នាល់នៅលើទីផ្សារក្នុងផ្នែក "ផ្សាយផ្ទាល់" ត្រូវបានទទួលយកតែតាមម៉ោងធម្មតាប៉ុណ្ណោះ។ ការភ្នាល់ផ្សាយផ្ទាល់លើ KHL និង NHL ត្រូវបានទទួលយក៖
   - នៅម៉ោងធម្មតា
   - នៅម៉ោងធម្មតា រាប់បញ្ចូលទាំងម៉ោងបន្ថែម (ដាក់ស្លាក "ជាមួយម៉ោងបន្ថែម")។
   - នៅម៉ោងធម្មតា រាប់បញ្ចូលទាំងម៉ោងបន្ថែមនិងប៉េណាល់ទីកាត់សេចក្តី (ដាក់ស្លាក "រួមទាំង ម៉ោងបន្ថែមនិងប៉េណាល់ទីកាត់សេចក្តី")។

     ឧទាហរណ៍ទី 1 ។ Buffalo Sabres – Toronto Maple Leafs (រួមទាំងម៉ោងបន្ថែមនិងប៉េណាល់ទីកាត់សេចក្តី)។ ក្នុងករណីនេះ ការភ្នាល់ត្រូវបានទទួលយកនៅម៉ោងធម្មតា រួមទាំងការថែមម៉ោង

និងប៉ែណាល់ទីកាត់សេចក្តី។ ពិន្ទុនៃការប្រកួតគឺ 2:3 (1:0, 1:1, 0:1, 0:0, 0:1)។ រាល់ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់ដោយផ្អែកលើពិន្ទុចុងក្រោយ 2:3 ។ ចំនួនគ្រាប់បាល់សរុបសម្រាប់គោលបំណងការភ្នាល់គឺ 5 ។

ឧទាហរណ៍ទី 2 ។ Buffalo Sabres – Toronto Maple Leafs (រួមទាំងម៉ោងបន្ថែម OT) ។ ក្នុងករណីនេះ ការភ្នាល់ត្រូវបានទទួលយកតាមម៉ោងធម្មតា រួមទាំងការថែមម៉ោង។ ពិន្ទុចុងក្រោយសម្រាប់គោលបំណងនៃការភ្នាល់គឺ 2:2 (1:0, 1:1, 0:1; 0:0)។ សរុប ចំនួនគ្រាប់បាល់សម្រាប់គោលបំណងការភ្នាល់គឺ 4 ។ ការភ្នាល់ W1 និង W2 នឹងចាញ់។

ឧទាហរណ៍ 3 ។Buffalo Sabres – Toronto Maple Leafs ។ ក្នុងករណីនេះការភ្នាល់ត្រូវបានទទួលយកតាមម៉ោងធម្មតាប៉ុណ្ណោះ។ ពិន្ទុចុងក្រោយសម្រាប់គោលបំណងនៃការភ្នាល់គឺ 2:2 (1:0, 1:1, 0:1)។ ចំនួនគ្រាប់បាល់សរុបសម្រាប់គោលបំណងការភ្នាល់គឺ 4 ។ ការភ្នាល់ W1 និង W2 នឹងចាញ់។

3. ប្រសិនបើការប្រកួតចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ រាល់ការភ្នាល់ទាំងអស់នៅលើនោះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1 លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានបញ្ឈប់។
4. យ៉ាងហោចណាស់ ត្រូវលេខឱ្យផុត 55 នាទីសិន ទើបការភ្នាល់មានសុពលភាពបាន។ នៅក្នុងករណីនេះ ការភ្នាល់ទាំងអស់នឹងត្រូវបានទូទាត់សង ដោយផ្អែកលើលទ្ធផលនៅពេលការប្រកួតត្រូវបានបញ្ឈប់។
5. NHL, AHL, CHL, OHL, WHL និងលីគហុកគីឆ្មេរខាងកើត អាចត្រូវបានបង្ហាញតាមលំដាប់ផ្ទាល់ (ក្រុមម្ចាស់ផ្ទះ – ក្រុមភ្ញៀវ) និងតាមលំដាប់បញ្ច្រាស។ ប្រសិនបើជាករណីចុងក្រោយ គ្មានប្រាក់ភ្នាល់ណាត្រូវបានបង្វិលសងវិញទេ។
6. "តូតាល់"។ នៅពេលដែលប៉ែណាល់ទីកាត់សេចក្តីត្រូវបានគេពិចារណា រាល់ការស៊ុតបាល់បញ្ចូលទីទាំងអស់ដោយក្រុមដែលឈ្នះ នឹងត្រូវបានចាត់ទុកថាជាគ្រាប់បាល់មួយសម្រាប់គោលបំណងទូទាត់សង រីឯគ្រាប់បាល់ដែលរកបានដោយការទាត់បាល់ដោយក្រុមចាញ់នឹងត្រូវចាត់ទុកថាជាគ្រាប់សូន្យ។
7. "គ្រាប់បាល់ពីនាទីទី 1 ដល់នាទីទី 7"។ ប្រសិនបើគ្រាប់បាល់មួយត្រូវបានគេរកបាននៅនាទីទី 7 វិនាទី 00 វាត្រូវបានគេគិតថាបានរកគ្រាប់បាល់នៅនាទីទី 8 ។
8. ការភ្នាល់នៅលើទីផ្សារខាងក្រោមត្រូវបានទូទាត់សង ដោយផ្អែកលើកំណត់ត្រាចុងក្រោយឬសេរីនៃដែលរៀបចំព្រឹត្តិការណ៍ជាផ្លូវការ៖ "ចំណាត់ថ្នាក់ខ្ពស់ជាងគេ នៅចុងបញ្ចប់នៃធូណាមិន" "ជើងឯកនៃកម្មវិធីប្រកួត" "អ្នកឈ្នះនៃគ្រុប" "ពិន្ទុដែលបានស៊ុតបញ្ចូលទី" "គ្រាប់បាល់ស៊ុតបញ្ចូលទី" និង "គ្រាប់ដែលត្រូវគេស៊ុតបញ្ចូលទី"។
9. ការភ្នាល់ "អំឡុងពេល () > អំឡុងពេល () – បាទ / ចាស" នឹងចាញ់ ប្រសិនបើចំនួនស្មើនៃគ្រាប់បាល់ត្រូវបានស៊ុតបញ្ចូលក្នុងអំឡុងពេលទាំងពីរដែលបានបញ្ជាក់។
10. ការភ្នាល់លើទីផ្សារ "អ្នក (ប្រទេស) អ្នករកគ្រាប់បាល់បានច្រើនជាងគេ ក្នុងធូណាមិន" ត្រូវបានទូទាត់សង ដោយផ្អែកលើចំណាត់ថ្នាក់ចុងក្រោយជាផ្លូវការ ដែលចំនួនសរុបនៃគ្រាប់បាល់បញ្ចូលទីនិងជំនួយត្រូវបានគេគិត។ រាល់ការភ្នាល់តទាំងអស់ស្រូវបានរាប់បញ្ចូលទាំងការថែមម៉ោង ប៉ុន្តែមិនរាប់បញ្ចូលការស៊ុតបាល់ប៉ែណាល់ទីកាត់សេចក្តីទេ។ ប្រសិនបើកីឡាករខកខានមិនបានចូលទៅកាន់ទីលានទឹកកកនោះការភ្នាល់លើពួកគេនឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។ ប្រសិនបើកីឡាករពីរនាក់ឬច្រើននាក់

មានពិន្ទុស្មើគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។

11. "ក្រុមនឹងឈ្នះ និងតូតាល់អាន់ឌ័រ/អូវ័រ"។ អតិថិជនគួរទស្សន៍ទាយថាតើក្រុមណានឹងឈ្នះការប្រកួត និងចំនួនគ្រាប់បាល់ដែលរកបាន (ច្រើនឬតិចជាងចំនួនដែលបានបញ្ជាក់) ។ ការភ្នាល់លើ NHL និង KHL ក៏ដូចជាលើការប្រកួតដែលបង្កើតជាផ្នែកមួយនៃកម្មវិធីជើងឯកផ្សេងទៀតនិងធួណាមិនអន្តរជាតិនានា ត្រូវបានទទួលយកតាមម៉ោងធម្មតា។
12. "ការប្រណាំងយក 3 (5 ។ល។) ពិន្ទុ"។ អតិថិជនគួរទស្សន៍ទាយថាតើអ្នកចូលរួមណានឹងក្លាយជាអ្នកដំបូងគេដែលរកពិន្ទុក្នុងចំនួនដែលបានបញ្ជាក់នៅក្នុងការប្រកួត។ ប្រសិនបើអ្នកចូលរួមណាម្នាក់បដិសេធមិនបន្ត ដោយសារមូលហេតុណាមួយ មុនពេលពួកគេឬគូប្រជែងរបស់ពួកគេ រកបានពិន្ទុដែលបានបញ្ជាក់ នោះប្រាក់ភ្នាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង 1។
13. "ក្រុមទី 2 ឈ្នះក្នុងម៉ោងបន្ថែម – ទេ"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើមិនមានម៉ោងបន្ថែម ឬក្រុមទី 2 ចាញ់ក្នុងម៉ោងបន្ថែម។ ការភ្នាល់លើការឈ្នះក្នុងការស៊ុតបាល់ប៉េណាល់ទីកាត់សេចក្តី ត្រូវបានទូទាត់សងតាមរបៀបដូចគ្នា។
14. "ការទទួលជ័យជម្នះនៅម៉ោងបន្ថែម"។ អ្នកឈ្នះត្រូវតែកំណត់ក្នុងម៉ោងបន្ថែម (OT)។
    ពិន្ទុគឺ (0:0; 1:1; 1:0) – ការភ្នាល់ចាញ់។
    ពិន្ទុគឺ (0:0; 1:1; 0:0; 0:1) – ការភ្នាល់ឈ្នះ។
    ពិន្ទុគឺ (0:0; 1:1; 0:0; 0:0; 1:0) – ការភ្នាល់ចាញ់។
15. ការភ្នាល់នៅលើទីផ្សារដែលមានស្លាក **"ម៉ោងប៉េណាល់ទីសរុប"** ត្រូវបានធ្វើឡើងតាមចំនួននាទីដែលកីឡាករបំពានត្រូវចំណាយនៅក្នុងប្រអប់ប៉េណាល់ទីសម្រាប់ការរំខានមួយ។ មានតែ ម៉ាយណ័រប៉េណាល់ទីដែលមានត្រឹមតែពីរនាទីប៉ុណ្ណោះ នឹងត្រូវរាប់។ ម៉ាយណ័រប៉េណាល់ទីទ្វេដង (2+2) ត្រូវបានចាត់ទុកជាប៉េណាល់ទីពីរផ្សេងគ្នា។ នាទីបាល់ប៉េណាល់ទី ដែលត្រូវបានផ្តល់មុនពេលចាប់ផ្តើមនៃអំឡុងពេលមួយ (ការប្រកួត) ឬបន្ទាប់ពីការបញ្ចប់អំឡុងពេលមួយ (ការប្រកួត) និងដែលត្រូវបានបញ្ជាក់នៅក្នុងកំណត់ត្រាចុងក្រោយនៃការប្រកួតនោះ នឹងរាប់បញ្ចូលក្នុងការភ្នាល់។ ចំនួននាទីប៉េណាល់ទីនឹងត្រូវបានកំណត់ដោយផ្អែកលើកំណត់ត្រាផ្លូវការ។
    ការភ្នាល់នៅលើទីផ្សារដែលមានស្លាក **"ម៉ាយណ័រប៉េណាល់ទីសរុប"** ត្រូវបានធ្វើឡើងតាមចំនួនម៉ាយណ័រប៉េណាល់ទី។
16. ការភ្នាល់នៅលើទីផ្សារដែលមានស្លាក "ស៊ុតសំដៅទី"។ ចំនួននៃការស៊ុតបញ្ចូលទី នឹងត្រូវបានកំណត់តែលើមូលដ្ឋាននៃកំណត់ត្រាផ្លូវការប៉ុណ្ណោះ។
17. តូតាល់ឯកត្តជនរបស់កីឡាករ (ក្នុងហុកគីលើទឹកកក)។ អតិថិជនគួរទស្សន៍ទាយចំនួនពិន្ទុសរុបដែលរកបានដោយកីឡាករម្នាក់ ដោយពិន្ទុត្រូវបានផ្តល់ជូនសម្រាប់គ្រាប់បាល់និងជំនួយ។ រាល់ការភ្នាល់ទាំងអស់លើចំនួនពិន្ទុតូតាល់ឯកត្តជនរបស់កីឡាករ ត្រូវបានទទួលយកតែតាមម៉ោងធម្មតាប៉ុណ្ណោះ។ ប្រសិនបើកីឡាករខកខានមិនបានចូលទៅកាន់ទីលានទឹកកកនោះការភ្នាល់លើពួកគេនឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។
18. "ក្រុមដែលនឹងរកបានគ្រាប់មុនដំបូងគេ ហើយឈ្នះការប្រកួត"។ ការភ្នាល់នេះត្រូវបានទទួលយកតែតាមម៉ោងធម្មតាប៉ុណ្ណោះ។

19. "ក្រុមទី 1 រកបានគ្រាប់មុនដំបូងគេ ហើយឈ្នះការប្រកួត – ទេ"។ ការភ្នាល់នេះនឹងឈ្នះ ប្រសិនបើក្រុមទី 1 មិនបានរកគ្រាប់ដំបូងគេទេ ឬប្រសិនបើពួកគេមិនឈ្នះការប្រកួតទេ។
20. "ពិន្ទុសរុបចន្លោះពី 6 ដល់ 8 – ទេ"
    ឧទាហរណ៍៖
    "ពិន្ទុសរុបចន្លោះពី 6 ដល់ 8 – ទេ"។ ពិន្ទុគឺ (2:3)។ ចំនួនពិន្ទុសរុបគឺ 5 ។ ការភ្នាល់ឈ្នះ។
    "ពិន្ទុសរុបចន្លោះពី 6 ដល់ 8 – ទេ"។ ពិន្ទុគឺ (3:4)។ ចំនួនពិន្ទុសរុបគឺ 7 ។ ការភ្នាល់ចាញ់។
21. គ្រាប់ស៊ុតបញ្ចូលទីសរុបក្នុងពេលលេងជាវ័រ។ អតិថិជនគួរទស្សន៍ទាយចំនួនគ្រាប់ដែលបានស៊ុតចូលក្នុងស្ថានភាពលេងជាវ័រ។
    ឧទាហរណ៍។ ក្រុមទី 1 រកបានមួយគ្រាប់ ខណៈពេលលេងជាវ័រ។ ក្រុមទី 2 រកបានមួយគ្រាប់ ខណៈពេលលេងជាវ័រ។ ដូច្នោះហើយមានតែការស៊ុតបញ្ចូលទីតែមួយគ្រាប់ប៉ុណ្ណោះ ក្នុងអំឡុងពេលលេងជាវ័រនៅក្នុងការប្រកួត។
    ការភ្នាល់ "គ្រាប់ស៊ុតបញ្ចូលទីសរុបក្នុងពេលលេងជាវ័រ អាន់ឌ័រ 1.5" នឹងត្រូវឈ្នះ។
    ការភ្នាល់ "គ្រាប់ស៊ុតបញ្ចូលទីសរុបក្នុងពេលលេងជាវ័រ អូវ័រ 1.5" នឹងត្រូវចាញ់។
22. "គ្រាប់សំណាញ់ទីទទេនឹងត្រូវបានស៊ុតបញ្ចូលទី"។ ការភ្នាល់នឹងឈ្នះ ប្រសិនបើនៅពេលដែលត្រូវបានស៊ុតបញ្ចូលទី អ្នកចាំទីមិននៅលើទីលានទឹកកក (ឧទាហរណ៍ ប្រសិនបើអ្នកចាំទីត្រូវបានជំនួសដោយអ្នកជិះស្គី)។
23. "ចំនួនសរុបនៃហាត-ទ្រីគ (3 គ្រាប់ដោយកីឡាករម្នាក់) អូវ័រ 0.5" មានតែគ្រាប់ដែលបានស៊ុតបញ្ចូលទីនឹងត្រូវរាប់ (មិនមានជំនួយណាមួយនឹងត្រូវបានគេយកមកពិចារណា នៅពេលកំណត់ហាត-ទ្រីគឡើយ)។
24. "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត"។
    "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – 1" – ក្រុមទាំងអស់នឹងរកគ្រាប់បានច្រើនក្នុងតង់ទីមួយជាងតង់ទីពីរឬទីបី។
    "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – 2" – ក្រុមទាំងអស់នឹងរកគ្រាប់បានច្រើនក្នុងតង់ទីពីរជាងតង់ទីមួយឬទីបី។
    "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – 3" – ក្រុមទាំងអស់នឹងរកគ្រាប់បានច្រើនក្នុងតង់ទីបីជាងតង់ទីមួយឬទីពីរ។
    "អំឡុងពេលដែលមានពិន្ទុខ្ពស់បំផុត – ស្មើ" – ក្រុមទាំងអស់នឹងរកគ្រាប់បានស្មើ (ខ្ពស់បំផុត) ក្នុងតង់យ៉ាងហោចណាស់ពីរ។
25. ការភ្នាល់លើការប្រកួតនៅក្នុង KHL Nadezhda Cup នឹងត្រូវទទួលយកតែតាមម៉ោងធម្មតាប៉ុណ្ណោះ។ លទ្ធផលនៃការប្រកួតត្រូវបានកំណត់នៅចុងបញ្ចប់នៃម៉ោងធម្មតា (ការប្រកួតអាចបញ្ចប់ដោយលទ្ធផលស្មើ)។
26. ការភ្នាល់លើការប្រកួតនៅលីគហុកគីរុស្ស៊ី អាចត្រូវបានទូទាត់សងក្នុងរយៈពេល 72 ម៉ោងបន្ទាប់ពីចប់ការប្រកួត។
27. "អ្នកឈ្នះការប្រកួត"។ ការភ្នាល់ត្រូវបានទូទាត់យោងទៅតាមច្បាប់នៃធូណាមិន ដែលការប្រកួតត្រូវបានធ្វើឡើង។ ឧទាហរណ៍ ការភ្នាល់លើទីផ្សារ "អ្នកឈ្នះប្រចាំការប្រកួត" ទាក់ទងនឹងរដូវកាលធម្មតារបស់

NHL ត្រូវបានទូទាត់រួមទាំងម៉ោងបន្ថែមនិងប៉េណាល់ទីកាត់សេចក្តី។ ការភ្នាល់លើទីផ្សារ "អ្នកឈ្នះប្រចាំការប្រកួត" ទាក់ទងនឹងការប្រកួត វគ្គជម្រុះ ត្រូវបានទូទាត់រួមទាំងម៉ោងបន្ថែម។

28. "អ្នកឈ្នះប្រចាំគ្រុប" "ស្ថិតិ"។ ស្ថិតិត្រូវបានកំណត់ដោយផ្អែកលើលទ្ធផលរបស់ក្រុម ដែលរួមមានការថែមម៉ោង ប៉ុន្តែមិនរាប់បញ្ចូលប៉េណាល់ទីកាត់សេចក្តីទេ។
29. **ការប្រកួតជម្រើសជំនួសនានា** ។ សម្រាប់ទីផ្សារនេះ លទ្ធផលនៃការប្រកួតដែលចាក់ផ្សាយផ្ទាល់ត្រូវបានប្រៀបធៀប។ ប្រសិនបើការប្រកួតណាមួយត្រូវបានលុបចោល នោះការភ្នាល់លើការប្រកួតជំនួសនឹងត្រូវទូទាត់តាមហាងឆេង 1 (ប្រាក់ភ្នាល់នឹងត្រូវបានសងប្រាក់វិញ)។

ឧទាហរណ៍។ ការប្រកួតជម្រើសជំនួសនានា។ Avangard – Sibir ។ តួតាល់អូវើ 5.5 ។ ការប្រកួតជាក់ស្តែងគឺ Avangard – Salavat Yulayev ដែលបញ្ចប់ដោយពិន្ទុ 4:1 និង Metallurg – Sibir ដែលបញ្ចប់ដោយពិន្ទុ 1:2 ។ ពិន្ទុនៃការប្រកួតជំនួស Avangard - Sibir ដូច្នេះគឺ 4:2 ។ ការភ្នាល់នឹងឈ្នះ ព្រោះចំនួនគ្រាប់សរុបក្នុងការប្រកួតជំនួសស្មើ 6 ។

ការប្រកួតជម្រើសជំនួសទ្វេដង។ ក្រុមទាំងអស់ដែលបានបញ្ជាក់នៅក្នុងប្រភេទទីផ្សារនេះ ត្រូវលេងដំណាលគ្នា។ ពិន្ទុ ដែលក្រុមនោះបញ្ចប់ការប្រកួតពិតប្រាកដរបស់ពួកគេជាមួយ នឹងត្រូវបានរាប់បញ្ចូលសម្រាប់ការភ្នាល់។

ឧទាហរណ៍។

Torpedo/SKA – Dinamo/CSKA តួតាល់អានឌ័រ 7.5

ការប្រកួត Torpedo – CSKA បានបញ្ចប់ដោយលទ្ធផល 3:2 ។ ការប្រកួត SKA - Dinamo បានបញ្ចប់ដោយលទ្ធផល 2:1 ។ ពិន្ទុរួម Torpedo/SKA ស្មើ 3+2=5 ។ ពិន្ទុរួមបញ្ចូលគ្នា Dinamo/CSKA ស្មើ 1+2=3 ។ ពិន្ទុរួម Torpedo/SKA – Dinamo/CSKA គឺ 5:3 ។ ចំនួនគ្រាប់សរុបក្នុងការប្រកួតជំនួសស្មើ 8 ។ ការភ្នាល់ចាញ់។

30. **អ្នករកគ្រាប់បាល់បានច្រើនជាងគេ** ។ លក្ខណៈវិនិច្ឆ័យបន្តបន្ទាប់ត្រូវបានអនុវត្ត៖ ពិន្ទុដែលទទួលបានក្នុងធួណាមិនទាំងមូល គ្រាប់បញ្ចូលទីនៅទូទាំងធួណាមិន ចំនួននៃការប្រកួតតិចតួចបំផុតបានលេង។ ការភ្នាល់ត្រូវបានទូទាត់សងដោយមិនរាប់បញ្ចូលម៉ោងបន្ថែមនិងប៉េណាល់ទីកាត់សេចក្តី។
31. **"ម៉ាយណ៍រប៉េណាល់ទីសរុប"**។ អតិថិជនគួរទស្សន៍ទាយពីម៉ាយណ៍រប៉េណាល់ទីសរុបនៅក្នុងការប្រកួត។
32. "គ្រាប់សរុបដែលរកបានដោយកីឡាករម្នាក់"។ អតិថិជនគួរទស្សន៍ទាយចំនួនគ្រាប់សរុបដែលរកបាននៅក្នុងសំណាញ់របស់ក្រុមគូប្រកួតដោយកីឡាជាក់លាក់។
33. "ស្ថិតិកំពូល បូក–ដក (រួមទាំងម៉ោងបន្ថែម)"។ ការភ្នាល់ត្រូវបានទូទាត់យោងតាមច្បាប់ដូចតទៅ៖ ក្រុមមួយ ដែលមានសមាជិកតិចជាងឬចំនួនសមាជិកដូចគ្នានឹងក្រុមប្រឆាំង រកគ្រាប់បានមួយគ្រាប់ (ការស៊ុតប៉េណាល់ទីមិនត្រូវបានរាប់បញ្ចូល) ហើយកីឡាកររបស់ក្រុមនេះ ដែលកំពុងតែស្ថិតនៅលើទីលានទឹកកកនៅពេលរកគ្រាប់បាន នឹងទទួលបានមួយ "បូក"។ វាមិនមានបញ្ហាទេថាតើអ្នកចាំទីរបស់ក្រុមគូប្រកួតគឺស្ថិតនៅក្នុង ទីឬអត់ នៅពេលនោះ ឬថាតើពួកគេត្រូវបានជំនួសដោយអ្នកជិះស្គី ហើយសំណាញ់ទីគឺទទេ។ ដូច្នោះហើយក្រុម ដែលមានសមាជិកច្រើនជាងនៅលើទឹកកកឬចំនួនសមាជិកដូចគ្នាទៅនឹងក្រុមដែលទទួលបានពិន្ទុ គឺទទួលបានមួយ "ដក" នៅពេលពួកគេត្រូវគេស៊ុតចូលមួយគ្រាប់ ។ ស្ថិតិនឹងត្រូវប្រមូលចេញពីប្រភពផ្លូវការ។

34. ការប្រកួតប្រជែងនៃកីឡាករ។ ពិន្ទុ (គ្រាប់បាល់ + ជំនួយ)។ នៅក្នុងហ្គេមប្រភេទនេះ នៅក្នុងការភ្នាល់លើ "គ្រាប់បាល់បន្ទាប់" ទាំងគ្រាប់បាល់និងជំនួយនឹងត្រូវបានរាប់។
35. ទីផ្សារ "វីដេអូពិនិត្យឡើងវិញ" រួមបញ្ចូលនូវការប្រើប្រាស់ VAR ណាមួយ ដើម្បីចាក់ឡើងវិញនូវឧប្បត្តិហេតុដែលមានជម្លោះ។
36. ការពិន័យរយៈពេល 2 នាទីដំបូង។ ប្រភេទនៃការប្រព្រឹត្តកំហុសដែលត្រូវទទួលការពិន័យលើកដំបូងត្រូវតែធ្វើការបញ្ជាក់។ ឧទាហរណ៍៖ ការធ្វើឱ្យគូប្រកួតដួល ការវាយតប់គ្នា មានកីឡាករច្រើនពេក ។ល។ ប្រសិនបើមានការប្រព្រឹត្តកំហុសពីរ ឬច្រើនប្រភេទកើតឡើងក្នុងពេលតែមួយ ដូច្នេះ ទីផ្សារទាំងនេះ នឹងត្រូវទូទាត់សងនៅហាងឆេង 1.00 ហើយការភ្នាល់ដែលនៅសល់ត្រូវទូទាត់សងស្របទៅតាមខនិងលក្ខខណ្ឌរបស់ទីផ្សារ។

10.31. ប៊ូល

1. ការភ្នាល់ត្រូវបានទទួលយកនៅលើសេតនិងការប្រកួត។ នៅក្នុងការប្រកួតមួយ សេតទាំងអស់ត្រូវបានតែលេង។ ប្រសិនបើអ្នកឈ្នះត្រូវបានកំណត់ មុនពេលការប្រកួតត្រូវបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់លើសេតនឹងត្រូវចាត់ទុកជាមោឃៈ ដរាបណាការលេងបន្តប៉ះពាល់ដល់លទ្ធផល។
2. ប្រសិនបើអ្នកឈ្នះត្រូវបានកំណត់ មុនពេលសេតទាំងអស់ត្រូវបានបញ្ចប់ ការភ្នាល់លើអ្នកឈ្នះនៃការប្រកួតនឹងត្រូវបានទូទាត់ដោយផ្អែកលើលទ្ធផលផ្លូវការដែលបានផ្តល់ឱ្យយ៉ាងហោចណាស់ចុងបញ្ចប់មួយត្រូវបានគេលេងសម្រាប់ការសន្និដ្ឋានរបស់វា។
3. ក្នុងករណីកីឡាករដែលមានឈ្មោះក្នុងការប្រកួតផ្លាស់ប្តូរមុនពេលការប្រកួតចាប់ផ្តើមនោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ។
4. ប្រសិនបើការប្រកួតត្រូវបានចាប់ផ្តើម ប៉ុន្តែមិនបានបញ្ចប់ កីឡាករនោះត្រូវបានជាប់ជម្រុះសម្រាប់វគ្គបន្ទាប់ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។

10.32. អុក

1. ការភ្នាល់លើលទ្ធផលនៃហ្គេមត្រូវបានទូទាត់ដោយផ្អែកលើលទ្ធផលផ្លូវការនៃហ្គេមនោះហើយការភ្នាល់លើលទ្ធផលនៃការប្រកួតត្រូវបានទូទាត់សងដោយផ្អែកលើលទ្ធផលនៃហ្គេមទាំងអស់ដែលត្រូវគ្នា។
2. ប្រសិនបើមានកីឡាករច្រើនជាងម្នាក់មានចំណាត់ថ្នាក់លេខមួយដូចគ្នា នៅចុងបញ្ចប់នៃធូណាមិន នោះច្បាប់ dead-heat នឹងត្រូវតែអនុវត្ត ប្រសិនបើមិនមានការប្រកួតកាត់សេចក្តីឬក៏មិនមានពិន្ទុបន្ថែមទេ។
3. ប្រសិនបើការចាប់ផ្តើមហ្គេមត្រូវបានពន្យាពេល ឬហ្គេមត្រូវបានពន្យារពេលដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់នឹងមានសុពលភាពរហូតដល់ចុងបញ្ចប់នៃហ្គេម ឬចុងបញ្ចប់នៃធូណាមិន។
4. គ្រាប់ត (0)។ ប្រសិនបើការប្រកួតបញ្ចប់ក្នុងលទ្ធផលស្មើគ្នា នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវ

ចាត់ទុកជាមោឃៈ។

5. ប្រសិនបើទ្រង់ទ្រាយនៃការប្រកួតត្រូវបានផ្លាស់ប្តូរ នោះការភ្នាល់លើការប្រកួតនោះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។

10.33. ប្រណាំងហ្វូមីឡាវ័ន ប្រណាំងម៉ូតូ ប្រណាំងម៉ូតូវិលជុំ

1. ប្រសិនបើការប្រកួតមិនបានបញ្ចប់ ហើយលទ្ធផលផ្លូវការមិនត្រូវបានប្រកាស នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែទីផ្សារដែលបានកំណត់រួចហើយ។
2. ការភ្នាល់នឹងត្រូវបានទូទាត់សងតាមចំណាត់ថ្នាក់របស់សហព័ន្ធយានយន្តអន្តរជាតិ (FIA) ភ្លាមៗបន្ទាប់ពីការប្រណាំងចុងក្រោយប្រចាំរដូវកាល។
3. ការភ្នាល់លើការជម្រុះ។ ពេលវេលាផ្លូវការ ចាប់ពីវគ្គជម្រុះ យោងទៅតាម FIA នឹងត្រូវបានប្រើសម្រាប់ការទូទាត់សងប្រាក់ភ្នាល់។ សម្រាប់ទីផ្សារ "លឿនបំផុត" ពេលវេលាពីវគ្គជម្រុះទីបីនឹងត្រូវបានរាប់។ ប្រសិនបើមិនមានវគ្គជម្រុះទីបី នោះការភ្នាល់នឹងត្រូវបានទូទាត់យោងតាមបណ្តាញផ្លូវការដែលបង្កើតឡើងដោយ FIA ។ ពិន័យនឹងមិនត្រូវបានរាប់បញ្ចូលសម្រាប់គោលបំណងទីផ្សារឡើយ។ ទោះយ៉ាងណាក៏ដោយ យោងទៅតាម FIA ពេលវេលាប៉ែណាល់ទីនៅក្នុងការជម្រុះ នឹងត្រូវយកមកពិចារណានៅពេលកំណត់អ្នកឈ្នះ។ អ្នកបើកបរត្រូវចាប់ផ្តើមវគ្គជម្រុះដំបូង ដើម្បីឱ្យការភ្នាល់មានសុពលភាព។ ការភ្នាល់នៅលើជុំជម្រុះទី 1 និង 2 ដែលមានល្បឿនលឿនបំផុត នឹងត្រូវបានផ្តល់ជូនប្រសិនបើអ្នកបើកបរបានចាប់ផ្តើមប្រណាំងជម្រុះជុំនោះ។
4. ដើម្បីត្រូវបានចាត់ថ្នាក់។ ដើម្បីត្រូវបានចាត់ថ្នាក់ អ្នកបើកបរត្រូវបំពេញចំនួន 90% នៃចំនួនជុំដែលគ្របដណ្តប់ដោយអ្នកឈ្នះ (បង្គត់ចុះដល់លេខទាំងគត់ដែលនៅជិតបំផុត) ។ អ្នកបើកបរដែលដកខ្លួនចេញពីការប្រណាំង បន្ទាប់ពីពួកគេបានបញ្ចប់ 90% នៃចំនួនជុំដែលគ្របដណ្តប់ដោយអ្នកឈ្នះ ត្រូវបានគេចាត់ទុកថាបានចាត់ថ្នាក់។
5. "អ្នកឈ្នះនៃការប្រណាំង" (អ្នកឈ្នះក្នុងចំណាត់ថ្នាក់ចុងក្រោយ)។ អ្នកបើកបរដែលទទួលបានចំណាត់ថ្នាក់លេខមួយ ក្នុងចំណាត់ថ្នាក់ចុងក្រោយ (ការចាត់ចំណាត់ថ្នាក់ចុងក្រោយ) នៃការប្រណាំងនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។
6. "ចំណាត់ថ្នាក់របស់អ្នកបើកបរនៅក្នុងចំណាត់ថ្នាក់ចុងក្រោយ"។
7. "កំណត់ត្រាប៉ះគ្នាពីមុន"។ អតិថិជនគួរទស្សន៍ទាយថាតើ អ្នកបើកបរណាមួយក្នុងចំណោមពីរនាក់ដែលបានដាក់ឈ្មោះ នឹងបើកបរបានល្អជាង។ អ្នកបើកបរដែលបានបញ្ចប់នៅ ចំណាត់ថ្នាក់ខ្ពស់ជាងគេ ក្នុងការប្រណាំង (នៅក្នុងចំណាត់ថ្នាក់ចុងក្រោយ) នឹងត្រូវបានគេចាត់ទុកថាបានបើកបរល្អជាងគេ។ អ្នកបើកបរទាំងពីរត្រូវតែចាប់ផ្តើមការប្រកួត ដើម្បីឱ្យការភ្នាល់មានសុពលភាព។ ប្រសិនបើអ្នកបើកបរទាំងពីរមិនបានបញ្ចប់ នោះការភ្នាល់នឹងត្រូវបានទូទាត់សងដោយផ្អែកលើចំនួនជុំដែលបានបញ្ចប់។ ប្រសិនបើអ្នកបើកបរទាំងពីរដកខ្លួនចេញពីការប្រណាំង អ្នកបើកបរដែលបានបញ្ចប់ការប្រណាំងច្រើនជុំជាង នឹងត្រូវបានគេចាត់ទុកថាបានបើកបរល្អជាងគេ។ ប្រសិនបើអ្នកបើកបរទាំងពីរដកខ្លួនចេញ បន្ទាប់ពី

បញ្ចប់ចំនួនជុំស្មើគ្នា នោះការភ្នាល់នឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
ប្រសិនបើអ្នកបើកបរខកខានមិនបានបញ្ចប់ការប្រណាំងជុំលឿនបំផុតរបស់គេទេ (ខកខានមិនបានបង្ហាញពីម៉ោងជម្រុះ) ចំណាត់ថ្នាក់របស់ពួកគេនឹងត្រូវបានកំណត់ដោយផ្អែកលើចំណាត់ថ្នាក់ចាប់ផ្តើមចុងក្រោយ។

8. "នឹងបញ្ចប់ការប្រណាំង – បាទ/ទេ"។ អតិថិជនគួរទស្សន៍ទាយថាតើអ្នកបើកបរដែលបានដាក់ឈ្មោះនឹងបញ្ចប់ការប្រណាំងដែរឬទេ។ អ្នកបើកបរត្រូវបានគេចាត់ទុកថាបានបញ្ចប់ ប្រសិនបើពួកគេត្រូវបានចាត់ថ្នាក់ថាជាអ្នកនៅពីក្រោយអ្នកនាំមុខ។
9. "ជុំលឿនបំផុត"។ អតិថិជនគួរទស្សន៍ទាយថាតើអ្នកបើកបរណាដែលនឹងកំណត់ពេលវេលាលឿនបំផុត។
10. ជុំកម្តៅសាច់ដុំក៏នឹងរាប់នៅក្នុងការប្រណាំងដែរ។
11. ប្រណាំងម៉ូតូវិលជុំ។ ប្រសិនបើព្រឹត្តិការណ៍មួយត្រូវបានអាក់ខានមុនពេលការបញ្ចប់ នោះការភ្នាល់ទាំងអស់នឹងត្រូវមានសុពលភាព ប្រសិនបើព្រឹត្តិការណ៍នេះនឹងបន្តក្នុងរយៈពេល 24 ម៉ោង ឬលទ្ធផលត្រូវបានកំណត់ដោយគ្មានលក្ខខណ្ឌ។ បើមិនដូច្នោះទេ ការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ។ ទាក់ទងទៅនឹងទីផ្សារនៃគ្រាប់ត បន្ទាប់ពីការប្រណាំងទីប្រាំបី ការបញ្ចប់ការប្រណាំងប្រាំបីដងមុនត្រូវបានបញ្ចប់បើមិនដូច្នេះទេការភ្នាល់នឹងត្រូវចាត់ទុកជាមោឃៈ ហើយការភ្នាល់មិនត្រូវបានរាប់បញ្ចូលឡើយ។
ប្រសិនបើព្រឹត្តិការណ៍មួយត្រូវបានពន្យាពេលមុនពេលកំណត់ នោះការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ ដរាបណាព្រឹត្តិការណ៍ចាប់ផ្តើមក្នុងរយៈពេល 24 ម៉ោង។ រាល់ទីផ្សារទាំងអស់នឹងត្រូវបានទូទាត់តាមលទ្ធផលបន្ទាប់ពីការប្រណាំងចុងក្រោយ (យោងទៅតាមកាលវិភាគនៃលីគ) ឬលទ្ធផលផ្លូវការ (ការប្រកួតជាលក្ខណៈបុគ្គល/Grand Prix) ។ គ្មានការប្តឹងតវ៉ា ការដកហូតសិទ្ធិ ឬការដកពិន្ទុ នឹងមិនរាប់បញ្ចូលទេ។ មានតែទិន្នន័យពីប្រភពផ្លូវការឬ វេបសាយផ្លូវការនៃធូណាមិនដែលត្រូវគ្នាប៉ុណ្ណោះដែលអាចត្រូវបានប្រើសម្រាប់ការទូទាត់សងប្រាក់ភ្នាល់។ ប្រសិនបើព័ត៌មានពីប្រភពផ្លូវការមិនត្រឹមត្រូវ ប្រភពឯករាជ្យនឹងត្រូវបានប្រើសម្រាប់ការទូទាត់សងប្រាក់ភ្នាល់។
12. ប្រណាំងម៉ូតូវិលជុំ។ ការពិពណ៌នាអំពីទីផ្សារដែលអាចរកបាន៖
    - **ពិន្ទុការប្រណាំងឯកត្តបុគ្គល** ។ ការភ្នាល់នឹងត្រូវបានទូទាត់តាមពិន្ទុការប្រណាំង មុនពេលពិន្ទុណាមួយត្រូវបានបន្ថែមតាមរយៈពិន្ទុទ្វេដង។
    - **អ្នកឈ្នះការប្រណាំងឯកត្តបុគ្គល** ។ អ្នកបើកបរទាំងបួនត្រូវតែចាប់ផ្តើមប្រណាំង បើមិនដូច្នេះទេរាល់ការភ្នាល់ទាំងអស់នឹងត្រូវលុបចោល។
    - **អ្នកឈ្នះការប្រណាំងបន្ទាប់/អ្នកឈ្នះការប្រណាំង 13 នាក់** ។ តម្លៃត្រូវបានផ្តល់ជូនសម្រាប់ការឈ្នះគ្រុប A ឈ្នះគ្រុប B និងការចាប់រង្វាន់សម្រាប់ការប្រណាំងដែលបានបញ្ជាក់។ ការប្រណាំងដែលបានដកស្រង់ត្រូវតែចប់ជាស្តាពរ ដើម្បីឱ្យការភ្នាល់មានសុពលភាព។
    - **ការផ្គូផ្គងអ្នកប្រណាំង/ការផ្គូផ្គងគ្រាប់ត (ការប្រកួតលីគ)**។ លទ្ធផលរបស់អ្នកប្រណាំងទាំងអស់នឹងត្រូវបានរាប់ជាពិន្ទុធម្មតា ពោលគឺ 3-2-1-0 ។ ពិន្ទុបូណាសមិនត្រូវបានរាប់បញ្ចូលសម្រាប់គោលបំណងទូទាត់សងទេ។ ការភ្នាល់នឹងមានសុពលភាពក្នុងការប្រកួត ប្រសិនបើអ្នកប្រណាំងទាំងពីរបញ្ចប់ការប្រកួត (ករណីលើកលែងរាប់បញ្ចូល)។ លើសពីនេះទៀត ប្រសិនបើព្រឹត្តិការណ៍មួយត្រូវបានអាក់ខានមុនពេលបញ្ចប់ នោះការភ្នាល់ទាំងអស់នឹងត្រូវបានលុបចោល

លើកលែងតែលទ្ធផលត្រូវបានកំណត់រួចហើយ។

- **ពិន្ទុអ្នកបើកបរសរុប** ។ រាល់ការប្រណាំងនឹងត្រូវរាប់ ហើយពិន្ទុតាក់តិចនឹងត្រូវបានរាប់ជាពិន្ទុធម្មតា ពោលគឺ 3-2-1-0 ។ ពិន្ទុបូណឹសមិនត្រូវបានរាប់បញ្ចូលសម្រាប់គោលបំណងទូទាត់សងទេ។ ការភ្នាល់នឹងមានសុពលភាព ប្រសិនបើអ្នកប្រណាំងបានបញ្ចប់។ ប្រសិនបើព្រឹត្តិការណ៍មួយត្រូវបានអាក់ខានមុនពេលបញ្ចប់ នោះការភ្នាល់ទាំងអស់នឹងត្រូវបានលុបចោល លើកលែងតែលទ្ធផលត្រូវបានកំណត់រួចហើយ។ នៅក្នុងការប្រកួត Knockout Cup 'Man on Man' ការជិះលើបុរសដោយមិនគិតពីការទូទាត់ទេ។ នៅពេលពិន្ទុសរុបរបស់អ្នកបើកបរត្រូវបានផ្តល់ជូនសម្រាប់ព្រឹត្តិការណ៍ Grand Prix ឬព្រឹត្តិការណ៍ European Championship ការភ្នាល់នឹងត្រូវបានទូទាត់សងដោយផ្អែកលើចំនួនពិន្ទុដែលរកបាននៅក្នុងជុំធំ (20 ជុំ) តែប៉ុណ្ណោះ ហើយមិនរាប់បញ្ចូលការប្រណាំងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រនិងចុងក្រោយទេ។

10.34. ប្រណាំងទូក

1. អ្នកប្រណាំង 6 នាក់ចូលរួមក្នុងការប្រណាំងមួយ។ ការប្រណាំងមួយមាន 3 ជុំ។ ឧបករណ៍របស់កីឡាការប្រណាំងទូកនិងទូកមានពណ៌ដូចខាងក្រោម៖
   - ទូក 1 – ស
   - ទូក 2 – ខ្មៅ
   - ទូក 3 – ក្រហម
   - ទូក 4 – ខៀវ
   - ទូក 5 – លឿង
   - ទូក 6 – បៃតង។
2. "អ្នកឈ្នះនៃការប្រណាំង"។ អ្នកប្រណាំងដែលបញ្ចប់ក្នុងចំណាត់ថ្នាក់លេខមួយ យោងទៅតាមលទ្ធផលចុងក្រោយ នឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះនៃការប្រណាំង។
3. ប្រសិនបើការប្រណាំងមិនបានបញ្ចប់ ហើយគ្មានលទ្ធផលផ្លូវការត្រូវបានប្រកាស នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ លើកលែងតែការភ្នាល់នៅលើទីផ្សារដែលបានកំណត់រួចហើយ។
4. ខ្សែបន្ទាត់ចាប់ផ្តើមត្រូវតែត្រូវបានឆ្លងកាត់ក្នុងចន្លោះពេលរវាងពី 0 ទៅ 1 វិនាទី។ ប្រសិនបើទូកចាប់ផ្តើមមុន 0 វិនាទី (ការចាប់ផ្តើមលឿន (F)) ឬបន្ទាប់ពី 1 វិនាទី (ការចាប់ផ្តើមយឺត (L)) ការភ្នាល់លើទូកទាំងនេះនឹងត្រូវទូទាត់តាមហាងឆេង 1.00 ។
5. SP (តម្លៃចាប់ផ្តើម) គឺជាហាងឆេងចុងក្រោយនៅលើទូក។ តម្លៃចាប់ផ្តើមត្រូវបានគណនាដោយផ្អែកលើហាងឆេងមធ្យម ដែលផ្តល់ដោយអ្នករៀបចំការប្រកួតនៅពេលបិទ។ ប្រសិនបើទូកមួយត្រូវបានដកចេញមុនពេលចាប់ផ្តើមប្រណាំង ឬត្រូវបានប្រកាសថាមិនប្រណាំង (យោងតាមកំណត់ត្រាផ្លូវការ) ហើយទីផ្សារ SP មិនទាន់ត្រូវបានបង្កើតទេ ការភ្នាល់លើទូកដែលបានដកចេញនឹងត្រូវបានទូទាត់សងតាមហាងឆេង "1" ។

10.35. ខារីន

1. ខេរីន គឺជាទម្រង់នៃការប្រណាំងកង់ដែលដំណើរការដោយម៉ូទ័រ ដែលអ្នកជិះកង់លោតដើម្បីទទួលជោគជ័យបន្ទាប់ពីការចាប់ផ្តើមល្បឿន។
2. ការប្រណាំងត្រូវបានត្រួតពិនិត្យដោយអាជ្ញាកណ្តាលបួននាក់។ នៅពេលការប្រកួតបានបញ្ចប់ អាជ្ញាកណ្តាលគ្រីទង់ក្រហមឬស ដែលបង្ហាញថា ច្បាប់ត្រូវបានរំលោភឬអនុវត្តតាមរៀងៗខ្លួន។ ប្រសិនបើការរំលោភលើច្បាប់ណាមួយកើតឡើង អាជ្ញាកណ្តាលនឹងមើលរូបភាពវីដេអូនៃឧប្បត្តិហេតុនេះ ហើយឈានដល់ការសម្រេចចិត្តមួយ។ ប្រសិនបើបានបង្ហាញថាអ្នកប្រកួតប្រជែងបានរំលោភលើច្បាប់ពួកគេ ជាគោលការណ៍ នឹងត្រូវបានជម្រុះចេញ។
3. ការភ្នាល់ខ្លះអាចនឹងមិនមានទេ ប្រសិនបើមានអ្នកចូលរួមប្រណាំងតិចជាង 9 នាក់។
4. ក្នុងកាល:ទេស:ពិសេស ប្រសិនបើការប្រណាំងមួយត្រូវបានអាក់ខានដោយសារហេតុផលបច្ចេកទេសឬខាងក្រៅ (ដោយគ្មានកំហុសរបស់អ្នកប្រណាំង) ការភ្នាល់លើលទ្ធផលទាំងអស់នឹងត្រូវចាត់ទុកជាមោឃៈ (ទូទាត់តាមហាងឆេង 1.00) ។

10.36. ការប្រណាំងយានយន្ត (ប្រណាំងម៉ូតូវិលជុំប្រទេសជប៉ុន)

1. ការប្រណាំងយានយន្ត គឺជាកីឡាប្រណាំងយានយន្តល្បឿនលឿនលក្ខណៈប្រកួតប្រជែង ដែលអ្នកប្រកួតប្រជែងប្រណាំងគ្នាលើម៉ូតូ។
2. ការប្រណាំងកើតឡើងនៅលើផ្លូវក្រាលកៅស៊ូចម្ងាយ 500 ម៉ែត្រ ដោយមានអ្នកចូលរួមប្រកួតចំនួន 8 នាក់ (7 នាក់ក្នុងកាល:ទេស:ពិសេស) និងរត់ចំនួន 6 ជុំ។ តាមច្បាប់មួយ ការប្រណាំងកើតឡើង 12 ដងក្នុងមួយថ្ងៃ។
3. កំណាត់ផ្លូវត្រង់ 2 ខ្សែមានបណ្តោយ 87 ម៉ែត្រ។ ល្បឿនអតិបរមាគឺ 150 គីឡូម៉ែត្រក្នុងមួយម៉ោង។
4. ការប្រណាំងធម្មតារត់បានចំនួន 6 ជុំ (3,100 ម៉ែត្រ) ចំណែកឯការប្រណាំងយូរមានរយៈពេល 8 ឬ 10 ជុំ។
5. ការគ្រីទង់បន្ទាប់ពីគូប្រជែងឆ្លងកាត់របត់ទីបួននៃជុំចុងក្រោយ បង្ហាញពីការបញ្ចប់នៃការប្រណាំង។
6. អ្នកប្រកួតប្រជែងអាចត្រូវបានគេដកសិទ្ធិ ប្រសិនបើពួកគេបើកចេញពីផ្លូវ។
7. អ្នកប្រកួតប្រជែងក៏អាចត្រូវបានដកហូតសិទ្ធិផងដែរ ប្រសិនបើពួកគេធ្វើល្បិចដែលហួសពីការគ្រប់គ្រងឬធ្វើល្បិចដែលអាចបង្កអន្តរាយដល់ដៃគូប្រកួតប្រជែងដទៃទៀត។

10.37. ឡាក្រោស

1. ការភ្នាល់នៅលើការប្រកួតឡាក្រោសត្រូវបានទទួលយក រួមទាំងម៉ោងបន្ថែម។
2. ប្រសិនបើគ្រាប់បាល់មួយត្រូវបានគេរកបាននៅនាទីទី 09 និង 00 វិនាទី វាត្រូវបានគេគិតថាត្រូវបាន

គេស៊ុតបញ្ចូលទីចន្លោះពេលពីនាទីទី 1 ដល់នាទីទី 9 ។ ប្រសិនបើគ្រាប់បាល់មួយត្រូវបានគេរកបាន នៅនាទីទី 01 និង 00 វិនាទី វាត្រូវបានគេគិតថាបានរកគ្រាប់បាល់នៅនាទីទី 1 ។

10.38. ស្គីក្រោស

1. ធ្លណាមិនការប្រណាំង SX4 គឺជាការប្រណាំងនៅលើផ្លូវដែលមានឧបសគ្គច្រើន។
2. អ្នកប្រកួតប្រជែងទាំងអស់ គឺជាអត្តពលិកបួននាក់លើក្តារជិះស្គី ដែលចាប់ផ្តើមពីបន្ទាត់តែមួយ ហើយព្យាយាមបញ្ចប់ទីមុនអ្នកប្រណាំងផ្សេងទៀត។
3. អត្តពលិកអាចធ្វើដំណើរឆ្លងកាត់ឧបសគ្គជាច្រើនរបស់ពួកគេ ទោះបីពួកគេមើលទៅសមក៏ដោយ។ ទោះយ៉ាងណាក៏ដោយ ពួកគេមិនត្រូវបានអនុញ្ញាតឱ្យរុញច្រានគ្នា ឬរារាំងគូប្រជែងរបស់ពួកគេទេ។
4. ការប្រណាំងទាំងនេះត្រូវបានធ្វើឡើងនៅកម្រិតខុសគ្នា ហើយបន្ទាប់ពីការប្រណាំងនីមួយៗ អត្តពលិកដែលស្ថិតក្នុងចំណាត់ថ្នាក់លេខ 1 និងលេខ 2 នឹងឡើងទៅវគ្គបន្ទាប់ ចំណែកឯចំណាត់ថ្នាក់លេខ 3 និងលេខ 4 ត្រូវធ្លាក់មួយកម្រិត។
5. អត្តពលិកម្នាក់ៗទទួលបានចំណាត់ថ្នាក់ ផ្អែកលើលទ្ធផលនៃធ្លណាមិននោះ (សេរីនៃការប្រណាំង)។ ចំណាត់ថ្នាក់របស់អត្តពលិកនីមួយៗ កំណត់ទីតាំងចាប់ផ្តើមរបស់ពួកគេនៅពេលចាប់ផ្តើមនៃធ្លណាមិននោះ។

10.39. ទូរទស្សន៍ហ្គេម

1. **ការប្រលងចម្រៀងអឺរ៉ូវីសិន។**
    - ការប្រកួត។ អតិថិជនគួរទស្សន៍ទាយថា តើប្រទេសមួយក្នុងចំណោមប្រទេសទាំងពីរដែលបានដាក់ឈ្មោះចូលរួម ថានឹងបញ្ចប់ខ្ពស់ជាង នៅក្នុងកម្មវិធីប្រកួតផ្តាច់ព្រ័ត្រ។ ប្រសិនបើប្រទេសទាំងពីរចូលរួមមានពិន្ទុស្មើគ្នា នោះរាល់ការភ្នាល់ផ្សេងទៀតនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។
    - ការភ្នាល់ត្រូវបានទូទាត់សង អាស្រ័យលើព័ត៌មាននៅលើគេហទំព័រ www.eurovision.tv ។
2. **ទូរទស្សន៍ហ្គេម។** ការិយាល័យប្រអប់។ ក្នុងករណីខ្លះ ការភ្នាល់អាចត្រូវបានទូទាត់សងនៅពាក់កណ្តាលសប្តាហ៍បន្ទាប់ នៅពេលមានទិន្នន័យការិយាល័យប្រអប់ពិតប្រាកដ។
   Game Of Thrones។ ចំនួនអ្នកមើលនៃភាគដែលបានបញ្ចាក់។ មានតែអ្នកមើលដែលបានមើលការចាក់ផ្សាយលើកដំបូងប៉ុណ្ណោះដែលនឹងរាប់។ Reruns, ការចែករំលែកឯកសារ P2P ឬការមើលនៅលើបច្ចេកវិទ្យាផ្សេងទៀតត្រូវបានដកចេញ។
   ការភ្នាល់លើព្រឹត្តិការណ៍នៅក្នុងស៊េរីត្រូវបានទូទាត់សង 24 ម៉ោង បន្ទាប់ពីការចេញផ្សាយភាគ។ លទ្ធផលការិយាល័យប្រអប់នៅសហរដ្ឋអាមេរិកនិងប្រទេសដទៃទៀតនឹងត្រូវបានកំណត់ដោយផ្អែកលើព័ត៌មាននៅលើ http://www.boxofficemojo.com ។
3. **ការភ្នាល់នៅលើសមរភូមិរ៉ែប** ត្រូវបានទទួលយក ដោយផ្អែកតាមពេលវេលាចាប់ផ្តើមប្រហាក់ប្រហែល

នៃការប្រយុទ្ធ។ សមរភូមិអាចនឹងចាប់ផ្តើមតាមជាក់ស្តែងនៅពេលក្រោយ។ ការភ្នាល់លើអ្នកឈ្នះនឹងត្រូវបានទូទាត់សង បន្ទាប់ពីវីដេអូផ្លូវការនៃសមរភូមិបានចាប់ផ្តើម។

4. **ការភ្នាល់ពិសេស** ។ ប្រសិនបើលទ្ធផលនៃព្រឹត្តិការណ៍មិនមាននៅក្នុងបញ្ជីការភ្នាល់ នោះការភ្នាល់ទាំងអស់នឹងនៅតែមានសុពលភាព ហើយនឹងត្រូវបានទូទាត់ជាចាញ់។

10.40. នយោបាយ

"អ្នកឈ្នះ"។ ប្រសិនបើបេក្ខជនបានដកខ្លួនមុនពេលការបោះឆ្នោតត្រូវបិទ ឬមិនត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងការបោះឆ្នោត នោះការភ្នាល់លើពួកគេនឹងត្រូវបានទូទាត់តាមហាងឆេង 1 ។

10.41. អ៊ីស្ពត

1. ការភ្នាល់តូតាល់និងគ្រាប់តនៅលើជុំនៃ Counter-Strike ត្រូវបានទទួលយក រួមទាំងការភ្នាល់ដែលអាចកើតមាន។
2. ប្រសិនបើកីឡាករ (ឬក្រុម) បោះបង់ចោលការប្រកួត (ដោយហេតុផលណាមួយ) ពួកគេត្រូវបានចាត់ទុកថាចាញ់នៅក្នុងជុំ/ផែនទីការប្រកួតដែលនៅសល់ទាំងអស់។ ការភ្នាល់នៅលើទីផ្សារផ្សាយផ្ទាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង "1" លើកលែងតែលទ្ធផលត្រូវបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានបញ្ឈប់។
3. បើសិនការប្រកួតត្រូវបានពន្យារពេលលើសពី 24 ម៉ោងក្រុមហ៊ុនមានសិទ្ធិទូទាត់សងប្រាក់ភ្នាល់តាមហាងឆេង "1"។
4. គ្មានការភ្នាល់ណានឹងត្រូវបានលុបចោលដោយសារតែមានបញ្ហានៃការព្រើនច្រឡំនៃឈ្មោះអ្នកប្រើរបស់កីឡាករឬក្រុម ទោះបីជាពួកគេប្រើគណនី smurf ក៏ដោយ។ នៅក្នុងករណីនេះ ការភ្នាល់នឹងត្រូវមានសុពលភាព។ មិនមានការជំនួសសមាជិកណាមួយ ទោះបីវាកើតឡើងក្នុងពេលប្រកួត នឹងប៉ះពាល់ដល់ការភ្នាល់ឡើយ។
5. ប្រសិនបើអ្នកចាត់ចែងបញ្ឈប់ការប្រកួត ហើយកំណត់ឱ្យប្រកួតឡើងវិញ លទ្ធផលនៃការប្រកួតដែលត្រូវអាក់ខាន នេះនឹងមិនត្រូវបានរាប់បញ្ចូលទេ។
6. គ្រាប់តនិងតូតាល់ត្រូវបានរាប់នៅក្នុងផែនទី លើកលែងតែនៅពេលដែលតូតាល់ឬគ្រាប់តត្រូវបានផ្តល់ឱ្យទាក់ទងនឹងផែនទីជាក់លាក់ ឬការប្រកួតមួយត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋានមួយល្អបំផុត។
7. "ផែនទីបញ្ចប់នៅពេលថ្ងៃ"។ ទីផ្សារនេះផ្អែកលើវដ្តថ្ងៃនិងយប់នៃហ្គេម។ ថ្ងៃដំបូងចាប់ផ្តើមនៅនាទី 0 និងឆ្លាស់គ្នាជាមួយពេលយប់រៀងរាល់ប្រាំនាទីម្តង។ ពេលរាត្រីភ្លាមៗ ដែលត្រូវបានហៅដោយតួអង្គ Night Stalker ដោយសារតែសមត្ថភាពពិសេសរបស់គាត់ នៅតែត្រូវបានគេចាត់ទុកថាជាថ្ងៃ។
8. នៅក្នុង Dota 2 និង League of Legends អ្នកឈ្នះនៃផែនទីឬការប្រកួតមួយត្រូវបានប្រកាស បន្ទាប់ពីរាជបល្ល័ង្កឬទីតាំងស្នូលរបស់ក្រុមទាំងពីរបានរលំ។

9. ការភ្នាល់លើការសម្លាប់ជាប់ៗគ្នា ("ការសម្លាប់បានបីនាក់" "ការសម្លាប់បានបួននាក់" "ការសម្លាប់បានប្រាំនាក់" "ការសម្លាប់ហ្វ៊ូបានបួន" "ការសម្លាប់ហ្វ៊ូបានប្រាំ" ។ល។) នឹងត្រូវទូទាត់សងផ្អែកលើថាតើការសម្លាប់ជាប់ៗគ្នាដែលបានលើកឡើងនោះ បានបញ្ចប់ឬអត់ ដោយមិនគិតពីព្រឹត្តិការណ៍ផ្សេងទៀតនៅក្នុងការប្រកួតឡើយ៖
   – ប្រសិនបើមានកត់ត្រាអំពីការឈ្នះជាប់ៗគ្នា ដូច្នេះ ការភ្នាល់ថា "មែន" នឹងឈ្នះ ឯការភ្នាល់ថា "មិនមែន" នឹងចាញ់
   – ប្រសិនបើមិនមានកត់ត្រាអំពីការឈ្នះជាប់ៗគ្នាទេ ដូច្នេះ ការភ្នាល់ថា "មែន" នឹងចាញ់ ឯការភ្នាល់ថា "មិនមែន" នឹងឈ្នះ
   ការភ្នាល់លើ "ការសម្លាប់ដ៏ច្រើនបំផុត" ត្រូវទូទាត់សងផ្អែកលើការសម្លាប់ជាប់ៗគ្នាខ្ពស់បំផុតដែលសម្រេចបានក្នុងការប្រកួតនោះ។
   ឧទាហរណ៍ (ហ្គេម Dota 2)៖ ប្រសិនបើមានការសម្លាប់ហ្វ៊ូបានប្រាំ ដូច្នេះ ការភ្នាល់លើ "ការសម្លាប់ហ្វ៊ូបានប្រាំ – មែន" និងការភ្នាល់លើ "ការសម្លាប់ហ្វ៊ូបានបួន – មែន" នឹងឈ្នះ ហើយការសម្លាប់ហ្វ៊ូបានប្រាំត្រូវរាប់ជាការសម្លាប់ច្រើនបំផុត។
10. Dota 2 'ការសម្លាប់ទ្វេដង', 'ការសម្លាប់បីដង', 'ការសម្លាប់ច្រើនសន្ធឹកសន្ធាប់' និង 'ការសម្លាប់រង្គាល' នឹងត្រូវបានទូទាត់សង យោងទៅតាមចំនួនខ្ពស់បំផុតនៃការជាប់គ្នាក្នុងមួយផែនទី។ ឧទាហរណ៍៖ ប្រសិនបើការសម្លាប់ច្រើនសន្ធឹកសន្ធាប់កើតឡើង ហើយវាជាចំនួនខ្ពស់បំផុតជាប់គ្នា នោះការភ្នាល់លើ 'ការសម្លាប់ច្រើនសន្ធឹកសន្ធាប់ – បាទ/ចាស' នឹងឈ្នះ ហើយការភ្នាល់ផ្សេងទៀតនឹងចាញ់។
    ការភ្នាល់លើ 'អ្នកដែលនឹងរកបានការបំណែកបន្ទាប់ (ទី 20 ទី 30 ទី 40 ។ល។) ក្នុង Dota 2 គឺជាការភ្នាល់លើបំណែកបន្ទាប់។ អ្នកឈ្នះគឺជាក្រុមដែលនឹងអនុវត្តបំណែកទី 10 (ទី 20 ទី 30 ទី 40 ។ល។) នៅលើផែនទី។ ឧទាហរណ៍៖ បន្ទាប់ពីពិន្ទុ 5:4 ពិន្ទុគឺ 5:5 ក្រុមទី 2 ឈ្នះ។
11. ការភ្នាល់លើរយៈពេលនៃផែនទីគិតជានាទី នឹងត្រូវបានទូទាត់សងទាក់ទងនឹងវិនាទីដែលបានកន្លងផុតទៅ ក្នុងនាទីនីមួយៗនៃហ្គេម។ ដូច្នេះប្រសិនបើលទ្ធផល "រយៈពេលនៃផែនទីលើសពី 27.5" ត្រូវបានជ្រើសរើស នោះផែនទីចាំបាច់ត្រូវបញ្ចប់បន្ទាប់ពីនាទី 27:30 ដើម្បីឲ្យការភ្នាល់ឈ្នះ – ឧទាហរណ៍ នៅនាទី 27:35, 27:44 ។ល។ ប្រសិនបើផែនទីបញ្ចប់នៅនាទី 27:15 ការភ្នាល់ចាញ់។ ហើយប្រសិនបើការប្រកួតបញ្ចប់នៅនាទី 27:30 នោះការភ្នាល់នឹងត្រូវបានទូទាត់សងតាមហាងឆេង 1 ។

Counter-Strike 2

1. អ្នកឈ្នះ – ការភ្នាល់លើអ្នកឈ្នះការប្រកួត។ ការប្រកួតមួយនឹងត្រូវចាត់ទុកថាបានចាប់ផ្តើម បន្ទាប់ពីការសម្លាប់ដំបូងនៅក្នុងជុំកាំភ្លើងខ្លី។ ការភ្នាល់ 1x2 គឺស្រដៀងគ្នានឹងការភ្នាល់លើអ្នកឈ្នះដែរ ប៉ុន្តែមានរាប់បញ្ចូលលទ្ធផលដែលអាចស្មើគ្នានៅក្នុងនោះដែរ។ ការភ្នាល់នេះ មានផ្តល់ជូននៅក្នុងការប្រកួតនានាដែលអាចមានការស្មើគ្នា (ឧទាហរណ៍៖ ការប្រកួត BO2 ឬការប្រកួត BO1 ដោយពុំមានម៉ោងបន្ថែម)។
2. គ្រាប់ត 0 – ការភ្នាល់លើក្រុមមួយក្នុងចំណោមក្រុមដែលឈ្នះ មិនរាប់បញ្ចូលលទ្ធផលស្មើគ្នាទេ។ ប្រសិនបើការប្រកួតមួយបញ្ចប់ដោយការស្មើគ្នា ការភ្នាល់នឹងត្រូវទូទាត់សងនៅហាងឆេង 1.00 (បង្វិលសងប្រាក់វិញ)។

3. ផែនទីសរុប - សេស/គូ – ការភ្នាល់ថាតើចំនួនផែនទីដែលបានលេងនៅក្នុងការប្រកួតមួយ នឹងមានចំនួនសេស ឬគូ។
4. ផែនទីសរុប – ការភ្នាល់លើចំនួនផែនទីសរុបដែលបានលេងក្នុងអំឡុងការប្រកួតមួយ ដោយរួមបញ្ចូលទាំងម៉ោងបន្ថែម។
5. ពិន្ទុផែនទីត្រឹមត្រូវ – ការភ្នាល់លើពិន្ទុចុងក្រោយបន្ថែមនៃផែនទីជាក់លាក់មួយ នៅក្នុងការប្រកួតណាមួយ។
6. ជុំសរុប – ការភ្នាល់លើចំនួនជុំដែលបានលេងដោយក្រុមទាំងពីរនៅក្នុងការប្រកួតមួយ។
7. លទ្ធផលផែនទីនីមួយៗ៖
    - អ្នកឈ្នះ (រួមបញ្ចូលទាំង OT) - ការភ្នាល់លើអ្នកឈ្នះនៃផែនទីជាក់លាក់មួយ នៅក្នុងការប្រកួតណាមួយ ដោយរួមបញ្ចូលទាំងជុំបន្ថែមផងដែរ។
    - អ្នកឈ្នះក្នុងតង់ទីមួយ - ការភ្នាល់លើក្រុមដំបូងគេដែលនឹងឈ្នះបាន 7 ជុំ នៅលើផែនទីជាក់លាក់មួយ។
    - ជុំសរុប សេស/គូ – ការភ្នាល់ថាតើចំនួនជុំដែលបានលេងនៅក្នុងផែនទីជាក់លាក់មួយ នឹងមានចំនួនសេស ឬគូ។
    - ជុំសរុប – ការភ្នាល់លើចំនួនជុំសរុបដែលបានលេងនៅក្នុងផែនទីជាក់លាក់មួយ។
    - ជុំសរុបនឹងត្រូវបញ្ចប់ដោយការបំផ្ទុះគ្រាប់បែក – ការភ្នាល់លើចំនួនជុំសរុបដែលនឹងត្រូវបញ្ចប់ដោយមានការបំផ្ទុះគ្រាប់បែក នៅក្នុងផែនទីជាក់លាក់មួយ។
    - តើនឹងមានម៉ោងបន្ថែមដែរទេ? មាន/មិនមាន - ការភ្នាល់លើថាតើផែនទីជាក់លាក់មួយ នឹងមានម៉ោងបន្ថែមឬអត់។
    - ការសម្លាប់ចំគ្នាឯង មែន/មិនមែន – ការភ្នាល់លើថាតើក្រុមដែលបានជ្រើសរើស នឹងធ្វើការសម្លាប់ចំគ្នាឯងនៅលើផែនទីជាក់លាក់មួយឬអត់។ "ការសម្លាប់ចំគ្នាឯង" គឺនៅពេលដែលអ្នកលេងណាម្នាក់ ត្រូវបានសម្លាប់ដោយសមាជិកណាម្នាក់នៃក្រុមរបស់ពួកគេ។
    - ការសម្លាប់ដោយកូនកាំបិត មែន/មិនមែន – ការភ្នាល់លើថាតើក្រុមដែលបានជ្រើសរើស នឹងសម្លាប់គូសត្រូវរបស់ខ្លួនដោយប្រើកូនកាំបិត នៅក្នុងផែនទីជាក់លាក់មួយឬអត់។
8. លទ្ធផលជុំកាំភ្លើងខ្លី (ជុំទីមួយ និងជុំទីដប់បីក្នុងការត្រួតពិនិត្យសរុបនៅលើផែនទី)៖
    - អ្នកឈ្នះជុំកាំភ្លើងខ្លីទី (X) - ការភ្នាល់លើថាតើក្រុមមួយណាដែលនឹងឈ្នះជុំកាំភ្លើងខ្លីជាក់លាក់មួយនៅលើផែនទីដែលបានបញ្ជាក់។
    - អ្នកឈ្នះជុំកាំភ្លើងខ្លីបានពីរជុំ – ការភ្នាល់លើថាតើក្រុមមួយណាដែលនឹងឈ្នះជុំកាំភ្លើងខ្លីទាំងពីរជុំនៅលើផែនទីដែលបានបញ្ជាក់។
    - ការដាក់គ្រាប់បែកនៅក្នុងជុំទី (X) - ការភ្នាល់លើថាតើនឹងមានការដាក់គ្រាប់បែកនៅក្នុងជុំជាក់លាក់មួយ នៅលើផែនទីដែលបានបញ្ជាក់ដែរឬអត់។
    - ជុំកាំភ្លើងខ្លីសរុបដែលបានឈ្នះ – ការភ្នាល់លើថាតើក្រុមដែលបានជ្រើសរើសនោះ នឹងឈ្នះចំនួនជុំកាំភ្លើងខ្លីដែលបានបញ្ជាក់នៅក្នុងការប្រកួតនោះឬអត់។
    - ការសម្លាប់សរុបនៅក្នុងជុំកាំភ្លើងខ្លី – ការភ្នាល់លើចំនួននៃការសម្លាប់សរុបដោយក្រុមទាំងពីរ

នៅក្នុងជុំកាំភ្លើងខ្លីជាក់លាក់មួយ នៅលើផែនទីដែលបានបញ្ជាក់។

9. លទ្ធផលរបស់ក្រុមនីមួយៗ៖
    - ជុំសរុប – ការភ្នាល់លើចំនួនជុំសរុបដែលបានឈ្នះដោយក្រុមជាក់លាក់ណាមួយនៅក្នុងការប្រកួតមួយ។
    - ជុំផែនទីសរុប – ការភ្នាល់ថា ក្រុមជាក់លាក់មួយ នឹងឈ្នះចំនួនជុំដែលបានបញ្ជាក់ នៅលើផែនទីដែលបានបញ្ជាក់។
    - ជុំសរុបដែលឈ្នះដោយក្រុមភេរវកម្ម/ក្រុមប្រឆាំងភេរវកម្ម – ការភ្នាល់ថាក្រុមជាក់លាក់មួយ នឹងឈ្នះចំនួនជុំដែលបានបញ្ជាក់ នៅលើផែនទីដែលបានបញ្ជាក់ នៅពេលកំពុងលេងក្នុងតួនាទីជាអ្នកវាយប្រហារ (ក្រុមភេរវកម្ម) ឬអ្នកការពារ (ក្រុមប្រឆាំងភេរវកម្ម)។
    - អ្នកឈ្នះជុំ (X) - ការភ្នាល់ថាក្រុមដែលបានជ្រើសរើស នឹងឈ្នះជុំជាក់លាក់មួយ នៅលើផែនទីដែលបានបញ្ជាក់។
    - ជ័យជម្នះនៅជុំណាមួយ អាចសម្រេចទៅបានដោយការសម្លាប់គូសត្រូវទាំងអស់នៅលើផែនទីដោយការបំផ្ទុះគ្រាប់បែក/ការដោះគ្រាប់បែក ឬយោងទៅតាមលទ្ធផលនៅពេលដែលពេលវេលាកំណត់បានដើរអស់។
    - ផែនទី (X) - ការប្រជែងយកឱ្យបាន X ជុំ – ការភ្នាល់ថាតើក្រុមមួយណា នឹងក្លាយជាក្រុមដំបូងគេដែលនឹងឈ្នះចំនួនជុំដែលបានបញ្ជាក់ នៅលើផែនទីជាក់លាក់មួយ។
    - ផែនទី (X) - ពិន្ទុត្រឹមត្រូវ – ការភ្នាល់លើថាតើផែនទីជាក់លាក់មួយ នឹងត្រូវបញ្ចប់ដោយមានពិន្ទុដែលបានបញ្ជាក់ឬអត់។
10. ម៉ោងបន្ថែម – ជ័យជម្នះនៅលើផែនទី អាចសម្រេចទៅបានដោយការឈ្នះយ៉ាងហោចណាស់ 13 ជុំ។ ក្នុងករណីដែលមានការស្មើគ្នានៅលើផែនទីមួយ (នៅពេលដែលពិន្ទុជុំមានចំនួន 12–12) ជាទូទៅបទប្បញ្ញត្តិនៃធ្នូណាមិននោះចែងថា ត្រូវមានការលេងបន្ថែម 6 ជុំទៀត ដែលហៅថា "ម៉ោងបន្ថែម"។ ជ័យជម្នះនៅក្នុងម៉ោងបន្ថែម នឹងត្រូវផ្តល់ជូនទៅក្រុមដំបូងគេដែលឈ្នះជុំបន្ថែមនោះបាន 4 ជុំ ក្នុងចំណោម 6 ជុំ។ ក្នុងករណីស្មើគ្មាននៅក្នុងម៉ោងបន្ថែម (ក្រុមទាំងពីរឈ្នះបាន 3 ជុំម្នាក់ នៅក្នុងម៉ោងបន្ថែម) ដូច្នេះ ត្រូវលេងម៉ោងបន្ថែម 6 ជុំទៀត។
    - ផែនទី (X) - ពិន្ទុត្រឹមត្រូវក្នុងម៉ោងបន្ថែម (X) - ការភ្នាល់ថារយៈពេលម៉ោងបន្ថែមដែលបានបញ្ជាក់នៅលើផែនទីជាក់លាក់មួយ នឹងត្រូវបញ្ចប់ដោយមានពិន្ទុដែលបានបញ្ជាក់។
    - ផែនទី (X) - ជុំសេស/គូ ក្នុងម៉ោងបន្ថែម (X) - ការភ្នាល់ថាតើចំនួនជុំក្នុងម៉ោងបន្ថែមដែលបានលេង នឹងមានចំនួនសេស ឬគូ។
    - ផែនទី (X) - ជុំសរុបនៅក្នុងម៉ោងបន្ថែម (X) - ការភ្នាល់លើចំនួនជុំសរុបដែលបានលេងនៅក្នុងរយៈពេលម៉ោងបន្ថែមជាក់លាក់មួយ។
    - ផែនទី (X) - អ្នកឈ្នះតង់ទីមួយនៅក្នុងម៉ោងបន្ថែម (X) - ការភ្នាល់ថាតើក្រុមមួយណា នឹងក្លាយជាក្រុមដំបូងគេដែលនឹងឈ្នះបាន 3 ជុំ នៅក្នុងរយៈពេលម៉ោងបន្ថែមជាក់លាក់មួយ។

10.42. ហ្គេមអូឡាំពិក

1. ការភ្នាល់លើចំនួនមេដាយ នឹងត្រូវបានទូទាត់ផ្អែកលើចំនួនមេដាយផ្លូវការ នៅពេលពិធីបិទចាប់ផ្តើម។
2. ប្រសិនបើព្រឹត្តិការណ៍មួយត្រូវបានពន្យាពេល ឬកាលបរិច្ឆេទឬទីកន្លែងរបស់វាត្រូវបានផ្លាស់ប្តូរ នោះការភ្នាល់ទាំងអស់នឹងមានសុពលភាពរហូតដល់ការប្រកួតចប់។
3. ការភ្នាល់លើការផ្គូផ្គងប្រកួត។ គូប្រកួតទាំងពីរ (មិនថាក្រុមឬកីឡាករ) ត្រូវតែចាប់ផ្តើម ដើម្បីឱ្យការភ្នាល់នឹងនៅមានសុពលភាព។ ប្រសិនបើគូប្រកួតដកខ្លួនចេញ ក្នុងករណីណាមួយដោយហេតុផលណាមួយ ដៃគូប្រកួតប្រជែងនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើគូប្រជែងទាំងពីរមិនបានបញ្ចប់ការប្រកួត នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវបានចាត់ទុកជាមោឃៈ។

10.43. កីឡារដូវរងា

1. ការភ្នាល់លើការផ្គូផ្គងប្រកួត។ គូប្រកួតទាំងពីរ (មិនថាក្រុមឬកីឡាករ) ត្រូវតែចាប់ផ្តើម ដើម្បីឱ្យការភ្នាល់នឹងនៅមានសុពលភាព។ ប្រសិនបើគូប្រកួតដកខ្លួនចេញ ក្នុងករណីណាមួយដោយហេតុផលណាមួយ ដៃគូប្រកួតប្រជែងនឹងត្រូវបានចាត់ទុកថាជាអ្នកឈ្នះ។ ប្រសិនបើគូប្រជែងម្នាក់ខកខានមិនបានបញ្ចប់ការប្រកួត នោះរាល់ការភ្នាល់ទាំងអស់នឹងត្រូវទូទាត់ដោយផ្អែកលើដំណាក់កាលជម្រុះចេញរបស់គូប្រជែង។

10.44. បាល់ទាត់ហ្គាអែល ហើលីង

បាល់ទាត់ហ្គាអែល គឺទាក់ទងទៅនឹងបាល់ទាត់និងបាល់ឱប។

1. រាល់ការភ្នាល់ទាំងអស់លើការប្រកួតត្រូវបានទូទាត់នៅលើលទ្ធផលនៅចុងបញ្ចប់នៃម៉ោងធម្មតា (ការលេង 70 នាទី មានពីរតង់ ដោយតង់នីមួយៗមានចំនួន 35 នាទី ឬការលេង 60 នាទី មានពីរតង់ ដោយតង់នីមួយៗមានចំនួន 30 នាទី)។ ការប្រកួតត្រូវតែត្រូវបានបញ្ចប់ ដើម្បីឱ្យការភ្នាល់មានសុពលភាព លើកលែងតែទីផ្សារនោះត្រូវបានកំណត់រួចហើយ នៅពេលដែលការប្រកួតត្រូវបានបញ្ឈប់។
2. រាល់ការភ្នាល់ទាំងអស់ត្រូវបានទូទាត់សង តាមពិន្ទុចុងក្រោយនៃការប្រកួត។ ប្រព័ន្ធដាក់ពិន្ទុមានដូចខាងក្រោម៖
   គ្រាប់បាល់មួយមានតម្លៃ 3 ពិន្ទុ (នៅពេលដែលបាល់ត្រូវបានទាត់ចូលទៅក្នុងសំណាញ់ខាងក្រោមរបាទី)។
   ពិន្ទុមួយគឺមានតម្លៃ 1 ពិន្ទុ (នៅពេលបាល់ឆ្លងលើរបាទី)។
   គ្រាប់ក្នុងបាល់ទាត់ហ្គាអែល គឺស្រដៀងនឹងបាល់ទាត់ដៃរ ដោយបង្គោលទីឈរនៅពីលើសំណាញ់ទី។

ឧទាហរណ៍ ពិន្ទុសម្រាប់ក្រុម 1 គឺ 0-12 (ដោយលេខ 0 ជាចំនួនគ្រាប់បាល់ ហើយ 12 ជាចំនួនពិន្ទុដែលរកបាន) រីឯពិន្ទុសម្រាប់ក្រុម 2 គឺ 2-5 (ដោយលេខ 2 ជាចំនួនគ្រាប់បាល់ ហើយ 5 គឺជាចំនួនពិន្ទុដែលរកបាន។ នេះសរុប

2x3 + 5 = 11 ពិន្ទុសរុបទាំងអស់)។ ដូច្នេះពិន្ទុរួមនៃការប្រកួតគឺ 12–11 ហើយក្រុម 1 នឹងត្រូវឈ្នះ។

10.45. អាកាសធាតុ

អាកាសធាតុនៅអាកាសយានដ្ឋាន។ យើងទទួលយកការភ្នាល់លើសន្ទស្សន៍អាកាសធាតុ ដែលបានកត់ត្រានៅអាកាសយានដ្ឋានជុំវិញពិភពលោក សម្រាប់ការបញ្ជូនទិន្នន័យអាកាសធាតុ។
ការភ្នាល់ត្រូវបានទទួលយកលើសីតុណ្ហភាពខ្យល់ និងសន្ទស្សន៍សម្ពាធបរិយាកាស។
ការភ្នាល់ត្រូវបានគណនាដោយផ្អែកលើរបាយការណ៍អាកាសធាតុ METAR ។ ការភ្នាល់ត្រូវបានគណនាប្រសិនបើការផ្លាស់ប្តូរអាកាសធាតុត្រូវបានកត់ត្រានៅក្នុងលេខកូដ METAR ជាមួយនឹងកាលបរិច្ឆេទ ពេលវេលាម៉ោង អាកាសយានដ្ឋាន និងលក្ខខណ្ឌអាកាសធាតុជាក់ស្តែងនៃការភ្នាល់ ក្នុងរយៈពេលមួយម៉ោងកន្លះនៃពេលវេលាដែលបានបញ្ជាក់នៅក្នុងការភ្នាល់។ ប្រសិនបើក្នុងអំឡុងពេលនោះ លទ្ធផលមិនអាចត្រូវបានបង្កើតឡើងទេ នោះការភ្នាល់ដែលត្រូវគ្នាត្រូវបានទូទាត់សងជាមួយនឹងហាងឆេងស្មើនឹង 1 ។
តូលេខ ដែលត្រូវបានប្រើសម្រាប់ការគណនាការភ្នាល់ ត្រូវបានទទួលដូចខាងក្រោម៖

- ទិន្នន័យសីតុណ្ហភាពខ្យល់ត្រូវបានផ្តល់ជាអង្សាសេ ហើយប្រើសម្រាប់ការគណនាដោយគ្មានការបម្លែង។
- ទិន្នន័យសម្ពាធបរិយាកាសត្រូវបានផ្តល់ជាហិកតូប៉ាស្កាល់។ ចំពោះការគណនាការភ្នាល់ហិកតូប៉ាស្កាល់ត្រូវបានបម្លែងទៅជាមីលីម៉ែត្របារត និងបង្គត់ទៅជាខ្ទង់ទសភាគ។
- ទិន្នន័យល្បឿនខ្យល់ត្រូវបានផ្តល់ជូនជា ណតឬម៉ាយល៍ក្នុងមួយម៉ោង។ សម្រាប់ការគណនាការភ្នាល់ ណតឬម៉ាយល៍ក្នុងមួយម៉ោងត្រូវបានបម្លែងទៅជាគីឡូម៉ែត្រក្នុងមួយម៉ោង និងបង្គត់ទៅខ្ទង់ទសភាគ។
- វាល់ការបង្គត់គឺតាមលក្ខណៈគណិតវិទ្យា ពោលគឺនៅពេលដែលលេខទីមួយដែលបានទម្លាក់គឺ 5 កន្លែងខ្ទង់ទសភាគចុងក្រោយត្រូវបានបង្គត់ឡើង។

ការគណនាការភ្នាល់អាចត្រូវបានពិនិត្យឡើងវិញ ដោយសារតែការផ្លាស់ប្តូរទិន្នន័យចូលថ្មី។ ទាំងការសង្កេតផ្ទាល់ខ្លួនរបស់អតិថិជននិងទិន្នន័យពីប្រភពផ្សេងៗទៀត ក្រៅពីការចង្អុលបង្ហាញក្នុងលក្ខខណ្ឌដែលត្រូវបានបញ្ជាក់ ត្រូវបានយកមកពិចារណា។

10.46. បាល់ទាត់ខ្លី

បាល់ទាត់ខ្លី 2X2

1. ការប្រកួតមានពីរតង់ដែលមានរយៈពេល 5 នាទី។ កម្មវិធីកំណត់ពេលវេលាត្រូវបានបញ្ឈប់ប្រសិនបើការផ្អាកលេងរយៈពេលយូរត្រូវបានតម្រូវ (ដោយសារតែការរងរបួស រឺទ បញ្ហាជាមួយបាល់ ។ល។)។
2. បាល់ទាត់ខ្លី ត្រូវបានលេងនៅលើតារាងបាល់ទាត់ដែលមានទំហំ 18 ម៉ែត្រ × 9 ម៉ែត្រ (អាចនឹងត្រូវផ្លាស់

ប្តូរ)។

3. បាល់ទាត់ខ្លី គឺជាកីឡាជាក្រុមដែលមាន 2 ក្រុម ដែលមានកីឡាករ 2 នាក់។ មិនមានដែនកំណត់លើចំនួននៃការជំនួសទេ។
4. មិនមានក្រុមណាលេងដោយមានអ្នកចាំទីឡើយ។ បាល់ហ្វ្រីឃីកមួយត្រូវបានផ្តល់ជូន ប្រសិនបើបាល់ប៉ះដៃកើតមានឡើង។ ប្រសិនបើបាល់ប៉ះដៃកើតមានឡើងនៅក្នុងតំបន់ប៉េណាល់ទី នោះបាល់ប៉េណាល់ទីនឹងត្រូវបានផ្តល់ជូន។
5. ប៉េណាល់ទីត្រូវបានធ្វើឡើងពីទីបើកចំហរពីបន្ទាត់ពាក់កណ្តាលទី។ ប្រសិនបើបាល់ឆ្លងកាត់បន្ទាត់ទីវានឹងត្រូវរាប់បញ្ចូលថាជាគ្រាប់បាល់ចូលទី។
6. បាល់ជ្រុងនិងការបោះបាល់ចូលត្រូវបានធ្វើឡើងពីចំណុចដែលបន្ទាត់ពាក់កណ្តាលតារាងប្រសព្វជាមួយបន្ទាត់ប៉ះ។ កីឡាកររបស់ក្រុមការពារត្រូវតែស្ថិតនៅក្នុងពាក់កណ្តាលទីលាន។
7. ក្នុងករណីមានអាកប្បកិរិយាមិនសមជាកីឡាករ ឬការបណ្តេញចេញ ក្រុមនោះនឹងត្រូវចាញ់។
8. ការសម្រេចចិត្តរបស់អាជ្ញាកណ្តាល គឺជាការសម្រេចចុងក្រោយទាក់ទងនឹងវិវាទទាំងអស់។
9. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់លើការប្រកួតនេះនឹងត្រូវចាត់ទុកជាមោឃៈ (ទូទាត់សងតាមហាងឆេង 1.00)។

បាល់ទាត់ខ្លី 3X3

1. ការប្រកួតមានពីរតង់ដែលមានរយៈពេល 5 នាទី។ កម្មវិធីកំណត់ពេលវេលាត្រូវបានបញ្ឈប់លុះត្រាតែមានការផ្អាកលេងរយៈពេលយូរ (ដោយសារតែការរងរបួស វិវាទ បញ្ហាជាមួយបាល់ ។ល។)។
2. បាល់ទាត់ខ្លី ត្រូវបានលេងនៅលើតារាងបាល់ទាត់ដែលមានទំហំ 18 ម៉ែត្រ × 9 ម៉ែត្រ (អាចនឹងត្រូវផ្លាស់ប្តូរ)។
3. បាល់ទាត់ខ្លី គឺជាកីឡាជាក្រុមដែលមាន 2 ក្រុម ដែលមានកីឡាករ 3 នាក់។ មិនមានដែនកំណត់លើចំនួននៃការជំនួសទេ។
4. មិនមានក្រុមណាលេងដោយមានអ្នកចាំទីឡើយ។ បាល់ហ្វ្រីឃីកមួយត្រូវបានផ្តល់ជូន ប្រសិនបើបាល់ប៉ះដៃកើតមានឡើង។ ប្រសិនបើបាល់ប៉ះដៃកើតមានឡើងនៅក្នុងតំបន់ប៉េណាល់ទី នោះបាល់ប៉េណាល់ទីនឹងត្រូវបានផ្តល់ជូន។
5. ប៉េណាល់ទីត្រូវបានធ្វើឡើងពីទីបើកចំហរពីបន្ទាត់ពាក់កណ្តាលទី។ ប្រសិនបើបាល់ឆ្លងកាត់បន្ទាត់ទីវានឹងត្រូវរាប់បញ្ចូលថាជាគ្រាប់បាល់ចូលទី។
6. ប៉េណាល់ទីនឹងត្រូវបានផ្តល់ជូន ប្រសិនបើកីឡាករស្ថិតនៅក្នុងតំបន់ប៉េណាល់ទីលើសពី 2 វិនាទី។
7. ក្នុងករណីមានអាកប្បកិរិយាមិនសមជាកីឡាករ ឬការបណ្តេញចេញ ក្រុមកីឡាកររនោះនឹងត្រូវចាញ់។
8. ការសម្រេចចិត្តរបស់អាជ្ញាកណ្តាល គឺជាការសម្រេចចុងក្រោយទាក់ទងនឹងវិវាទទាំងអស់។
9. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់លើការប្រកួតនេះនឹងត្រូវចាត់ទុកជាមោឃៈ (ទូទាត់សងតាមហាងឆេង 1.00)។

ឌ្រីមលីគ បុរស

1. ការប្រកួតមានពីរតង់ ដែលមានរយៈពេល 15 នាទី។ 2 ក្រុម ដែលមានកីឡាករ 3 នាក់ប្រកួតប្រជែងគ្នា។
2. ធូណាមិនរួមមានវគ្គចែកពូលក្នុងទម្រង់ជាលក្ខណៈវិលជុំទ្វេដងសន្សំពិន្ទុមួយ វគ្គកាត់សេចក្តីដណ្តើមចំណាត់ថ្នាក់លេខបី និងវគ្គផ្តាច់ព្រ័ត្រ។ ការដាក់ពិន្ទុ៖ ឈ្នះ – 3 ពិន្ទុ, ស្មើ – 1 ពិន្ទុ, ចាញ់ – 0 ពិន្ទុ។
3. គ្រាប់បាល់មួយអាចត្រូវបានរកគ្រាប់បាល់ បន្ទាប់ពីការបញ្ជូនបាល់ទៅក្នុងទឹកដីនៃគូប្រកួត។
4. មិនមានក្រុមណាលេងដោយមានអ្នកចាំទីឡើយ ហើយការប្រើដៃប៉ះបាល់ត្រូវហាមឃាត់។
5. គ្រាប់បាល់ចូលទីខ្លួនឯងមិនត្រូវបានរាប់បញ្ចូលទេ។
6. ប៉ែណាល់ទីមួយត្រូវបានផ្តល់ជូន បន្ទាប់ពីមានកំហុស 3 លើក។
7. បាល់ប៉ែណាល់ទីគឺត្រូវទាត់នៅចម្ងាយមួយជំហានពីទីខាងក្រុមរបស់ខ្លួន ហើយទាត់កាត់តារាងតម្រង់ទៅរកទីដែលគ្មានអ្នកចាំទីរបស់ក្រុមគូប្រកួត។
8. ប្រសិនបើបាល់ចេញទៅក្រៅ នោះការគប់បាល់ចូលនឹងត្រូវធ្វើឡើងពីចំហៀងតារាង។
9. ក្រុមទាំងឡាយត្រូវបានផ្តល់ជូន 1 ពិន្ទុសម្រាប់ការស្មើគ្នា ក្នុងវគ្គចែកពូលនៃធូណាមិន។
ប្រសិនបើមានការស្មើគ្នានៅវគ្គផ្តាច់ព្រ័ត្រ នោះប៉ែណាល់ទីនឹងត្រូវធ្វើឡើង (ការទាត់ 3 ដង) ។

បាល់ទាត់ខ្លី 4X4

1. ការប្រកួតមានពីរតង់ដែលមានរយៈពេល 5 នាទី។ កម្មវិធីកំណត់ពេលវេលាត្រូវបានបញ្ឈប់លុះត្រាតែមានការផ្អាកលេងរយៈពេលយូរ (ដោយសារតែការរងរបួស វិវាទ បញ្ហាជាមួយបាល់ ។ល។)។
2. ទំហំរបស់ទីលានគឺមិនត្រូវបានកំណត់ជាកំហិតឡើយ។
3. មិនមានក្រុមណាលេងដោយមានអ្នកចាំទីឡើយ។ បាល់ហ្វ្រីឃីកមួយត្រូវបានផ្តល់ជូន ប្រសិនបើបាល់ប៉ះដៃកើតមានឡើង។ ប្រសិនបើបាល់ប៉ះដៃកើតមានឡើងនៅក្នុងតំបន់ប៉ែណាល់ទី នោះបាល់ប៉ែណាល់ទីនឹងត្រូវបានផ្តល់ជូន។
4. ប៉ែណាល់ទីត្រូវបានធ្វើឡើងពីទីបើកចំហរពីបន្ទាត់ពាក់កណ្តាលទី។ ប្រសិនបើបាល់ឆ្លងកាត់ខ្សែទី វានឹងត្រូវរាប់បញ្ចូលថាជាគ្រាប់បាល់ចូលទីមួយគ្រាប់។
5. កីឡាករមិនអាចឈរស្របនឹងទីរបស់ពួកគេ នៅក្នុងតំបន់ប៉ែណាល់ទីឡើយ។ ប្រសិនបើច្បាប់នេះត្រូវបានល្មើស ប៉ែណាល់ទីមួយត្រូវបានផ្តល់ជូន។
6. នៅពេលការទាត់បាល់ហ្វ្រីឃីកត្រូវបានធ្វើឡើង ក្រុមការពារមិនអាចបង្កើតជញ្ជាំងការពារបានឡើយ។ មានតែកីឡាករម្នាក់ប៉ុណ្ណោះដែលអាចឈរនៅក្នុងទី ដើម្បីបញ្ឈប់បាល់មិនឱ្យចូលក្នុងសំណាញ់បាន។
7. ធូណាមិនត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ និងអនុវត្តតាមច្បាប់ 'អ្នកឈ្នះនឹងនៅបន្ត' ។ ក្នុងករណីស្មើគ្នា ក្រុមទាំងពីរនឹងត្រូវចាកចេញពីទីលាន ហើយក្រុមទាំងពីរនោះនឹងមិនត្រូវបានចូលរួមនូវក្នុងការប្រកួតបន្ទាប់ទៀតទេ។
8. ប្រសិនបើការបណ្តេញចេញបានកើតឡើង ក្រុមដែលបាត់បង់កីឡាករម្នាក់នោះ ត្រូវបន្តលេងឱ្យអស់រយៈពេល 1 នាទី ឬរហូតដល់ពួកគេបានគេស៊ុតបញ្ចូលទី។
9. ការសម្រេចចិត្តរបស់អាជ្ញាកណ្តាល គឺជាការសម្រេចចុងក្រោយទាក់ទងនឹងវិវាទទាំងអស់។
10. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់

លើការប្រកួតនេះនឹងត្រូវចាត់ទុកជាមោឃៈ (ទូទាត់សងតាមហាងឆេង 1.00)។

បាល់ទាត់ខ្លី 5X5

1. ការប្រកួតមានពីរតង់ដែលមានរយៈពេល 5 នាទី។ កម្មវិធីកំណត់ពេលវេលាត្រូវបានបញ្ឈប់លុះត្រាតែមានការផ្អាកលេងរយៈពេលយូរ (ដោយសារតែការរងរបួស វិវាទ បញ្ហាជាមួយបាល់ ។ល។)។
2. ទំហំរបស់ទីលានគឺមិនត្រូវបានកំណត់ជាក់ហិតឡើយ។
3. ប៉ៃណាល់ទីត្រូវបានធ្វើឡើងពីគំនូស 6 ម៉ែត្រ។
4. ប្រសិនបើការបណ្តេញចេញបានកើតឡើង ក្រុមដែលបាត់បង់កីឡាករម្នាក់នោះ ត្រូវបន្តលេងឱ្យអស់រយៈពេល 1 នាទី ឬរហូតដល់ពួកគេបានគេស៊ុតបញ្ចូលទី។
5. ធូណាមិនត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ និងអនុវត្តតាមច្បាប់ 'អ្នកឈ្នះនឹងនៅបន្ត' ។ ក្នុងករណីស្មើគ្នា ក្រុមទាំងពីរនឹងត្រូវចាកចេញពីទីលាន ហើយក្រុមទាំងពីរនោះនឹងមិនត្រូវបានចូលរួមនូវក្នុងការប្រកួតបន្ទាប់ទៀតទេ។
6. ការសម្រេចចិត្តរបស់អាជ្ញាកណ្តាល គឺជាការសម្រេចចុងក្រោយទាក់ទងនឹងវិវាទទាំងអស់។
7. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់លើការប្រកួតនេះនឹងត្រូវចាត់ទុកជាមោឃៈ (ទូទាត់សងតាមហាងឆេង 1.00)។

ចាំរើបលខាប់ 4X4

1. ទម្រង់នៃការប្រកួត៖ ពីរតង់ដែលមានរយៈពេល 15 នាទី។ សមាជិកក្រុមទាំងឡាយលេងនៅក្នុងបាល់សប់ខ្យល់។
2. ទម្រង់នៃធូណាមិន៖ វគ្គចែកពូលដែលមាន 2 ជុំ, វគ្គកាត់សេចក្តីដណ្តើមចំណាត់ថ្នាក់លេខ 3, វគ្គផ្តាច់ព្រ័ត្រ។ ការដាក់ពិន្ទុ៖ ឈ្នះ – 3 ពិន្ទុ; ស្មើ – 1 ពិន្ទុ; ចាញ់ – 0 ពិន្ទុ។
3. ក្នុងករណីមានការស្មើនៅក្នុងវគ្គចែកពូល ក្រុមនីមួយៗនឹងទទួលបាន 1 ពិន្ទុរៀងៗខ្លួន។ ប្រសិនបើមានការស្មើគ្នាកើតឡើងនៅវគ្គផ្តាច់ព្រ័ត្រ នោះការប្រកួតនឹងឈានដល់វគ្គប៉ៃណាល់ទី (ការទាត់ 5 ដង) ។
4. ការទាត់បាល់ប៉ៃណាល់ទី ត្រូវបានធ្វើឡើងពីគែមតំបន់ប៉ៃណាល់ទី។
5. មិនមានអ្នកចាំទីទេ។
6. គេបានហាមឃាត់មិនឱ្យលេងនៅក្នុងតំបន់ទីទេ ចំពោះទាំងកីឡាករខ្សែប្រយុទ្ធនិងខ្សែការពារ។
7. កីឡាករដែលល្មើសនឹងច្បាប់ណាមួយនឹងត្រូវបានបណ្តេញចេញរយៈពេល 1 នាទី ហើយក្រុមរបស់ពួកគេនៅបន្តលេងជាមួយនឹងការខ្វះចំនួនកីឡាករនេះ។
8. ប្រសិនបើការគប់បាល់ចូលកើតឡើង វានឹងត្រូវបានធ្វើឡើងពីកន្លែងដែលបាល់ឆ្លងកាត់បន្ទាត់នោះ។

10.47. ស្ទ្រីតហ្វូតបល 3X3

1. ការភ្នាល់នៅលើស្ទ្រីតហ្វូតបល 3X3 រួមបញ្ចូលម៉ោងធម្មតា។
2. ការប្រកួតនីមួយៗមានរយៈពេល 2 តង់ ដែលមានរយៈពេល 5 នាទី (ម៉ោងធម្មតា)។
3. ការប្រកួតត្រូវតែត្រូវបានលេងទាំងស្រុង ដើម្បីឱ្យការភ្នាល់មានសុពលភាព។ ការភ្នាល់ ដែលលទ្ធផលរបស់វាត្រូវបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានអាក់ខាន ត្រូវបានលើកលែងពីច្បាប់នេះ។
4. ការប្រកួតត្រូវបានលេងជាមួយបាល់តូចទំហំលេខ 4 ។
5. ក្រុមទាំងពីរមានកីឡាករចេញលេងចំនួន 3 នាក់ ដែលមិនមានកំណត់មុខតំណែងអ្វីឡើយ។ មិនមានក្រុមណាលេងដោយមានអ្នកចាំទីឡើយ ហើយកីឡាករមិនអាចប៉ះបាល់ដោយដៃរបស់ពួកគេឡើយ។
6. បាល់ប្រ៊ីយ៉ឺកមួយត្រូវបានផ្តល់ជូន ប្រសិនបើបាល់ប៉ះដៃកើតមានឡើងដោយចេតនា នៅកន្លែងណាមួយនៅលើតារាងបាល់ទាត់។
7. បាល់ប្រ៊ីយ៉ឺកមួយត្រូវបានផ្តល់ជូន ប្រសិនកីឡាកប្រព្រឹត្តកំហុសណាមួយ។ ក្រុមការពារអាចបង្កើតជាជញ្ជាំងការពារចម្ងាយ 3 ម៉ែត្រពីបាល់បាន។ ក្រុមប្រយុទ្ធអាចបញ្ជូនបាល់ពីការទាត់បាល់ប្រ៊ីយ៉ឺកក៏បាន ឬស៊ុតបញ្ចូលទីក៏បាន។
8. ប៉េណាល់ទីត្រូវបានធ្វើឡើងពីចំណុចកណ្តាលទីលានដោយកីឡាករណាម្នាក់ បន្ទាប់ពីអាជ្ញាកណ្តាលផ្លុំកញ្ចែ។ សម្រាប់ស៊ុតបញ្ចូលទីឱ្យបានមួយគ្រាប់ បាល់ត្រូវតែចូលទៅក្នុងទីដោយមិនប៉ះដីនិងឆ្លងកាត់ខ្សែទី។
9. ប្រសិនបើបាល់ចេញពីតារាង នោះការទាត់បាល់ចូលនឹងត្រូវបានធ្វើឡើងនៅលើដី។ កីឡាកររបស់ក្រុមការពារត្រូវតែស្ថិតនៅចម្ងាយមួយម៉ែត្រពីកន្លែងដែលបាល់ទាត់ចូលនោះ។ កីឡាករមិនអាចស៊ុតដោយផ្ទាល់ពីបាល់ប្រ៊ីយ៉ឺកបានទេ។ ប្រសិនបើមានការទាត់តម្រង់ទីដោយផ្ទាល់ គ្រាប់នេះនឹងមិនត្រូវបានរាប់បញ្ចូលទេ ហើយការទាត់ចេញពីទីនឹងត្រូវបានផ្តល់ជូន។
10. ការប៉ះផ្ទាល់លើរាងកាយត្រូវហាមឃាត់ លើកលែងតែការប៉ះ។ ការដណ្តើមបាល់ ការរុញច្រាន ការត្រួតពិនិត្យរាងកាយ និងការលេង ខណៈពេលកំពុងដេកដួលលើទីលាន ត្រូវបានហាមឃាត់។

10.48. បាល់ទាត់តេន្នីស

1. បាល់ទាត់តេន្នីស គឺជាកីឡាជាក្រុមមួយ ដែលក្នុងនោះ 2 ក្រុមមានកីឡាករ 2 នាក់ប្រកួតប្រជែងគ្នា។ ចំនួននៃការជំនួសគ្មានដែនកំណត់ត្រូវបានអនុញ្ញាត។
2. បាល់ទាត់តេន្នីស ត្រូវបានគេលេងជាមួយបាល់ទាត់ នៅលើទីលានដែលមានទំហំ 9 ម៉ែត្រ× 12.8 ម៉ែត្រ ដែលខណ្ឌចែកដោយសំណាញ់តេន្នីសមួយ។ ការប្រកួតត្រូវបានលេងរហូតដល់ក្រុមមួយឈ្នះបាន 2 សេត (ល្អបំផុតក្នុងចំណោម 3) ។ សេតមួយចប់នៅពេលក្រុមមួយរកបានពិន្ទុយ៉ាងតិច 11 ហើយនិងមានពីរពិន្ទុនាំមុខ។
3. ក្រុមនីមួយៗត្រូវតែផ្ទេរបាល់ពីខាងរបស់ខ្លួនរំលងពីលើសំណាញ់ទៅខាងរបស់គូប្រជែង ដោយប៉ះបាល់បានបីដង (តិចជាងនេះត្រូវបានអនុញ្ញាត ច្រើនទៀតមិនត្រូវបានអនុញ្ញាតទេ) ។ កីឡាករតែមួយមិនអាចប៉ះបាល់ពីរដងជាប់គ្នាបានទេ។ កីឡាករមិនអាចប៉ះបាល់ដោយដៃរបស់ពួកគេបានឡើយ។ បាល់លោត

ពីរដងត្រូវបានអនុញ្ញាត (តិចជាងនេះត្រូវបានអនុញ្ញាត ច្រើនទៀតមិនត្រូវបានអនុញ្ញាតទេ) មុនពេលបាល់ត្រូវបញ្ជូនទៅខាងរបស់គូប្រជែង ហើយការលោតម្តងត្រូវបានអនុញ្ញាតបន្ទាប់ការចេញសីរីសរបស់ក្រុមគូប្រជែង។

4. បាល់ត្រូវបានចេញសីរីសដោយទាត់វាពីខាងក្រោយបន្ទាត់គោល។ ប្រសិនបើបាល់ប៉ះសំណាញ់ ហើយបន្ទាប់មកធ្លាក់ចុះលើខាងគូប្រជែង នោះបាល់នឹងត្រូវបានចេញសីរីសម្តងទៀត។ កីឡាកររបស់ក្រុមគូប្រកួតមិនអាចប្តូកសីរីស ដោយការឆោងលើសំណាញ់បានឡើយ។
5. ប្រសិនបើការប្រកួតចាប់ផ្តើម ក៏ប៉ុន្តែមិនបានបញ្ចប់ ដោយហេតុផលណាមួយ នោះការភ្នាល់ទាំងអស់នៅលើនោះនឹងត្រូវបានទូទាត់សងតាមហាងឆេង 1.00 លើកលែងតែការភ្នាល់លើទីផ្សារដែលបានកំណត់រួចហើយ នៅពេលការប្រកួតត្រូវបានបញ្ឈប់។
6. គ្រាប់តនិងតូតាល់ ត្រូវបានបញ្ជាក់ជាពិន្ទុ លើកលែងតែនៅក្នុងទីផ្សារ "សេតគ្រាប់ត" និង "តូតាល់សេត"។
7. "ពិន្ទុបន្ថែម"។ នៅក្នុងទីផ្សារនេះ អតិថិជនគួរតែទស្សន៍ទាយថាតើនឹងមានពិន្ទុបន្ថែមណាមួយនៅក្នុងសេតដែរឬទេ។ ការភ្នាល់ "ពិន្ទុបន្ថែមក្នុងសេត – បាទ/ចាស" នឹងត្រូវបានទូទាត់ជាការឈ្នះប្រសិនបើក្រុមណាមួយឈ្នះសេតបន្ទាប់ពីពិន្ទុ 10:10 ។

10.49. ស្នឹតជាវ័ហ្វូតបល 2X2 ។ ពានរង្វាន់ពិភពលោក

ស្នឹតជាវ័ហ្វូតបល ពាក់ព័ន្ធនឹងការចាក់ផ្សាយហ្គេមដែលមានអ្នកលេងច្រើនគ្នា (បាល់ទាត់និម្មិត)។

1. រាល់ប្រាក់ភ្នាល់ទាំងអស់ត្រូវបានទូទាត់សង បន្ទាប់ពីការបញ្ចប់ការប្រកួត។
2. ប្រាក់ភ្នាល់អប្បបរមា និងអតិបរមា ត្រូវបានកំណត់ដោយក្រុមហ៊ុនភ្នាល់ សម្រាប់ជម្រើសនីមួយៗ ដាច់ដោយឡែកពីគ្នា។
3. ក្រុមហ៊ុនភ្នាល់អាចផ្លាស់ប្តូរដែនកំណត់ប្រាក់ភ្នាល់បាន ដោយមិនចាំបាច់ជូនដំណឹងជាមុនឡើយ។
4. ការប្រកួតមានមួយតង់។ តង់មួយមានការលេងរយៈពេល 5 នាទី ឬរហូតដល់ក្រុមណាមួយរកបាន 5 គ្រាប់។
